សម្ព័ន្ធខ្មែរជំរឿន
និងការពារសិទ្ធិមនុស្ស

លីកាដូ

LICADHO

Cambodian League for the Promotion and Defense of Human Rights



# ការវាយប្រហារ និងគំរាមកំហែង អ្នកការពារសិទ្ធិមនុស្ស នៅកម្ពុជា ២០១០-២០១២

របាយការណ៍ចេញ
ខែធ្នូ ឆ្នាំ២០១២

# ការវាយប្រហារ និងគំរាមកំហែង

## អ្នកការពារសិទ្ធិមនុស្ស នៅកម្ពុជា២០១០-២០១២

របាយការណ៍ចេញខែធ្នូ ឆ្នាំ២០១២


**សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស លីកាដូ**

**LICADHO**

CAMBODIAN LEAGUE FOR THE PROMOTION
AND DEFENSE OF HUMAN RIGHTS

# សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស
# (លីកាដូ)

លីកាដូ គឺជាអង្គការសិទ្ធិមនុស្សជាតិមួយនៅកម្ពុជា។ ចាប់តាំងពីអង្គការលីកាដូ ត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៩២ អង្គការនេះ គឺជាអង្គការដែលស្ថិតនៅជួរមុខគេ ក្នុងកិច្ចការពារ និងលើកកម្ពស់ការគោរពសិទ្ធិពលរដ្ឋ សិទ្ធិនយោបាយ សិទ្ធិសេដ្ឋកិច្ច និងសិទ្ធិសង្គមរបស់ប្រជាពលរដ្ឋនៅក្នុងប្រទេសកម្ពុជា តាមរយៈរាជរដ្ឋាភិបាលកម្ពុជា និងស្ថាប័ននានា។ ការកសាងសមិទ្ធិផលរបស់ខ្លួនក្នុងអតីតកាលលីកាដូ បានបន្តដើរតួនាទីជាអ្នកតស៊ូមតិសម្រាប់ប្រជាពលរដ្ឋ និងធ្វើការឃ្លាំមើលរាជរដ្ឋាភិបាលតាមរយៈកម្មវិធីសិទ្ធិមនុស្សនានា ពីការិយាល័យកណ្ដាលរបស់ខ្លួននៅភ្នំពេញ និងនៅតាមសាខាទូទាំង ១២ ខេត្ត-រាជធានីផ្សេងទៀត។

## កម្មវិធីឃ្លាំមើល និងការពារសិទ្ធិមនុស្ស

**ឃ្លាំមើលការរំលោភសិទ្ធិមនុស្ស ដែលប្រព្រឹត្ត ដោយបុគ្គលរបស់រដ្ឋ លើការរំលោភសិទ្ធិស្ត្រី និងការរំលោភសិទ្ធិកុមារៈ**
បុគ្គលិកធ្វើការស៊ើបអង្កេតលើករណីរំលោភសិទ្ធិមនុស្ស ដែលប្រព្រឹត្ត ដោយបុគ្គលរដ្ឋ ចំពោះការរំលោភបំពានលើស្ត្រី និងកុមារ ហើយជនរងគ្រោះ ត្រូវបានផ្ដល់សេវាជួយជ្រោមជ្រែងតាមរយៈការធ្វើអន្តរាគមន៍ជាមួយអាជ្ញាធរមូលដ្ឋាន និងមន្ត្រីតុលាការ។

**ជំនួយផ្នែកវេជ្ជសាស្ត្រ និងសេវាកម្មសង្គមកិច្ចៈ**
ក្រុមគ្រូពេទ្យផ្ដល់សេវាវេជ្ជសាស្ត្រដល់ជនជាប់ឃុំ និងមន្ត្រីពន្ធនាគារ ចំនួន១៤ កន្លែង ជនរងគ្រោះពីការរំលោភសិទ្ធិមនុស្ស និងគ្រួសារ ដែលស្ថិតនៅតំបន់តាំងទីលំនៅថ្មី។ ក្រុមការងារសេវាសង្គមធ្វើការវាយតម្លៃពីតម្រូវការរបស់ជនរងគ្រោះ និងក្រុមគ្រួសាររបស់ពួកគេ ហើយផ្ដល់ជំនួយ សម្ភារៈ និងម្ហូបអាហាររយៈពេលខ្លី។

**ការឃ្លាំមើលពន្ធនាគារៈ**
អ្នកស្រាវជ្រាវពន្ធនាគារ ធ្វើការឃ្លាំមើលពន្ធនាគារចំនួន១៨ ដើម្បីធ្វើការវាយតម្លៃអំពីស្ថានភាពនៅក្នុងពន្ធនាគារ និងដើម្បីធានាថាជនជាប់ឃុំ ទទួលបាននូវតំណាងផ្នែកច្បាប់។

**ការប្រឹក្សាផ្នែកច្បាប់ និងកិច្ចការពារផ្នែកច្បាប់ៈ**
ជនរងគ្រោះ ត្រូវបានផ្ដល់ជូននូវការប្រឹក្សាផ្នែកច្បាប់ ហើយចំពោះករណីសំខាន់ៗទទួលបាននូវកិច្ចការពារផ្នែកច្បាប់ ដែលផ្ដល់ជូនដោយក្រុមប្រឹក្សាផ្នែកច្បាប់ និងក្រុមមេធាវីការពារសិទ្ធិមនុស្ស។

## កម្មវិធីលើកកម្ពស់ និងការទាក់ទាញមតិគាំទ្រ

**គាំទ្រសហជីព ក្រុមពលរដ្ឋមូលដ្ឋាន និងបណ្ដាញនានាៈ**
ជួយដល់សហជីព ក្រុមពលរដ្ឋមូលដ្ឋាន និងសហគមន៍ ដែលរងគ្រោះ ដោយផ្ដល់នូវកិច្ចការពារសេវាកម្មផ្នែកច្បាប់ ព្រមទាំងជួយពង្រឹងនូវសមត្ថភាពរបស់ពួកគេ ក្នុងការធ្វើយុទ្ធនាការ និងការតស៊ូមតិអំពីសិទ្ធិមនុស្ស។

**ការហ្វឹកហ្វឺនសហគមន៍ អប់រំ និងការតស៊ូមតិៈ**
អ្នកហ្វឹកហ្វឺន និងអ្នកទាក់ទាញមតិគាំទ្រ ធ្វើការអប់រំដល់ក្រុមគោលដៅជាក់លាក់មួយចំនួន បណ្ដាញគាំទ្រកិច្ចការពារសិទ្ធិមនុស្សនៅថ្នាក់មូលដ្ឋាន និងធ្វើការតស៊ូមតិសម្រាប់ការផ្លាស់ប្ដូរសង្គម និងច្បាប់ ជាមួយស្ត្រី យុវវ័យ និងកុមារ។

**ទាក់ទាញមតិគាំទ្រជាសាធារណៈ និងតាមសហគមន៍ៈ**
ករណីរំលោភសិទ្ធិមនុស្ស ដែលស៊ើបអង្កេត ដោយអង្គការលីកាដូ ត្រូវបានចងក្រងទុកនៅក្នុងប្រព័ន្ធទិន្នន័យដើម្បីឲ្យមានភាពងាយស្រួលក្នុងការស្វែងរកព័ត៌មាន វិភាគ ផលិត ជារបាយការណ៍ជាប្រចាំ (ការបោះពុម្ពជារបាយការណ៍ និងរបាយការណ៍សោតទស្សន៍) និងសម្រាប់ធ្វើការតស៊ូមតិផ្សេងៗទៀត។


**សម្រាប់ពត៌មានបន្ថែម សូមទាក់ទងៈ**

លោកស្រីវេជ្ជបណ្ឌិត ពុង ឈីវកេក, ប្រធានអង្គការសិទ្ធិមនុស្ស លីកាដូ
ផ្ទះលេខ ១៦ ផ្លូវ៩៩ រាជធានីភ្នំពេញ កម្ពុជា
ទូរស័ព្ទលេខៈ (+៨៥៥)២៣ ៧២៧ ១០២/២១៦ ៦០២
ទូរសារៈ (+៨៥៥)២៣ ៧២៧ ១០២/២១៧ ៦២៦

អ៊ីមែលៈ contact@licadho-cambodia.org
គេហទំព័រៈ www.licadho-cambodia.org Facebook: www.facebook.com/licadho Twitter: www.twitter.com/licadho

# មាតិកា


## សេចក្តីសង្ខេប ទំព័រ១

និន្នាការដែលកំពុងលេចចេញឡើងក្នុងឆ្នាំ២០១០ - ២០១២ ទំព័រ២

## ការពិនិត្យអនុសាសន៍នានានៅឆ្នាំ២០០៩ ទំព័រ៥១

## សេចក្តីផ្តើម ទំព័រ៧

តើអ្នកការពារសិទ្ធិមនុស្សជានរណា? ទំព័រ៧

កិច្ចការពារអ្នកការពារសិទ្ធិមនុស្សស្របច្បាប់ ទំព័រ៨

## អនុសាសន៍នានា ទំព័រ៥៦

## សាវតា ទំព័រ១០

ប្រវត្តិសកម្មភាពរបស់រាជរដ្ឋាភិបាលទៅលើបញ្ហាសិទ្ធិមនុស្ស ទំព័រ១០

ចារ៉ ទំព័រ១២

## ការវិភាគ ទំព័រ១៤

ស្ថាប័នតុលាការជាអាវុធដ៏មានប្រយោជន៍ទប់ទល់នឹងអ្នកការពារសិទ្ធិមនុស្ស ទំព័រ១៤

ការបំភិតបំភ័យតាមរយៈការចាប់ខ្លួន និងការឃុំខ្លួនបណ្តោះអាសន្នដោយគ្មានការចោទប្រកាន់ ទំព័រ១៩

រដ្ឋគាំទ្រឲ្យមានអំពើហិង្សា: ការបំពារបំពានទៅលើសិទ្ធិជាមូលដ្ឋាន ទំព័រ២៤

ការបង្ក្រាបតាមរយៈការអនុវត្តមិនត្រឹមត្រូវលើច្បាប់ស្រពិចស្រពិល ទំព័រ២៩

ការគំរាមកំហែងដល់អាយុជីវិត និងការប៉ុនប៉ងសម្លាប់លើអ្នកការពារសិទ្ធិមនុស្ស ទំព័រ៣១

ការបំភិតបំភ័យ និងការវាយប្រហារ ដោយអាថ៌កំបាំងទៅលើអ្នកការពារសិទ្ធិមនុស្ស ទំព័រ៣៧

ការវាយប្រហារទៅលើសង្គមស៊ីវិល ទំព័រ៣៧

ការវាយប្រហារ និងការបំភិតបំភ័យទៅលើអ្នកសារព័ត៌មាន ទំព័រ៤១

ការគំរាមកំហែងទាក់ទងនឹងប្រព័ន្ធអ៊ីនធឺណិត ទំព័រ៤៤

អាជ្ញាធរសាសនាជួយបំបិទសម្លេងបុព្វជិតដែលជាសកម្មជនសិទ្ធិមនុស្ស ទំព័រ៤៦

## ឧបសម្ព័ន្ធ ទំព័រ៥៨

ឧបសម្ព័ន្ធ ១: អ្នកការពារសិទ្ធិមនុស្សនៅកម្ពុជា (មករា ដល់ ធ្នូ ឆ្នាំ២០១០) ទំព័រ៥៨

ឧបសម្ព័ន្ធ ២: អ្នកការពារសិទ្ធិមនុស្សនៅកម្ពុជា (មករា ដល់ ធ្នូ ឆ្នាំ២០១១) ទំព័រ៨៧

ឧបសម្ព័ន្ធ ៣: អ្នកការពារសិទ្ធិមនុស្សនៅកម្ពុជា(មករា ដល់ តុលា ឆ្នាំ២០១២) ទំព័រ១០៦

ឧបសម្ព័ន្ធ៤: អ្នកការពារសិទ្ធិមនុស្សត្រូវបានឃុំខ្លួនក្នុងពន្ធនាគារគិតមកត្រឹម ថ្ងៃទី១ ខែធ្នូ ឆ្នាំ២០១២) ទំព័រ១២៤




គម្របមុខ៖ បុរសម្នាក់តវ៉ានៅរាជធានីភ្នំពេញ ដើម្បីអំពាវនាវសុំឲ្យមានការដោះលែងស្ត្រីបឹងកក់ទាំង ១៣នាក់ ដែលជាសកម្មជនដីធ្លី កាលពីថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១២

រូបថត/លីកាដូ

# សេចក្តីសង្ខេប

ចាប់តាំងពីអង្គការ លីកាដូ បានចេញរបាយការណ៍ចុងក្រោយនៅឆ្នាំ២០០៩ ស្តីពីអ្នកការពារសិទ្ធិមនុស្ស បង្ហាញអោយយើងឃើញថា បរិយាកាសសម្រាប់អ្នកការពារសិទ្ធិមនុស្សនៅប្រទេសកម្ពុជាមានភាពអាប់អួយ៉ាងខ្លាំង ការបង្កើតឲ្យមានបរិយាកាសសិទ្ធិមនុស្សនៅប្រទេសកម្ពុជាកាន់តែធ្ងន់ធ្ងរបំផុតក្នុងរយៈពេលជាង ១ ទសវត្សរ៍មកនេះ។ អំពើហិង្សាទៅលើសកម្មជនសិទ្ធិមនុស្សកាន់តែមានចំនួនកើនឡើងដែលអ្នកការពារសិទ្ធិមនុស្សសំខាន់ៗត្រូវបានគេសម្លាប់ដោយគ្មានទោស (និទ្ទណ្ឌភាព) ហើយសូម្បីតែតុលាការបានបាត់បង់នូវភាពមិនលំអៀងរបស់ស្ថាប័ននេះផងដែរ។

ឆ្នាំ២០១២ គឺជាឆ្នាំដ៏យ៉ាប់យឺនបំផុត។

លោក ម៉ម សូណង់ដូ ម្ចាស់ស្ថានីយវិទ្យុឯករាជ្យមួយ បានទទួលការកាត់ទោសឲ្យជាប់ពន្ធនាគារចំនួន ២០ឆ្នាំ ក្នុងរឿងនយោបាយដោយចំហនៅអំឡុងខែតុលា។ បុគ្គលិកអង្គការមិនមែនរដ្ឋាភិបាលមួយចំនួន បានទទួលរងនូវការរំខានយាយីពីស្ថាប័នតុលាការ។ អភិបាលក្រុងមួយរូបបានបាញ់រះដោយគ្មានញញើតទៅលើក្រុមកម្មករកាត់ដេរ ដែលកំពុងធ្វើបាតុកម្មធ្វើឲ្យកម្មករចំនួន ៣ នាក់ទទួលរងរបួសជាទម្ងន់ ហើយអភិបាលក្រុងនោះបានរត់គេចពីការចាប់ខ្លួនរហូតមកទល់បច្ចុប្បន្ននេះ។ អ្នកតំណាងចំនួន ១៣ នាក់ពីសហគមន៍បឹងកក់ ដែលមានទំនាស់ដីធ្លីត្រូវបានកាត់ទោសឲ្យជាប់ពន្ធនាគារបន្ទាប់ពីមានកាប្រមូលផ្តុំគ្នាដោយអហិង្សា ដោយមានច្រៀងចំរៀងទាក់ទងនឹងសិទ្ធិដីធ្លី។ កងកម្លាំងប្រដាប់អាវុធរបស់អាជ្ញាធររដ្ឋរាប់ទាំងទាហានរាប់រយនាក់ផង បានធ្វើការបង្ក្រាបបែបយោធាទៅលើភូមិមួយពាក់ព័ន្ធនឹងទំនាស់ដីធ្លី ដែលនាំឲ្យក្មេងស្រីម្នាក់អាយុ ១៤ ឆ្នាំបាត់បង់ជីវិត។ ពួកអ្នកទាំងនោះបានព្យាយាមធ្វើការដោះសារដោយមិនគួរឲ្យជឿថា អ្នកភូមិទាំងនោះកំពុងព្យាយាមបំបែករដ្ឋ។

លោក ឈុត វុទ្ធី ជាសកម្មជនបរិស្ថានត្រូវបានកងកម្លាំងរាជរដ្ឋាភិបាលបាញ់សម្លាប់នៅខណៈដែលគាត់កំពុងធ្វើការស៊ើបអង្កេតការកាប់ឈើខុសច្បាប់នៅខេត្តកោះកុង។ ហើយនៅក្នុងឧប្បត្តិហេតុមួយដោយឡែក អ្នកសារព័ត៌មានមួយរូប ដែលជាអ្នកស៊ើបអង្កេត និងធ្វើការលើបញ្ហាអាជីវកម្មកាប់ឈើដែរនោះ ក៏ត្រូវបានគេបាញ់សម្លាប់ផងដែរនៅក្នុងខេត្តរតនគីរី។ អាជ្ញាធរបានប្រើប្រាស់កម្លាំងទៅលើបាតុករ និងអ្នកការពារសិទ្ធិមនុស្សបណ្តាលឲ្យស្លាប់ យ៉ាងតិចណាស់ចំនួន ៨ លើក នៅចន្លោះខែវិច្ឆិកា ឆ្នាំ២០១១ និងខែឧសភា ឆ្នាំ២០១២។

ប្រើប្រៀបធៀបឆ្នាំ២០១០ និងឆ្នាំ២០១១ ស្ថានភាពឆ្នាំ២០១២ ហាក់ដូចជាកាន់តែមានសភាពពិបាកឡើងៗ។ អង្គការមិនមែនរដ្ឋាភិបាលមួយ ដែលធ្វើការលើសិទ្ធិដីធ្លីត្រូវបានក្រសួងមហាផ្ទៃផ្អាក

លែងឲ្យដំណើរការមួយរយៈដោយគ្មានមូលដ្ឋានច្បាប់។ ជនសង្ស័យបានប៉ុនប៉ងធ្វើឃាតអ្នកការពារសិទ្ធិមនុស្សចំនួនយ៉ាងតិចណាស់ ៣ នាក់ ហើយពួកគេបានសម្រេចបំណងក្នុងការធ្វើឃាតទៅលើអ្នកការពារសិទ្ធិមនុស្សបានចំនួន ១ នាក់។ ហើយករណីទាំងនេះ គឺជាឧប្បត្តិហេតុ ដែលត្រូវបានគេផ្សព្វផ្សាយច្រើនបំផុត។ ទោះតាមបទដ្ឋានណាក៏ដោយសិទ្ធិមនុស្សនៅប្រទេសកម្ពុជាបានធ្លាក់យ៉ាងខ្លាំង ហើយគ្មានតម្រុយថានឹងអាចទប់ស្កាត់បាននៅពេលណាមួយឆាប់ៗឡើយ។

## និន្នាការដែលកំពុងលេចចេញឡើងក្នុងឆ្នាំ២០១០ - ២០១២

ការគំរាមកំហែង និងការវាយប្រហារថ្មីៗទៅលើអ្នកការពារសិទ្ធិមនុស្ស គឺសំដៅលើសលុបទៅរកក្រុមសំខាន់ៗចំនួន ៤ គឺ ក្រុមទី១ ជាអ្នកតំណាងសហគមន៍ពាក់ព័ន្ធក្នុងជម្លោះដីធ្លី ក្រុមទី២ ជាកម្មកររោងចក្រ និងប្រធានសហជីព ក្រុមទី៣ជាអង្គការមិនមែនរដ្ឋាភិបាល និងបុគ្គលិកអង្គការមិនមែនរដ្ឋាភិបាល ព្រមទាំងក្រុមទី៤ ជាអ្នកសារព័ត៌មាន។ ក្រុមសំខាន់ៗទាំងនេះ បានប្រឈមទៅនឹងអំពើហិង្សា ពាក្យបណ្តឹងគ្មានមូលដ្ឋាន ការឃុំឃាំងក្នុងពន្ធនាគារ ការបំពារបំពានលើរាងកាយ ការសងសឹករហូតដល់ឃាតកម្ម។

ជនសង្ស័យដែលធ្វើការគំរាមកំហែង និងវាយប្រហារទៅលើអ្នកការពារសិទ្ធិមនុស្ស ដំបូងគេ គឺជាមន្ត្រីអាជ្ញាធររដ្ឋចាប់ពីអាជ្ញាធរថ្នាក់មូលដ្ឋាន និងថ្នាក់ខេត្តរហូតដល់សមាជិកជាន់ខ្ពស់បំផុតមួយចំនួនរបស់គណៈបក្សកំពុងកាន់អំណាច។ កងកម្លាំងប្រដាប់អាវុធបានចូលរួមដោយផ្ទាល់ផងដែរ ក្នុងការរំលោភបំពានទៅលើសិទ្ធិរបស់អ្នកការពារសិទ្ធិមនុស្សក្នុងនាមខ្លួនផ្ទាល់ ឬក្នុងនាមវិស័យឯកជន។ ជនសង្ស័យនៅតែបន្តគេចផុតពីការនាំខ្លួនមកកាត់ទោស។ វប្បធម៌និទ្ទណ្ឌភាពនៅប្រទេសកម្ពុជានៅតែបន្តកើតមាន ហើយនៅតែជាបញ្ហា នៅពេលមានករណីពាក់ព័ន្ធនឹងអ្នកការពារសិទ្ធិមនុស្ស។

ចាប់តាំងពីឆ្នាំ២០១០ អង្គការលីកាដូ បានប្រមូលចងក្រងជាឯកសារ នូវនិន្នាការគួរឲ្យព្រួយបារម្ភចំនួន ៣ ក្នុងការធ្វើទុក្ខបុកម្នេញអ្នកការពារសិទ្ធិមនុស្ស។

និន្នាការទី១ **ស្ថាប័នតុលាការស្ថិតនៅក្រោមការត្រួតត្រាយ៉ាងតឹងរឹងរបស់អង្គការនីតិប្រតិបត្តិ។** នៅតែមានការបន្តប្រើប្រាស់ស្ថាប័នតុលាការមិនត្រឹមត្រូវ ជាអាវុធតាមបំណងប្រឆាំងនឹងអ្នកការពារសិទ្ធិមនុស្ស។ គួរអោយព្រួយបារម្ភ មួយចំនួននៃអ្នកការពារសិទ្ធិមនុស្សថ្នាក់មូលដ្ឋាន ប្រធានសហជីព អ្នកតំណាងសហគមន៍ពាក់ព័ន្ធនឹងជម្លោះដីធ្លី បុគ្គលិកអង្គការមិនមែនរាជរដ្ឋាភិបាល ហើយសូម្បីតែព្រះសង្ឃក៏ត្រូវបានចាប់ខ្លួន ធ្វើការចោទប្រកាន់មិនត្រឹមត្រូវ និងត្រូវបានឃុំខ្លួនចាប់តាំងពីឆ្នាំ២០១០ (ជួនកាលគ្មានសិទ្ធិទទួលបានមេធាវីការពារខ្លួន ឬមិនដឹងពីបទចោទប្រកាន់ប្រឆាំងនឹងខ្លួន)។ នៅពេលកំពុងឃុំខ្លួន សកម្មជនសិទ្ធិមនុស្សមួយចំនួនត្រូវបានគេបង្ខំឲ្យផ្តិតមេដៃលើសេចក្តីប្រកាស (ចម្លើយ)

ដោយឲ្យសន្យាថានឹងបញ្ឈប់ការងារសិទ្ធិមនុស្សរបស់ពួកគេ។ សកម្មជនខ្លះទៀត ត្រូវបានគេបំបាក់ទឹកចិត្តមិនឲ្យបន្តការងារសិទ្ធិមនុស្សរបស់ពួកគេ តាមរយៈការរំខានយាយីពីស្ថាប័នតុលាការ។

ការចូលជាធរមាននៃក្រមព្រហ្មទណ្ឌថ្មីនៅឆ្នាំ២០១០ មិនបានធ្វើឲ្យស្ថានភាពសិទ្ធិមនុស្សល្អប្រសើរឡើយ។ ផ្ទុយទៅវិញបទល្មើសមួយចំនួនដែលចែងមិនច្បាស់លាស់ និងស្រពិចស្រពិលត្រូវបានយកមកប្រើដដែលៗ ដើម្បីប្រឆាំងនឹងអ្នកការពារសិទ្ធិមនុស្ស។ ជាពិសេសបទញុះញង់ បទជេរប្រមាថ និងបទប្រឆាំងនឹងអ្នករាជការសាធារណៈ ត្រូវបានគេយកមកប្រើប្រាស់ដើម្បីគំរាមកំហែង និងដោះសារចំពោះការចាប់ខ្លួន និងឃុំខ្លួនអ្នកការពារសិទ្ធិមនុស្ស នៅពេលធ្វើការតវ៉ាដោយអហិង្សា និងការបណ្ដេញចេញដោយបង្ខំ។ ក្នុងករណីដទៃទៀតការចោទប្រកាន់បែបនេះ ត្រូវបានយកមកប្រើដើម្បីតបតទៅនឹងការងារ ដែលគេមើលឃើញថាជាការរិះគន់ចំពោះចំណាត់ការរបស់អាជ្ញាធរដ្ឋ។ នៅខែឧសភា ឆ្នាំ២០១២ ការចាប់ខ្លួនសកម្មជនការពារសិទ្ធិដីធ្លីចំនួន ១៣ នាក់ ពីសហគមន៍បឹងកក់បានកត់សម្គាល់ឃើញថា ជាផ្នែកជោគជ័យបំផុតថ្មីមួយ ក្នុងការប្រើប្រាស់ស្ថាប័នតុលាការ ដើម្បីរឹតត្បិតសិទ្ធិរបស់អ្នកការពារសិទ្ធិមនុស្ស។ ប៉ុន្តែ ២ ឬ ៣ ខែក្រោយមកស្ថានភាពសិទ្ធិមនុស្សក៏កាន់តែលំបាកទៅៗ ដោយសារលោក ម៉ម សូណង់ដូ ជាម្ចាស់វិទ្យុសំបុកឃ្មុំត្រូវបានចាប់ខ្លួន ហើយតុលាការក៏បានចេញដីកាកោះក្នុងរឿងព្រហ្មទណ្ឌ ដើម្បីបង្គាប់ឲ្យលោក ចាន់ សុវ៉េត ដែលជាអ្នកស៊ើបអង្កេតជាន់ខ្ពស់របស់អង្គការអាដហុក (Adhoc) ចូលខ្លួន។



អ្នកគាំទ្រធ្វើការតវ៉ានៅខាងក្រៅសវនាការ លើរឿងក្ដីអ្នកការពារសិទ្ធិមនុស្ស លោក ម៉ម សូណង់ដូ នៅរាជធានីភ្នំពេញ កាលពីថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០១២

លោក ម៉ម សូណង់ដូ ត្រូវបានកាត់ទោសក្នុងខែតុលា ឆ្នាំ២០១២ ពីបទញុះញង់ឲ្យមានចលនា “អបគមន៍” ក្នុងខេត្តក្រចេះ ទោះជានៅចំពោះមុខសវនាការគ្មានភស្តុតាងដាក់បន្ទុក (ឬមិនឃើញមានផែនការអបគមន៍) ត្រូវបានលើកមកបង្ហាញក៏ដោយ។ អ្នកភូមិចំនួន ១៣ នាក់ផ្សេងទៀតមកពីខេត្តក្រចេះក៏ត្រូវបានកាត់ទោសជាមួយលោក ម៉ម សូណង់ដូ ពីបទល្មើសទាក់ទងនឹងផែនការអបគមន៍មួយ

នេះ។ ដីកាកោះហៅ ដែលបង្គាប់លោក ចាន់ សុវ៉េត ចូលខ្លួនក៏ត្រូវបានគេជឿថា មានការពាក់ព័ន្ធនឹងករណី "អបគមន៍" នៅខេត្តក្រចេះនេះផងដែរ ទោះជាពាក្យពេចន៍ក្នុងដីកាកោះនោះ មិនមានលក្ខណៈច្បាស់លាស់ក៏ដោយ។

អង្គការលីកាដូ ក៏បានប្រមូលចងក្រងឯកសារឧប្បត្តិហេតុជាឈុត ដែលអាជ្ញាធរស៊ីវិល និងអាជ្ញាធរសាសនាបានគំរាមកំហែងព្រះសង្ឃ ១ អង្គ ព្រះនាម លួន សូវ៉ាត ដែលជាសកម្មជនសិទ្ធិមនុស្សនៅចន្លោះឆ្នាំ២០១០ និងឆ្នាំ២០១២។

និន្នាការទី២ ដែលត្រូវបានចងក្រងទុកជាឯកសារចាប់តាំងពីឆ្នាំ២០១០ គឺជា**ការកើនឡើងគួរឲ្យព្រួយបារម្ភនូវអំពើហិង្សា ដែលត្រូវបានប្រព្រឹត្តពីសំណាក់កងកម្លាំងប្រដាប់អាវុធរបស់អាជ្ញាធររដ្ឋទៅលើអ្នកតវ៉ាដោយសន្តិវិធី**។ ជាពិសេសនៅឆ្នាំ២០១២ ការស៊ើបអង្កេតរបស់អង្គការលីកាដូ បានបង្ហាញឲ្យឃើញថា មានការកើនឡើងនៃការប្រើប្រាស់កងកម្លាំងសន្តិសុខ និងយោធា ដែលអាចបណ្ដាលឲ្យគ្រោះថ្នាក់ដល់ជីវិតទៅលើប្រជាពលរដ្ឋស៊ីវិល។ គ្រាន់តែនៅចន្លោះខែវិច្ឆិកា ឆ្នាំ២០១១ និងខែឧសភា ឆ្នាំ២០១២ អាជ្ញាធរបានបើកការបាញ់ប្រហារចំនួនយ៉ាងតិចណាស់ ៨ លើក នៅពេលកំពុងមានការតវ៉ា កូដកម្ម ឬបាតុកម្មដោយអហិង្សា។ ភាគច្រើននៃឧប្បត្តិហេតុទាំងនេះ បានកើតឡើងក្នុងបរិបទជម្លោះដីធ្លី ជាទីដែលកងកម្លាំងប្រដាប់អាវុធរបស់អាជ្ញាធររដ្ឋបានដើរតួជាឆ្មាំសន្តិសុខឲ្យក្រុមហ៊ុនឯកជន។ ជារួមឧប្បត្តិហេតុទាំងនេះ បានបង្ហាញឲ្យឃើញនូវការបន្តការសហការគ្នា ដែលកើតឡើងរវាងអាជ្ញាធររដ្ឋ និងក្រុមហ៊ុនឯកជនមានអំណាចក្នុងការស្វែងរកការរឹបអូសយកដីធ្លីពីប្រជាពលរដ្ឋកម្ពុជា។

ភាពឃោឃៅ និងការបំពារបំពានរាងកាយដោយមានគោលដៅទៅលើ លោក សួង សុភ័ណ្ឌ ដែលជាសកម្មជនការពារសិទ្ធិដីធ្លី និងលោក រ៉ុង បញ្ញា ជាប្រធានសហជីព នៅពេលកំពុងធ្វើការតវ៉ាដោយអហិង្សា បានបង្កឲ្យមានកង្វល់កាន់តែធ្ងន់ធ្ងរសម្រាប់សុវត្ថិភាពអ្នកការពារសិទ្ធិមនុស្ស។ លោក សុភ័ណ្ឌ បានទទួលរងនូវការវាយដំចំនួន ២ លើក ដែលមានមួយលើក បង្កឡើងដោយក្រុមនគរបាលអន្តរាគមន៍ប្រឆាំងកុប្បកម្ម។ ការសម្លាប់លោក ពេជ្រ សុផុន និងលោក ឈុត វុទ្ធី ដែលអ្នកទាំងពីរជាអ្នកការពារសិទ្ធិមនុស្សនៅចន្លោះឆ្នាំ២០១០ និងឆ្នាំ២០១២ ហើយនឹងហេតុការណ៍គំរាមសម្លាប់ជាច្រើនទៀតទៅលើអ្នកការពារសិទ្ធិមនុស្សបានគូសបញ្ជាក់ថែមទៀតនូវគ្រោះថ្នាក់ ដែលអ្នកការពារសិទ្ធិមនុស្សបានទទួលរង។

លើសពីនេះទៅទៀត ច្បាប់ថ្មីស្ដីពីការធ្វើបាតុកម្មដោយអហិង្សា បានផ្ដល់ឲ្យមន្ត្រីនគរបាលនូវឱកាសបន្ថែមមួយទៀត សម្រាប់ធ្វើការបង្ក្រាបដោយហិង្សាទៅលើសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ និងការជួបប្រជុំគ្នា។ ដូចគ្នាទៅនឹងច្បាប់ដ៏ទៃទៀត ដែលទើបតែត្រូវបានអនុម័តថ្មីៗនេះ ភាពមិនច្បាស់

លាស់ គឺជាបញ្ហាមួយជាមួយនឹងច្បាប់។ និយមន័យគ្មានលក្ខណៈគ្រប់គ្រាន់ និងការកំណត់ព្រំដែនហេតុផលទៅលើឆន្ទានុសិទ្ធិរបស់អាជ្ញាធរ បានអនុញ្ញាតឲ្យមានការរំលោភបំពានទៅលើសិទ្ធិជាមូលដ្ឋានយ៉ាងច្រើន។

និន្នាការទី៣ ដែលត្រូវបានកត់សម្គាល់ គឺការប្រើប្រាស់**យុទ្ធសាស្ត្រផ្សេងៗ ដោយគ្មានតម្លាភាព ដើម្បីបំបិទមាត់អ្នកដែលហ៊ានរិះគន់ចំណាត់ការរបស់អាជ្ញាធររដ្ឋ**។ អង្គការមិនមែនរដ្ឋាភិបាល និងបុគ្គលិកអង្គការមិនមែនរដ្ឋាភិបាល បានទទួលរងនូវការបំភិតបំភ័យតាមមធ្យោបាយច្រើនយ៉ាងនៅចន្លោះឆ្នាំ២០១០ និងឆ្នាំ២០១២។ ការបណ្ដុះបណ្ដាលអំពីសិទ្ធិដីធ្លីជាមួយសហគមន៍ ដែលពាក់ព័ន្ធក្នុងជម្លោះដីធ្លី ត្រូវបានរំខានដោយអាជ្ញាធរមូលដ្ឋាន ដោយមូលហេតុគួរឲ្យសង្ស័យ ហើយក្រសួងមហាផ្ទៃបានផ្អាកដំណើរការអង្គការមិនមែនរដ្ឋាភិបាលមួយជាបណ្ដោះអាសន្ន គឺសមាគមន៍ធាងត្នោត ដែលបានធ្វើការតស៊ូមតិជាសាធារណៈសម្រាប់សិទ្ធិជនរងគ្រោះពីការរឹបអូសដីធ្លីក្នុងករណីទ្រង់ទ្រាយធំ។

អ្នកសារព័ត៌មាន ដែលរាយការណ៍អំពីបញ្ហាសិទ្ធិមនុស្ស ក៏ត្រូវក្លាយទៅជាជនរងគ្រោះផងដែរ ពីការបំភិតបំភ័យពីរដ្ឋអំណាច។ ឧបករណ៍សារព័ត៌មាន ត្រូវបានរឹបអូសនៅពេលកំពុងធ្វើសន្និសីទកាសែត រូបភាពនៃការបណ្ដេញចេញដោយបង្ខំត្រូវបានលុបចោល ដោយមន្ត្រីនគរបាល និងអាជ្ញាប័ណ្ណសារព័ត៌មានត្រូវបញ្ចប់សុពលភាព ដោយគ្មានការសំអាងតាមផ្លូវច្បាប់។

ដោយសារតែអ្នកប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិតកាន់តែមានចំនួនច្រើនឡើងៗ និងយ៉ាងឆាប់រហ័សពី ១ ឆ្នាំទៅ ១ ឆ្នាំ ទើបអាជ្ញាធររដ្ឋទំនងជាមានការព្រួយបារម្ភកាន់តែច្រើនឡើងក្នុងការគ្រប់គ្រងព័ត៌មានតាមប្រព័ន្ធអនឡាញ (Online)។ ការបិទគេហទំព័រដ៏ចំរូងចំរាសនៅខែមករា ឆ្នាំ២០១១ គឺជាសញ្ញាជាក់ស្ដែងលើកដំបូង នៃការត្រួតពិនិត្យចាប់ពិរុទ្ធតាមប្រព័ន្ធអ៊ីនធឺណិត។ សេចក្ដីណែនាំនៅឆ្នាំ២០១២ បានតម្រូវថា ហាងកាហ្វេ ដែលមានភ្ជាប់សេវាអ៊ីនធឺណិត និងសេវាទូរស័ព្ទសាធារណៈ ត្រូវតែដំឡើងកាមេរ៉ាត្រួតពិនិត្យ ហើយនឹងត្រូវរក្សាទុកកំណត់ត្រាព័ត៌មានពិស្ដាររបស់អតិថិជន។ បច្ចុប្បន្នមនុស្សភាគច្រើនមានការភ័យខ្លាចថា គ្រប់គ្រងប្រព័ន្ធអ៊ីនធឺណិតនាពេលខាងមុខ (ច្បាប់នេះ មិនទាន់បានបញ្ជាក់ពីរាជរដ្ឋាភិបាលថា មាននៅឡើយទេ ទោះជាតាមការដឹងមកថា ច្បាប់នេះ ស្ថិតនៅទីស្ដីការគណៈរដ្ឋមន្ត្រីក៏ដោយ) នឹងត្រូវបានគេប្រើជាឧបករណ៍ថ្មីមួយ ដើម្បីបំពានលើសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិតាមប្រព័ន្ធអ៊ីនធឺណិត។

របាយការណ៍នេះ មិនមែនជាការពិនិត្យទូលំទូលាយនូវការវាយប្រហារ និងការគំរាមកំហែងទៅលើអ្នកការពារសិទ្ធិមនុស្សទាំងអស់នៅប្រទេសកម្ពុជានៅចន្លោះឆ្នាំ២០១០ និងឆ្នាំ២០១២នោះឡើយ ដោយសារតែករណីភាគច្រើនមិនត្រូវបានគេរាយការណ៍ឲ្យដឹង។ ផ្ទុយទៅវិញរបាយការណ៍នេះ មាន

គោលដៅផ្ដល់នូវទិដ្ឋភាពសង្ខេបស្ដីពីការរំលោភបំពានសិទ្ធិមនុស្ស ដែលអង្គការលីកាដូ បានធ្វើសេចក្ដីសង្កេត និងស៊ើបអង្កេតនៅអំឡុងពេលនោះ។ របាយការណ៍នេះ ដើរតួជាឯកសារយោងផងដែរ ដើម្បីលើកពីបញ្ហាការវាយប្រហារ និងការគំរាមកំហែងទៅលើអ្នកការពារសិទ្ធិមនុស្សមកពិភាក្សារកដំណោះស្រាយ ព្រមទាំងលើកកំពស់ការយល់ដឹងអំពីស្ថានភាពសិទ្ធិមនុស្សនៅប្រទេសកម្ពុជាចាប់តាំងពីឆ្នាំ ២០១០ កន្លងទៅ។




បាតុកម្មនៅថ្ងៃទិវាគ្រូបង្រៀនអន្តរជាតិ នៅទីលានប្រជាធិបតេយ្យ នៅរាជធានីភ្នំពេញ
កាលពីថ្ងៃទី៥ ខែតុលា ឆ្នាំ២០១២

# សេចក្ដីផ្ដើម

## តើអ្នកការពារសិទ្ធិមនុស្សជានរណា?

ពាក្យថា "អ្នកការពារសិទ្ធិមនុស្ស" ត្រូវបានយកមកប្រើសំដៅទៅរកតួអង្គសង្គម ជាបុគ្គលក្ដី ឬជាផ្នែកនៃក្រុមមនុស្សមួយក្រុមក្ដី ដែលធ្វើការងារដើម្បីលើកកម្ពស់ និងការពារសិទ្ធិមនុស្សជាមូលដ្ឋានតាមរយៈមធ្យោបាយដោយអហិង្សា។ អ្នកការពារសិទ្ធិមនុស្សត្រូវបានគេកំណត់ជាអាទិភាពតាមសកម្មភាពរបស់ពួកគេ មិនមែនតាមវិជ្ជាជីវៈរបស់ពួកអ្នកទាំងនោះឡើយ។ ជនណាដែលដើរតួការពារ ឬលើកស្ទួយសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច ឬសិទ្ធិវប្បធម៌ សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយក្នុងនាមបុគ្គលទាំងឡាយ ឬក្នុងនាមក្រុមមនុស្ស គឺជាអ្នកការពារសិទ្ធិមនុស្ស។ ជាទូទៅអ្នកការពារសិទ្ធិមនុស្សមានដូចជានិស្សិត បុគ្គលិកអង្គការមិនមែនរដ្ឋាភិបាល គ្រូបង្រៀន មេធាវី ប្រធានសហជីព ព្រះសង្ឃ អ្នកតំណាងសហគមន៍ និងអ្នកសារព័ត៌មានជាដើម។

បច្ចុប្បន្ននេះ សកម្មជនសហគមន៍ និងអង្គការសិទ្ធិមនុស្ស ដែលកាន់តែមានចំនួនច្រើនឡើងដើរតួនាទីសំខាន់ដើម្បីការពារ និងលើកស្ទួយសិទ្ធិមនុស្សនៅប្រទេសកម្ពុជា។ នៅក្នុងរបាយការណ៍នេះអ្នកការពារសិទ្ធិមនុស្សត្រូវបានគេកំណត់ដើម្បីសំដៅទៅរកសិទ្ធិមនុស្ស ដែលមានចែងក្នុងសេចក្ដីប្រកាសជាសាកលស្ដីពីសិទ្ធិមនុស្ស ហើយដែលត្រូវបានធានាការពារតាមកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ហើយនឹងកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងសិទ្ធិវប្បធម៌។ តាមន័យនេះ ដើម្បីកំណត់ថា ករណីមួយចូលជាការគំរាមកំហែងដល់អ្នកការពារសិទ្ធិមនុស្ស ឬយ៉ាងណានោះ អង្គការលីកាដូ ពិនិត្យមើលថា តើជនរងគ្រោះបានបំពេញសកម្មភាព ដែលស្វែងរកការការពារ ឬការលើកស្ទួយសិទ្ធិមនុស្សពិតប្រាកដ ដូចបានគូសបញ្ជាក់ក្នុងសន្ធិសញ្ញាអន្តរជាតិទាំងនេះ ឬយ៉ាងណា។ ម្យ៉ាងទៀត សកម្មភាពបែបនេះ គួរតែត្រូវបានគេបំពេញទាំងស្រុង ឬមួយផ្នែកក្នុងនាមមនុស្សដទៃទៀត ហើយនឹងបានស៊ើបអង្កេតទៅលើការគំរាមកំហែង ឬការវាយប្រហារទៅលើ អ្នកការពារសិទ្ធិមនុស្ស។

អ្នកនយោបាយក៏អាចដើរតួជាអ្នកការពារសិទ្ធិមនុស្សបានផងដែរ។ ទោះបីយ៉ាងណាក៏ ដោយគណៈបក្សកាន់អំណាចនៃប្រទេសទាំងឡាយ ដែលមានកំណត់ត្រាខាងសិទ្ធិមនុស្សទន់ខ្សោយ ដូចជាប្រទេសកម្ពុជាជាដើម ល្បីថាមានការព្យាយាមបង្ខូចកិត្តិយសអង្គការសិទ្ធិមនុស្ស ដែលជាអង្គការអព្យាក្រឹត និងមិនលំអៀង ដោយភ្ជាប់អង្គការទាំងនោះទៅនឹងការប្រឆាំងខាងនយោបាយ។ ដើម្បីចៀសវាងការចោទប្រកាន់ពីការប្រកាន់បក្សពួកបែបនេះ អង្គការលីកាដូ បានសំរេចមិនដាក់បញ្ចូលទៅក្នុងរបាយការណ៍នេះ នូវការគំរាមកំហែង ដែលអ្នកនយោបាយទទួលរងឡើយ។

## កិច្ចការពារអ្នកការពារសិទ្ធិមនុស្សស្របច្បាប់

ដោយសារមានការចុះហត្ថលេខា និងផ្តល់សច្ចាប័នទៅលើសេចក្តីប្រកាស សេចក្តីសំរេចចិត្ត និងសេចក្តីថ្លែងការអន្តរជាតិនានា ដែលមានគោលដៅលើកស្ទួយ និងជម្រុញសកម្មភាពសិទ្ធិមនុស្ស ទើបរដ្ឋាភិបាលនៅទូទាំងពិភពលោក បានទទួលស្គាល់ករណីកិច្ច ដើម្បីការពារសិទ្ធិមនុស្សអស់រយៈពេលជាច្រើនទសវត្សរ៍មកហើយ។ អ្នកសកម្មនិយមខាងសិទ្ធិមនុស្សត្រូវបានចាត់ទុកជាកត្តាចាំបាច់ក្នុងការធ្វើឲ្យប្រសើរឡើងនូវសេចក្តីថ្លៃថ្នូរខាងមនុស្សជាតិ ដោយកាត់បន្ថយភាពក្រីក្រ និងការរើសអើង ហើយនឹងដោយធានាបាននូវការពង្រឹងគោលការណ៍លទ្ធិប្រជាធិបតេយ្យ និងនីតិរដ្ឋ។

នៅក្នុងប្រទេសកម្ពុជាកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស ថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ បានជួយបង្កើតក្របខ័ណ្ឌច្បាប់សម្រាប់ការពារសិទ្ធិក្នុងការបញ្ចេញមតិ សិទ្ធិបង្កើតនិងចូលរួមសមាគម និងសិទ្ធិជួបប្រជុំនៅប្រទេសកម្ពុជា (ជាសិទ្ធិស្នូល ដែលត្រូវបានអនុវត្តដោយអ្នកការពារសិទ្ធិមនុស្ស)។

នៅឆ្នាំ១៩៩២ រាជរដ្ឋាភិបាលកម្ពុជាបានចុះហត្ថលេខា និងផ្តល់សច្ចាប័ន ទៅលើសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិសំខាន់ចំនួនពីរ គឺកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ និងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌។ បន្ទាប់មកនៅឆ្នាំ១៩៩៣ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានអនុម័ត ហើយមាត្រា ៣១ បានបញ្ចូលបទប្បញ្ញត្តិនៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ និងកតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ទៅក្នុងច្បាប់កំពូលរបស់ប្រទេសកម្ពុជា។

> ព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ និងគោរពសិទ្ធិមនុស្ស ដូចមានចែងក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញា ព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងទៅនឹងសិទ្ធិមនុស្ស សិទ្ធិនារី និងសិទ្ធិកុមារ
>
> រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
> មាត្រា ៣១ កថាខ័ណ្ឌ ១

នៅឆ្នាំ១៩៩៨ មហាសន្និបាតអង្គការសហប្រជាជាតិបានអនុម័តផងដែរនូវសេចក្តីប្រកាសស្តីពីសិទ្ធិ និងការទទួលខុសត្រូវរបស់បុគ្គល ក្រុមមនុស្ស និងអង្គការសង្គម ដើម្បីលើកស្ទួយ និងការពារសេរីភាពជាមូលដ្ឋានព្រមទាំងសិទ្ធិមនុស្ស ដែលត្រូវបានទទួលស្គាល់ជាសកល។ សេចក្តីប្រកាសនេះ ត្រូវបានគេស្គាល់ជាទូទៅថា ជា"សេចក្តីប្រកាសស្តីពីអ្នកការពារសិទ្ធិមនុស្ស"។[១] សេចក្តីប្រកាសឆ្នាំ១៩៩៨ នេះ មានចែងអំពីកិច្ចការពារអ្នកការពារសិទ្ធិមនុស្ស

[១] ព័ត៌មានបន្ថែម និងអត្ថបទទាំងស្រុងនៃសេចក្តីប្រកាស សូមមើល http://www2.ohchr.org/english/law/freedom.htm

ដែលតម្រូវឲ្យរដ្ឋជាសមាជិករបស់អង្គការសហប្រជាជាតិ (ប្រទេសកម្ពុជា ក៏ជាសមាជិកមួយរបស់អង្គការសហប្រជាជាតិដែរ) ត្រូវតែលើកកម្ពស់ ហើយផ្អែកលើគោលការណ៍ទាំងឡាយ ដែលជាប់កាតព្វកិច្ចខាងផ្លូវច្បាប់ ព្រមទាំងសិទ្ធិដែលមានចែងក្នុងបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ ដែលមានស្រាប់។ កិច្ចការពារទាំងនេះ រាប់ទាំងសិទ្ធិស្វែងរកធ្វើលទ្ធកម្ម ទទួល និងរក្សាទុកព័ត៌មានទាក់ទងនឹងសិទ្ធិមនុស្ស ព្រមទាំងសិទ្ធិដាក់ពាក្យបណ្ដឹងអំពីប្រការ ដែលរដ្ឋាភិបាលមិនបានអនុវត្តទៅតាមបទដ្ឋានសិទ្ធិមនុស្សនានា។



ការហែក្បួននៅថ្ងៃទិវាពលកម្មអន្តរជាតិ នៅរាជធានីភ្នំពេញ ថ្ងៃទី១ ខែឧសភា ឆ្នាំ២០១២

# សាវតា

## ប្រវត្តសកម្មភាពរបស់រាជរដ្ឋាភិបាលនៅលើបញ្ហាសិទ្ធិមនុស្ស

កេរ្តិ៍ដំណែលនៃរបបខ្មែរក្រហម ដែលបានសម្លាប់ប្រជាពលរដ្ឋខ្មែរប្រមាណ ១.៧ លាននាក់នៅចន្លោះឆ្នាំ១៩៧៥ និងឆ្នាំ១៩៧៩ នៅតែជិតជាមអស់ជាង ៣ ទសវត្សរ៍កន្លងមកហើយ។ នៅអំឡុងពេលនោះ ការរំលោភសិទ្ធិមនុស្សយ៉ាងធ្ងន់ធ្ងរ បានកើតឡើងទូទាំងប្រទេស។ របបខ្មែរក្រហមបានបញ្ចប់ទៅនៅឆ្នាំ១៩៧៩ ប៉ុន្តែសង្គ្រាមស៊ីវិលបានបន្តកើតមានពេញអំឡុងឆ្នាំទសវត្សរ៍ឆ្នាំ១៩៨០។ ការបង្កើតអាជ្ញាធរអន្តរកាលអង្គការសហប្រជាជាតិ នៅប្រទេសកម្ពុជា (UNTAC) នៅឆ្នាំ១៩៩២ បានបង្កើតច្រកមួយចំនួនសម្រាប់ការចាប់បដិសន្ធិ និងការកសាងឡើងវិញនូវសង្គមស៊ីវិល។ ទោះបីយ៉ាងណាក៏ដោយបរិបទនយោបាយនៅប្រទេសកម្ពុជាបច្ចុប្បន្ន នៅតែទទួលរងនូវឥទ្ធិពលពីប្រវត្តិនៃអំពើហិង្សានេះ ហើយប្រទេសកម្ពុជា នៅតែបន្តមានកំណត់ត្រាខាងសិទ្ធិមនុស្សទន់ខ្សោយនៅឡើយ។ រហូតមកទល់បច្ចុប្បន្ន នៅឆ្នាំ២០១២នេះ គឺជាឆ្នាំដ៏លំបាកបំផុតក្នុងរយៈពេលមួយទសវត្សរ៍ ដោយសារតែកើតមាននូវអំពើហិង្សា និងការបង្ក្រាបសិទ្ធិមនុស្ស។

> "អ្វីដែលជាសេចក្តីត្រូវការនៅកម្ពុជា គឺមិនមែនគ្រាន់តែជាការប្តេជ្ញាចិត្តជាផ្លូវការពីរាជរដ្ឋាភិបាលចំពោះសិទ្ធិមនុស្សប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងការអនុវត្តរបស់រាជរដ្ឋាភិបាល តាមរយៈសកម្មភាពកំណត់ក្នុងវិស័យសំខាន់ៗមួយចំនួនផងដែរ។ ដូចនេះ គឺត្រូវការ ឲ្យមានការសន្ទនា និងសហប្រតិបត្តិការប្រកប ដោយអត្ថន័យ និងស្ថាបនាក្នុងវិស័យទាំងនេះរវាងរាជរដ្ឋាភិបាល សង្គមស៊ីវិល និងសហគមន៍អន្តរជាតិ។ ”
>
> *អ្នកាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅប្រទេសកម្ពុជា*

រាជរដ្ឋាភិបាល មិនត្រឹមតែមិនបានធ្វើការជាមួយសង្គមស៊ីវិល និងសហគមន៍អន្តរជាតិដើម្បីកែលំអសិទ្ធិមនុស្ស ដោយស្មោះត្រង់នៅប្រទេសកម្ពុជា លោកបែរជាចូលចិត្តប្រើមធ្យោបាយបង្ក្រាប និងការសងសឹកទៅលើអ្នកដែលស្វែងរកការការពារ និងការលើកស្ទួយសិទ្ធិមនុស្សយ៉ាងសកម្មទៅវិញ។ រាជរដ្ឋាភិបាល ជាយូរៗម្តងបានផ្តល់សេវាចំពោះសិទ្ធិមនុស្ស តែលើសេចក្តីប្រកាសហើយរាជរដ្ឋាភិបាលមិនគ្រាន់តែខកខានមិនសូវគោរពតាមកាតព្វកិច្ចអន្តរជាតិប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងមិនសូវមានឆន្ទៈក្នុងការអនុវត្តច្បាប់ជាតិរបស់ប្រទេសផងដែរ។

នៅក្នុងខែមីនា ឆ្នាំ២០១០ ក្រុមប្រឹក្សាសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិបានអនុម័តរបាយការណ៍ ស្តីពីលទ្ធផលតាមយន្តការពិនិត្យរបាយការណ៍ភាគីជាសកល និងតាមពេលកំណត់របស់

ប្រទេសកម្ពុជា។ នៅអំឡុងពេលពិនិត្យរបាយការណ៍ភាគីជាសកល និងតាមពេលកំណត់ ប្រទេសកម្ពុជាបានទទួលយកអនុសាសន៍ទាំងអស់ចំនួន ៩១ ស្តីពីបញ្ហាសិទ្ធិមនុស្ស ដែលដាក់ចេញ ដោយប្រទេសមួយចំនួន។ ទោះបីយ៉ាងណាក៏ដោយ ២ ឆ្នាំ បន្ទាប់ពីបានពិនិត្យរបាយការណ៍ភាគីជាសកល (UPR) និងតាមពេលកំណត់រួចមក ស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជាកាន់តែមានភាពយ៉ាប់យឺនឡើងៗ។[២] អនុសាសន៍សំខាន់ៗ មិនទាន់ត្រូវបានយកមកអនុវត្ត។ កម្លាំងប្រដាប់អាវុធត្រូវបានគេប្រើប្រាស់កាន់តែច្រើនឡើងដើម្បីទប់ទល់ទៅលើអ្នកតវ៉ា រីឯជនសង្ស័យភាគច្រើននៅតែមិនត្រូវបានគេនាំខ្លួនមកកាត់ទោស។ ជម្លោះដីធ្លីភាគច្រើន តែងតែបណ្តាលឲ្យមានការបណ្តេញចេញដោយបង្ខំជាលក្ខណៈប្រព័ន្ធ ឬបណ្តាលឲ្យមានការរឹបអូសយកដីធ្លី ដោយមិនបានផ្តល់ ឬផ្តល់តិចតួចបំផុតនូវសំណងដល់ជនរងគ្រោះ។ សហគមន៍ ដែលត្រូវបណ្តេញចេញ ត្រូវបានគេផ្លាស់ទីលំនៅទៅតំបន់ថ្មីដោយគ្មានសិទ្ធិទទួលបានសេវាជាមូលដ្ឋាន ថ្វីបើសិទ្ធិទាំងនោះ ត្រូវបានធានាការពារតាមច្បាប់ភូមិបាលឆ្នាំ២០០១ (រាប់ទាំងសិទ្ធិទទួលបានកម្មសិទ្ធិផ្អែកលើសិទ្ធិភោគៈ) ក៏ដោយ។ ក្រមព្រហ្មទណ្ឌថ្មីតាមការកត់សម្គាល់បទល្មើសញុះញង់ត្រូវបានគេយកមកប្រើ ភាគច្រើនទៅលើអ្នកសារព័ត៌មានសកម្មជនសិទ្ធិមនុស្ស និងថ្នាក់ដឹកនាំនយោបាយ។ ស្ថាប័នតុលាការមិនបានអនុវត្ត ឬបកស្រាយច្បាប់ឲ្យបានច្បាស់លាស់ទេ ហើយរឹតតែមិនអនុវត្តតាមកាតព្វកិច្ចជាអន្តរជាតិឡើយ។

ទន្ទឹមនឹងនេះ ប្រព័ន្ធយុត្តិធម៌តែងតែខកខានមិនបានធ្វើការស៊ើបអង្កេត និងផ្តន្ទាទោសបទល្មើសឲ្យបានទៀងទាត់ឡើយ ជាពិសេសបទល្មើសដែលធ្វើលើអ្នកការពារសិទ្ធិមនុស្ស។ នៅឆ្នាំ១៩៩៩ លោក Thomas Hammarberg កាលនោះ លោកជាអ្នកតំណាងពិសេសរបស់លោកអគ្គលេខាធិការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា បានសរសេរថា "បាតុភូតនៃនិទ្ទណ្ឌភាព (ភាពធ្វើខុសច្បាប់តែមិនទទួលទោស) និងការសំដែងចេញជាលក្ខណៈស្ថាប័ន បង្កើតជាឧបសគ្គដ៏សំខាន់បំផុតតែមួយគត់ដល់កិច្ចខិតខំប្រឹងប្រែង ដើម្បីបង្កើតនីតិរដ្ឋនៅប្រទេសកម្ពុជា"។[៣] អស់រយៈពេលជាង ១២ ឆ្នាំក្រោយមក និទ្ទណ្ឌភាពនៅតែបន្តកើតមាននៅប្រទេសកម្ពុជា រីឯការប្រកាន់ខ្ជាប់នូវនីតិរដ្ឋ នៅតែជាករណីលើកលែង ជាពិសេសនៅពេលអ្នកការពារសិទ្ធិមនុស្សត្រូវបានគេកំណត់ជាគោលដៅ។

ព្រឹត្តិការណ៍សោកនាដកម្មមួយ ជាឧទាហរណ៍បានបង្ហាញនិទ្ទណ្ឌភាពដ៏អាក្រក់របស់ប្រទេសកម្ពុជាក្នុងឆ្នាំ២០១២។ នៅថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១២ កងកំលាំងនគរបាល និងកងរាជអាវុធហត្ថប្រដាប់អាវុធរាប់រយនាក់ បានចូលទៅវាយប្រហារក្នុងភូមិមួយនៅខេត្តក្រចេះ ដែលជាផ្នែកនៃការ

[២] សេចក្តីប្រកាសព័ត៌មានរបស់អង្គការលីកាដូ "និយាយច្រើន សកម្មភាពតិច: ២ ឆ្នាំក្រោយការពិនិត្យស្ថានភាពសិទ្ធិមនុស្ស ដោយ UN ប្រទេសកម្ពុជាបន្តមិនអើពើនឹងអនុសាសន៍សំខាន់ៗ" ថ្ងៃទី២២ ខែមីនា ឆ្នាំ២០១២។

[៣] របាយការណ៍របស់លោក Thomas Hammarberg ជាអ្នកតំណាងពិសេសរបស់លោកអគ្គលេខាធិការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា (ថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ១៩៩៩) "សេវាប្រឹក្សាយោបល់ និងសហប្រតិបត្តិការខាងបច្ចេកទេសក្នុងវិស័យសិទ្ធិមនុស្ស: ស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា គណៈកម្មការសិទ្ធិមនុស្ស សម័យប្រជុំលើកទី៥៥ ចំណុចរបៀបវារៈទី១៩។

បណ្តេញចេញដោយបង្ខំយ៉ាងក្លាំងក្លា។ ក្មេងស្រីម្នាក់អាយុ ១៤ ឆ្នាំ ត្រូវបានបាញ់សម្លាប់ក្នុងដំណើរការនោះ។ អ្នកភូមិទាំងនោះ មានជាប់ពាក់ព័ន្ធក្នុងជម្លោះដីធ្លី ដែលត្រូវបានគេដឹងជាសាធារណៈជាមួយក្រុមហ៊ុនកាសូទីម ដែលក្រុមហ៊ុននេះ កាន់កាប់ដីសម្បទានចំនួន ១៥,០០០ ហិកតា នៅជិតភូមិរបស់ពួកគេ។ ក្រៅពីមិនបានបញ្ជាឲ្យធ្វើការស៊ើបអង្កេតទៅលើការស្លាប់របស់ក្មេងស្រី អាជ្ញាធរបានលើកយកការធ្វើអន្តរាគមន៍ដោយហិង្សានេះ ថាជាមូលហេតុចាំបាច់ដើម្បីបង្ក្រាបចលនាបំបែករដ្ឋ ហើយបានធ្វើការចោទប្រកាន់ថ្នាក់ដឹកនាំសហគមន៍ចំនួន ៥ នាក់ ថាជាមេខ្លោងទៅវិញ។ នៅអំឡុងខែកញ្ញា សាលាដំបូងរាជធានីភ្នំពេញ បានកាត់ទោសសមាជិកសហគមន៍ចំនួន ១៣ នាក់ ដោយចោទប្រកាន់ពីបទពាក់ព័ន្ធទៅនឹងការបំបែករដ្ឋ ថ្វីបើពុំមានភស្តុតាងគួរឲ្យជឿជាក់ណាមួយបង្ហាញពីចលនាបះបោរនេះក៏ដោយ។ តុលាការនេះ ក៏បានកាត់ទោស និងផ្តន្ទាទោសលោក ម៉ម សូណង់ដូ អាយុ ៧១ ឆ្នាំជាម្ចាស់ស្ថានីយវិទ្យុឯករាជ្យមួយឲ្យជាប់ពន្ធនាគារចំនួន ២០ ឆ្នាំផងដែរ ពីបទញុះញង់ឲ្យប្រព្រឹត្តអំពើបះបោរនេះ។

## ចារី

ការគំរាមកំហែង និងការវាយប្រហារភាគច្រើនទៅលើអ្នកការពារសិទ្ធិមនុស្ស កើតចេញមកពីតួអង្គរដ្ឋ ចាប់ពីថ្នាក់មន្ត្រីនគរបាល និងមន្ត្រីដ៏ទៃទៀតនៅថ្នាក់មូលដ្ឋាន និងថ្នាក់ខេត្ត រហូតដល់សមាជិកថ្នាក់ខ្ពស់បំផុតមួយចំនួនរបស់គណៈបក្សកាន់អំណាច។ កងកំលាំងប្រដាប់អាវុធគ្រប់ជាន់ថ្នាក់ មានការពាក់ព័ន្ធក្នុងការគំរាមកំហែង ការបំពារបំពានរាងកាយ និងការចាប់ខ្លួនអ្នកការពារសិទ្ធិមនុស្ស។

"ការសម្លាប់លោក ឈុត វុទ្ធី បែបណានោះ មិនមានតំរុយច្បាស់លាស់ទេ ប៉ុន្តែការពន្យល់ជាផ្លូវការបានធ្វើឲ្យមានការងឿងឆ្ងល់"

"Cambodia Blood Trail: The Forest Witnessed an Unsettling Death"
The Economist
(May 5, 2012)

ក្នុងការការពារសិទ្ធិមនុស្ស សកម្មជនសិទ្ធិមនុស្សតែងប៉ះពាល់ ជាមួយផលប្រយោជន៍ក្រុមហ៊ុនជំនួញបរទេស និងក្រុមហ៊ុនខ្មែរ ដែលជាអ្នកមានអំណាច ជាពិសេសក្រុមហ៊ុន ដែលមានទំនាក់ទំនងជិតស្និតជាមួយអាជ្ញាធរ។ ក្រុមហ៊ុនឯកជនទាំងនេះ ជាញឹកញាប់ដាក់ ឬញុះញង់ឲ្យដាក់ពាក្យបណ្តឹង ដែលមិនសមហេតុផល ឬក្នុងន័យព្យាបាទ។ ជួនកាលពួកគេគាំទ្រឲ្យមានអំពើហិង្សាទៀតផង។

នៅក្នុងការវាយប្រហារ ឬការគំរាមកំហែងដទៃទៀតទៅលើអ្នកការពារសិទ្ធិមនុស្ស ជនសង្ស័យអាចត្រូវបានគេស្គាល់អត្តសញ្ញាណ។ ប្រការនេះ អាចដោយសារតែជនសង្ស័យបានទទួលនិទ្ទណ្ឌភាព ឬដោយសារតែមន្ត្រីនគរបាលមិនសូវមានឆន្ទៈធ្វើការស៊ើបអង្កេតឲ្យបានត្រឹមត្រូវទៅលើឧប្បត្តិហេតុ

នោះ។ ការស្លាប់របស់លោក ឈុត វុទ្ធី ជាសកម្មជនការពារបរិស្ថាន បានបង្ហាញនូវធាតុពិត ដែលជាឧទាហរណ៍មួយ។

លោក ឈុត វុទ្ធី ត្រូវបានបាញ់សម្លាប់នៅខណៈកំពុងពិនិត្យមើលការកាប់ឈើខុសច្បាប់ក្នុងខេត្តកោះកុង ដោយមានអ្នកសារព័ត៌មានពីកាសែត ខ្មែរ ខេមបូឌា ដេលី ចំនួន ២ នាក់បានធ្វើដំណើរអមលោកផង។ នៅពេលដែលលោកទទួលមរណភាព មានមនុស្សប្រុសមួយក្រុមបានឡោមព័ទ្ធរថយន្តរបស់គាត់ ពោល គឺទាហ៊ានចំនួន ២ នាក់ កងរាជអាវុធហត្ថចំនួន ២ នាក់ ព្រមទាំងបុគ្គលិករបស់ក្រុមហ៊ុនអាជីវកម្មឈើឯកជនចំនួន ១ នាក់។ កងរាជអាវុធហត្ថម្នាក់ក៏ត្រូវបានបាញ់សម្លាប់ផងដែរ។

ការស៊ើបអង្កេតជាផ្លូវការទៅលើការស្លាប់របស់លោក ឈុត វុទ្ធី បានត្រូវបញ្ចប់ក្នុងរយៈពេល ២ ឬ៣ថ្ងៃប៉ុណ្ណោះ បន្ទាប់ពីមានសោកនាដកម្មនេះ និងខកខានមិនបានពិនិត្យមើលហេតុកាណ៍នៃការសម្លាប់នេះឲ្យបានត្រឹមត្រូវទេ។ មន្ត្រីរដ្ឋបានផ្តល់សេណារីយ៉ូចំនួន ៤ ខុសៗគ្នាក្នុងការពន្យល់ការសម្លាប់នេះ។ ពីដំបូងអាជ្ញាធរបានថ្លែងថា លោក ឈុត វុទ្ធី គឺជាអ្នកបាញ់មុន ហើយត្រូវបានគេបាញ់ស្លាប់ដោយអាវុធ ជាមួយនឹងកងរាជអាវុធហត្ថម្នាក់ក៏ត្រូវបានគេរកឃើញថាស្លាប់នៅនឹងកន្លែងកើតហេតុផងដែរ។ ក្រោយមកអាជ្ញាធរបានអះអាងថា កងរាជអាវុធហត្ថនោះ បានបាញ់កាំភ្លើងទៅលើលោក ឈុត វុទ្ធី ហើយគាត់បានស្លាប់ដោយសារក្បាលគ្រាប់ផ្លាតត្រូវគាត់។ បន្ទាប់មកអាជ្ញាធរបានបញ្ជាក់ថា កងរាជអាវុធហត្ថនោះ បានធ្វើអត្តឃាត ដោយសារមានវិប្បដិសារីក្រោយពីបានបាញ់សម្លាប់លោក ឈុត វុទ្ធី[៤]។ នៅទីបំផុតអាជ្ញាធរបានអះអាងថា កងរាជអាវុធហត្ថម្នាក់ក្នុងចំណោមកងរាជអាវុធហត្ថទាំងនោះ បានបាញ់លោក ឈុត វុទ្ធី រួចហើយគាត់ក៏ត្រូវបានគេសម្លាប់ដោយចៃដន្យ នៅពេលបុគ្គលិកសន្តិសុខក្រុមហ៊ុន ព្យាយាមដកហូតយកអាវុធចេញពីកងរាជអាវុធហត្ថនោះ ហេតុដូច្នេះហើយទើបអាជ្ញាធរអះអាងថា គ្មានជនណាម្នាក់ត្រូវបានចោទប្រកាន់ពីបទសម្លាប់លោក ឈុត វុទ្ធី ឡើយ។ គ្មានសេណារីយ៉ូណាមួយក្នុងចំណោមសេណារីយ៉ូទាំងនេះ គួរឲ្យជឿជាក់បានទេ នៅពេលពិនិត្យមើលភស្តុតាង ដែលប្រមូលបានដោយអង្គការលីកាដូ។ បន្ទាប់ពីមានចំណាត់ការជំនុំជម្រះក្តីអស់រយៈពេល ៩០ នាទីរួចមក នៅក្នុងខែតុលា បុគ្គលិកក្រុមហ៊ុននោះ ត្រូវបានគេកាត់ទោសពីបទមនុស្សឃាតដោយអចេតនា ហើយនឹងផ្តន្ទាទោសដាក់ពន្ធនាគារចំនួន ២ ឆ្នាំ ដោយព្យួរទោសរយៈពេល ១៨ ខែ។ សាក្សីសំខាន់ៗជាច្រើនពុំមានវត្តមាននៅក្នុងសវនាការទេ ហើយក៏គ្មានភស្តុតាងរឹងមាំ ឬគួរឲ្យជឿជាក់ត្រូវបានលើកយកមកបង្ហាញ ដើម្បីគាំទ្រដល់បំណកស្រាយចុងក្រោយបំផុតចំពោះការបាញ់នេះឡើយ។

[៤] http://www.rfa.org/english/news/cambodia/chut-wuthy-04272012155601.html

# ការវិភាគ

## ស្ថាប័នតុលាការជាអាវុធមួយដ៏មានប្រយោជន៍ ទប់ទល់នឹងអ្នកការពារសិទ្ធិមនុស្ស

*"ថ្វីត្បិតតែមានកិច្ចធានាការពារតាមរដ្ឋធម្មនុញ្ញ និងអត្ថិភាពនៃស្ថាប័នផ្សេងៗ ដើម្បីកែលំអ និងធានាការពារឯករាជ្យភាពតុលាការក៏ដោយ ក៏អ្នករាយការណ៍ពិសេសបង្ហាញ ទស្សនៈថា ស្ថាប័នតុលាការមិនបានដំណើរការប្រកបដោយប្រសិទ្ធភាព ឯករាជ្យ និងមិនលំអៀងតាមដែលអាចធ្វើទៅបានឡើយ (...)។ ថ្វីបើរដ្ឋធម្មនុញ្ញកម្ពុជា មានចែងអំពីការបែងចែកអំណាចដាច់ពីគ្នា រវាងស្ថាប័នរបស់រដ្ឋសំខាន់ៗ ចំនួន ៣ ក៏ដោយ ក៏តាមការអនុវត្តជាក់ស្តែង ការបែងចែករវាងស្ថាប័នទាំងនេះ មានភាពស្រពិចស្រពិល រីឯអំណាចប្រតិបត្តិគ្របសង្កត់ទៅលើស្ថាប័នតុលាការ ".[៨]*

### ករណីសិក្សា: អ្នករស់នៅសហគមន៍បឹងកក់ ត្រូវបានឃុំខ្លួន និងកាត់ទោស ដោយសារការពារសិទ្ធិដីធ្លី[៥]

សហគមន៍បឹងកក់នៅក្នុងរាជធានីភ្នំពេញ បានកំពុងតស៊ូដើម្បីការពារសិទ្ធិដីធ្លីរបស់អ្នកទាំងនោះ អស់រយៈពេល ៥ ឆ្នាំកន្លងមកហើយ ចាប់តាំងពីពេលនោះមក ដីសហគមន៍បឹងកក់ ត្រូវបានជួលតាមកិច្ចសន្យាទៅឲ្យក្រុមហ៊ុន ស៊ូកាគូ ដែលគ្រប់គ្រងដោយ លោក ឡៅ ម៉េងឃិន សមាជិកព្រឹទ្ធភាគណៈបក្សកាន់អំណាច។ ជម្លោះដីធ្លីនេះ បានធ្វើឲ្យប៉ះពាល់ដល់ប្រជាពលរដ្ឋចំនួន ៤,២៥២ គ្រួសារ ដែលបានរស់នៅជុំវិញបឹងកក់។ បច្ចុប្បន្នបឹងកក់នេះ ត្រូវបានគេបូមយកទឹកចេញ ហើយប្រជាពលរដ្ឋចំនួនច្រើនជាង ៣,០០០ គ្រួសារ ត្រូវបានគេបណ្តេញចេញ បន្ទាប់ពីត្រូវបានបង្ខំឲ្យទទួលយកសំណងមិនសមរម្យ បើមិនដូច្នោះទេនឹងត្រូវបូមខ្សាច់កប់ផ្ទះសម្បែងចោល។ អស់រយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះ សហគមន៍បឹងកក់បានធ្វើការតវ៉ាជាច្រើនលើកច្រើនសារ ដោយសន្តិវិធីក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីឲ្យគេគោរព និងទទួលស្គាល់សិទ្ធិកម្មសិទ្ធិទៅលើដីធ្លីរបស់ពួកអ្នកទាំងនោះ។

នៅអំឡុងពាក់កណ្តាលឆ្នាំ២០១១ ធនាគារពិភពលោកបានប្រកាសថា ខ្លួនបានផ្អាកមូលនិធិទាំងអស់ដែលត្រូវផ្តល់ទៅឲ្យប្រទេសកម្ពុជា ដើម្បីឆ្លើយតបទៅនឹងការបដិសេធរបស់អាជ្ញាធរប្រទេសកម្ពុជា មិនព្រមស្វែងរកដំណោះស្រាយសមស្របសម្រាប់អ្នករស់នៅសហគមន៍បឹងកក់ ដែលត្រូវគេ

[៥] ក្រុមការងារពិសេសសិទ្ធិលំនៅឋាន(HRTF) "ថ្កោលទោសការឆ្លើយតបដោយហិង្សា និងគ្មានយុត្តិកម្មចំពោះបាតុកម្មដោយអហិង្សា ដែលបានរៀបចំឡើងដោយអ្នករស់នៅសហគមន៍បឹងកក់" ថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១២ សូមមើល http://www.licadho-cambodia.org/pressrelease.php?perm=278 ។ សូមមើលរបាយការណ៍ឃ្លាំមើលរបស់អង្គការលីកាដូ ដែលមិនបានផ្សព្វផ្សាយផងដែរ: PP058IAD12 ។សូមមើលសេចក្តីប្រកាសព័ត៌មានរបស់អង្គការលីកាដូ "អង្គការមិនមែនរដ្ឋាភិបាលថ្កោលទោសចំពោះការបណ្តេញចេញ ដោយគ្មានមូលដ្ឋាន និងអំពើហិង្សាទៅលើអ្នកការពារសិទ្ធិមនុស្សកម្ពុជា" ថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១២ សូមមើល http://www.licadho-cambodia.org/pressrelease.php?perm=279។ សូមមើលផងដែរ: ឃុត សុភចរិយា និងប៊ុត រស្មីគង្គា "យុទ្ធវិធីរបស់មន្ត្រីនគរបាលប្រឆាំងកុប្បកម្ម ដែលគួរអោយចាប់អារម្មណ៍" កាសែតភ្នំពេញប៉ុស្ត៍ថ្ងៃទី១ ខែសីហា ឆ្នាំ២០១២ http://www.phnompenhpost.com/index.php/2012080157741/National-news/cambodian-riot-polices-tactics-in-spotlight .html។

បណ្តេញចេញ។ ក្រោយមកតែប៉ុន្មានថ្ងៃប៉ុណ្ណោះ រាជរដ្ឋាភិបាលបានប្រកាសថា ដីចំនួន ១២,៤៤ ហិកតានឹងត្រូវប្រគល់ទៅឲ្យគ្រួសារប្រជាពលរដ្ឋបឹងកក់ដែលនៅសេសសល់។ ទោះបីយ៉ាងណាក៏ដោយ ដំណោះ ស្រាយនេះ ធ្វើឲ្យមានការសៅហ្មង ដោយហេតុថាអាជ្ញាធរនៅតែផាត់ចោលប្រជាពលរដ្ឋចំនួនច្រើនជាង ៩០ គ្រួសារតាមទំនើងចិត្ត មិនឲ្យទទួលបាននូវកម្មសិទ្ធិដីធ្លីទៅវិញ។ រហូតមកទល់ពេលនេះ អាជ្ញាធរមិនទាន់បានបោះបង្គោលព្រំដីចំនួន ១២,៤៤ ហិកតានៅឡើយ។ ជាលទ្ធផល សមាជិកសហគមន៍បឹងកក់ បានបន្តធ្វើការតស៊ូមតិរបស់ខ្លួនដោយអហិង្សា ព្រមទាំងខិតខំតវ៉ាបន្តទៀតផងដែរ។

នៅថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១២ ប្រជាពលរដ្ឋបឹងកក់ចំនួន ១៦ គ្រួសារ បានធ្វើសន្និសីទសារព័ត៌មានមួយនៅជិតកន្លែងដែលផ្ទះសម្បែងរបស់ពួកគេបានចាក់ខ្សាច់កប់។ មានមួយគ្រួសារ បាននាំយកឈើទៅជាមួយ ដើម្បីបង្ហាញពីទីកន្លែង ដែលផ្ទះសម្បែងពួកគេត្រូវបានគេបំផ្លាញ ប៉ុន្តែអាជ្ញាធររារាំងពួកគេមិនឲ្យធ្វើដូច្នោះឡើយ។ នៅព្រឹកថ្ងៃនោះ អ្នកភូមិភាគច្រើនបានស្វែងរកម្លប់ជ្រកតាមផ្ទះអ្នកជិតខាង និងក្រោមដើមឈើ រីឯអ្នកភូមិមួយក្រុមទៀតកំពុងតែអង្គុយលើដីខ្សាច់ និងច្រៀងបទចម្រៀងផង។

ដោយគ្មានបានប្រកាសជាមុន និងគ្មានដីកា ស្រាប់តែអាជ្ញាធរបានចូលទៅក្នុងក្រុមអ្នកភូមិមួយក្រុម ដែលកំពុងច្រៀង ហើយចាប់ខ្លួនស្ត្រីទាំង ១៣ នាក់នោះរាប់ទាំងអ្នកតំណាងសហគមន៍បឹងកក់សំខាន់ៗមួយចំនួនផង។ ស្ត្រីទាំងនោះ ត្រូវបានគេនាំយកទៅឃុំខ្លួននៅអង្គភាពនគរបាលចំនួន ២ យប់។

នៅថ្ងៃទី២៤ ខែឧសភា ស្ត្រីទាំងនោះ ត្រូវបានគេនាំខ្លួនមកកាន់សាលាដំបូងរាជធានីភ្នំពេញនៅម៉ោង៥:០០ព្រឹក មុនពេលមេធាវី ឬក្រុមគ្រួសារ និងមិត្តភ័ក្តិរបស់ពួកអ្នកទាំងនោះបានដឹងថា មានអ្វីបានកើតឡើង។ នៅរសៀលថ្ងៃដដែល ស្ត្រីទាំងនោះ ត្រូវទទួលការចោទប្រកាន់ បើកសវនាការកាត់ទោស និងផ្តន្ទាទោសក្នុងចំណាត់ការជំនុំជម្រះទ្រង់ទ្រាយធំ ដែលប្រើពេលត្រឹមតែ ៣ ម៉ោងប៉ុណ្ណោះ។ តុលាការបានបដិសេធសំណើសុំចម្លងសំណុំរឿងរបស់មេធាវី សំណើសុំលើកពេលសវនាការ ដើម្បីត្រៀមការពារក្តី (ព្រះរាជអាជ្ញាបានធ្វើការចោទប្រកាន់តែ ១ ម៉ោងប៉ុណ្ណោះ មុនពេលចាប់ផ្តើមបើកសវនាការ) ព្រមទាំងបដិសេធសំណើរបស់មេធាវី ដែលសុំបញ្ជូលសាក្សីបំភ្លឺក្នុងសវនាការ។

ស្ត្រីទាំងនោះ ម្នាក់ៗត្រូវបានគេចាប់កំហុសពីបទប្រឆាំងអ្នករាជការសាធារណៈ (មាត្រា ៥០៤ នៃក្រមព្រហ្មទណ្ឌ) និងពីបទកាន់កាប់ដីរដ្ឋដោយខុសច្បាប់ (តាមច្បាប់ភូមិបាល)។ ចៅក្រមជំនុំជម្រះបានកាត់ទោសស្ត្រីទាំងនោះ ម្នាក់ៗឲ្យជាប់ពន្ធនាគារចំនួន ២ ឆ្នាំកន្លះ ថ្វីបើទោសនេះ ត្រូវបានព្យួរមួយ

ផ្នែកសម្រាប់ស្ត្រីខ្លះក៏ដោយ។

នៅពេលកំពុងបើកសវនាការ មន្ត្រីនគរបាលបានចាប់ខ្លួនអ្នកតំណាងសហគមន៍បឹងកក់ចំនួន ២ នាក់ថែមទៀត នៅពីមុខសាលាដំបូងរាជធានីភ្នំពេញ ដែលអ្នកទាំង ២ នាក់នេះ បានមកបំភ្លឺក្នុងនាមជាសាក្សី ដើម្បីដោះបន្ទុកសម្រាប់ស្ត្រីទាំង ១៣ នាក់។ អ្នកទាំងពីរត្រូវបានឃុំខ្លួនបណ្តោះអាសន្ន ប៉ុន្តែទីបំផុតត្រូវបានដោះលែងវិញ នៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១២ ដោយដាក់ឲ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ។

ក្រោយពីមានអន្តរាគមន៍យ៉ាងខ្លាំងពីថ្នាក់អន្តរជាតិ និងថ្នាក់ជាតិ (រាប់ទាំងអន្តរាគមន៍ពីលោកស្រី ហ៊ីលឡារី គ្លិនតុន (Hillary Clinton)[៦] ជារដ្ឋមន្ត្រីក្រសួងការបរទេសប្រទេសអាមេរិក) សាលាឧទ្ធរណ៍បានកំណត់ពេលបើកសវនាការជាបន្ទាន់ ដោយកម្រ និងមិនដែលធ្លាប់មានពីមុនមក។ នៅថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១២ បន្ទាប់ពីជាប់ឃុំបានរយៈពេល ១ខែ និង ៣ ថ្ងៃ ស្ត្រីទាំងនោះ ត្រូវបានគេនាំខ្លួនមកកាន់សាលាឧទ្ធរណ៍។ នៅខាងក្រៅមានអ្នកគាំទ្រប្រមាណជាង ៥០០ នាក់ ត្រូវបានកងកម្លាំងប្រដាប់អាវុធចម្រុះ រារាំងមិនអនុញ្ញាតឲ្យចូលទៅក្នុងបរិវេណសាលាឧទ្ធរណ៍។ នៅចំណុចមួយមន្ត្រីនគរបាលបានប៉ះទង្គិចជាមួយអ្នកគាំទ្រទាំងនោះ ហើយបានវាយដំទៅលើរាងកាយក្រុមបាតុករមួយចំនួន។ បាតុករម្នាក់ជាស្ត្រីវ័យក្មេងមានផ្ទៃពោះ បានរលូតកូនក្រោយពីមន្ត្រីនគរបាលម្នាក់បានធាក់ចំពោះរបស់នាង។

បន្ទាប់ពីបើកសវនាការអស់រយៈពេល ៤ ម៉ោង ក្រុមប្រឹក្សាជំនុំជម្រះបានសម្រេចតម្កល់ការចោទប្រកាន់ និងតម្កល់ទោស ប៉ុន្តែព្យួរទោសដែលនៅសេសសល់របស់ស្ត្រី ទាំង ១៣ នាក់។ ស្ត្រីទាំង ១៣ នាក់ក៏ត្រូវបានដោះលែងឲ្យមានសេរីភាពនៅថ្ងៃនោះតែម្តង ប៉ុន្តែបច្ចុប្បន្នដោយសារតែពួកអ្នកទាំងនោះមានកំណត់ត្រាខាងព្រហ្មទណ្ឌ ស្ត្រីទាំងនោះ នៅតែប្រឈមនឹងការរំខានយាយី និងការចាប់ខ្លួននៅឡើយ។ ◄◄

---

រដ្ឋធម្មនុញ្ញកម្ពុជាកំណត់ការប្តេជ្ញាចិត្តរបស់ប្រទេសនេះ ចំពោះឯករាជ្យភាព និងភាពមិនលំអៀងរបស់ស្ថាប័នតុលាការ។ មាត្រា៥១ ១២៨ ១២៩ និងមាត្រា១៣០ នៃច្បាប់កំពូលនេះ ធានាការពារនូវអំណាចផ្តាច់មុខរបស់ស្ថាប័នតុលាការក្នុងការវិនិច្ឆ័យក្តី ហើយបានដំកល់ទុកនូវភាពត្រឹមត្រូវតាមនីតិវិធី និងជាសារៈសំខាន់ អនុលោមតាមសិទ្ធិ និងសេរីភាពរបស់ប្រជាពលរដ្ឋខ្មែរគ្រប់រូបនៃព្រះរាជាណាចក្រកម្ពុជា។ ទោះបីយ៉ាងណាក៏ដោយ ស្ថាប័នតុលាការនៅតែស្ថិតក្រោមការត្រួតត្រាយ៉ាង

---

[៦] សូមមើល http://www.dailykhmerpost.com/2012/06/us-calls-for-release-of-boeung-kak.html

តឹងរឹងរបស់ស្ថាប័នប្រតិបត្តិ។ ច្បាប់នីតិវិធី និងច្បាប់គ្រឹះមិនសូវត្រូវបានគេអនុវត្ត ហើយបុគ្គលត្រូវចោទជារឿយៗត្រូវបានកាត់ឲ្យជាប់ទោស បើទុកជាគ្មានភស្តុតាងដាក់បន្ទុកក៏ដោយ។

ប្រព័ន្ធឧបត្ថម្ភផ្នែកនយោបាយ គ្របដណ្ដប់ទៅលើស្ថាប័នតុលាការនៅគ្រប់កំរិត។ ឧទាហរណ៍ ទន្ទឹមនឹងចៅក្រមទទួលបៀវត្សជាមូលដ្ឋានពីក្រសួងយុត្តិធម៌ គណៈរដ្ឋមន្ត្រីក៏ផ្ដល់ប្រាក់ឧបត្ថម្ភការងារដល់ចៅក្រមផងដែរ។[៧] ទម្លាប់អនុវត្តបែបនេះ ស្ថាប័នតុលាការ ពុំមានឯករាជ្យភាពពីស្ថាប័ននីតិប្រតិបត្តិឡើយ។ នៅក្នុងរបាយការណ៍ឆ្នាំ២០០៥ របស់ខ្លួន ដែលមានចំណងជើងថា *កំរនិទ្ទណ្ឌភាពនៅប្រទេសកម្ពុជានៅតែបន្តកើតមាន* អ្នកតំណាងពិសេសរបស់លោកអគ្គលេខាធិការ អង្គការសហប្រជាជាតិ ទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជាបានថ្លែងថា ចាប់តាំងពីឆ្នាំ១៩៩៣ "ប្រទេសកម្ពុជាមិនទាន់បានបង្កើតស្ថាប័នរដ្ឋអព្យាក្រឹត្យ យន្តការត្រួតពិនិត្យអំណាចនីតិប្រតិបត្តិ ហើយនឹងមធ្យោបាយនានា ដើម្បីដាក់ឲ្យប្រតិបត្តិនូវសិទ្ធិទាំងឡាយ ដែលត្រូវបានធានាការពារតាមច្បាប់ និងតាមរដ្ឋធម្មនុញ្ញនៅឡើយ។ ស្ថាប័នតុលាការនៅតែបន្តទទួលរងនូវការជ្រៀតជ្រែកពីស្ថាប័ននីតិប្រតិបត្តិ ហើយនឹងបើកចំហរឲ្យមានការប្រព្រឹត្តិអំពើពុករលួយ"។[៨] នៅចន្លោះឆ្នាំ២០១០ និងឆ្នាំ២០១២ ស្ថានភាពសិទ្ធិមនុស្សមិនទាន់មានភាពប្រសើរនៅឡើយ។ ស្ថាប័នតុលាការនៅតែបន្តស្ថិតក្រោមការត្រួតត្រាពីស្ថាប័ននីតិប្រតិបត្តិ បណ្ដោយឲ្យតុលាការក្លាយជាឧបករណ៍នយោបាយទប់ទល់នឹងអ្នកការពារសិទ្ធិមនុស្ស។

> អំណាចអង្គនីតិបញ្ញត្តិ អំណាចស្ថាប័នប្រតិបត្តិ និងអំណាចស្ថាប័នតុលាការ ត្រូវបានបែងចែកដាច់ដោយឡែកពីគ្នា។
> មាត្រា ៥១
>
> អំណាចតុលាការជាអំណាចឯករាជ្យ។ អំណាចតុលាការធានារក្សាអនាគតិ និងការពារសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋ។
> មាត្រា ១២៨
>
> **រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា**

ប្រភេទនៃការចោទប្រកាន់ក្នុងរឿងព្រហ្មទណ្ឌ ដែលត្រូវបានគេយកមកប្រើដើម្បីធ្វើការទប់ទល់នឹងអ្នការពារសិទ្ធិមនុស្សមានការខុសគ្នាទៅតាមករណីនីមួយៗ។ ប៉ុន្តែបទបញ្ញត្តិច្បាប់មួយចំនួនត្រូវបានគេយកមកប្រើច្រើនជាងបទបញ្ញត្តិផ្សេងៗ។

---

[៧] របាយការណ៍របស់លោក Surya Subedi អ្នករាយការណ៍ពិសេសស្ដីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា (ថ្ងៃទី២ ខែសីហា ឆ្នាំ២០១១) "ការកសាងសមត្ថភាព និងជំនួយបច្ចេកទេស" ក្រុមប្រឹក្សាសិទ្ធិមនុស្ស សម័យប្រជុំលើកទី១៨ ចំណុចរបៀបវារៈទី១០។

[៨] របាយការណ៍អ្នករាយការណ៍ពិសេសរបស់លោកអគ្គលេខាធិការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា (ថ្ងៃទី៥ ខែតុលា ឆ្នាំ២០០៥) "បែបផែននិទ្ទណ្ឌភាពនៅប្រទេសកម្ពុជានៅតែបន្តកើតមាន" សូមមើល http://cambodia.ohchr.org/WebDOCs /DocReports/2-Thematic-Reports/ Thematic_CMB05102005E.pdf។

ចាប់តាំងពីក្រមព្រហ្មទណ្ឌថ្មីបានចូលជាធរមាននៅខែធ្នូ ឆ្នាំ២០១០ សម្រាប់ជាឧទាហរណ៍ អង្គការលីកាដូ បានចងក្រងទុកជាឯកសារនូវបទបញ្ញត្តិភាគច្រើន ដែលមានបញ្ហា ហើយដែលត្រូវបានគេយកមកប្រើដដែលៗទប់ទល់នឹងអ្នកការពារសិទ្ធិមនុស្ស។ នៅក្នុងរបាយការណ៍មួយថ្មីៗនេះ ដែលមានចំណងជើងថា *ការយល់ខុសពីដំណើការជឿនលឿនៈ ការប្រើច្បាប់ដើម្បីដាក់កម្រិតទៅលើសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ* អង្គការលីកាដូ បានសម្តែងនូវកង្វល់យ៉ាងជ្រៀលជ្រៅអំពីភាពស្រពិចស្រពិល ការកំណត់ព្រំដែនមិនច្បាស់លាស់ ហើយនឹងទណ្ឌកម្មធ្ងន់ធ្ងរទាក់ទងនឹងបទបញ្ញត្តិទាំងអស់នេះ[៩] អំឡុងពេល ២ឆ្នាំកន្លងទៅនេះបានបង្ហាញថា កង្វល់ទាំងនេះក្លាយជាការពិតមែន។ ជាការកត់សម្គាល់បទបរិហារកេរ្តិ៍ បទជេរប្រមាថ បទញុះញង់ឲ្យប្រព្រឹត្តបទឧក្រិដ្ឋហើយនឹងបទប្រឆាំងអ្នករាជការសាធារណៈ គឺស្ថិតនៅក្នុងចំណោមការចោទប្រកាន់ញឹកញាប់បំផុត ដែលធ្វើឡើងទៅលើអ្នកការពារសិទ្ធិមនុស្ស។

គ្មានបុគ្គលណាមួយត្រូវបានគេដកហូតកម្មសិទ្ធិរបស់ខ្លួនបានទេ ប្រសិនបើការដកហូតនេះមិនមែនដើម្បីប្រយោជន៍សាធារណៈ។ ការដកហូតកម្មសិទ្ធិត្រូវធ្វើទៅតាមទម្រង់ និងនីតិវិធីបញ្ញត្តិ ដោយច្បាប់ និងបទបញ្ញាបន្ទាប់ពីបានផ្តល់សំណងជាមុនដោយសមរម្យ និងយុត្តិធម៌។

ច្បាប់ភូមិបាល ឆ្នាំ២០០១ មាត្រា៥

ច្បាប់ភូមិបាលឆ្នាំ ២០០១ ក៏ត្រូវបានគេយកមកប្រើមិន ត្រឹមត្រូវជាច្រើនដងផងដែរ ដើម្បីបំបិទមាត់អ្នកការពារសិទ្ធិមនុស្ស ដែលបំពេញការងារខាងបញ្ហាដីធ្លី។ ច្បាប់នេះដាក់បញ្ចូលនូវបទប្បញ្ញត្តិព្រហ្មទណ្ឌមួយឈុត ដែលមានភាពមិនច្បាស់លាស់ (ហើយជាញឹកញាប់បែបរំលោភបំពាន) ដើម្បីបំពារបំពានទៅលើសិទ្ធិនៃកម្មសិទ្ធិ ដែលអាចនាំទៅរកការកាត់ទោសឲ្យជាប់ពន្ធនាគាររហូតដល់ ៥ឆ្នាំ។ ជាការហួសចិត្តបទបញ្ញត្តិទាំងនេះ បានត្រូវគេយកមកប្រើប្រាស់ទប់ទល់នឹងអ្នកតំណាងសហគមន៍ ដែលកំពុងតស៊ូមតិ ដើម្បីទាមទារឲ្យគេគោរពនូវសិទ្ធិទទួលបានកម្មសិទ្ធិដីធ្លីរបស់ពួកគេ។ នៅពេលជាមួយគ្នានេះ បទបញ្ញត្តិច្បាប់ភូមិបាល ដែលមានន័យថា ត្រូវតែការពារម្ចាស់កម្មសិទ្ធិដីធ្លី ដែលមិនត្រូវបានគេអើពើ។ ឧៈ មាត្រា៥ ចែងថា "គ្មានបុគ្គលណាមួយ ត្រូវបានគេដកហូតកម្មសិទ្ធិរបស់ខ្លួនបានទេ ប្រសិនបើ ការដកហូតនេះមិនមែនដើម្បីប្រយោជន៍សាធារណៈ" ហើយធានានូវសំណងត្រឹមត្រូវ និងសមរម្យក្នុងករណីមានការដកហូតដីធ្លី។ បទបញ្ញត្តិនេះ មិនត្រូវបានគេយកចិត្តទុកដាក់ជាលក្ខណៈប្រព័ន្ធទេ។ ច្បាប់ភូមិបាលនេះ ធានាការពារសិទ្ធិកម្មសិទ្ធិលើទ្រព្យសម្បត្តិផ្អែកតាមសិទ្ធិភោគៈផងដែរ (ជាសិទ្ធិដែលមិនសូវត្រូវបានគេអើពើ ឬជួនកាលត្រូវបានរំលោភបំពានដោយចេតនា)។

[៩] របាយការណ៍របស់អង្គការលីកាដូ (ខែតុលា ឆ្នាំ២០១១) "ការបំភ័ន្តភាពជឿនលឿនៈ ការរំលោភបំពានពីអង្គនីតិបញ្ញត្តិរបស់កម្ពុជាទៅលើសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ" សូមមើល http://www.licadho-cambodia.org/reports/files/162LICADHOReport-LegislativeAssaultFreedomExpression2011 English.pdf

## ការបំភិតបំភ័យតាមរយៈការចាប់ខ្លួន និងការឃុំខ្លួនបណ្ដោះអាសន្ន ដោយគ្មានការចោទប្រកាន់

និន្នាការមួយទៀត ដែលអង្គការលីកាដូ បានចងក្រងទុកជាឯកសារ គឺការចាប់ខ្លួន និងការឃុំខ្លួនអ្នកតំណាងសហគមន៍ នៅពេលកំពុងធ្វើបាតុកម្មដោយអហិង្សា។ ក្នុងករណីបែបនេះអ្នកការពារសិទ្ធិមនុស្ស ត្រូវបានឃុំខ្លួនអស់រយៈពេល ១ យប់ ឬរហូតដល់ ២ ឬ ៣ ថ្ងៃដោយគ្មានមិនមានការចោទប្រកាន់ប្រឆាំងនឹងពួកគេទេ។ ឧ: នៅថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១១ យ៉ាងហោចណាស់សកម្មជនការពារព្រៃឈើចំនួន ១០៦ នាក់ត្រូវបានចាប់ខ្លួន និងឃុំខ្លួនដើម្បីសាកសួរ និងដើម្បី "ធ្វើការអប់រំឡើងវិញ"។ សមាជិកសហគមន៍ព្រៃឡង់មួយក្រុម ដែលមានគ្នាចំនួន ៣០០ នាក់ បានធ្វើការប្រមូលផ្ដុំគ្នានៅមុខព្រះរាជវាំងក្នុងរាជធានីភ្នំពេញ ដើម្បីរៀបចំពិធីតាមបែបសាសនាមួយ។ នៅពេលនោះសមាជិកបណ្ដាញព្រៃឈើ បានបំបែកជាក្រុមតូចៗទូទាំងរាជធានីភ្នំពេញ ដើម្បីចែកចាយខិតប័ណ្ណ ដោយធ្វើការតស៊ូមតិសម្រាប់អភិរក្សព្រៃឡង់។ មន្ត្រីនគរបាល និងមន្ត្រីមូលដ្ឋានចុះទៅកាន់ទីកន្លែងទាំងនោះភ្លាមៗ ហើយបានដកហូតយក ខិតប័ណ្ណ និងធ្វើការឃាត់ខ្លួនសកម្មជនទាំងនោះ។

ការជ្រៀតជ្រែកពីមន្ត្រីនគរបាលក្នុងការចែកចាយខិតប័ណ្ណព័ត៌មាន អំពីបញ្ហាកង្វល់ជាសាធារណៈ ហើយនឹងការឃាត់ខ្លួនសកម្មជនដោយខុសច្បាប់ គឺជាការបង្កបញ្ហាយ៉ាងធ្ងន់ធ្ងរ។ យុទ្ធវិធីទាំងនេះ មិនគ្រាន់តែជាឧបសគ្គទៅលើ ការបំពេញសកម្មភាពស្របច្បាប់ ដើម្បីការពារសិទ្ធិមនុស្សប៉ុណ្ណោះទេ ប៉ុន្តែជាការធ្វើឲ្យភាពជាអ្នកដឹកនាំ ដែលជាសេចក្ដីត្រូវការយ៉ាងច្រើនពីសហគមងាយរងគ្រោះចុះខ្សោយ ហើយនឹងបង្កើនស្វ័យត្រួតពិនិត្យចាប់ពិរុទ្ធ (ការរិះគន់ខ្លួនឯង) ថែមទៀតផង។

### ករណីសិក្សា: លោក ម៉ម សូណង់ដូ ជាម្ចាស់ស្ថានីយវិទ្យុឯករាជ្យ ត្រូវបានកាត់ទោស ពីបទញុះញង់ឲ្យប្រព្រឹត្តចលនាបំបែករដ្ឋ[១០]

នៅថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១២ វិទ្យុសំបុកឃ្មុំ ដែលជាស្ថានីយ៍វិទ្យុមួយក្នុងចំណោមស្ថានីយវិទ្យុមួយចំនួនតូច ដែលមានភាពឯករាជ្យបានធ្វើការចាក់ផ្សាយរបាយការណ៍មួយស្ដីពី "ពាក្យបណ្ដឹង" ដែលត្រូវបានដាក់ជូនទៅតុលាការព្រហ្មទណ្ឌអន្តរជាតិ ដោយចោទប្រកាន់មន្ត្រីមួយចំនួននៅក្នុងជួររាជរដ្ឋាភិបាលកម្ពុជា ពីបទប្រព្រឹត្តអំពើឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិទាក់ទងនឹងការបណ្ដេញចេញ និងការបន្លាស់ទីដោយបង្ខំ។ ចលនាអំណាចប្រជាជនខ្មែរបានធ្វើការរៀបចំសន្និសិតសារព័ត៌មានមួយដើម្បីបង្ហាញឲ្យដឹងពីការបញ្ជូនពាក្យបណ្ដឹងទៅទីក្រុងឡាអេ (Hague) ប្រទេសហូឡង់កាលពីថ្ងៃទី២២

---

[១០] សេចក្ដីប្រកាសព័ត៌មានរបស់អង្គការលីកាដូ "ដោះលែងលោក ម៉ម សូណង់ដូ ជាម្ចាស់ស្ថានីយវិទ្យុឯករាជមួយដ៏ចំណាស់ជាងគេ" ថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១២ សូមមើល http://www.licadho-cambodia.org/pressrelease.php?perm=287 ។ សូមមើលផងដែរ David Boyle "លោក ម៉ម សូណង់ដូ បានចាក់ផ្សាយព័ត៌មានសំដៅដល់នាយករដ្ឋមន្ត្រី" កាសែតភ្នំពេញប៉ុស្ដិ៍ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១២ សូមមើល http://www.phnompenhpost.com/index.php/2012071857483/National-news/sonando-broadcast-targeted-pm.html ។

ខែមិថុនា ឆ្នាំ២០១២។ លោក ម៉ម សូណង់ដូ ម្ចាស់វិទ្យុសំបុកឃ្មុំ ហើយជាអ្នកស្វែងរកមូលនិធិដ៏សំខាន់ម្នាក់ បានយកព័ត៌មានពីព្រឹត្តិការណ៍នោះ ក្នុងនាមជាអ្នកសារព័ត៌មានមួយរូប។

២៤ម៉ោង ក្រោយពីវិទ្យុសំបុកឃ្មុំបានចាក់ផ្សាយរបាយការណ៍លើកទី១ សម្តេចនាយករដ្ឋមន្ត្រីបានធ្វើការអំពាវនាវជាសាធារណៈ ឲ្យមានការចាប់ខ្លួនលោក ម៉ម សូណង់ដូ នៅអំឡុងពេលថ្លែងសុន្ទរកថាតាមទូរទស្សន៍ទូទាំងប្រទេស។ នៅថ្ងៃទី២ ខែកក្កដា ឆ្នាំ២០១២ លោក ចុក ងួន ជាចៅក្រមស៊ើបអង្កេតសាលាដំបូងខេត្តក្រចេះ បានចេញដីកាចាប់ខ្លួនលោក ម៉ម សូណង់ដូ ដោយចោទប្រកាន់លោកពីបទឧក្រិដ្ឋទាក់ទងនឹងចលនាមួយ ដែលគេហៅថា ចលនាបំបែករដ្ឋក្នុងខេត្តក្រចេះ។ ក្រៅពីការចោទប្រកាន់ដាក់បន្ទុក អាជ្ញាធរពុំបានបង្ហាញភស្តុតាងណាមួយ ដែលគួរឲ្យជឿជាក់បាន ដើម្បីគាំទ្រការអះអាង ដែលថាមានចលនាបំបែករដ្ឋនៅខេត្តក្រចេះឡើយ។

ចាប់តាំងពីខែមករា ឆ្នាំ២០១២ អ្នករស់នៅក្នុងឃុំកំពង់ដំរីក្នុងខេត្តក្រចេះ មានការពាក់ព័ន្ធក្នុងជម្លោះដីធ្លីយ៉ាងធ្ងន់ធ្ងរ ដែលត្រូវបានគេដឹងឮយ៉ាងច្បាស់ជាសាធារណៈ ជាមួយនឹងក្រុមហ៊ុនកាសូទីម ជាក្រុមហ៊ុនឯកជនមួយ មានទំនាក់ទំនងល្អជាមួយអាជ្ញាធរ ហើយកាន់កាប់ដីសម្បទានចំនួន ១៥.០០០ ហិកតានៅជិតភូមិរបស់ពួកគេ។ នៅថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១២ រដ្ឋាភិបាលបានបញ្ជូនកងកំលាំប្រដាប់អាវុធរាប់រយនាក់ ដោយមានជំនួយពីឧទ្ធម្ភាគចក្រ ដើម្បីធ្វើការបណ្តេញអ្នកភូមិនៅក្នុងឃុំកំពង់ដំរី។ នៅអំឡុងពេលប្រតិបត្តិការណ៍បង្ក្រាបប្រជាពលរដ្ឋរាប់រយគ្រួសារត្រូវបានគេបណ្តេញចេញ ហើយក្មេងស្រីម្នាក់ឈ្មោះ ហេង ចន្ថា អាយុ ១៤ ឆ្នាំ ត្រូវបានគេបាញ់សម្លាប់។ ក្រោយមកមន្ត្រីរដ្ឋាភិបាល បានលើកយកប្រតិបត្តិការណ៍បង្ក្រាបនេះមកដោះសារ ដោយថ្លែងថា អ្នកភូមិទាំងនោះគឺជាផ្នែកនៃចលនាបំបែករដ្ឋ។ អ្នកភូមិមួយចំនួនគឺជាសមាជិករបស់អង្គការមិនមែនរដ្ឋាភិបាលមួយ ដែលត្រូវបានបង្កើតឡើងដោយលោក ម៉ម សូណង់ដូ ដែលហៅថា " សមាគមអ្នកប្រជាធិបតេយ្យ" ។

លោក ម៉ម សូណង់ដូ ដែលបានចាកចេញទៅក្រៅប្រទេសនៅពេលដែលចៅក្រមស៊ើបអង្កេតបានចេញដីកាបង្គាប់ឲ្យចាប់ខ្លួន បានវិលត្រឡប់មកកាន់រាជធានីភ្នំពេញវិញ នៅថ្ងៃទី ១២ ខែកក្កដា ឆ្នាំ២០១២ នៅពេលដែលកិច្ចប្រជុំកំពូលអាស៊ានកំពុងដំណើរការ។ ៣ ថ្ងៃ ក្រោយមក លោក ម៉ម សូណង់ដូ ត្រូវបានចាប់ខ្លួន តែរយៈពេល ២៤ ម៉ោងប៉ុណ្ណោះ ក្រោយពេលបណ្តារដ្ឋមន្ត្រីការបរទេស និងអង្គទូតដែលមានវត្តមាននៅក្នុងកិច្ចប្រជុំកំពូលនោះបានចាកចេញពីរាជធានីភ្នំពេញ។

ក្រោយពេលចាប់ខ្លួនលោក ម៉ម សូណង់ដូ ត្រូវបានគេនាំមកបង្ហាញខ្លួននៅចំពោះមុខអ្នកស្រី សែម សក្តិកូឡា ជាចៅក្រមសាលាដំបូងក្រុងភ្នំពេញដើម្បីធ្វើការសាកសួរយកចំលើយ។ នៅរសៀលថ្ងៃនោះលោក ម៉ម សូណង់ដូ ត្រូវបានចោទប្រកាន់តាមមាត្រា ២៨ ៤៥៦ ៤៥៧ ៤៦៤ ៥០៤ និងមាត្រា ៦០៩ នៃក្រមព្រហ្មទណ្ឌ។ ការចោទប្រកាន់រាប់បញ្ចូលទាំងការចូលរួមក្នុងចលនាកុបកម្ម ញុះញុង់

ប្រជាពលរដ្ឋឲ្យកាន់អាវុធប្រឆាំងនឹងរដ្ឋ ហើយនឹងបទរារាំងនឹងអ្នករាជការសាធារណៈ។

នៅថ្ងៃទី១ ខែតុលា ឆ្នាំ២០១២ លោក ម៉ម សូណង់ដូ ត្រូវបានកាត់ទោស និងផ្តន្ទាទោសឲ្យជាប់ពន្ធនាគារចំនួន ២០ ឆ្នាំ ទោះជាគ្មានភស្តុតាងគ្រប់គ្រាន់ត្រូវបានបង្ហាញដាក់បន្ទុកទៅលើ លោក ម៉ម សូណង់ដូ ក្នុងតុលាការក៏ដោយ។ ពុំឃើញមានសក្ខីកម្មក្នុងតុលាការ ឬភស្តុតាងរឹងមាំដែលគាំទ្រផែនការបំបែករដ្ឋ ឬគាំទ្រតួនាទីរបស់លោក ម៉ម សូណង់ដូ ក្នុងការធ្វើជាមេក្លោងនៅពីក្រោយគម្រោងការបំបែករដ្ឋនេះទេ។ សក្ខីកម្មរបស់សាក្សីភាគច្រើននៅក្នុងតុលាការ គឺមានភាពផ្ទុយគ្នាទៅនឹងចំលើយ ដែលពួកគេបានឆ្លើយពីដំបូងនៅចំពោះមុខមន្ត្រីនគរបាលយុត្តិធម៌។ ប៉ុន្តែលោកស្រី ចាំង ស៊ីណាត ប្រធានក្រុមប្រឹក្សាជំនុំជម្រះ បានបង្ហាញភាពលំអៀងនៅក្នុងសាលក្រមរបស់គាត់ ទៅរកសំណុំបែបបទឯកសាររបស់មន្ត្រីនគរបាលទាក់ទងនឹងសក្ខីកម្មក្នុងតុលាការ។

បច្ចុប្បន្ននេះ ដោយសារតែលោក ម៉ម សូណង់ដូ មានអាយុ ៧១ ឆ្នាំហើយ ទំនងជាគាត់អាចចំណាយពេលអស់មួយជីវិតក្នុងពន្ធនាគារ ប្រសិនបើទោសរបស់គាត់មិនត្រូវបានគេបដិសេធចោលតាមរយៈបណ្តឹងឧទ្ធរណ៍នោះទេ។

អ្នកភូមិចំនួន ១៣នាក់ផ្សេងទៀត មកពីខេត្តក្រចេះក៏ត្រូវគេផ្តន្ទាទោសជាមួយ លោក ម៉ម សូណង់ដូ ពីបទពាក់ព័ន្ធក្នុងផែនការបំបែករដ្ឋនេះដែរ។◄◄

---

## សេចក្តីពិពណ៌នា: លោក ចាន់ សុវ៉េត ជាសមាជិកបុគ្គលិកអង្គការមិនមែនរដ្ឋាភិបាលកំពុងប្រឈមនឹងការចោទប្រកាន់ទាក់ទងនឹងការងារសិទ្ធិមនុស្សស្របច្បាប់

លោក ចាន់ សុវ៉េត គឺជាសមាជិកបុគ្គលិកដ៏សំខាន់ម្នាក់ ដែលបានធ្វើការនៅអង្គការអាដហុក (Adhoc) ចាប់តាំងតែពីឆ្នាំ១៩៩៥។ គាត់ជាបុគ្គលិកសិទ្ធិមនុស្សម្នាក់ក្នុងចំណោមបុគ្គលិកសិទ្ធិមនុស្សទាំងឡាយរបស់ប្រទេសកម្ពុជា ដែលហ៊ាននិយាយឥតសំចៃមាត់បំផុត។ បច្ចុប្បន្នលោកជាមន្ត្រីស៊ើបអង្កេតជាន់ខ្ពស់ ហើយជាអនុប្រធានផ្នែកឃ្លាំមើលស្ថានភាពសិទ្ធិមនុស្សរបស់អង្គការអាដហុក។

## ដីកាកោះរបស់តុលាការ

នៅថ្ងៃទី៩ ខែសីហា ឆ្នាំ២០១២ សាលាដំបូងរាជធានីភ្នំពេញ បានសម្រេចចេញដីកាកោះហៅលោក ចាន់ សុវ៉េត ឲ្យចូលខ្លួនមកកាន់តុលាការ នៅថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១២។ យោងតាមដីកាកោះលោក ចាន់ សុវ៉េត ត្រូវបានគេសង្ស័យថា បានប្រព្រឹត្តបទល្មើសក្នុងមាត្រា ៥៤៤ នៃក្រមព្រហ្មទណ្ឌ ដែលមាត្រានេះ ហាមប្រាមមិនឲ្យផ្តល់ជំនួយដល់ចារីក្នុងបទឧក្រិដ្ឋ។ ប្រសិនបើការចោទប្រកាន់

ទាំងនេះ ត្រូវបានរកឃើញថាមានពិរុទ្ធ លោក ចាន់ សុវ៉េត នឹងត្រូវប្រឈមនឹងការកាត់ទោសឲ្យជាប់ពន្ធនាគារចំនួនរហូតដល់ ៣ ឆ្នាំ និងពិន័យជាប្រាក់ពី ២,០០០,០០០ រៀលទៅ ៦,០០០,០០០ រៀល។

អាជ្ញាធរមិនទាន់បានបញ្ចេញឲ្យឃើញ នូវមូលដ្ឋានជាក់លាក់សម្រាប់ករណីទាក់ទងនឹងលោក ចាន់ សុវ៉េត នៅឡើយទេ ប៉ុន្តែដីកាកោះទំនងជាមានជាប់ពាក់ព័ន្ធទៅនឹងជម្លោះដូចគ្នាក្នុងខេត្តក្រចេះ ដែលអាជ្ញាធរព្យាយាមភ្ជាប់ទៅនឹងលោក ម៉ម សូណង់ដូ ម្ចាស់ស្ថានីយ៍វិទ្យុឯករាជ្យមួយ។ ដីកាកោះលោក ចាន់ សុវ៉េត បានធ្វើឡើងតែប៉ុន្មានសប្ដាហ៍ប៉ុណ្ណោះ បន្ទាប់ពីលោក ម៉ម សូណង់ដូ ត្រូវបានចាប់ខ្លួន និងឃុំខ្លួនបណ្ដោះអាសន្នរង់ចាំបើកសវនាការ។



សាកសពរបស់ក្មេងស្រី ហេង ចន្ថា អាយុ ១៤ ឆ្នាំ ដែលត្រូវបានបាញ់សម្លាប់ដោយកងកម្លាំងរបស់រាជរដ្ឋាភិបាលនៅពេលអ្នកទាំងនោះចូលលុកលុយភូមិមួយនៅខេត្តក្រចេះដើម្បីធ្វើការបណ្ដេញចេញដោយបង្ខំ កាលពីខែឧសភា ឆ្នាំ២០១២

ដីកាកោះលោក ចាន់ សុវ៉េត ត្រូវបានចេញមិនដល់ ២ សប្ដាហ៍ផងបន្ទាប់ពី សម្ដេចនាយករដ្ឋមន្ត្រី បានមានប្រសាសន៍តាមរយៈសុន្ទរកថាតាមទូរទស្សន៍ទូទាំងប្រទេស នៅថ្ងៃទី ២ ខែសីហា ឆ្នាំ២០១២ថា បុគ្គលិកអង្គការមិនមែនរដ្ឋាភិបាលម្នាក់ ដែលមិនបញ្ចេញឈ្មោះឲ្យដឹងបានផ្ដល់ជំនួយដល់អ្នកបំបែករដ្ឋម្នាក់ ក្នុងចំណោមអ្នកបំបែករដ្ឋក្នុងខេត្តក្រចេះ។ នៅពេលធ្វើសុន្ទរកថានោះ សម្ដេចនាយករដ្ឋមន្ត្រីបានសួរមន្ត្រីរបស់លោកថា តើអាជ្ញាធរបានសាកសួរបុគ្គលិកអង្គការនោះ ហើយឬនៅ ហើយជំរុញឲ្យបុគ្គលិករូបនោះ ចេញមុខមកផ្ដល់ចំលើយសារភាព។ កំណត់ហេតុបានបញ្ជាក់ថា សំណុំរឿងព្រហ្មទណ្ឌនោះ ត្រូវបានបើកការស៊ើបអង្កេត ដោយលោក ឆៃ វីរៈ ជាចៅក្រមស៊ើបសួរតែ ៤៨ ម៉ោងប៉ុណ្ណោះ បន្ទាប់ពីមានសុន្ទរកថារបស់សម្ដេចនាយករដ្ឋមន្ត្រី។

នៅថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១២ មួយថ្ងៃមុនលោក ចាន់ សុវ៉េត ត្រូវមកបង្ហាញខ្លួននៅតុលាការ លោក ឆៃ វីរៈ ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ បានសម្រេចលើកពេលក្នុងការចូលមកបង្ហាញខ្លួន តាមការស្នើសុំរបស់លោក ចាន់ សុវ៉េត។ កាលបរិច្ឆេទថ្មីនៃការចូលមកបង្ហាញខ្លួនត្រូវបានកំណត់នៅថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១២ ប៉ុន្តែកាលបរិច្ឆេទថ្មីនេះ ត្រូវបានគេលើកម្ដងទៀត

ដោយគ្មានកំណត់ពេល។ ថ្វីបើមានការលើកពេលម្តងទៀតក៏ដោយ លោក សំ សុគង់ ជាមេធាវីរបស់លោក ចាន់ សុវ៉េត បានប្រាប់កាសែតភ្នំពេញប៉ុស្តិ៍ឲ្យបានដឹងថា "តុលាការនឹងមិនអនុញ្ញាតឲ្យថតចំលងសំណុំរឿងដើម្បីផ្តល់ឲ្យពួកគេឡើយ រហូតដល់ពេលដែលលោក ចាន់ សុវ៉េត បានចូលមកបង្ហាញខ្លួននៅចំពោះមុខតុលាការ។ ប្រសិនបើតុលាការមិនអនុញ្ញាតឲ្យយើងបានថតចំលងសំណុំរឿងរបស់លោក ចាន់ សុវ៉េត យើងក៏មិនអាចដឹងពីមូលហេតុដែលកូនក្តីរបស់ខ្ញុំត្រូវបានចោទប្រកាន់ ឬមិនដឹងថាត្រូវលើកអំណះអំណាង ដើម្បីការពារក្តីនេះដោយរបៀបណាទេ"។

## ទ្រឹស្តី "ចលនាបំបែករដ្ឋ ឬចលនាអបគមន៍"

នៅថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១២ អាជ្ញាធរបានបញ្ជូនកងកម្លាំងប្រដាប់អាវុធរាប់រយនាក់ ដោយមានជំនួយពីឧទ្ធម្ភាគចក្រមួយគ្រឿង ដើម្បីបណ្តេញអ្នកភូមិ ដែលមានជាប់ពាក់ព័ន្ធក្នុងជម្លោះដីធ្លីជាមួយក្រុមហ៊ុន កាស៊ូទីម ដែលជាក្រុមហ៊ុនឯកជន។ នៅអំឡុងពេលប្រតិបត្តិការបង្ក្រាបនោះ ក្មេងស្រីម្នាក់អាយុ ១៤ ឆ្នាំ ត្រូវបានគេបាញ់ស្លាប់។

នៅពេលកំពុងមានការរិះគន់ពីសំណាក់អន្តរជាតិ ទៅលើប្រតិបត្តិការបង្ក្រាបយ៉ាងតក់ស្លុត អាជ្ញាធរបានថ្លែងថា ការប្រើប្រាស់កម្លាំងហួសប្រមាណ គឺជាការចាំបាច់ដើម្បីបង្ក្រាបចលនាអ្នកបំបែករដ្ឋក្នុងតំបន់នោះ។ ការដោះសារបែបនេះ ត្រូវបានគេរិះគន់ពីគ្រប់មជ្ឈដ្ឋាន។ គ្មានកងកម្លាំងប្រដាប់អាវុធណាម្នាក់ បានទទួលរងរបួសទេ ហើយក៏ពុំទាន់មានភស្តុតាងណាមួយគួរឲ្យជឿជាក់បាន ត្រូវបានលើកយកមកបង្ហាញថា អ្នកភូមិរស់នៅក្នុងតំបន់នោះ បានកាន់អាវុធប្រឆាំងនឹងអាជ្ញាធរឡើយ។ ហើយក៏គ្មានភស្តុតាងណាមួយ ដែលថាអ្នកភូមិមានចេតនាធ្វើផែនការ ឬមានមធ្យោបាយដើម្បីប៉ុនប៉ងធ្វើអបគមន៍ដែរ។ ជាការពិតណាស់ក៏គ្មានការលើកឡើង នៅក្នុងសេចក្តីថ្លែងការណ៍ជាសាធារណៈប្រភេទណាមួយ ឬតាមសារព័ត៌មាន ដែលពិពណ៌នាអំពីកិច្ចខិតខំប្រឹងប្រែងបំបែករដ្ឋ ឬធ្វើអបគមន៍នៅក្នុងតំបន់នោះ នៅមុនពេលមានចំណាត់ការយោធាឡើយ។ ហើយក្រៅពីការកត់សម្គាល់ដែលមានលក្ខណៈមិនច្បាស់លាស់ និងបែបសន្និដ្ឋាន ដោយគ្មានការលើកឡើងអំពីកត្តាផ្លូវច្បាប់ ឬភស្តុតាងនោះ អាជ្ញាធរនៅតែមិនព្រមព្យាយាមពន្យល់ជាសាធារណៈអំពីមូលដ្ឋានសម្រាប់ការចោទប្រកាន់បែបនេះទេ។

## ឥទ្ធិពលអវិជ្ជមានសំខាន់ដែលកើតពីព្រឹត្តិការណ៍នោះ

ដីកាកោះរបស់លោក ចាន់ សុវ៉េត គឺជាអំពើរំខានយាយីពីតុលាការមួយយ៉ាងជាក់ស្តែង ដែលមានគោលដៅរារាំងសកម្មភាពសិទ្ធិមនុស្សស្របច្បាប់របស់គាត់។ ដោយសារតែលោក ចាន់ សុវ៉េត ជាមនុស្សម្នាក់ ដែលមានឋានៈជាអ្នកតស៊ូមតិខាងសិទ្ធិមនុស្សជាន់ខ្ពស់ និងបាននិយាយបំផុតរបស់

ប្រទេសកម្ពុជា ទើបភាពធ្ងន់ធ្ងរនៃករណីរបស់គាត់ មិនអាចត្រូវបានគេមើលស្រាលបានឡើយ។ វាជាការគំរាមកំហែងដ៏ធ្ងន់ធ្ងរដល់ការងារសិទ្ធិមនុស្សនៅប្រទេសកម្ពុជា នៅក្នុងទស្សវត្សរ៍នេះ។

## រដ្ឋគាំទ្រឲ្យមានអំពើហិង្សា: ការបំពារបំពានទៅលើសិទ្ធិជាមូលដ្ឋាន

ការធ្វើបាតុកម្មជាសាធារណៈ បានកើនឡើងនៅប្រទេសកម្ពុជា ដែលជាផលវិបាកដោយផ្ទាល់ពីការខ្វះនីតិរដ្ឋ។ នៅពេលកំពុងប្រឈមនឹងអំពើពុករលួយយ៉ាងរាលដាល ការឃើតយ៉ាវក្នុងចំណាត់ការរឿងក្តីរដ្ឋប្បវេណី ដែលមិនមានពេលកំណត់ទាក់ទងនឹងសិទ្ធិដីធ្លី ហើយនឹងបរិយាកាសសិទ្ធិមនុស្សកំពុងតែដុនដាប ព្រមទាំងប្រជាពលរដ្ឋកំពុងព្យាយាមការពារសិទ្ធិរបស់ពួកគេ ប្រការទាំងអស់នេះ បានប្រកាន់យកដំណោះស្រាយតាមផ្លូវផ្សេងកាន់តែច្រើនឡើង។ ការធ្វើបាតុកម្មជាសាធារណៈ ទោះជាតាមទម្រង់តវ៉ា កូដកម្ម និងទោះជាតាមទម្រង់ប្រមូលផ្តុំគ្នាក្តី បានក្លាយជាមធ្យោបាយធម្មតាទៅហើយ។

ចាប់តាំងពីមានរបាយការណ៍ចុងក្រោយរបស់ខ្លួន អង្គការលីកាដូ បានចងក្រងទុកជាឯកសារនូវការកើនឡើងគួរឲ្យបារម្ភ ចំពោះការធ្វើអន្តរាគមន៍ប្រកបដោយហិង្សាពីមន្ត្រីនគរបាលទៅលើបាតុករដោយអហិង្សា។ កងកម្លាំងសន្តិសុខបានប្រើប្រាស់កម្លាំងហួសប្រមាណកាន់តែច្រើនឡើងជាការបង្ការទុកដើម្បីបញ្ចប់ការប្រមូលផ្តុំ។ មន្ត្រីនគរបាល កងរាជអាវុធហត្ថ ព្រមទាំងទាហាន ត្រូវបានដាក់ពង្រាយ ដើម្បីរារាំងមិនឲ្យធ្វើការប្រមូលផ្តុំដោយអហិង្សា (ជារឿយៗប្រកបដោយហិង្សា) ហើយនឹងបំបែកក្រុមអ្នកតវ៉ា។ ការធ្វើអន្តរាគមន៍បែបនេះ ត្រូវបានគេប្រើជាទូទៅផងដែរ ដើម្បីការពារដីសម្បទានរបស់ក្រុមហ៊ុនឯកជន។ គ្រាន់តែនៅចន្លោះខែវិច្ឆិកា ឆ្នាំ២០១១ និងខែឧសភា ឆ្នាំ២០១២ អាជ្ញាធរបានបើកការវាយប្រហារចំនួន ៨ លើកនៅពេលមានការតវ៉ាដោយអហិង្សា។[១១]

កាលៈទេសៈជុំវិញឧប្បត្តិហេតុភាគច្រើនទាំងនេះ បង្ហាញឲ្យឃើញនូវការរួមគំនិតគ្នាយ៉ាងជិតស្និទ្ធិរវាងអាជ្ញាធរ និងក្រុមហ៊ុនឯកជនមានអំណាច ដែលព្យាយាមរំលោភយកដីធ្លី។ កងកម្លាំងប្រដាប់អាវុធត្រូវបានគេប្រើប្រាស់ជាប្រចាំ ជាឆ្មាំសន្តិសុខសម្រាប់ការពារក្រុមហ៊ុន ដែលមានពាក់ព័ន្ធក្នុងជម្លោះដីធ្លី។

[១១] សេចក្តីប្រកាសព័ត៌មានរបស់អង្គការលីកាដូ "ត្រូវតែបញ្ឈប់វប្បធម៌និទ្ទណ្ឌភាព និងអំពើហិង្សា" ថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១២ សូមមើល http://www.licadho-cambodia.org/pressrelease.php?perm=282។ សូមមើលផងដែរ: សេចក្តីប្រកាសព័ត៌មានរបស់អង្គការលីកាដូ "ឧប្បត្តិហេតុបាញ់អ្នកតវ៉ាជំលោះដីធ្លីចំនួន ៥ លើក កាលពី ២ខែកន្លងទៅបង្ហាញឲ្យឃើញនូវការកើនឡើងគួរឲ្យព្រួយបារម្ភក្នុងការប្រើប្រាស់កម្លាំងស្លាប់រស់" ថ្ងៃទី២៦ ខែមករា ឆ្នាំ២០១២ សូមមើល http://www.licadho-cambodia.org/pressrelease.php?perm=269។

## ករណីសិក្សា: យោធាការពារក្រុមហ៊ុនសាជីវកម្មបើកការបាញ់រះទៅលើអ្នកភូមិ[១២]

នៅថ្ងៃទី១៨ ខែមករា ឆ្នាំ២០១២ បុគ្គលិកយោធាដើរតួជាឆ្មាំសន្តិសុខក្រុមហ៊ុន TTY Co. Ltd. បានបើកការបាញ់ប្រហារទៅលើអ្នកភូមិមួយក្រុម ដែលគ្មានអាវុធនៅក្នុងស្រុកស្នួលខេត្តក្រចេះ។ អ្នកភូមិប្រមាណ ៥០០ នាក់បានប្រមូលផ្តុំគ្នា ដើម្បីរារាំងគ្រឿងចក្ររបស់ក្រុមហ៊ុនមិនឲ្យធ្វើការឈូសឆាយដីចំការរបស់ពួកគេ។ ការឈូសបំផ្លាញចំការដំឡូងមីបានធ្វើឲ្យប៉ះពាល់ប្រជាពលរដ្ឋចំនួន ៣០០ គ្រួសារ។ អ្នកភូមិបានព្យាយាមប្រមូលផលដំណាំដំឡូងមី មុនពេលក្រុមហ៊ុនឈូសឆាយដីរបស់ពួកគេ។

អ្នកភូមិចំនួន ៤ នាក់ មានឈ្មោះ លី ឥសា ម៉ុង អូ នេត រតនា និងទ្រី យ៉ា បានទទួលរងរបួសយ៉ាងធ្ងន់ធ្ងរ។ ជនរងគ្រោះចំនួន ៣ នាក់ ក្នុងចំណោមជនរងគ្រោះទាំងអស់ពីការបាញ់ប្រហារនោះ ត្រូវបានបញ្ជូនភ្លាមៗទៅកាន់មន្ទីរពេទ្យនៅខេត្តកំពង់ចាម។ ជនរងគ្រោះម្នាក់បន្ទាប់មក ត្រូវបានបញ្ជូនទៅព្យាបាលនៅប្រទេសវៀតណាម ដោយសារមុខរបួសរបស់គាត់មានសភាពធ្ងន់ធ្ងរ។ អាជ្ញាធរដែលមានវត្តមាននៅអំឡុងពេលបាញ់ប្រហារនោះ មិនបានព្យាយាមចាប់ខ្លួនជនដៃដល់ឡើយ។

ប្រមាណថ្ងៃបន្ទាប់ពីមានការបាញ់ប្រហារ អ្នកភូមិបានបិទផ្លូវជាតិលេខ ៧៦A ដោយទាមទារឲ្យរាជរដ្ឋាភិបាលបណ្តេញក្រុមហ៊ុននេះចេញពីខេត្តក្រចេះ និងធ្វើការដកហូតយកដីសម្បទានពីក្រុមហ៊ុននោះមកវិញ។

ក្រុមហ៊ុន TTY Co. Ltd. ដែលមានម្ចាស់ឈ្មោះ ឧកញ៉ា អាន មារ៉ាឌី និងជាទីប្រឹក្សាសម្តេចនាយករដ្ឋមន្ត្រី បានទទួលដីសម្បទានសេដ្ឋកិច្ចចំនួនជាង ៩,០០០ ហិកតាក្នុងឆ្នាំ២០០៨នៅស្រុកស្នួល សម្រាប់ធ្វើជាចំការកៅស៊ូ និងដាំដំឡូងមី។ ដីសម្បទានមួយផ្នែកគឺស្ថិតនៅក្នុងដែនជម្រកសត្វព្រៃ។

ក្រោយពីមានការរិះគន់យ៉ាងរាលដាលទៅលើអំពើហិង្សានេះ (ហើយបន្ទាប់ពីមានការផ្សព្វផ្សាយខ្សែវីដេអូអំពីព្រឹត្តិការណ៍បាញ់ប្រហារ) សម្តេចនាយករដ្ឋមន្ត្រី បានលោកអំពាវនាវឲ្យមានការចាប់ខ្លួនជនដៃដល់។ ឆ្មាំសន្តិសុខចំនួន ២ នាក់ របស់ក្រុមហ៊ុនត្រូវ បានតុលាការកោះហៅជាបន្ទាន់ឲ្យចូលខ្លួន ដើម្បីធ្វើការសាកសួរនៅថ្ងៃទី៣០ ខែមករា ឆ្នាំ២០១២ ក្រោមការចោទប្រកាន់ពាក់ព័ន្ធនឹងការកាន់កាប់អាវុធខុសច្បាប់។ ជនសង្ស័យទាំង ២ នាក់នោះ ម្នាក់មានឈ្មោះ កែ សុវណ្ណា អាយុ ៥០ ឆ្នាំ និងម្នាក់ទៀត ឈ្មោះ ពិន គឹមឡេង អាយុ ២៦ ឆ្នាំ ហើយអ្នកទាំង ២ នាក់នេះ ត្រូវបានចោទប្រកាន់ពីបទប្រើប្រាស់អាវុធខុសច្បាប់ បើទុកជាមានភស្តុតាងគ្រប់គ្រាន់ ដើម្បីគាំទ្រឲ្យមានការចោទប្រកាន់

[១២] របាយការណ៍ឃ្លាំមើលរបស់អង្គការលីកាដូ ដែលមិនបានផ្សព្វផ្សាយ: PP010PA12 សូមមើលផងដែរ: វីដេអូអង្គការលីកាដូ "យោធាបាញ់ទៅលើអ្នកតវ៉ានៅភាគឦសាននៃប្រទេសកម្ពុជា" ថ្ងៃទី២១ ខែមករា ឆ្នាំ២០១២ សូមមើល: http://licadho-cambodia.org/video.php?perm=29 ។

ធ្ងន់ធ្ងរជាងនេះ ដូចជាការប៉ុនប៉ងធ្វើឃាតក៏ដោយ។ នៅក្នុងខែមីនា ឆ្នាំ២០១២ លោក អ៊ុន ពិសិទ្ធិ ជាអ្នកគ្រប់គ្រងយូរឆ្នាំរបស់ក្រុមហ៊ុន TTY Co. Ltd. តាមរាយការណ៍មក ត្រូវបានចាប់ខ្លួន ក្រោមការចោទប្រកាន់ទាក់ទងទៅនឹងការបាញ់ប្រហារនោះផងដែរ។

សកម្មជនការពារដីធ្លី និងកម្មករកំពុងតែប្រើប្រាស់មធ្យោបាយធ្វើញត្តិ ដាក់ជូនសម្ដេចនាយករដ្ឋមន្ត្រីកាន់តែច្រើនឡើង និងទៅបណ្ដាស្ថាប័នជាតិព្រមទាំងអង្គទូតបរទេសនានា ដើម្បីសុំធ្វើអន្តរាគមន៍ក្នុងនាមរបស់ពួកគេ។◄◄




នគរបាលកំពុងឈរ ខណៈដែលអ្នកតវ៉ាបានប្រមូលផ្ដុំគ្នាដើម្បីគាំទ្រស្ត្រីបឹងកក់ទាំង ១៣ នាក់ នៅរាជធានីភ្នំពេញ កាលពីថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១២

## ខែវិច្ឆិកា ឆ្នាំ២០១១ - ខែឧសភា ឆ្នាំ២០១២: មានករណីប្រើប្រាស់កម្លាំងយ៉ាងខ្លាំងក្លាចំនួន ៨ នៅអំឡុងពេលធ្វើការតវ៉ា ឬទប់ទល់នឹងសកម្មជនសិទ្ធិមនុស្ស

**ថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០១១**

*ឃុំត្រែងត្រយឹង ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ*

មន្ត្រីកងរាជអាវុធហត្ថ រួមជាមួយមន្ត្រីនគរបាលស៊ីវិល បានបាញ់កាំភ្លើងសំដៅឡើងលើដើម្បីបំបែកការបិទផ្លូវថ្នល់ ដែលត្រូវបានធ្វើឡើងដោយអ្នកភូមិចំនួន ១០០ នាក់។ អ្នកភូមិទាំងនោះ កំពុងធ្វើការតវ៉ាប្រឆាំងនឹងការព្យាយាមរបស់ព្រះរាជអាជ្ញាអមសាលាដំបូងខេត្ត ដើម្បីអនុវត្តសាលដីកាតុលាការកំពូល ដោយបង្គាប់ឲ្យរឹបអូសយកដីស្រែចំការរបស់ពួកគេ តាមរយៈសមាគមកសិករមួយដែលមិនច្បាស់លាស់ ដែលមានលោកវរៈសេនីយ៍ឯកមួយរូបជាអ្នកតំណាង។ គ្មានជនណាម្នាក់ទទួលរងរបួសឡើយ។

**ថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១១**

*ស្រុកភ្នំព្រឹក ខេត្តបាត់ដំបង*

មេបញ្ជាការកងរាជអាវុធហត្ថមួយរូប ដែលដើរតួជាឆ្មាំសន្តិសុខរបស់ក្រុមហ៊ុន សួនមានសម្បត្តិ បានបាញ់ប្រហារទៅលើអ្នកភូមិមួយក្រុម ដែលកំពុងធ្វើបាតុកម្មប្រឆាំងនឹងក្រុមហ៊ុនឈូសឆាយដីស្រែចំការ ដែលក្រុមហ៊ុននេះ បានទទួលដីសម្បទានសេដ្ឋកិច្ចចំនួន ៩,០៩៥ ហិកតា នៅក្នុងតំបន់នោះនៅក្នុងអំឡុងខែមេសា ឆ្នាំ២០១១។ អ្នកភូមិចំនួន ៣ នាក់បានទទួលរងរបួស។

**ថ្ងៃទី៣ ខែមករា ឆ្នាំ២០១២**

*ការដោះស្រាយបញ្ហាដីធ្លីនៅសហគមន៍បូរីកីឡា រាជធានីភ្នំពេញ*

កងកម្លាំងនគរបាលចំរុះចំនួនជាង ១០០ នាក់ បានបាញ់ឧស្ម័នបង្ហូរទឹកភ្នែក និងគ្រាប់កាំភ្លើងពិតទៅលើអ្នករស់នៅសហគមន៍បូរីកីឡានៅពេលដែលពួកគេបាន ត្រួតពិនិត្យមើលការកំទេចផ្ទះសំបែង ដែលធ្វើឡើងដោយបុគ្គលិកក្រុមហ៊ុន ផានអ៊ីមិច (Phanimex)។ នៅពេលនោះ ប្រជាពលរដ្ឋចំនួន ១២ នាក់ បានទទួលរងរបួស ក្នុងនោះមានមន្ត្រីនគរបាល ១ រូបផង។

**ថ្ងៃទី៣ ខែមករា ឆ្នាំ២០១២**

*ភូមិកាណាត់ធំ ខេត្តរតនៈគីរី*

មេបញ្ជាការកងរាជអាវុធហត្ថមួយរូប បានបាញ់កាំភ្លើងចំនួន ២គ្រាប់សំដៅអ្នកភូមិជនជាតិដើមភាគតិចមួយក្រុម ដែលកំពុងតវ៉ានឹងក្រុមហ៊ុនចំការកៅស៊ូ ដែលកំពុងឈូសឆាយដីធ្លី។ អ្នកភូមិទាំង

នោះមានជម្លោះដីធ្លីជាយូរលង់មកហើយ ជាមួយក្រុមហ៊ុនចំការកៅស៊ូវៀតណាមមួយឈ្មោះ ហេង ប្រាឌឺរាប់ប៊ឺ (Heng Brother Rubber)។ ពុំមានសេចក្ដីរាយការណ៍អំពីការរងរបួសឡើយ។

### ថ្ងៃទី១៨ ខែមករា ឆ្នាំ២០១២

*ស្រុកស្នួល ខេត្តក្រចេះ*

មន្ត្រីកងរាជអាវុធហត្ថ ដែលដើរតួជាឆ្មាំសន្តិសុខរបស់ក្រុមហ៊ុន TTY Co. Ltd. បានបើកការបាញ់ប្រហារទៅលើអ្នកភូមិ ដែលកំពុងធ្វើការតវ៉ាប្រឆាំងនឹងការឈូសឆាយចំការដំឡូងមីរបស់ពួកគេ។ ក្រុមហ៊ុន TTY Co. Ltd. នេះបានទទួលដីសម្បទានសេដ្ឋកិច្ចក្នុងតំបន់នោះ។ អ្នកភូមិចំនួន ៤ នាក់បានទទួលរងរបួស។

### ថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១២

*តំបន់សេដ្ឋកិច្ចពិសេស មាហាតាន់ ស្រុកបាវិត ខេត្តស្វាយរៀង*

លោក ឈូក បណ្ឌិត អភិបាលស្រុកបាវិត បានបើកការបាញ់ប្រហារទៅលើកម្មករកាត់ដេរមួយក្រុម ដែលមានចំនួន ១,០០០ នាក់ នៅពេលដែលពួកគេកំពុងធ្វើបាតុកម្ម។ កម្មការិនីចំនួន ៣ នាក់បានទទួលរងរបួសយ៉ាងធ្ងន់ធ្ងរ ដោយសារត្រូវគ្រាប់កាំភ្លើង។

### ថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១២

*ឃុំបាក់ខ្លង ស្រុកមណ្ឌលសៀម ខេត្តកោះកុង*

លោក ឈុត វុទ្ធី ជាសកម្មជនការពារបរិស្ថាន និងជាប្រធានក្រុមការពារធនធានធម្មជាតិ ត្រូវបានបាញ់គេសម្លាប់ នៅពេលមានជម្លោះជាមួយមន្ត្រីកងរាជអាវុធហត្ថ ដែលដើរតួជាឆ្មាំសន្តិសុខរបស់ក្រុមហ៊ុន ធីមប៊ឺគ្រីន (Timber Green Company) ។ លោក ឈុត វុទ្ធី ត្រូវបានអមដំណើរដោយអ្នកសារព័ត៌មានចំនួន ២ នាក់ របស់កាសែត The Cambodia Daily នៅពេលកំពុងយកព័ត៌មានអំពីអាជីវកម្មកាប់ឈើខុសច្បាប់។

### ថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១២

*ឃុំកំពង់ដំរី ខេត្តក្រចេះ*

ទាហានកងយោធាបានធ្វើការបើកការបាញ់ប្រហារ នៅអំឡុងពេលបណ្ដេញអ្នកភូមិ ចំនួន ៤០០ នាក់។ អ្នកភូមិចំនួន ២ នាក់ បានទទួលរងរបួស ហើយក្មេងស្រីអាយុ ១៤ឆ្នាំម្នាក់ក៏ត្រូវបានបាញ់សម្លាប់ផងដែរ។

## ការបង្ក្រាបតាមរយៈការអនុវត្តមិនត្រឹមត្រូវលើច្បាប់ស្រពិចស្រពិល

"ប្រជាពលរដ្ឋខ្មែរមានសេរីភាពខាងការបញ្ចេញមតិរបស់ខ្លួន សេរីភាពខាងសារព័ត៌មាន សេរីភាពខាងការបោះពុម្ពផ្សាយ និងសេរីភាពខាងការប្រជុំ។ ជនណាក៏ដោយមិនអាចឆ្លៀតប្រើសិទ្ធិនេះ ដោយរំលោភនាំឲ្យប៉ះពាល់ដល់កិត្តិយសអ្នកដ៏ទៃ ដល់ទំនៀមទំលាប់ល្អរបស់សង្គម ដល់សណ្តាប់ធ្នាប់សាធារណៈ និងដល់សន្តិសុខជាតិបានឡើយ"។

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
មាត្រា ៤១

ការប្រើប្រាស់កម្លាំងតាមទំនើងចិត្តរបស់អាជ្ញាធរ មិនមែនគ្រាន់តែជាអាវុធមួយមុខ នៅពេលដែលធ្វើការបង្ក្រាបបាតុកម្មជាសាធារណៈប៉ុណ្ណោះទេ។ អង្គនីតិបញ្ញត្តិបានជួយដល់អាជ្ញាធរដោយចែងច្បាប់ស្តីពីការធ្វើបាតុកម្ម ដោយអហិង្សាផងដែរ ដែលច្បាប់នេះ បានចូលជាធរមានក្នុងខែមេសា ឆ្នាំ២០១០។

ច្បាប់នេះ ត្រូវបានគេយកមកបង្ហាញជាការចាំបាច់ ដើម្បីគ្រប់គ្រងការប្រមូលផ្តុំគ្នា ហើយនឹងការពារសណ្តាប់ធ្នាប់សាធារណៈ ប៉ុន្តែតាមការអនុវត្តជាក់ស្តែង ច្បាប់នេះ កំពុងត្រូវបានគេយកមកប្រើប្រាស់ដើម្បីធ្វើឲ្យស្របច្បាប់នូវការរំលោភបំពានទៅលើសិទ្ធិ ដែលត្រូវបានការពារដោយរដ្ឋធម្មនុញ្ញ។ ច្បាប់នេះ តម្រូវថា ស្ទើរតែគ្រប់ការប្រមូលផ្តុំគ្នា ដោយមិនគិតពីទំហំ ឬគោលបំណង ត្រូវតែទទួលបានការអនុម័តយល់ព្រមជាមុនពីអាជ្ញាធរ។ ច្បាប់នេះ ប្រគល់អំណាចទៅឲ្យមន្ត្រី ដើម្បីហាមឃាត់មិនឲ្យធ្វើបាតុកម្ម ដោយអហិង្សា ដោយឈរលើមូលហេតុទាក់ទងនឹងការគំរាមកំហែងធ្ងន់ធ្ងរដល់សន្តិសុខ សុវត្ថិភាព ឬសណ្តាប់ធ្នាប់សាធារណៈ។ បញ្ហាគឺនៅត្រង់ថាការកំណត់ព្រំដែននេះ មិនមានចែងនៅក្នុងច្បាប់ទេ។ ភាពមិនច្បាស់លាស់នៃច្បាប់បានបើកចំហរឲ្យមានការអនុវត្តច្បាប់តាមទំនើងចិត្ត ហើយថែមទាំងធ្វើការបង្ក្រាបទៅលើសិទ្ធិសេរីភាពក្នុងការជួបប្រជុំគ្នា និងសេរីភាពក្នុងការបញ្ចេញមតិទៀតផង។

បទបញ្ញត្តិផ្សេងៗទៀតនៅក្នុងច្បាប់ ស្តីពីការធ្វើបាតុកម្មដោយអហិង្សា បានដាក់អ្នកការពារសិទ្ធិមនុស្សឲ្យទទួលរងនូវការគំរាមកំហែង និងការបំពារបំពានរាងកាយផងដែរ។ ឧ: នៅក្រោមច្បាប់ថ្មីនេះ ការជូនដំណឹងដល់អាជ្ញាធរត្រូវភ្ជាប់មកជាមួយនូវអត្តសញ្ញាណប័ណ្ណមួយច្បាប់ របស់អ្នកតំណាងចំនួន ៣ រូបជាសញ្ជាតិខ្មែរ។ អ្នកការពារសិទ្ធិមនុស្សបានសម្តែងនូវការភ័យខ្លាច ដែលថាលក្ខខ័ណ្ឌតម្រូវបែបនេះ បង្កលក្ខណៈឲ្យអាជ្ញាធរងាយស្រួលក្នុងការកំណត់អត្តសញ្ញាណអ្នកការពារសិទ្ធិមនុស្សនាំមុខគេ ហើយនឹងកំណត់ពួកគេជាគោលដៅសម្រាប់ធ្វើការតបតចំពោះការងាររបស់ពួកគេ។

## ករណីសិក្សា: សួង សុភ័ណា ជាសកម្មជនសហគមន៍បឹងកក់ម្នាក់ ត្រូវបានមន្ត្រីនគរបាលវាយដំរាងកាយជាច្រើនដង[១៣]

នៅថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១០ អ្នកតវ៉ាមួយក្រុមមានគ្នាចំនួន ៥០ នាក់បាន មកប្រមូលផ្តុំគ្នានៅមុខមន្ទីរពេទ្យមិត្តភាពខ្មែរសូវៀត នៅរាជធានីភ្នំពេញ នៅខណៈ លោក បាន គីមូន (Ban Ki-moon) ជាអគ្គលេខាធិការអង្គការសហប្រជាជាតិកំពុងធ្វើទស្សនៈកិច្ចមកកាន់មន្ទីរពេទ្យនេះ។ អ្នកតវ៉ាទាំងនោះ កំពុងតែស្វែងរកសុំកិច្ចអន្តរាគមន៍ព ពីលោកអគ្គលេខាធិការរូបនេះ ក្នុងជំលោះដីធ្លីដ៏រ៉ាំរ៉ៃនៅសហគមន៍បឹងកក់។



សកម្មជន លោក សួង សុភ័ណ្ឌ ត្រូវបានគេថតរូបនៅរាជធានីភ្នំពេញ បន្ទាប់ពីលោក ត្រូវបាននគរបាលប្រឆាំងកុប្បកម្មវាយឲ្យរបួស អំឡុងពេលដំណើរទស្សនកិច្ចរបស់អគ្គលេខាធិការអង្គការសហប្រជាជាតិ កាលពីថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១០

នៅវេលាម៉ោងប្រហែល ១០:១៥ នាទីព្រឹក មន្ត្រីនគរបាលចម្រុះប្រឆាំងកុប្បកម្ម ប្រដាប់ដោយអាវុធមួយក្រុម និងមន្ត្រីនគរបាលរដ្ឋបាល បានបើកយុទ្ធនាការបង្ក្រាប ដោយហិង្សាទៅលើអ្នកតវ៉ាទាំងនោះដោយអហិង្សា។ ក្រុមបាតុករត្រូវបានគេរុញផ្តួលទៅលើដី វាយដំនឹងវិទ្យុទាក់ទង ព្រមទាំងឆក់ពួកគេនឹងដំបងឆក់ទៀតផង។

មន្ត្រីនគរបាលបានកំណត់ សួង សុភ័ណ្ឌ ជាគោលដៅក្នុងការវាយដំយ៉ាងខ្លាំងក្លា និងធ្វើឲ្យគាត់របួសក្បាលយ៉ាងដំណំ។ បន្ទាប់មកមន្ត្រីនគរបាលបានអូសគាត់ចេញ នៅពេលដែលជនរងគ្រោះសន្លប់បាត់បង់ស្មារតីដោយសារមុខរបួសនោះ។ នៅពេលដែលជនរងគ្រោះ ត្រូវបានគេកំពុងអូស មន្ត្រីនគរបាលនៅតែបន្តវាយដំទៅលើរូបគាត់ទៀតផង។

នេះមិនមែនជាលើកទី១ ទេ ដែលអាជ្ញាធរបានកំណត់ សួង សុភ័ណ្ឌ ជាគោលដៅ។ សកម្ម

---

[១៣] សេចក្តីប្រកាសព័ត៌មានរបស់អង្គការលីកាដូ "ការបង្ក្រាបដោយហិង្សាទៅលើអ្នកតវ៉ាដោយអហិង្សានៅអំឡុងពេលទស្សនៈ កិច្ចរបស់អគ្គលេខាធិការអង្គការសហប្រជាជាតិ" ថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១០ សូមមើល: http://www.licadho-cambodia.org /pressrelease.php?perm=229។ សូមមើលផងដែរ: វីដេអូរបស់អង្គការលីកាដូ http://www.licadho-cambodia.org/video.php?perm=20។ សូមមើលផងដែរ: របាយការណ៍ឃ្លាំមើលសិទ្ធិមនុស្សរបស់អង្គការលីកាដូ ដែលមិនទាន់ផ្សព្វផ្សាយ PP14OFEA10។ សូមមើលផងដែរ: វីដេអូរបស់អង្គការលីកាដូ "សកម្មជនសហគមន៍បឹងកក់ត្រូវបានវាយដំយ៉ាងឃោរឃៅពីសំណាក់ហ្វូងមន្ត្រីនគរបាលនៅអំឡុងពេលធ្វើការបណ្តេញចេញ" ថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១១ http://www.licadho-cambodia.org/video.php?perm=25។ មើលផងដែរ: សេចក្តីប្រកាសព័ត៌មានរបស់អង្គការលីកាដូ "អាជ្ញាធរក្រុងភ្នំពេញត្រូវតែគោរពទៅតាមបទបញ្ជារបស់រដ្ឋាភិបាលក្នុងការផ្តល់ដីធ្លីទៅឲ្យគ្រួសារប្រជាពលរដ្ឋសហគមន៍បឹងកក់ដែលនៅសេសសល់" ថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១១ http://www.licadho-cambodia.org/pressrelease.php?perm=259។

ជនការពារសិទ្ធិដីធ្លីរូបនេះ ធ្លាប់បានរស់នៅក្នុងសហគមន៍បឹងកក់ ហើយនៅខែមិថុនា ឆ្នាំ២០០៩ លោកត្រូវបានគេឃុំខ្លួនអស់រយៈពេល ៣ ថ្ងៃមុនពេលនាំ ទៅបង្ហាញខ្លួននៅចំពោះមុខតុលាការ។ នៅក្នុងសវនាការដ៏ប្រញាប់ប្រញាល់មួយ លោកត្រូវបានគេរកឃើញកំហុសពី "បទបរិហារកេរ្តិ៍" រាជរដ្ឋាភិបាល បន្ទាប់ពីគាត់បានបាញ់ថ្នាំ ដោយបង្កើតជាពាក្យនៅលើដំបូលផ្ទះរបស់គាត់ថា៖ "បញ្ឈប់ការបណ្តេញចេញ"។

ជិតមួយឆ្នាំក្រោយមក លោក សុភ័ណ នៅតែត្រូវបានគេកំណត់ជាគោលដៅដដែល។

នៅរសៀលថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១១ មន្ត្រីនគរបាលអន្តរាគមន៍ប្រឆាំងកុប្បកម្មចំនួន ១០០ នាក់ ហើយនឹងឆ្មាំសន្តិសុខខណ្ឌដូនពេញ បានសម្រុកចូលទៅក្នុងសង្កាត់សហគមន៍បឹងកក់ ដើម្បីការពារគ្រឿងចក្រចំនួន ២ ដែលកំពុងឈូសឆាយផ្ទះសម្បែងប្រជាពលរដ្ឋនៅទីនោះ។ ផ្ទះសម្បែង គឺជាកម្មសិទ្ធិរបស់ក្រុមគ្រួសារប្រជាពលរដ្ឋ ដែលត្រូវបានគេដកហូតសិទ្ធិតាមទំនើងចិត្តមិនឲ្យទទួលកម្មសិទ្ធិលើក្បាលដីក្នុងទំហំដីចំនួន ១២.៤៤ ហិកតា ដែលត្រូវបានរាជរដ្ឋាភិបាលចុះអនុក្រឹត្យចែកជូនដល់អ្នករស់នៅសេសសល់ក្នុងសហគមន៍បឹងកក់។

នៅពេលដែលគ្រឿងចក្រកំពុងធ្វើការឈូសឆាយផ្ទះផ្សេងៗថែមទៀត មន្ត្រីនគរបាលអន្តរាគមន៍មួយក្រុម បានធ្វើការបំពារបំពានទៅលើរាងកាយ សួង សុភ័ណ្ឌ យ៉ាងខ្លាំងក្លា។ សកម្មជនការពារសិទ្ធិដីធ្លីរូបនេះ ត្រូវបានមន្ត្រីនគរបាលទាត់ធាក់ និងវាយនឹងដុំឥដ្ឋ និងដំបងយ៉ាងហិង្សា។ ចំណងជើងខ្សែវីដេអូ ដែលអង្គការលីកាដូ ថតបានបង្ហាញឲ្យឃើញថា មន្ត្រីនគរបាលមួយរូបបានវាយទៅលើក្បាល លោក សុភ័ណ្ឌ ជាច្រើនដងនឹងកាំភ្លើងបាញ់ឧស្ម័នបង្ហូរទឹកភ្នែកទៀតផង។

បន្ទាប់ពីទទួលរងការបំពារបំពានលើរាងកាយរួចមក មន្ត្រីនគរបាលមួយក្រុមបានទុក លោក សុភ័ណ្ឌ ចោលនៅកណ្តាលថ្នល់ ដែលសន្លប់បាត់បង់ស្មារតីក្នុងថ្លុកឈាម ។ អ្នកឃ្លាំមើលសិទ្ធិមនុស្សរបស់អង្គការលីកាដូ បាននាំយកសកម្មជនដែលរងរបួសធ្ងន់ធ្ងរនេះ ទៅព្យាបាលនៅមន្ទីរពេទ្យមូលដ្ឋាន ដោយសារគាត់មានរបួសក្បាលយ៉ាងធ្ងន់ធ្ងរ ហើយម្រាមដៃរបស់លោកបែកជាពីរផងដែរក្រោយពីប៉ះទង្គិចនឹងដុំឥដ្ឋ។ បន្ទាប់ពីទទួលការព្យាបាលជនរងគ្រោះរូបនេះ ក៏បានដឹងខ្លួនឡើងវិញ។ ◄◄

---

## ការគំរាមកំហែងដល់អាយុជីវិត និងការប៉ុនប៉ងសម្លាប់លើអ្នកការពារសិទ្ធិមនុស្ស

នៅចន្លោះឆ្នាំ២០១០ និង២០១២ អ្នកការពារសិទ្ធិមនុស្សបានប្រឈមនឹងការគំរាមកំហែង ព្រមទាំងការប៉ុនប៉ងធ្វើឃាត។ ជនសង្ស័យក្នុងការប្រព្រឹត្តិបំពានទាំងនេះ ជាញឹកញាប់មិនត្រូវបានគេកំណត់អត្តសញ្ញាណ ហើយក៏មិនដែលត្រូវបានគេចោទប្រកាន់នោះទេ។

អង្គការលីកាដូ បានចងក្រងទុកជាឯកសារនូវការប៉ុនប៉ងធ្វើឃាតចំនួនពីរករណី ស្ថិតនៅក្នុងខែមេសា ឆ្នាំ២០១០។ នៅថ្ងៃទី២១ ខែមេសា លោកស៊ិម ម៉ី ជាសកម្មជនការពារសិទ្ធិដីធ្លី បានគេចផុតពីការស្លាប់ បន្ទាប់ពីជនមិនស្គាល់មុខចំនួន ២ នាក់ បានបាញ់កាំភ្លើងសំដៅទៅរកលោក នៅក្នុងឃុំអូរសំរី ខេត្តបាត់ដំបង។ ប៉ុន្តែ ២ ឬ ៣ ថ្ងៃក្រោយមក លោក ពេជ្រ សុផុន ដែលជាអ្នកតំណាងសហគមន៍ដូចគ្នានឹងលោក ស៊ិម ម៉ី ត្រូវបានគេបាញ់សម្លាប់ (សូមមើលករណីសិក្សាខាងក្រោម)។[១៤]

ពីរថ្ងៃក្រោយមក នៅខេត្តបន្ទាយមានជ័យ អ្នកស្រី នី ឡេង និងស្វាមីរបស់អ្នកស្រី ឈ្មោះ អ៊ិម គឹមសាន ដែលអ្នកទាំងពីរជាសកម្មជនសហគមន៍ ត្រូវបានមនុស្សមួយក្រុមដឹកនាំដោយ ស៊ា ហ៊ុយ ជាប្រធានភូមិសន្តិភាពធ្វើការវាយប្រហារដោយហិង្សា។ អ្នកស្រី នី ឡេង បានចូលរួមក្នុងការការពារសិទ្ធិដីធ្លីរបស់អ្នកភូមិក្រោយពី ស៊ា ហ៊ុយ ដែលជាប្រធានភូមិ បានកំទេច និងដុតបំផ្លាញផ្ទះសម្បែង ដើម្បីប៉ុនប៉ងរឹបអូសយកដីភូមិទាំងនោះ។[១៥]

នៅថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០១១ ខ្មាន់កាំភ្លើងម្នាក់មិនស្គាល់អត្តសញ្ញាណបានបាញ់ចំនួន ៨ដងសំដៅផ្ទះរបស់លោក នេត សួង ជាសកម្មជនអភិរក្សធនធានជលផលនៅភូមិតាអ៊ុងខេត្តកោះកុង។ លោក សួង បានធ្វើសកម្មភាពយ៉ាងសកម្មក្នុងការផ្សព្វផ្សាយព័ត៌មានអំពីអភិរក្សជលផលក្នុងចំណោមអ្នកភូមិទាំងឡាយ។

នៅក្នុងឧប្បត្តិហេតុស្រដៀងគ្នាមួយនាថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១១ ខ្មាន់កាំភ្លើងម្នាក់ទៀតមិនស្គាល់អត្តសញ្ញាណ បានបាញ់សំដៅទៅលើផ្ទះរបស់លោក គុន អេង ជាសកម្មជនការពារសិទ្ធិដីធ្លីនៅឃុំត្បែងខេត្តសៀមរាប។ តែសំណាងល្អគាត់ និងប្រពន្ធរបស់គាត់ ព្រមទាំងកូនស្រីអាយុ ៨ ខែម្នាក់មិនបានទទួលរងរបួស។ ក្រោយមកគ្រួសារនេះ បានចាកចេញពីផ្ទះដើម្បីគេចខ្លួន ដោយសារភ័យខ្លាចពីសុវត្ថិភាពផ្ទាល់ខ្លួនរបស់ពួកគេ។ មិនយូរប៉ុន្មានមុនពេលឧប្បត្តិហេតុនេះកើតឡើងលោក គុន អេង បាននិយាយមិនសំចៃជាសាធារណៈអំពីផែនការរដ្ឋបាលព្រៃឈើ ដែលអាចបង្កផលប៉ះពាល់ដល់ប្រជាពលរដ្ឋក្នុងឃុំរបស់គាត់ចំនួន ១០៥ គ្រួសារ។

នៅក្នុងខែមេសា ឆ្នាំ២០១២ អ្នកស្រី រស់ បុប្ផា ជាសកម្មជនសហគមន៍ផ្លូវរទេះភ្លើង បានភៀសខ្លួនចេញពីផ្ទះសម្បែង បន្ទាប់ពីគាត់បានដឹកនាំសហគមន៍ធ្វើការតវ៉ាទាក់ទងនឹងលក្ខខ័ណ្ឌរស់នៅរបស់ពួកគេនៅតំបន់តាំងទីលំនៅថ្មីក្នុងភូមិត្រពាំងអញ្ចាញ។[១៦] បុប្ផា ត្រូវបានគេបណ្តេញចេញជាមួយប្រជា

---

[១៤] របាយការណ៍ឃ្លាំមើលសិទ្ធិមនុស្សរបស់អង្គការលីកាដូ ដែលមិនទាន់ផ្សព្វផ្សាយ BB029AK10។

[១៥] របាយការណ៍ឃ្លាំមើលសិទ្ធិមនុស្សរបស់អង្គការលីកាដូ ដែលមិនទាន់ផ្សព្វផ្សាយ BM055AK10។

[១៦] សេចក្តីប្រកាសព័ត៌មានរបស់អង្គការលីកាដូ "ការវាយប្រហារដោយហិង្សាពីអាជ្ញាធរទៅលើអ្នករស់នៅតំបន់តាំងទីលំនៅថ្មី រថភ្លើង" ថ្ងៃទី៦ ខែមេសា ឆ្នាំ ២០១២ សូមមើល http://www.licadho-cambodia.org/pressrelease.php?perm=274។ សូមមើលផងដែរ: ឯកសារអង្គការលើកលែងទោសអន្តរជាតិ "ស្ត្រីខ្មែរ

ពលរដ្ឋរាប់រយគ្រួសារផ្សេងទៀត ចេញពីផ្ទះចាស់របស់នាងស្ថិតនៅតាមបណ្ដោយផ្លូវរទេះភ្លើងនៅក្នុងរាជធានីភ្នំពេញ។ ផ្លូវរទេះភ្លើងរបស់ប្រទេសកម្ពុជាបច្ចុប្បន្ន កំពុងត្រូវបានជួសជុលឡើងវិញ ដែលបណ្ដាលឲ្យមានការបណ្ដេញប្រជាពលរដ្ឋរាប់ពាន់គ្រួសារចេញពីលំនៅដ្ឋាន។

អ្នកស្រី រស់ បុប្ផា និងអ្នកតំណាងសហគមន៍ដ៏ទៃទៀត បានដាក់ពាក្យបណ្ដឹងតវ៉ា អំពីស្ថានភាពរស់នៅមិនសមរម្យនៅឯតំបន់តាំងទីលំនៅថ្មីនៅភូមិត្រពាំងអញ្ចាញ ទៅធានាគារអភិវឌ្ឍន៍អាស៊ី (ADB) ដែលជាម្ចាស់ជំនួយមូលនិធិ សម្រាប់គម្រោងស្ដារផ្លូវដែកឡើងវិញនៅកម្ពុជា។ ពីរថ្ងៃក្រោយមក លោក ចាន់ ស៊ីដារ៉ា មេភូមិបានដឹកនាំអ្នកភូមិ ហើយនឹងឆ្មាំសន្តិសុខប្រមាណ ៤០ នាក់ ដើម្បីវាយប្រហារទៅលើក្រុមគ្រួសារប្រជាពលរដ្ឋសហគមន៍ផ្លូវរទេះភ្លើង ដែលទើបតែមកដល់ថ្មី ដោយប្រើប្រាស់ដំបងឆក់ កាំបិត ដំបង ព្រមទាំងគប់ដុំឥដ្ឋ និងដុំថ្មទៅលើពួកគេទៀតផង។ មន្ត្រីនគរបាលបានឈរមើលការវាយប្រហារនេះ ដោយពុំបានធ្វើកិច្ចអន្តរាគមន៍សោះឡើយ។ ក្នុងអំឡុងពេលធ្វើការវាយប្រហារ លោកប្រធានភូមិ ចាន់ ស៊ីដារ៉ា បានចូលទៅក្នុងផ្ទះរបស់ បុប្ផា ដោយកាន់កាំភ្លើង និងស្រែកគម្រាម ប៉ុន្តែពេលនោះ អ្នកស្រីបានគេចខ្លួនរួចបាត់ទៅហើយ។ នៅថ្ងៃទី ១០ ខែមេសា រស់ បុប្ផា ត្រូវបានគេគម្រាមចាប់ខ្លួនម្ដងទៀត ហើយអ្នកស្រីក្លាយជាជនរងគ្រោះពីការវាយប្រហារនេះ ដោយសារតែប្រធានភូមិ ហើយនឹងអ្នកគាំទ្ររបស់គាត់ បានមកប្រមូលផ្ដុំនៅមុខផ្ទះរបស់អ្នកស្រីនៅពេលយប់។ ពួកគេបានទទួលទានស្រា ហើយពួកគេគប់ដុំថ្ម និងស្រែកកំហោកដាក់អ្នកស្រី។ ទីបំផុត ដោយការកើនឡើងនូវការគំរាមកំហែង ព្រមទាំងការបំពារបំពានទាំងនេះ បានបង្ខំឲ្យ រស់ បុប្ផា ភាសខ្លួនចេញពីសហគមន៍។

## ករណីសិក្សា: ការធ្វើឃាតទៅលើសកម្មជនការពារសិទ្ធិដីធ្លី លោក ពេជ្រ សុផុន ក្នុងខេត្តបាត់ដំបង[១៧]

នៅថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១០ លោក ពេជ្រ សុផុន អាយុ ៥៩ឆ្នាំ បានស្លាប់នៅមុខផ្ទះរបស់លោក បន្ទាប់ពីត្រូវជនប្រដាប់អាវុធមិនស្គាល់មុខចំនួន ៣ នាក់បានបាញ់ចំនួន ៨គ្រាប់។ តាមសេចក្ដីរាយការណ៍ ពេជ្រ សុផុន បានដើរតួជាអ្នកតំណាងសហគមន៍មួយរូបក្នុងជម្លោះដីធ្លីមួយ រវាងភូមិរបស់លោក កងយោធពលខេមរភូមិន្ទ និងក្រុមហ៊ុនកូរ៉េខាងត្បូង។ លោក សុផុន បានរស់នៅភូមិចម្លងរមាំងលើ ឃុំសម្រែ ស្រុកសំឡូតខេត្តបាត់ដំបង។

នៅដើមខែមេសា លោក ស៊ិម ម៉ី ជាតំណាងសហគមន៍ដូចគ្នារបស់ ពេជ្រ សុផុន បានទទួលរងរបួសដោយសារការបាញ់ប្រហារពីខ្មាន់កាំភ្លើង ២ នាក់បានបាញ់ទៅលើលោក។ ឆ្លើយតបទៅនឹងការ

ត្រូវគេគំរាមសម្លាប់: រស់ បុប្ផា” ថ្ងៃទី១៣ ខែមេសា ឆ្នាំ២០១២ សូមមើល: http://www.amnesty.org/en/library/asset/ASA23/005/2012/en/cbb1b531-b422-45d3-9e3f-89099e50fab5/asa230052012en.html។

[១៧] របាយការណ៍ឃ្លាំមើលសិទ្ធិមនុស្សរបស់អង្គការលីកាដូ ដែលមិនបានផ្សព្វផ្សាយ BB035K10។ សូមមើលផងដែររបាយការណ៍អង្គការលីកាដូ "សិទ្ធិសេរីភាពក្នុងការបញ្ចេញមតិនៅប្រទេសកម្ពុជា: ការបំភ័ន្តលទ្ធិប្រជាធិបតេយ្យ" ខែធ្នូ ឆ្នាំ២០១០ ករណីសិក្សាទី២៦។

ប៉ុនប៉ងធ្វើឃាតនេះ លោក សុផុន បានសម្រេចដាក់ពាក្យ បណ្តឹងក្នុងរឿងព្រហ្មទណ្ឌទៅអាជ្ញាធរខេត្ត ប្រឆាំងនឹងក្រុមហ៊ុន និងកងយោធពលខេមរភូមិន្ទ។ នៅថ្ងៃធ្វើឃាត លោកកំពុងតែធ្វើដំណើរត្រឡប់មកផ្ទះវិញបន្ទាប់ពីដើរប្រមូលស្នាមមេដៃពីអ្នកភូមិរបស់លោកដើម្បីដាក់ពាក្យបណ្តឹង។ ◄◄

---

## សេចក្តីពិពណ៌នា: លោក ឈុត វុទ្ធី ជាសកម្មជនការពារព្រៃឈើដ៏សំខាន់មួយរូបរបស់ប្រទេសកម្ពុជា ត្រូវបានបាញ់សម្លាប់ នៅខណៈកំពុងធ្វើការស៊ើបអង្កេតទៅលើអាជីវកម្មកាប់ឈើខុសច្បាប់។

"យោងតាមច្បាប់ ប្រជាពលរដ្ឋដែលរស់នៅជុំវិញព្រៃឈើមានសិទ្ធិអាស្រ័យផលនូវអនុផលពីព្រៃឈើ។ ពួកគេមានសិទ្ធិប្រើប្រាស់ឈើពីព្រៃឈើ ដើម្បីសាងសង់ផ្ទះសំបែងរបស់ពួកគេ។ សិទ្ធិអាស្រ័យផលនេះ គឺត្រូវបានគេបដិសេធ "ខ្ញុំយល់ថា បើខ្ញុំមិនជួយពួកគេទេ គ្មានអ្នកណានឹងជួយ" អាជ្ញាធរភាគច្រើនផ្សេងទៀតគ្រាន់តែចង់បានមុខតំណែងជាន់ខ្ពស់ ដើម្បីបានទទួលបានលាភសក្ការៈតែប៉ុណ្ណោះ៖ ដើម្បីរកលុយឲ្យបានកាន់តែច្រើន ទោះជាប៉ះពាល់ដល់អ្នកដទៃក៏ដោយ"។

## ការតស៊ូរបស់លោក ឈុត វុទ្ធី

លោក ឈុត វុទ្ធី ជាសកម្មជនបរិស្ថាន ដែលត្រូវបានគេទទួលស្គាល់បំផុតនៅប្រទេសកម្ពុជា។ លោកជាអ្នកបង្កើត និងជាប្រធានក្រុមការពារធនធានធម្មជាតិ ហើយបានបូជាជីវិតដើម្បីតស៊ូប្រឆាំងនឹងអាជីវកម្មកាប់ឈើ និងការបំផ្លិចបំផ្លាញព្រៃឈើខុសច្បាប់នៅក្នុងតំបន់ការពារនៅកម្ពុជា។ លោក ឈុត វុទ្ធី គឺជាមនុស្សតែម្នាក់ ដែលអ្នកហ៊ាននិយាយឥតសំចៃអំពីតួនាទី ដែលយោធាបានបំពេញក្នុងការសម្របសម្រួលឲ្យមានអាជីវកម្មព្រៃឈើខុសច្បាប់ ដែលប្រព្រឹត្តដោយក្រុមហ៊ុនទាំងឡាយ ដែលបានទទួលដី សម្បទានសម្រាប់គោលបំណងផ្សេងៗ។ លោក វុទ្ធី បានដើរតួនាទីមួយយ៉ាងសំខាន់ក្នុងការញ៉ាំងឲ្យប្រជាពលរដ្ឋចេះធ្វើការតវ៉ាទៅនឹងការកេងប្រវ័ញ្ច និងការអភិវឌ្ឍន៍ ដែលមិនត្រឹមត្រូវនៅទូទាំងប្រទេសកម្ពុជា។

លោក វុទ្ធី កើតនៅភូមិមាស ឃុំវិហារសួគ៌ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល មានតួនាទីជាទាហានមួយរូបរហូតដល់ថ្ងៃដែលលោកទទួលមរណៈភាព បន្ទាប់ពីលោកទទួលបានបរិញ្ញាបត្រជាន់ខ្ពស់ពីការសិក្សានៅប្រទេសរុស្ស៊ី។ លោកបានបំពេញការងារនៅមជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា ហើយធ្វើការជាមន្ត្រីយោធាមួយរូប ដែលធ្លាប់បានទទួលការបណ្តុះបណ្តាលនៅក្រសួងការពារជាតិ។ ក្រោយមក លោកបានក្លាយជានាយករងអង្គការ Global Witness ជាអង្គការមិនមែនរដ្ឋាភិបាលមួយរបស់ប្រទេសអង់គ្លេសទទួលបន្ទុកឃ្លាំមើលបរិស្ថាន។ បន្ទាប់ពីអង្គការ Global Witness ត្រូវបានរដ្ឋាភិបាលកម្ពុជាបណ្តេញចេញពីប្រទេសកម្ពុជា លោកក៏បានបង្កើតក្រុមការពារធនធានធម្មជាតិមួយ។

លោកបានធ្វើសកម្មភាពនៅជួរភ្នំក្រវាញ និងនៅតំបន់ព្រៃឡង់។ នៅឆ្នាំ២០១១ លោកបានដើរតួនាទីជាគន្លឹះមួយក្នុងការជួយគាំទ្រដល់បណ្តាញសហគមន៍ព្រៃឡង់ ដែលជាចលនាសហគមន៍មូលដ្ឋានមួយចូលរួមជាមួយសហគមន៍ផ្សេងៗមកពីខេត្តបួនផ្សេងៗគ្នា ដែលរស់នៅពឹងផ្អែកទៅលើព្រៃឈើសម្រាប់ជីវភាពរស់នៅរបស់ពួកគេ។

មុនពេលមរណៈភាព លោក គឺជាជនរងគ្រោះពីការគំរាមកំហែង និងការបំភិតបំភ័យជាច្រើនលើក។ នៅក្នុងខែកញ្ញា ឆ្នាំ២០១១ លោក ឈុត វុទ្ធី ត្រូវបានចាប់ខ្លួន ហើយត្រូវបានហាមប្រាមមិនឲ្យរៀបចំបើកវគ្គបណ្តុះបណ្តាលស្តីពីច្បាប់ព្រៃឈើ និងភូមិបាលនៅក្នុងឃុំមានរិទ្ធិ ស្រុកសណ្តាន់ ខេត្តកំពង់ធំ។ បន្ទាប់មក នៅខែវិច្ឆិកា ឆ្នាំ២០១១ លោកក៏ត្រូវបានគេគំរាមចាប់ខ្លួនទាក់ទងទៅនឹងការដើរល្បាតឃ្លាំមើលព្រៃឈើដោយអហិង្សា ដែលដឹកនាំដោយសហគមន៍នៅក្នុងព្រៃឡង់ ដើម្បីទប់ស្កាត់ការធ្វើអាជីវកម្មព្រៃឈើខុសច្បាប់ និងពិនិត្យមើលក្រុមហ៊ុនសម្បទានចំការកៅស៊ូវៀតណាម ឈ្មោះ CRCK។ លោក ត្រូវបានមន្ត្រីយោធាម្នាក់ចាប់ក្របួចកលោកពីក្រោយ និងចាប់បោក រីឯមន្ត្រីនគរបាលម្នាក់ទៀតភ្ជង់លោកនឹងកាំភ្លើង AK-47 ។ ទោះបីយ៉ាងណាក៏ដោយ ការគំរាមកំហែងទាំងនេះ មិនបានធ្វើឲ្យលោកបញ្ឈប់ភាពសកម្មនិយមរបស់លោកឡើយ។

## ការបាញ់សម្លាប់នៅក្នុងព្រៃ

នៅព្រឹកថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១២ លោក ឈុត វុទ្ធី បានធ្វើដំណើរអមដោយអ្នកសារព័ត៌មាន ២នាក់ មកពីកាសែត The Cambodia Daily ដែលធ្វើការស៊ើបអង្កេតអាជីវកម្មព្រៃឈើ និងប្រមូលផលវល្លិ៍ល្មៀតខុសច្បាប់នៅជួរភ្នំក្រវាញ។ នៅប្រហែលរសៀលថ្ងៃនោះ នៅក្នុងតំបន់ឫស្សីជ្រុំ អ្នកសារព័ត៌មានទាំងពីរ បានថតរូបភាពជាច្រើនប៉ុស្តិ៍នៅជិតអាងគម្រោងទំនប់វារីអគ្គិសនីឫស្សីជ្រុំលើ។ ភ្លាមៗនោះ មានក្រុមចម្រុះមួយក្រុម ដែលជាមន្ត្រីកងរាជអាវុធហត្ថ និងទាហាន ដែលដើរតួជាឆ្មាំសន្តិសុខរបស់ក្រុមហ៊ុន Timber Green បានរារាំងក្រុមអ្នកសារព័ត៌មានទាំងនោះ មិនឲ្យធ្វើការថតរូប។

ឆ្មាំសន្តិសុខព្យាយាមរឹបអូសយកសម្ភារៈថតសម្លេងទាំងអស់ពីអ្នកសារព័ត៌មានទាំងនោះ។ បន្ទាប់ពីអ្នកសារព័ត៌មានបានប្រគល់ម៉ាស៊ីនថតរបស់ពួកគេទៅឲ្យក្រុមអាជ្ញាធរចម្រុះ លោក ឈុត វុទ្ធី មិនព្រមប្រគល់មិមម៉ូរីកាតនៃម៉ាស៊ីនថត (Memory Card) របស់គាត់ទេ បន្ទាប់មក ក៏ផ្ទុះជម្លោះរវាងពាក្យសម្តីដាក់គ្នា។ បុគ្គលិកកងរាជអាវុធហត្ថប្រដាប់អាវុធជាច្រើនទៀតក៏បានមកដល់តំបន់នោះផងដែរ។ ស្ថានភាពនៅពេលនោះ មានសភាពកាន់តែធ្ងន់ធ្ងរឡើង ហើយនៅក្នុងរយៈពេលប្រហែលកន្លះម៉ោងកងរាជអាវុធហត្ថ និងទាហានប្រដាប់អាវុធបានចាប់ផ្តើមឡោមព័ទ្ធរថយន្តរបស់លោក។ លោក ត្រូវទទួលរងនូវការរំលោភបំពានខាងរាងកាយ និងពាក្យសម្តីមុនពេលដែលលោក ត្រូវបានគេបាញ់នឹង

កាំភ្លើងចំពោះ។ លោក អ៊ិន រតនា ដែលជាមន្ត្រីកងរាជអាវុធហត្ថមួយរូប ក៏ត្រូវបានគេបាញ់សម្លាប់នឹងកាំភ្លើង AK-47 នៅចំងាយជិតនោះផងដែរ។

អស់រយៈពេលជាច្រើនម៉ោង និងច្រើនថ្ងៃបន្ទាប់ពីមានការបាញ់សម្លាប់ អាជ្ញាធរក៏បានផ្តល់នូវសេចក្តីពន្យល់ផ្សេងៗដែលមិនស៊ីសង្វាក់គ្នាទាក់ទងនឹងការបាញ់សម្លាប់នេះ (ដែលសេចក្តីពន្យល់ទាំងអស់នេះមានភាពផ្ទុយគ្នាទៅនឹងភស្តុតាងដែលមានស្រាប់)។ ពីដំបូងអាជ្ញាធរបានអះអាងថា ការបាញ់ប្រហារគ្នាយ៉ាងខ្លាំងក្លាមួយជាមួយលោក ឈុត វុទ្ធី ដែលជាអ្នកបាញ់មុនគេ បានបណ្តាលឲ្យមនុស្ស ២ នាក់ស្លាប់ ទោះមានអង្គហេតុបង្ហាញថា អាវុធរបស់លោក ឈុត វុទ្ធីត្រូវបានគេរកឃើញរុំនឹងក្រណាត់ក្នុងហោប៉ៅរបស់លោកពុំឃើញមានគ្រាប់បាញ់ចេញក៏ដោយ។ ក្រោយមកពួកគេបានអះអាង ថាការស្លាប់មនុស្សទាំងពីរនាក់នេះ គឺបណ្តាលមកពីក្បាលគ្រាប់ផ្លាតត្រូវ ដោយចៃដន្យ ទោះមានអង្គហេតុបង្ហាញថា គន្លងគ្រាប់រត់ និងប្រភេទគ្រាប់បាញ់មិនមែនបណ្តាលមកពីក្បាលគ្រាប់ផ្លាតក៏ដោយ។ នៅទីបំផុតត្រូវបានគេលើកឡើងថា លោក អ៊ិន រតនា បានបាញ់សម្លាប់លោក ឈុត វុទ្ធី បន្ទាប់មកគាត់បានបង្វែរចុងកាណុងកាំភ្លើង AK-47 របស់គាត់មកចំរូបគាត់ដើម្បីធ្វើអត្តឃាត ដោយបាញ់ខ្លួនឯងចំនួនពីរគ្រាប់ដោយសារមានវិប្បដិសារី។ ក្រោយពីមានការរិះគន់យ៉ាងរាលដាលទៅលើសាច់រឿង ដែលមិនទំនងទាំងនេះ រាជរដ្ឋាភិបាលបានបង្កើតក្រុមស៊ើបអង្កេតមួយជាផ្លូវការ។ ក្រុមស៊ើបអង្កេតនេះ មានសមាសភាពមន្ត្រីថ្នាក់ខ្ពស់មួយចំនួនតូច ដែលមានទំនាក់ទំនងទៅនឹងគណបក្សកាន់អំណាច។ របាយការណ៍ក្រុមស៊ើបអង្កេតនេះ បានអះអាងថា លោក អ៊ិន រតនា គឺជាអ្នកបាញ់សម្លាប់លោក ឈុត វុទ្ធី ហើយបន្ទាប់មក គាត់ត្រូវបានស្លាប់ដោយសាររាលកៃកាំភ្លើងដោយចៃដន្យ នៅពេលដែលលោក រ៉ាន់ បូរ័ត្ន ជាឆ្មាំសន្តិសុខក្រុមហ៊ុនប៉ុនប៉ងដកហូតកាំភ្លើងពីគាត់។

ទោះបីយ៉ាងណាក៏ដោយ ការស៊ើបអង្កេតនេះ មិនបានពិនិត្យមើលព្រឹត្តិការណ៍នានាឲ្យបានគ្រប់ជ្រុងជ្រោយមុនពេលមរណៈភាពរបស់លោក ឈុត វុទ្ធី និងមន្ត្រីកងរាជអាវុធហត្ថ និងមិនបានពន្យល់ពីមូលហេតុ ដែលកងកំលាំងប្រដាប់អាវុធអាជ្ញាធរបានដើរតួជាឆ្មាំសន្តិសុខសម្រាប់ក្រុមហ៊ុនឯកជនឡើយ។ របាយការណ៍នេះ ក៏ខកខានផងដែរ ក្នុងការមិនបានលើកឡើងអំពីការអះអាងទាក់ទងនឹងសកម្មភាពខុសច្បាប់ធ្វើឡើងដោយក្រុមហ៊ុន Timber Green ដែលលោក ឈុត វុទ្ធី និងអ្នកសារព័ត៌មានកំពុងធ្វើការស៊ើបអង្កេត។

លោក រ៉ាន់ បូរ័ត្ន ត្រូវបានបើកសវនាការកាត់ទោសក្រោមការចោទប្រកាន់ពីបទមនុស្សឃាតដោយអចេតនា នៅថ្ងៃទី៥ ខែតុលា ឆ្នាំ២០១២។ នៅពេលកំពុងសវនាការពុំមានភស្តុតាងគួរឲ្យជឿជាក់ត្រូវបានលើកយកមកបង្ហាញ ដើម្បីគាំទ្រដល់ការសន្និដ្ឋានចុងក្រោយរបស់ក្រុមស៊ើបអង្កេតនោះទេ។ សាក្សីសំខាន់ៗភាគច្រើនក៏ពុំឃើញមានវត្តមាន (ប្រាកដណាស់មានតែបុគ្គលមួយរូបប៉ុណ្ណោះ ដែល

បានមកបង្ហាញខ្លួនផ្តល់សក្ខីកម្មនៅចំពោះមុខតុលាការ និងអះអាងថា ខ្លួនបានឃើញព្រឹត្តិការណ៍បាញ់សម្លាប់នេះទាំងអស់)។ ពុំឃើញមានភស្តុតាងរឹងមាំត្រូវបានលើកយកមកបង្ហាញ ទោះជាភស្តុតាងបែបណាក៏ដោយ។ ប្រការដែលគួរឲ្យព្រួយបារម្ភបំផុតនោះ គឺលោក រ៉ាន់ បូរ័ត្ន រឹតតែមិនអាចមានសមត្ថភាពខាងផ្លូវកាយ ដើម្បីធ្វើគ្រាប់តាមរបៀប ដែលគាត់បានលៃលកបាញ់លោក អ៊ិន រតនា ដោយចៃដន្យនាខណៈប៉ុនប៉ងដកហូតយកអាវុធពីលោក អ៊ិន រតនា ដែលបាញ់សម្លាប់លោក វុទ្ធី។ ទោះបីយ៉ាងណាក៏ដោយនៅថ្ងៃទី២២ ខែតុលា ឆ្នាំ២០១២ តុលាការបានកាត់ទោស និងផ្តន្ទាទោសលោក រ៉ាន់ បូរ័ត្ន ឲ្យជាប់ពន្ធនាគារចំនួន ២ ឆ្នាំ តែទោសនេះ ត្រូវព្យួររយៈពេលចំនួន ១៨ ខែ។

ដូច្នេះនៅទីបំផុតការបាញ់សម្លាប់សកម្មជនបរិស្ថានដ៏សំខាន់បំផុតម្នាក់នោះ ក្នុងចំណោមសកម្មជនទាំងឡាយរបស់ប្រទេសកម្ពុជា បានបណ្តាលឲ្យសមាជិកយោធាថ្នាក់ទាបម្នាក់ជាប់ពន្ធនាគារត្រឹមតែរយៈពេល ៦ ខែប៉ុណ្ណោះ ដែលសមាជិកយោធារូបនេះកំពុងធ្វើការបន្ទាប់បន្សំជាឆ្មាំសន្តិសុខសម្រាប់ក្រុមហ៊ុនឯកជនមួយ ដែលក្រុមហ៊ុននេះ ត្រូវបានគេចោទប្រកាន់ស្ទើតែគ្រប់ៗគ្នាពីបទរួមគំនិតក្នុងអាជីវកម្មកាប់ឈើខុសច្បាប់ ។

## ការបំភិតបំភ័យ និងការវាយប្រហារដោយអាជីកំបាំង នៅលើអ្នកការពារសិទ្ធិមនុស្ស

បន្ថែមទៅលើការបំភិតបំភ័យពីតុលាការ និងអំពើហិង្សា អាជ្ញាធរបានប្រើប្រាស់វិធីសាស្ត្រមិនសូវផ្ទាល់ផងដែរ ដើម្បីរារាំងការងារអ្នកការពារសិទ្ធិមនុស្សនៅចន្លោះឆ្នាំ២០១០ និងឆ្នាំ២០១២។ យុទ្ធសាស្ត្រទាំងនេះរាប់ទាំងការពិនិត្យចាប់ពិរុទ្ធប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន ការបិទអង្គការមិនមែនរដ្ឋាភិបាលមួយ ការបិទគេហទំព័រក្នុងប្រព័ន្ធអ៊ិនធឺណិតជាក់លាក់មួយចំនួន និងការបង្ក្រាបព្រះសង្ឃដែលធ្វើសកម្មភាពនយោបាយ។

## ការវាយប្រហារនៅលើសង្គមស៊ីវិល

នៅឆ្នាំ២០១១ លោក Surya Subedi អ្នករាយការណ៍ពិសេសអង្គការនៃសហប្រជាជាតិ ស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជាបានរាយការណ៍ថា "នៅក្នុងរយៈពេល ២ឆ្នាំ កន្លងទៅនេះ ក្រុមអ្នកការពារសិទ្ធិមនុស្ស និងអង្គការមិនមែនរដ្ឋាភិបាលផ្សេងៗ ដែលធ្វើការលើកស្ទួយ និងការពារសិទ្ធិលំនៅដ្ឋាន សិទ្ធិដីធ្លីរបស់ប្រជាពលរដ្ឋក្រីក្របំផុត ការអភិវឌ្ឍន៍ប្រកបដោយនិរន្តរ៍ ឬសិទ្ធិសេរីភាពតាមរដ្ឋធម្មនុញ្ញក្នុងការបញ្ចេញមតិ សិទ្ធិក្នុងការជួបប្រជុំ ព្រមទាំងសិទ្ធិខាងសារព័ត៌មាន ត្រូវទទួលរងនូវការរំខានយាយី និងការបំភិតបំភ័យតាមទម្រង់ផ្សេងៗកាន់តែច្រើនឡើង រាប់ទាំងការរឹតត្បិតទៅលើការធ្វើដំណើរ និងសេរីភាពខាងការជួបប្រជុំ ការគំរាមតាម ពាក្យសំដី ការគំរាមដាក់ពាក្យបណ្តឹង ព្រមទាំងក្នុងករណីខ្លះ ត្រូវទទួលរងនូវចំណាត់ការខាងព្រហ្មទណ្ឌ។ កិច្ចខំប្រឹងប្រែងរបស់ពួកអ្នកទាំងនោះដើម្បី

អប់រំ និងផ្ដល់យោបល់ដល់សហគមន៍មូលដ្ឋានអំពីសិទ្ធិស្របច្បាប់ និងរបៀបប្រើប្រាស់សិទ្ធិទាំងនេះដោយអហិង្សា តាមរយៈស្ថាប័នដែលមានស្រាប់ ត្រូវបានគេលាបពណ៌ថា ជា "ការញុះញង់" កាន់តែច្រើនឡើង និងត្រូវបានគេដាក់ឲ្យជាប់ពាក់ព័ន្ធក្នុងការប្រឆាំងខាងនយោបាយ"។[១៨] គោលគំនិតខាងលើនេះ ដែលចាត់ទុកការរិះគន់ជាការប្រឆាំងខាងនយោបាយ គឺមានគ្រោះថ្នាក់យ៉ាងធ្ងន់ធ្ងរដល់លទ្ធិប្រជាធិបតេយ្យនៅកម្ពុជា។

ជាពិសេសការវាយប្រហារទៅលើអង្គការមិនមែនរដ្ឋាភិបាល មានចំនួនយ៉ាងច្រើន នៅចន្លោះឆ្នាំ២០១០ និងឆ្នាំ២០១២។ អង្គការមិនមែនរដ្ឋាភិបាល ដែលបានជួបប្រជុំជាមួយសមាជិកសហគមន៍ត្រូវបានគេឆាឆៅបង្អាក់ សមាជិកបុគ្គលិកអង្គការមិនមែនរដ្ឋាភិបាល ត្រូវបានគេគំរាមចាត់វិធានការតាមផ្លូវតុលាការ គំរាមកំហែងដល់អាយុជីវិត ហើយសកម្មជនអង្គការមិនមែនរដ្ឋាភិបាល ត្រូវបានហាមឃាត់មិនឲ្យរៀបចំវគ្គបណ្ដុះបណ្ដាល ស្ដីពីសិទ្ធិការពារព្រៃឈើ និងដីធ្លី។ ឧ: នៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១២ អាជ្ញាធរមូលដ្ឋាននៅខេត្តរតនគីរី ដែលអមដំណើរការពារដោយមន្ត្រីនគរបាលបានឆាឆៅបន្ទច់បង្អាក់វគ្គបណ្ដុះបណ្ដាលមួយ ស្ដីពីសិទ្ធិដីធ្លី ដែលរៀបចំដោយអង្គការមិនមែនរដ្ឋាភិបាល គឺអង្គការអាដហុក និងមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា។[១៩] ឯកឧត្តម ណាប់ ប៊ុន ហេង ជាអភិបាលខេត្តរងបានព្យាយាមលើកយកសកម្មភាពមន្ត្រីនគរបាលមកសំអាង ដោយលើកឡើងថា អ្នករៀបចំខកខានមិនបានជូនដំណឹងដល់អាជ្ញាធរ។ ទោះបីយ៉ាងណាក៏ដោយ តាមមាត្រា ៣ នៃ**ច្បាប់ស្ដីពីការធ្វើបាតុកម្មដោយអហិង្សា** អ្នករៀបចំត្រូវបានដាក់ឲ្យរួចផុតពីលក្ខខ័ណ្ឌជូនដំណឹងសម្រាប់សកម្មភាពផ្សព្វផ្សាយអប់រំទាំងអស់ ដើម្បីផលប្រយោជន៍សង្គម។ ម្យ៉ាងវិញទៀត វគ្គបណ្ដុះបណ្ដាលនេះ បានរៀបចំឡើងក្នុងបរិវេណផ្ទះឯកជនមួយ ដែលធ្វើឲ្យការអះអាងពីអាជ្ញាធរ រឹតតែមានភាពមិនគួរឲ្យជឿថែមទៀត។

ទោះយ៉ាងណាក៏ដោយ ប្រហែលឧប្បត្តិហេតុដ៏ចម្រូងចម្រាសនេះ បានកើតឡើងនៅឆ្នាំ២០១១ នៅពេលរដ្ឋាភិបាលបានផ្អាកអង្គការមិនមែនរដ្ឋាភិបាលមួយមួយរយៈ ហៅថាសមាគមន៍ធាងត្នោត ដូចដែលបានរៀបរាប់ពិស្ដារក្នុងករណីសិក្សាខាងក្រោម។

[១៨] របាយការណ៍លោក Surya Subedi អ្នករាយការណ៍ពិសេស ស្ដីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា (ថ្ងៃទី២ ខែសីហា ឆ្នាំ២០១១) "ជំនួយបច្ចេកទេស និងការកសាងសមត្ថភាព" ក្រុមប្រឹក្សាសិទ្ធិមនុស្ស សម័យប្រជុំលើកទី១៨ ចំណុចរបៀបវារៈទី១០។

[១៩] កាសែត The Cambodia Daily ថ្ងៃទី២៧ - ២៨ ខែកក្កដា ឆ្នាំ២០១២ សូមមើលផងដែរ: ខ្សែវីដេអូមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា "នៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១២ អាជ្ញាធរ និងមន្ត្រីនគរបាលបានបន្ទច់ចង្អាក់វគ្គបណ្ដុះបណ្ដាល ដែលរៀបចំរួមគ្នាដោយមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា និងអង្គការអាដហុក" ថ្ងៃទី២ ខែសីហា ឆ្នាំ២០១២: http://www.youtube. com/watch?v=e37f00WTd24។

## ករណីសិក្សា: អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកមួយ ត្រូវបានផ្អាកមួយរយៈ បន្ទាប់ពីធ្វើការបោះពុម្ពផ្សាយរបាយការណ៍រិះគន់[២០]

នៅថ្ងៃទី៤ ខែសីហា ឆ្នាំ២០១១ ឯកឧត្តម នុត សាអាន ជារដ្ឋលេខាធិការក្រសួងមហាផ្ទៃ បានចេញលិខិតមួយច្បាប់ផ្ញើទៅសមាគមន៍ធាងត្នោត ដោយប្រកាសថា សកម្មភាពរបស់សមាគមនេះ ត្រូវតែព្យួររយៈពេល ៥ ខែ។ លិខិតនោះ មិនបានផ្តល់មូលដ្ឋានច្បាប់សម្រាប់ការព្យួរសកម្មភាពឡើយ។ សេចក្តីពន្យល់ដែលបានធ្វើឡើងនោះ ត្រឹមតែបង្ហាញថា សមាគមធាងត្នោតខកខានមិនបានកែសម្រួលរចនាសម្ព័ន្ធថ្នាក់ដឹកនាំ និងខកខានមិនបានធ្វើការកែសម្រួលលក្ខន្តិកៈរបស់ខ្លួន "យោងតាមសេចក្តីណែនាំរបស់មន្ទីរជំនាញ"។ កិច្ចខិតខំប្រឹងប្រែងរបស់សមាគមធាងត្នោត ដើម្បីធ្វើការបំភ្លឺមូលដ្ឋានច្បាប់សម្រាប់ការព្យួរសកម្មភាពពីក្រសួងមហាផ្ទៃ មិនបានទទួលការឆ្លើយតប។

ចំពោះបញ្ហាចម្រូងចម្រាសបែបនេះ ជារឿងសាមញ្ញទៅហើយសម្រាប់សមាគមធាងត្នោត ។ អង្គការមិនមែនរដ្ឋាភិបាលមួយនេះ ធ្វើការងារជាមួយសហគមន៍ជាយក្រុងក្រីក្រទាក់ទងនឹងសិទ្ធិលំនៅដ្ឋាន ព្រមទាំងសិទ្ធិដីធ្លី។ អតិថិជនភាគច្រើនរបស់ពួកគេបានទទួលរងផលប៉ះពាល់ពីការរឹបអូសដីធ្លី ដែលប្រព្រឹត្តដោយអាជ្ញាធរ ឬមនុស្សជិតស្និទ្ធរបស់អ្នកទាំងនោះ។ មិនយូរប៉ុន្មាន មុនពេលផ្អាកសកម្មភាពដោយបង្ខំ សមាគមធាងត្នោតបានបោះពុម្ពផ្សាយរបាយការណ៍មួយ ដែលបានប្រើប្រាស់ទិន្នន័យ ដែលអាចវាយតម្លៃជាសត្យានុម័តបាន ដើម្បីបង្ហាញថាគ្រួសារប្រជាពលរដ្ឋ ដែលត្រូវបានគេបណ្តេញចេញនៅពេលអនុវត្តគម្រោងស្តារផ្លូវរថភ្លើងឡើងវិញនៅក្នុងរាជធានីភ្នំពេញ ត្រូវបានគេផ្តល់សំណងដ៏តិចតួចបំផុត។ គម្រោងស្តារផ្លូវរថភ្លើងឡើងវិញនេះ ត្រូវបានផ្តល់មូលនិធិមួយផ្នែកពីធនាគារអភិវឌ្ឍន៍អាស៊ី (ADB)។

ក្រោយពីការព្យួរសកម្មភាពសមាគមធាងត្នោត ការតវ៉ាយ៉ាងខ្លាំងពីសង្គមស៊ីវិលបានកើតឡើងភ្លាមៗ។ រាជរដ្ឋាភិបាលបានឆ្លើយតបដោយបញ្ជាក់ថា ការព្យួរសកម្មភាពសមាគមធាងត្នោត គឺមានការទាក់ទងនឹងការចោទប្រកាន់ថា សមាគមនេះបាន "ញុះញង់" បណ្តាសហគមន៍ ដែលបានទទួលរងផលប៉ះពាល់ពីគម្រោងស្តារផ្លូវរថភ្លើងឡើងវិញ។ ក្រសួងមហាផ្ទៃក៏បានចេញលិខិតព្រមានជាផ្លូវការមួយច្បាប់ផងដែរដល់អង្គការចំនួន ២ ផ្សេងទៀត ដែលបានធ្វើការសិក្សាវាយតម្លៃទៅលើផលប៉ះពាល់ពីផែនការណ៍អភិវឌ្ឍន៍ផ្លូវរថភ្លើងនេះ។

---

[២០] សេចក្តីប្រកាសព័ត៌មានរបស់អង្គការលីកាដូ "យើងទាំងអស់គ្នាជាសមាគមន៍ធាងត្នោត: សង្គមស៊ីវិល និងបណ្តាក្រុមវិស័យឯកជនថ្កោលទោសទៅលើការព្យួរសកម្មភាពអង្គការក្រៅរដ្ឋាភិបាលនៅមូលដ្ឋានមួយតាមទំនើងចិត្តពីសំណាក់រដ្ឋាភិបាល" ថ្ងៃទី២១ ខែសីហា ឆ្នាំ២០១១: http://www.licadho-cambodia.org/pressrelease.php?perm=256។ សូមមើលផងដែរ: របាយការណ៍អង្គការលីកាដូ (ខែតុលា ឆ្នាំ២០១១) "ការបំភ័ន្តភាពជឿនលឿន: ការរំលោភបំពានពីអង្គនីតិបញ្ញត្តិរបស់ប្រទេសកម្ពុជាទៅលើសិទ្ធិសេរីភាពខាងការបញ្ចេញមតិ" សូមមើល: http://www.licadho-cambodia.org/reports/files/162LICADHOReport-LegislativeAssault Freedom Expression2011-English.pdf។

មូលហេតុពិត ដែលជំរុញដល់ការព្យួរសកម្មភាពនេះ ត្រូវបានបញ្ជាក់បន្ថែមនៅថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១១ នៅពេលដែលសេចក្តីរាយការណ៍ព័ត៌មានបានបង្ហើបឲ្យដឹងថា ឯកឧត្តមឧបនាយករដ្ឋមន្ត្រី គាត ឈុន បានសរសេរលិខិតមួយច្បាប់ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១ ផ្ញើជូនទៅសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន[២១]។ លិខិតនោះ និយាយយោងទៅរកសមាគមផាងត្នោត និងអង្គការស្ពានទៅកាន់សន្តិភាពកម្ពុជាដោយចំឈ្មោះ ហើយប្តឹងអង្គការមិនមែនរដ្ឋាភិបាលទាំងនេះ ពីបទរិះគន់ទៅលើគម្រោងអភិវឌ្ឍន៍ផ្លូវរថភ្លើង។ លិខិតនោះ ធ្វើការចោទប្រកាន់ "ជនបរទេសលួងខ្លៅដែលធ្វើការក្នុងអង្គការមិនមែនរដ្ឋាភិបាលទាំងនេះ" ពីបទញុះញង់ប្រជាពលរដ្ឋចំនួនប្រមាណ ៩,០០០ នាក់ ដែលទទួលរងផលប៉ះពាល់ពីគម្រោងផ្លូវរថភ្លើង។ ឯកឧត្តម គាត ឈុន បានមានប្រសាសន៍បន្ថែមដោយលើកអនុសាសន៍ថា ជនបរទេស ដែលកំពុងធ្វើការឲ្យអង្គការមិនមែនរដ្ឋាភិបាល ត្រូវហាមឃាត់មិនឲ្យបំពេញការងារតស៊ូមតិណាមួយនៅក្នុងប្រទេសកម្ពុជាឡើយ ហើយជំរុញឲ្យគណៈរដ្ឋមន្ត្រីពន្លឿនឲ្យបានឆាប់នូវការពិនិត្យរបស់ខ្លួនទៅលើសេចក្តីស្នើច្បាប់ស្តីពីការបង្កើតសមាគម និងអង្គការមិនមែនរដ្ឋាភិបាល។

ការព្យួរសកម្មភាពរបស់សមាគមន៍ផាងត្នោតត្រូវបានបញ្ចប់ទៅវិញក្នុងខែមករា ឆ្នាំ២០១១។◂◂

---

តួអង្គសង្គមស៊ីវិលដើរតួនាទីមួយយ៉ាងសំខាន់ ក្នុងការធ្វើឲ្យប្រសើរឡើងនូវសុខមាលភាពរបស់ប្រជាពលរដ្ឋខ្មែរតាមរយៈការឃ្លាំមើល ការអភិវឌ្ឍន៍សហគមន៍ ការកាត់បន្ថយភាពក្រីក្រ ជំនួយមនុស្សធម៌ ការសិក្សាស្រាវជ្រាវ និងការស៊ូមតិ។ ដើម្បីលើកកំពស់ការអភិវឌ្ឍន៍ស្មើភាព និងអភិបាលកិច្ចល្អ សង្គមស៊ីវិលមានសិទ្ធិ និងមានការទទួលខុសត្រូវក្នុងការបញ្ចេញមតិ នៅពេលដែលគម្រោងអភិវឌ្ឍន៍មានឥទ្ធិពលគ្រោះថ្នាក់ទៅលើប្រជាពលរដ្ឋងាយរងគ្រោះ។ ការតបតចំពោះការរិះគន់ទៅលើការអភិវឌ្ឍន៍ប្រកបដោយគ្រោះថ្នាក់ចូលជាការបំពារបំពានទៅលើសង្គមស៊ីវិលជាទូទៅ ហើយវាបញ្ជូនសារអវិជ្ជមានមួយដ៏ខ្លាំងដល់អ្នកការពារសិទ្ធិមនុស្ស។

នៅចន្លោះឆ្នាំ២០១០ និងឆ្នាំ២០១២ ជំហរសង្គមស៊ីវិលនៅកម្ពុជាបានជួបប្រទះនឹងស្ថានភាពកាន់តែតានតឹងឡើងៗ។ ការបិទសមាគមផាងត្នោតបណ្តោះអាសន្ន រំលេចឲ្យឃើញនូវភាពទន់ខ្សោយនេះ។ ការប្រើប្រាស់បច្ចេកទេសភាពផ្នែករដ្ឋបាល ដែលមិនច្បាស់លាស់ ដើម្បីព្យួរសកម្មភាពរបស់អង្គការមួយ គឺជាសញ្ញាមួយគួរឲ្យព្រួយបារម្ភយ៉ាងច្បាស់អំពីរបៀប ដែលរាជរដ្ឋាភិបាលកម្ពុជា មាននិន្នាការរឹតត្បិតសកម្មភាពរបស់អង្គការសង្គមស៊ីវិល ដែលធ្វើការតស៊ូមតិសម្រាប់សិទ្ធិរបស់ក្រុមមនុស្សរងគ្រោះនៅកម្ពុជា។ ម្យ៉ាងវិញទៀត ករណីសមាគមផាងត្នោតបានកើតឡើង នៅពេលដែល

---

[២១] សូមមើល: http://www.atimes.com/atimes/Southeast_Asia/MI20Ae02.html។

រដ្ឋាភិបាលកំពុងជំរុញឲ្យមានច្បាប់មួយស្ដីពីការបង្កើតសមាគម និងអង្គការមិនមែនរដ្ឋាភិបាល។ ការព្យួរសកម្មភាពរបស់សមាគមផាងត្នោត បានផ្ដល់កាលានុវត្តភាពដល់សង្គមស៊ីវិល ដើម្បីពិនិត្យមើលការត្រួតត្រារបស់រាជរដ្ឋាភិបាលនាពេលអនាគត ជាមុនទៅលើអង្គការ និងសមាគម ក្រោម**សេចក្ដីព្រាងច្បាប់ស្ដីពីការបង្កើតសមាគម និងអង្គការមិនមែនរដ្ឋាភិបាល**។

នៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១០ រាជរដ្ឋាភិបាលបានបញ្ចេញ**សេចក្ដីព្រាងច្បាប់លើកទីមួយ ស្ដីពីការបង្កើតសមាគម និងអង្គការមិនមែនរដ្ឋាភិបាល** នេះ។[២២] ក្រោយមក សេចក្ដីព្រាងច្បាប់ចំនួន ៣ បន្តបន្ទាប់ត្រូវបានលើកមកបង្ហាញសេចក្ដីព្រាងច្បាប់ទាំងអស់នេះ ត្រូវបានក្រុមសង្គមស៊ីវិលបរទេស និងក្នុងស្រុកធ្វើការរិះគន់យ៉ាងហ្មត់ចត់។ បញ្ហា ដែលមានការព្រួយបារម្ភបំផុតនោះ គឺលក្ខខ័ណ្ឌតម្រូវឲ្យសមាគម និងអង្គការមិនមែនរដ្ឋាភិបាលត្រូវតែធ្វើការចុះបញ្ជី ព្រមទាំងបទបញ្ញត្តិមិនច្បាស់លាស់ស្ដីពីការរំលាយអង្គការ និងសមាគមចោលដោយបង្ខំ។

នៅខែធ្នូ ឆ្នាំ២០១១ រដ្ឋាភិបាលបានបញ្ចេញសេចក្ដីព្រាងច្បាប់នេះលើកទី៤។ លក្ខខណ្ឌតម្រូវឲ្យធ្វើការចុះបញ្ជីត្រូវបានគេសម្រួល (ប៉ុន្តែចុងបញ្ចប់នៅតែចាំបាច់ដដែល) ហើយច្បាប់នេះនៅតែមានពាក្យពេចន៍មិនច្បាស់លាស់ និងស្រពិចស្រពិលដដែល ដោយផ្ដល់លទ្ធភាពដល់រាជរដ្ឋាភិបាល ដើម្បីកំណត់អង្គការមិនមែនរដ្ឋាភិបាល និងសមាគមជាគោលដៅ ដោយបញ្ជាឲ្យមានការបិទអង្គការទាំងនេះ ឬ បដិសេធមិនឲ្យពួកគេធ្វើការចុះបញ្ជី។

នៅទីបំផុត ដើម្បីឆ្លើយតបនឹងការរិះគន់យ៉ាងខ្លាំងពីសង្គមស៊ីវិល និងប្រទេសម្ចាស់ជំនួយមួយចំនួនអស់រយៈពេលពេញ ១ ឆ្នាំមក រាជរដ្ឋាភិបាលកម្ពុជាបានប្រកាសនៅថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១១ ថា ការប្រកាសឲ្យប្រើច្បាប់ស្ដីពីការបង្កើតសមាគម និងអង្គការមិនមែនរដ្ឋាភិបាលនេះ នឹងត្រូវព្យួរទុកសិនយ៉ាងតិចណាស់រហូតដល់ឆ្នាំ២០១៤។

## ការវាយប្រហារ និងការបំភិតបំភ័យទៅលើអ្នកសារព័ត៌មាន

អ្នកសារព័ត៌មានបានក្លាយជាជនរងគ្រោះ ដោយសារតែការបំភិតបំភ័យ ដែលមានការគាំទ្រពីអាជ្ញាធរមួយចំនួន។ មានករណីមួយចំនួននៅចន្លោះឆ្នាំ២០១០ និងឆ្នាំ២០១២ បង្ហាញឲ្យឃើញនូវភាព

---

[២២] របាយការណ៍សង្ខេបអង្គការលីកាដូ (ខែធ្នូ ឆ្នាំ២០១១) "សេចក្ដីព្រាងច្បាប់ស្ដីពីការបង្កើតសមាគម និងអង្គការមិនមែនរដ្ឋាភិបាល: សេចក្ដីស្នើមតិយោបល់ទៅលើសេចក្ដីព្រាងច្បាប់លើកទី៤" សូមមើល: http://www.licadho-cambodia.org/reports/_files/1632011_JointStatementanalysisOf4thdraft_LANGO.pdf។ សូមមើលផងដែរ: សេចក្ដីប្រកាសព័ត៌មានរបស់អង្គការលីកាដូ "កែសម្រួល ឬបោះបង់ចោលសេចក្ដីព្រាងច្បាប់ ស្ដីពីការបង្កើតសមាគម និងអង្គការមិនមែនរដ្ឋាភិបាល: ប្រទេសម្ចាស់ជំនួយត្រូវជម្រុញឲ្យមានការការពារសម្រាប់សង្គមស៊ីវិល" ថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១១ សូមមើល: http://www.licadho-cambodia.org/pressrelease. php?perm=266។

មិនចុះសម្រុងរវាងអាជ្ញាធរទៅលើវិជ្ជាជីវៈសារព័ត៌មាន ជាពិសេសនៅពេលអ្នកសារព័ត៌មានព្យាយាមបញ្ចេញឲ្យដឹងការពិតអំពីព្រឹត្តិការណ៍នានា ដែលអាចឆ្លុះបញ្ចាំងពីភាពអវិជ្ជមានរបស់អាជ្ញាធរ។

ព្រឹត្តិការណ៍គួរឲ្យតក់ស្លុតបំផុត បានកើតឡើងនៅក្នុងខែកញ្ញា ឆ្នាំ២០១២ នៅពេលលោក ហង្ស សេរីឧត្តម ជាអ្នកសារព័ត៌មាន ដែលហ៊ានជជីករឿងអាស្រូវម្នាក់ត្រូវបានគេធ្វើឃាត។[២៣] សាកសពរបស់លោក ដែលត្រូវបានគេវាយដំ និងកាប់យ៉ាងតិចណាស់ចំនួន ៦ ពូថៅ ត្រូវបានគេរកឃើញក្នុងឃ្លុបឡានរបស់លោក។ ការងាររបស់លោក គឺផ្តោតទៅលើផ្សាយបង្ហាញពីអាជីវកម្មកាប់ឈើ និងបទល្មើសព្រៃឈើខុសច្បាប់ ដែលមានការពាក់ព័ន្ធទៅនឹងមន្ត្រីមូលដ្ឋានមួយចំនួន។

នៅថ្ងៃទី១៤ ខែមករា ឆ្នាំ២០១២ មន្ត្រីនគរបាលបានឃាត់ខ្លួនអ្នកថតរូបម្នាក់ពី*កាសែតភ្នំពេញប៉ុស្តិ៍* ហើយលុបចោលរូបភាពចេញពីម៉ាស៊ីនថត ដែលថតបាននៅអំឡុងពេលបណ្តេញចេញមួយនៅសហគមន៍បឹងកក់។

នៅថ្ងៃទី២២ ខែមករា ឆ្នាំ២០១១ អ្នកសារព័ត៌មានចំនួន ៤ រូប ដែលមាន ឈ្មោះ ផាន់ អានណាវង់ សុខហេង ហៃ ស៊ីណា និងសុខ គុន ត្រូវបានគេរឹបអូសយកម៉ាស៊ីនថតសម្លេងរបស់ពួកគេនៅអំឡុងពេលសន្និសីទសារព័ត៌មានមួយ ដែលត្រូវបានរៀបចំឡើងដោយលោក សេង បូរ័ត្ន ជាអនុប្រធានអង្គភាពប្រឆាំងអំពើពុករលួយ។[២៤]

ឯកឧត្តម ឱម យិនទៀង ប្រធានអង្គភាពប្រឆាំងអំពើពុករលួយ បានបើកអង្គសន្និសីទដើម្បីធ្វើការរៀបរាប់ឲ្យបានពិស្តារ អំពីការស៊ើបអង្កេតរបស់អង្គភាពប្រឆាំងអំពើពុករលួយ និងការចាប់ខ្លួនលោក ម៉ឹក ដារ៉ា ជាមន្ត្រីប្រឆាំងគ្រឿងញៀនម្នាក់។ នៅអំឡុងពេលសួរសំណួរ និងចម្លើយបន្ទាប់ពីព្រឹត្តិការណ៍នោះ ឯកឧត្តម ឱម យិនទៀង បានឆ្លើយទៅនឹងសំណួរយ៉ាងច្រើន។ ការរឹបអូសយកម៉ាស៊ីនថតសម្លេងបានកើតឡើងក្រោយពីអ្នករាយការណ៍ព័ត៌មានពីកាសែត ឌឹ ខេមបូឌា ដេលី មួយរូបបានចោទសួរឯកឧត្តម ឱម យិនទៀង ប្រធានអង្គភាពប្រឆាំងអំពើពុករលួយ អំពីការស៊ើបអង្កេតរបស់ FBI ទៅលើការវាយប្រហារ ដោយគ្រាប់បែកដៃយ៉ាងសាហាវក្នុងឆ្នាំ១៩៩៧ នៅអំឡុងពេលប្រមូលផ្តុំដោយគណបក្សប្រឆាំង ដែលសម្លាប់ប្រជាពលរដ្ឋចំនួនយ៉ាងតិចណាស់ ១៦ នាក់ និងប្រជាពលរដ្ឋជាង ១០០ នាក់ផ្សេងទៀតត្រូវរងរបួស។

---

[២៣] សូមមើល: http://www.rfa.org/english/news/cambodia/journalist-09122012130944.html និងសូមមើល: http://cpj.org/2012/09/cambodian-journalist-found-dead-in-his-own-car.php។

[២៤] របាយការណ៍ឃ្លាំមើលសិទ្ធិមនុស្សរបស់អង្គការលីកាដូដែលមិនបានផ្សព្វផ្សាយ: PP011OFEA11។ សូមមើលផងដែរ របាយការណ៍របស់អង្គការលីកាដូ (ខែតុលា ឆ្នាំ២០១១) "ការបំភ័ន្តភាពជឿនលឿន: ការបំពារបំពានពីអង្គនីតិបញ្ញត្តិរបស់ប្រទេសកម្ពុជាទៅលើសិទ្ធិសេរីភាពខាងការបញ្ចេញមតិ" សូមមើល: http://www.licadho-cambodia.org/reports/files/ 162LICADHOReport-LegislativeAssaultFreedomExpression2011-English.pdf។

ឯកឧត្តម ឱម យ៉ិនទៀង បានឆ្លើយថា "កុំរុញខ្ញុំចូលអន្ទាក់ អ្នកបានដឹងអំពីរបាយការណ៍របស់ FBI ច្រើនប៉ុណ្ណា។ អ្នកជាកូនខ្មែរមួយរូប មានឈាមជ័រជាខ្មែរ ហើយអ្នកបានថតយកសម្លេងខ្ញុំ ដោយគ្មានការអនុញ្ញាត"។ ឯកឧត្តម ឱម យ៉ិនទៀង បានមានប្រសាសន៍បន្ថែមថា អ្នករាយការណ៍ព័ត៌មាននេះ អាចប្រឈមនឹងការដាក់ពាក្យបណ្តឹងទៅតុលាការ មុនពេលម៉ាស៊ីនថតសម្លេងត្រូវបានរឹបអូស ហើយព័ត៌មានដែលថតបានពីសំណួរ និងចម្លើយត្រូវបានលុបចោល។

បន្ទាប់ពីក្លឹបអ្នកសារព័ត៌មានបរទេសនៃកម្ពុជា (Overseas Press Club of Cambodia) បានធ្វើការរិះគន់ទៅលើការរឹបអូសយកម៉ាស៊ីនថតសម្លេង អ្នកនាំពាក្យគណៈរដ្ឋមន្ត្រី បានព្យាយាមលើកយកឧប្បត្តិហេតុនោះមកសំអាង ដោយហៅសំណួរនោះថាជា "ការជេរប្រមាថ"។

អ្នកសារព័ត៌មាន មានការទទួលខុសត្រូវ ក្នុងការទទួលបានព័ត៌មានតាមវិធីសាស្ត្រត្រឹមត្រូវ ដែលរាប់បញ្ចូលទាំងការចោទសួរមន្ត្រីសារធារណៈនូវសំណួរ ដែលមានការចាប់អារម្មណ៍នៅអំឡុងពេលសន្និសីទសារព័ត៌មាន។ អ្នកសារព័ត៌មាន ដែលធ្វើការស៊ើបអង្កេត ដើម្បីបញ្ចេញឲ្យដឹងនូវការបំពារបំពានទៅលើប្រជាពលរដ្ឋខ្មែរ មិនត្រូវបានគេគំរាមចោទប្រកាន់ក្នុងរឿងព្រហ្មទណ្ឌ ហើយនឹងសម្ភារៈរបស់ពួកគេ ក៏មិនត្រូវបានគេរឹបអូសយកដែរ។ ការរឹបអូសយកខ្សែអាត់ និងម៉ាស៊ីនថតសម្លេង គឺជាការត្រួតពិនិត្យចាប់ពិរុទ្ធមួយបែបមុនពេលបោះពុម្ពផ្សាយ ដែលត្រូវបានហាមឃាត់តាមមាត្រា ៣ នៃច្បាប់ស្តីពីរបបសារព័ត៌មាន ឆ្នាំ១៩៩៥។

វិធានការរដ្ឋបាល ត្រូវបានគេយកមកប្រើផងដែរ ដើម្បីប្រឆាំងនឹងប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន។ នៅក្នុងខែសីហា ឆ្នាំ២០១១ ក្រសួងព័ត៌មានបានលុបចោលអាជ្ញាប័ណ្ណកាសែតចំនួន ២ ដែលជាកម្មសិទ្ធិរបស់អ្នកបោះពុម្ពផ្សាយម្នាស់តែមួយ កាសែតទាំងនោះ គឺកាសែតទឹក និងភ្លើង ព្រមទាំងកាសែតពិភពលោក[២៥] *(The Water and Fire News and The World News)*។ ឯកឧត្តម ខៀវ កញ្ញារិទ្ធ រដ្ឋមន្ត្រីក្រសួងព័ត៌មានបាន ចុះហត្ថលេខាលើសេចក្តីជូនដំណឹង ដោយគូសបញ្ជាក់ពីសេចក្តីសម្រេចនេះ។ ដូចគ្នាទៅនឹងករណីសមាគមជាងត្នោតដែរ ក្រសួងនេះ បានលើកយកការបិទនេះ មកសំអាងជាមួយនឹងបច្ចេកទេសខាងរដ្ឋបាលមិនច្បាស់លាស់។ យោងតាម លោក កែវ អំណាត់សាខែម ជានាយកកាសែតទាំងនេះ ការបោះពុម្ពផ្សាយ គឺមានឯករាជ្យភាពខាងនយោបាយ ប៉ុន្តែមិនខ្លាចនឹងធ្វើការរិះគន់ទៅលើគណបក្សកាន់អំណាចឡើយ។

---

[២៥] សេចក្តីប្រកាសព័ត៌មានរបស់អ្នកការពារសិទ្ធិមនុស្សនៃមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា៖ "បាវចនាកាសែត ដែលកត់សម្គាល់ផ្ទៃដីកម្ពុជា ចាត់ទុកជា 'ការជេរប្រមាថ' កាសែតចំនួន ២ ត្រូវបានបិទ" ថ្ងៃទី៨ ខែសីហា ឆ្នាំ២០១១ សូមមើល: http://www.cchrcambodia.org/ indexold.php?url=media/ media.php&p=alert_detail.php&alid=3&id=5។

## ករណីសិក្សា: កាសែតខ្មែរម្ចាស់ស្រុក និងតម្លៃនៃការរិះគន់ទៅលើរដ្ឋាភិបាល[២៦]

នៅថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០០៩ លោក ហង្ស ចក្រា និពន្ធនាយកកាសែតខ្មែរប្រឆាំងដ៏សំខាន់មួយរូប ត្រូវបានឃុំខ្លួនក្នុងពន្ធនាគារពីបទផ្សាយព័ត៌មានមិនពិត បន្ទាប់ពីបានបោះពុម្ពផ្សាយអត្ថបទមួយ ដោយធ្វើការចោទប្រកាន់មន្ត្រីដែលស្និទ្ធនឹងឧបនាយករដ្ឋមន្ត្រី សុខ អាន ពីបទប្រព្រឹត្តិអំពើពុករលួយ។

នៅថ្ងៃទី១៣ ខែមេសា ឆ្នាំ២០១០ លោក ហង្ស ចក្រា ត្រូវបានដោះលែងពីពន្ធនាគារឲ្យមានសេរីភាពវិញ ក្រោយពីមានការលើកលែងទោសពីព្រះមហាក្សត្រ ហើយលោកសន្យាថានឹងបន្តធ្វើការរិះគន់រដ្ឋាភិបាល។ ទោះយ៉ាងណាក៏ដោយ នៅពេលជាមួយគ្នានោះ អ្នកសារព័ត៌មានខ្មែរម្ចាស់ស្រុកបានបន្ថយការរិះគន់ទៅលើរដ្ឋាភិបាល ក្រោយពីមានការចាប់ខ្លួនលោក ហង្ស ចក្រា ដោយសារពួកគេខ្លាចថានឹងមានការចាប់ខ្លួន។ ការលក់ក៏មានការធ្លាក់ចុះដោយសារផលវិបាកនេះ។

នៅអំឡុងពេលធ្វើកិច្ចសម្ភាសន៍ជាមួយអង្គការលីកាដូ ក្នុងខែកក្កដា ឆ្នាំ២០១០ លោក ហង្ស ចក្រា បាននិយាយថា កាសែតរបស់លោកប្រឈមនឹងផលវិបាកខាងហិរញ្ញវត្ថុ ដោយសារអ្នកឃោសនាទំនិញ និងអ្នកធានាទទួលរងនូវការបំភិតបំភ័យពីសំណាក់រដ្ឋាភិបាល។ នៅទីបំផុតកាសែតនេះបានបញ្ឈប់ការបោះពុម្ពផ្សាយ ដោយសារតែខ្វះខាតមូលនិធិ។ ◄◄

---

## ការគំរាមកំហែងទាក់ទងនឹងប្រព័ន្ធអ៊ីនធឺណិត

**ច្បាប់ស្តីពីការគ្រប់គ្រងប្រព័ន្ធអ៊ីនធឺណេត** ជាពាក្យចចាមអារាម ដែលមានយូរលង់ណាស់មកហើយ គឺជាប្រភពសក្តានុពលនៃសេចក្តីកង្វល់មួយផ្សេងទៀត ពីព្រោះអ្នកការពារសិទ្ធិមនុស្សកំពុងតែមានការពឹងផ្អែកច្រើនឡើងទៅលើប្រព័ន្ធអ៊ីនធឺណិត ដើម្បីធ្វើការទំនាក់ទំនងផ្សព្វផ្សាយព័ត៌មាន ហើយនឹងធ្វើការតស៊ូមតិសម្រាប់បុព្វហេតុរបស់ពួកគេ។ ថ្វីបើ រដ្ឋាភិបាលគ្រប់គ្រងបណ្តាញប្រព័ន្ធផ្សព្វផ្សាយព័ត៌មានមិនសូវជាតឹងរឹងក៏ដោយ ក៏ប្រព័ន្ធអ៊ិនធឺណិតនៅកម្ពុជានៅតែបើកចំហរហូតមកទល់បច្ចុប្បន្ន។ នេះទំនងដោយសារតែមានអត្រាប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិតនៅទាប។ គិតមកត្រឹមចុងឆ្នាំ២០០៩ ប្រជាពលរដ្ឋខ្មែរមានចំនួនតិចជាង ០.៥% ជាអ្នកប្រើប្រាស់ប្រព័ន្ធអ៊ិនធឺណិត។[២៧] បច្ចុប្បន្នតួលេខនេះ

---

[២៦] របាយការណ៍របស់អង្គការលីកាដូ (ខែធ្នូ ឆ្នាំ២០១០) "សិទ្ធិសេរីភាពខាងការបញ្ចេញមតិនៅកម្ពុជា: ការបំភ័ន្តលទ្ធិប្រជាធិបតេយ្យ" សូមមើល: http://www.licadho-cambodia.org/reports/files/ 148LICADHOIllusion Democracy2010.pdf ។

[២៧] ធនាគារពិភពលោក "វិស័យព័ត៌មានវិទ្យាក្នុងមួយប្រព្រិចភ្នែក (ICT At-a-glance)": ប្រទេសកម្ពុជា សូមមើល: http://www.google.com/search?client=safari&rls=en&q= world+bank+cambodia+Internet+use&ie=UTF-8&oe=UTF-8 ។

បានកើនឡើងប្រហែល ៣%។ ហើយដោយសារតែមានប្រជាពលរដ្ឋខ្មែរកាន់តែច្រើនប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិត រដ្ឋាភិបាលកំពុងតែបង្ហាញការចាប់អារម្មណ៍ក្នុងការធ្វើច្បាប់ (ហើយនឹងត្រួតពិនិត្យចាប់ពិរុទ្ធ) នូវប្រព័ន្ធអ៊ីនធឺណិត។

រាជរដ្ឋាភិបាលអះអាងថា ច្បាប់គ្រប់គ្រងប្រព័ន្ធអ៊ីនធឺណិត គឺមានលក្ខណៈចាំបាច់សម្រាប់សន្តិសុខជាតិ ប៉ុន្តែព្រឹត្តិការណ៍ថ្មីៗនេះបង្ហាញថា ច្បាប់នេះ អាចត្រូវបានគេប្រើប្រាស់ជាទូទៅ ដើម្បីបំបិទមាត់អ្នករិះគន់ទាំងឡាយ។ សញ្ញានៃការត្រួតពិនិត្យ ចាប់ពិរុទ្ធថ្មីៗបំផុត បានកើតមានក្នុងខែមករា ឆ្នាំ២០១១ នៅពេលប្រព័ន្ធផ្សព្វផ្សាយ ព័ត៌មាន KI-Media តាមគេហទំព័រដ៏ចម្រុងចម្រាស ដែលជាគេហទំព័រមួយ (blog) ត្រូវបានដាក់ឲ្យប្រើដើម្បីប្រមូលផ្តុំអត្ថបទព័ត៌មាន និងមតិយោបល់ស្តីពីប្រទេសកម្ពុជា រាប់ទាំងឯកសារ ដែលរិះគន់រាជរដ្ឋាភិបាលផង ត្រូវបានអ្នកផ្គត់ផ្គង់សេវាប្រព័ន្ធអ៊ិអ៊ីនធឺណិតកម្ពុជា ភាគច្រើនបំផុតធ្វើការរាំងខ្ទប់។ ការកាត់ផ្តាច់នេះ បានរាំងខ្ទប់គេហទំព័រទាំងអស់ ដែលទទួលផ្ទុកដោយ domain BlogSpot (ដែទទួលផ្ទុកប្រព័ន្ធផ្សព្វផ្សាយ KI-Media)។[២៨] បញ្ហានេះ បានធ្វើឲ្យប៉ះពាល់ដល់អ្នកផ្គត់ផ្គង់សេវាប្រព័ន្ធអ៊ីនធឺណិត (ISPs) មួយចំនួនរាប់ទាំង Ezecom, Metfone and WiCAM ។

នៅក្នុងខែកុម្ភៈ ឆ្នាំ២០១១ រលកថ្មីមួយនៃការកាត់ផ្តាច់បានធ្វើឲ្យប៉ះពាល់ដល់ប្រព័ន្ធផ្សព្វផ្សាយ KI-Media ម្តងទៀត ព្រមទាំងប្រព័ន្ធគេហទំព័រផ្សេងៗទៀតផងដែរ រាប់ទាំងគេហទំព័រខ្មែររូបនីយកម្ម (Khmerization) ជាគេហទំព័រអ្នកសារព័ត៌មានពលរដ្ឋមួយ ដែលជារឿយៗធ្វើការរិះគន់រដ្ឋាភិបាល និងគេហទំព័រ Sacrava ជាអ្នកគូររូបតុ្លកអ្នកនយោបាយខ្មែរ។

បន្ទាប់ពីមានការកាត់ផ្តាច់ប្រព័ន្ធគេហទំព័រ កាសែតភ្នំពេញប៉ុស្ត៏បានរាយការណ៍ថា អតិថិជនគេហទំព័រ WiCam ដែលព្យាយាមបើកចូលប្រព័ន្ធផ្សព្វផ្សាយ KI-Media បានឃើញព័ត៌មានប្រាប់ថា គេហទំព័រនេះ "ត្រូវបានបិទតាមបញ្ជារបស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍កម្ពុជា"។[២៩] ក្រោយមកឯកឧត្តមរដ្ឋមន្ត្រី សូ យុន បានបដិសេធថា រដ្ឋាភិបាលមិនបានចេញបញ្ជាឲ្យបិទគេហទំព័រនេះឡើយ ប៉ុន្តែតាមការពិនិត្យឡើងវិញភ្លាមៗទៅលើព័ត៌មានប្រទេសកម្ពុជា កាលពីប្រមាណខែកន្លងទៅនេះ មានការបញ្ជាក់ផ្សេងពីការអះអាងខាងលើ។ នៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១០ លោក វ៉ា គឹមហុង ជាប្រធានគណៈកម្មការព្រំដែនរួមកម្ពុជា-វៀតណាម បានប្រាប់វិទ្យុអាស៊ីសេរីថា រដ្ឋាភិបាលនឹងបិទប្រព័ន្ធផ្សព្វផ្សាយ KI-Media នេះនៅថ្ងៃទី៣១ ខែធ្នូ។

---

[២៨] សេចក្តីប្រកាសព័ត៌មានរបស់អង្គការលីកាដូ "អង្គការលីកាដូថ្កោលទោសទៅលើការត្រួតពិនិត្យចាប់ពិរុទ្ធប្រព័ន្ធវេប សាយ ដែលរិះគន់រដ្ឋាភិបាល" ថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១១ សូមមើល: http://www.licadho-cambodia.org/pressrelease.php?perm =238។

[២៩] ដូចគ្នាក្នុងកំណត់សម្គាល់ជើងទំព័រ ២៨។

ជម្រៅនៃការបង្ក្រាបពីរដ្ឋាភិបាលទៅលើសេរីភាពខាងការបញ្ចេញមតិ តាមប្រព័ន្ធអ៊ីនធឺណិត ត្រូវបានលើកជាឧទាហរណ៍តាមរយៈការឃុំខ្លួនលោក សេង គុណាកា ក្នុងខែធ្នូ ឆ្នាំ២០១០ ដែលលោកជាសមាជិកបុគ្គលិកកម្មវិធីស្បៀងអាហារពិភពលោក។ សមាជិកបុគ្គលិកកម្មវិធីស្បៀងអាហារពិភពលោករូបនេះ ត្រូវបានកាត់ទោសឲ្យជាប់ពន្ធនាគារ បន្ទាប់ពីលោកគ្រាន់តែបានបោះពុម្ព និងចែករំលែកឯកសារព័ត៌មាន ដែលត្រូវបានរកឃើញលើវេបសាយ KI-Media ។[៣០] ការកាត់ទោស ដែលគ្មានមូលដ្ឋាននេះ បានបញ្ជូនសារគួរឲ្យខ្លាចមួយដល់សកម្មជនសិទ្ធិមនុស្ស ដែលការងាររបស់ពួកគេជារឿយៗទាក់ទងនឹងការផលិត និងផ្សព្វផ្សាយព័ត៌មាន ដែលអាចត្រូវបានគេមើលឃើញថាជាការរិះគន់ទៅលើរដ្ឋាភិបាល។

## អាជ្ញាធរសាសនាជួយបំបិទសម្លេងបុព្វជិត ដែលជាសកម្មជនសិទ្ធិមនុស្ស

នៅទីបំផុតព្រឹត្តិការណ៍មួយឈុតគួរឲ្យបារម្ភទាក់ទងនឹងអាជ្ញាធរសាសនា ដែលគំរាមកំហែងព្រះសង្ឃជាសកម្មជនសិទ្ធិមនុស្ស ត្រូវបានអង្គការលីកាដូ ចងក្រងទុកជាឯកសារនៅចន្លោះឆ្នាំ២០១០ និងឆ្នាំ២០១២។

អាជ្ញាធរសាសនាបានរួមសហការជាមួយអាជ្ញាធរ ក្នុងការព្យាយាមបំបិទសម្លេងព្រះសង្ឃ ដែលបញ្ចេញមតិយោបល់ក្នុងនាមសហគមន៍នានា ដែលធ្លាក់ខ្លួនជាជនរងគ្រោះពីការរំលោភសិទ្ធិមនុស្ស។

ក្នុងករណីមួយ ដែលបានកើតឡើងនៅខែសីហា ឆ្នាំ២០១០ កន្លងទៅ ព្រះសង្ឃព្រះនាម ថាច់ ប្រ៊ីយជាឃឿន ត្រូវបានប្រធានសង្ឃ និងអ្នកតំណាងក្រសួងមហាផ្ទៃមួយរូបធ្វើការគំរាម ដោយសារព្រះអង្គមានការពាក់ព័ន្ធក្នុងការបោះពុម្ពផ្សាយកាសែតព្រៃនគរ ដែលជាកាសែតមួយត្រូវបានបោះពុម្ពផ្សាយពីសំណាក់ខ្មែរក្រោម។[៣១] ខ្មែរក្រោម គឺជាជនជាតិខ្មែរភាគតិច ដែលកំពុងរស់នៅក្នុងប្រទេសវៀតណាមភាគខាងត្បូង។ ពួកគេបានក្លាយជាជនរងគ្រោះពីការធ្វើទុក្ខបុកម្នេញ និងការរើសអើងពីអាជ្ញាធរវៀតណាម។

ព្រះតេជគុណព្រះនាម ថាច់ ប្រ៊ីយជាឃឿន ដែលបានស្នាក់នៅបណ្តោះអាសន្ននៅក្នុងវត្តអង្គតាមិញក្នុងរាជធានីភ្នំពេញ ត្រូវបានគេដកហូតលិខិតឆ្លងដែន និងព្រះឆាយាល័ក្ខ (អត្តសញ្ញាណប័ណ្ណ) របស់ព្រះអង្គ។ លោក គឹម វ៉ានឆេង ជាមន្ត្រីជាន់ខ្ពស់ពីក្រសួងមហាផ្ទៃ និងជាទីប្រឹក្សាផ្ទាល់រដ្ឋមន្ត្រី

---

[៣០] សេចក្តីប្រកាសព័ត៌មានរបស់អង្គការលីកាដូ "ការបង្ក្រាបទៅលើសេរីភាពខាងការបញ្ចេញមតិៈ បុរសម្នាក់ត្រូវបានបញ្ជូនទៅឃុំខ្លួនក្នុងពន្ធនាគារ បន្ទាប់ពីចែករំលែកឯកសារព័ត៌មានយកចេញពីគេហទំព័រ" ថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១០ សូមមើលៈ http://www .licadho-cambodia.org/pressrelease.php?perm=235។

[៣១] របាយការណ៍របស់អង្គការលីកាដូ "សិទ្ធិសេរីភាពខាងការបញ្ចេញមតិនៅកម្ពុជាៈ ការបំភ័ន្តលទ្ធិប្រជាធិបតេយ្យ" ខែធ្នូ ឆ្នាំ២០១២ ករណីសិក្សា៣៣ សូមមើលផងដែរៈ របាយការណ៍ឃ្លាំមើលសិទ្ធិមនុស្សអង្គការលីកាដូ ដែលមិនបានបោះពុម្ពផ្សាយៈ PP115THI10។

ក្រសួងមហាផ្ទៃ បានបង្ខំព្រះតេជគុណ ថាច់ ប្រីជាយឿន ឲ្យចុះហត្ថលេខាលើលិខិតមួយច្បាប់ ដោយសន្យាថានឹងឈប់សរសេរ ឬបោះពុម្ពផ្សាយកាសែតព្រៃនគរ ដោយសាកាសែតនេះ បានបោះពុម្ពផ្សាយអត្ថបទប្រឆាំងនឹងរាជរដ្ឋាភិបាល។

## សេចក្តីពិពណ៌នា: ព្រះតេជគុណ លួន សូវ៉ាត ត្រូវបានគេធ្វើទុក្ខបុកម្នេញ ដោយសារព្រះអង្គចងក្រងទុកជាឯកសារនូវករណីរំលោភបំពានសិទ្ធិមនុស្ស

ព្រះតេជគុណ លួន សូវ៉ាត គឺជាព្រះសង្ឃមួយអង្គកាន់ព្រះពុទ្ធសាសនា ដែលលះបង់ពេលវេលាយ៉ាងច្រើនរបស់ព្រះអង្គ ដើម្បីផលិតខ្សែវីដេអូ ដោយចងក្រងទុកនូវករណីរំលោភបំពានសិទ្ធិមនុស្ស ដែលព្រះអង្គបានឃើញជាពិសេសករណីរំលោភបំពានសិទ្ធិមនុស្សទាក់ទងនឹងជម្លោះដីធ្លី។ សារដ៏សំខាន់ និងសេចក្តីក្លាហានផ្ទាល់ខ្លួនធ្វើឲ្យព្រះអង្គសមនឹងទទួលបាននូវកិត្តិនាមជាអ្នកការពារសិទ្ធិមនុស្សនាំមុខមួយអង្គ ក្នុងចំណោមអ្នកការពារសិទ្ធិមនុស្សនៅកម្ពុជា។ នៅថ្ងៃទី២ ខែតុលា ឆ្នាំ ២០១២ ព្រះតេជគុណ លួន សូវ៉ាត បានទទួលរង្វាន់ Martin Ennals សម្រាប់អ្នកការពារសិទ្ធិមនុស្សប្រចាំឆ្នាំ២០១២នេះ ប្រហែលជារង្វាន់ខាងសិទ្ធិមនុស្សប្រកបដោយកិត្យានុភាពបំផុតនៅក្នុងពិភពលោក។ ព្រះអង្គ គឺជាជនជាតិខ្មែរមួយរូបដែលទទួលបានរង្វាន់នេះមុនគេ។

## ការហាមមិនឲ្យនិមន្តចូលក្នុងវត្ត

ព្រះតេជគុណ លួន សូវ៉ាត បានចូលរួមបំពេញការងារសិទ្ធិមនុស្សលើកដំបូងនៅឆ្នាំ២០០៩ នៅពេលសមាជិកគ្រួសារព្រះអង្គបានទទួលរងរបួស នៅអំឡុងពេលបណ្តេញចេញប្រកបដោយហិង្សាមួយនៅក្នុងស្រុកជីក្រែង ខេត្តសៀមរាប។ នៅអំឡុងពេលប្រឈមមុខជាមួយអាជ្ញាធរ មន្ត្រីនគរបាលបានបាញ់កាំភ្លើងទៅលើអ្នកភូមិ ដែលគ្មានអាវុធដែលធ្វើឲ្យបងប្អូនប្រុស និងក្មួយប្រុសព្រះអង្គបានទទួលរងរបួស។ អ្នកភូមិខ្លះ បានថតវីដេអូនូវព្រឹត្តិការណ៍បាញ់នេះ ហើយព្រះអង្គ ក៏បានថតវីដេអូនូវព្រឹត្តិការណ៍នោះផងដែរ។

មន្ត្រីនគរបាលបានអះអាងថា ពួកគេបានបាញ់កាំភ្លើងការពារខ្លួន ប៉ុន្តែខ្សែវីដេអូបានបង្ហាញឲ្យឃើញផ្សេងពីការអះអាងខាងលើ។ អាជ្ញាធរមូលដ្ឋានព្យាយាមបំភិតបំភ័យព្រះតេជគុណ ដើម្បីឲ្យព្រះអង្គប្រគល់ខ្សែវីដេអូទៅឲ្យពួកគេ។ ប៉ុន្តែព្រះអង្គមិនព្រមប្រគល់។ ផ្ទុយទៅវិញព្រះអង្គបានផ្ញើខ្សែវីដេអូនោះទៅឲ្យអង្គការមិនមែនរដ្ឋាភិបាលសិទ្ធិមនុស្សសំខាន់ៗនៅកម្ពុជាទៅវិញ។ ខ្លឹមសារខ្សែវីដេអូបង្កើតនូវចំណាប់អារម្មណ៍៖ ខ្សែវីដេអូផ្ទុយគ្នាស្រឡះជាមួយនឹងការអះអាងរបស់អាជ្ញាធរ ដែលថាមន្ត្រីនគរបាលបានធ្វើសកម្មភាពការពារខ្លួន។

អំណាចនៃខ្សែរីដេអូបាន បង្ហាញយ៉ាងច្បាស់ថា ជាការតស៊ូដើម្បីទាមទារសិទ្ធិមនុស្សនៅកម្ពុជា។

ចាប់តាំងពីពេលនោះមក ព្រះតេជគុណ បាននិមន្តទៅគ្រប់ច្រកល្ហកទូទាំងប្រទេសទៅកាន់ទីកន្លែងដែលមានជម្លោះដីធ្លីពីមួយកន្លែងទៅមួយកន្លែង ដោយចងក្រងទុកជាឯកសារនូវរាល់ជំហាននៃដំណើររបស់ព្រះអង្គ។ វាមិនមានការលំបាកនឹងស្វែងរកទីកន្លែងមានជំលោះឡើយ៖ តាមការស្រាវជ្រាវពីអង្គការលីកាដូ បង្ហាញថាមានដីប្រមាណជា ២,១ លានហិកតា ត្រូវបានផ្តល់ទៅឲ្យក្រុមហ៊ុនឯកជនតាមទម្រង់ជាដីសម្បទាន ចាប់តាំងពីឆ្នាំ១៩៩៣។ ការផ្ទេរដីធ្លីយ៉ាងច្រើនសន្ធឹកសន្ធាប់ បានបង្កឲ្យមានការបណ្តេញចេញដោយបង្ខំរាប់មិនអស់ ហើយបង្កឲ្យមានផលប៉ះពាល់ដល់ប្រជាពលរដ្ឋប្រមាណជាង ៤០០,០០០ នាក់ ក្នុងខេត្តចំនួន ១២ ដែលអង្គការលីកាដូ បានធ្វើការឃ្លាំមើល គ្រាន់តែចាប់តាំងពីឆ្នាំ២០០៣ ប៉ុណ្ណោះ។



ព្រះតេជគុណ លួន សូវ៉ាត និយាយទៅកាន់អ្នកគាំទ្រ ដែលស្ថិតនៅខាងក្រៅសវនាការកាត់ទោស លោក ម៉ម សូណង់ដូ កាលពីថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១២

ដោយសារតែភាពសកម្មនិយមខាងសិទ្ធិមនុស្សរបស់ព្រះអង្គ ត្រូវបានគេហាមមិនឲ្យព្រះអង្គនិមន្តចូលទៅក្នុងវត្តបុទុមវតី ជាទីដែលព្រះអង្គគង់នៅព្រមទាំងមិនឲ្យនិមន្តចូលក្នុងវត្តផ្សេងៗទៀតនៅក្នុង និងជុំវិញរាជធានីភ្នំពេញ។ សម្តេចសង្ឃ នួន ង៉ែត ដែលគង់នៅក្នុងរាជធានីភ្នំពេញ បានសរសេរលិខិតមួយច្បាប់ជាផ្លូវការ ដោយធ្វើការចោទប្រកាន់ព្រះតេជគុណពីបទមានគំនិតអាក្រក់ទៅលើព្រះពុទ្ធសាសនា។ ការរួមសហការគ្នាពីអាជ្ញាធរសាសនាកម្ពុជា គឺកំពុងបង្កជាបញ្ហា។

## ការរំខានយាយី និងការបំភិតបំភ័យ

ព្រះតេជគុណ លួន សូវ៉ាត ត្រូវបានគេកំណត់ជាគោលដៅច្រើនលើក នៅក្នុងរយៈពេលដែលបានកំណត់ក្នុងរបាយការណ៍នេះ សម្រាប់ការងាររបស់ព្រះអង្គជាមួយសហគមន៍ដើម្បីតស៊ូទាមទារសិទ្ធិរបស់ពួកគេ នៅអំឡុងពេលមានជម្លោះដីធ្លី។ នៅក្នុងខែសីហា ឆ្នាំ២០១០ នៅពេលកំពុងប្រមូលផ្តុំដោយអហិង្សាមួយនៅក្រៅសាលាដំបូងខេត្តសៀមរាប ដើម្បីគាំទ្រដល់ថ្នាក់ដឹកនាំសហគមន៍ជីក្រែង មានលោកសង្ឃ ៤០ អង្គបាននិមន្តដល់តុលាការ ដើម្បីប្រឈមមុខនឹងព្រះតេជគុណ។ ព្រះសង្ឃទាំង

នោះ បានចោទប្រកាន់ព្រះតេជគុណពីបទរំលោភបំពានប្រកាសសង្ឃ លេខ ៥០៣/០៧ ជាដីកាសង្ឃ ឆ្នាំ២០០៧ មួយច្បាប់ ដែលហាមប្រាមព្រះសង្ឃព្រះពុទ្ធសាសនានៅកម្ពុជាមិនឲ្យបង្កើត ឬ ចូលរួមបាតុកម្ម ឬកូដកម្ម ដែលនាំឲ្យប៉ះពាល់ដល់សន្តិសុខ ឬសណ្តាប់ធ្នាប់សាធារណៈ។ ព្រះសង្ឃទាំងនោះត្រូវបានមន្ត្រីនគរបាលចំនួន ២០នាក់ ធ្វើដំណើរអមការពារសន្តិសុខ។

លោកសង្ឃទាំងនោះ បានទទួលបទបញ្ជាដើម្បីបញ្ឈប់ព្រះតេជគុណ លួន សូវ៉ាត មិនឲ្យចូលរួមបាតុកម្ម ហើយនឹងត្រូវឃុំព្រះកាយ ប្រសិនបើព្រះអង្គបដិសេធ។ ទោះជាព្រះអង្គបដិសេធមិនព្រមចាកចេញក៏ដោយ ក៏ព្រះអង្គមិនត្រូវបានគេឃុំព្រះកាយឡើយនៅថ្ងៃនោះ ដោយសារតែអ្នកភូមិនៅព័ទ្ធជុំវិញធ្វើជាខែលការពារព្រះអង្គ។ យ៉ាងណាក៏ដោយ បន្ទាប់ពីចាកចេញតាមរថយន្តរបស់អង្គការមិនមែនរដ្ឋាភិបាលមួយ មន្ត្រីនគរបាលចរាចរបានរាំងព្រះអង្គ ហើយបញ្ជាឲ្យនាំព្រះអង្គទៅកាន់វត្តក្នុងមូលដ្ឋានមួយ ដែលមានអាជ្ញាធរសាសនាកំពុងនៅរង់ចាំទីនោះ។ ជាថ្មីម្តងទៀត អ្នកភូមិបាននៅព័ទ្ធជុំវិញធ្វើជាខែលការពារ ដោយមិនឲ្យអាជ្ញាធរនាំព្រះអង្គចេញពីទីនោះឡើយ។

ទោះបីយ៉ាងណាក៏ដោយការបំភិតបំភ័យ មិនត្រូវបានបញ្ឈប់នៅទីនោះឡើយ។ នៅថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១១ នៅអំឡុងពេលធ្វើការតវ៉ាមួយនៅរាជធានីភ្នំពេញ ប្រឆាំងនឹងការផ្តល់ដីសម្បទាននៅក្នុងព្រៃឡង់ ព្រះអង្គ ត្រូវបានបង្ខំឲ្យភៀសព្រះកាយចេញពីកន្លែងកើតហេតុនោះម្តងទៀត ដោយមានជំនួយពីក្រុមការពារសិទ្ធិមនុស្ស ពីព្រោះអាជ្ញាធរបានគំរាមចាប់ខ្លួនព្រះអង្គ។

## ការចាប់ពង្រត់ និងការឃុំព្រះកាយ

ការគំរាមកំហែងទាំងនេះ បានឈានដល់ភាពខ្លាំងបំផុតនៅខែឧសភា ឆ្នាំ២០១២។ ព្រះតេជគុណ លួន សូវ៉ាត បានថតយករូបភាព និងចងក្រងទុកជាឯកសារនូវបាតុកម្មនៅមុខសាលាដំបូងរាជធានីភ្នំពេញ ជាទីដែលសកម្មជនការពារសិទ្ធិដីធ្លីសហគមន៍បឹងកក់ ចំនួន ១៣ នាក់ កំពុងត្រូវបានសួរចម្លើយបន្ទាប់ពីត្រូវបានចាប់ខ្លួន ២ ថ្ងៃកន្លងទៅ។ ព្រះអង្គ លួន សូវ៉ាត ត្រូវបានអាជ្ញាធរសាសនាចាប់ពង្រត់ ដែលបង្ខំឲ្យព្រះអង្គចូលទៅក្នុងរថយន្ត ដែលកំពុងរង់ចាំដោយបំពាន ដោយមានការជួយរុញព្រះអង្គចូលទៅក្នុងរថយន្តពីមន្ត្រីនគរបាលទៀតផង។ បន្ទាប់មកអាជ្ញាធរក៏នាំព្រះអង្គទៅកាន់វត្តបុទុមវតី ជាទីដែលព្រះអង្គត្រូវបានឃុំព្រះកាយ និងធ្វើការសួរចម្លើយពីសំណាក់មន្ត្រីនគរបាល និងមន្ត្រីក្រសួងមហាផ្ទៃ និងក្រសួងធម្មការ និងសាសនាអស់រយៈពេលប្រហែល ១០ ម៉ោង។

នៅពេលកំពុងសួរយកចម្លើយ គ្រប់ផ្លូវចូលទៅកាន់វត្តនេះត្រូវបានរាំងខ្ទប់ ហើយទូរស័ព្ទដៃព្រះអង្គត្រូវបានគេដកហូត។ មន្ត្រីសាសនាបានបង្ហាញព្រះអង្គនូវឯកសារដោយបញ្ជាក់ថា ឯកឧត្តមរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ អង្គ វង្សវឌ្ឍនា បានអនុម័តយល់ព្រមលើសំណើពីសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីធ្វើការចោទប្រកាន់ពីបទញុះញង់ តាមមាត្រា ៤៩៥ នៃក្រមព្រហ្មទណ្ឌ។ ព្រះអង្គ ត្រូវបានគេផ្តល់ជម្រើសមួយ៖ គឺត្រូវចុះហត្ថលេខាលើឯកសារមួយច្បាប់ ដោយសន្យាថានឹងឈប់ពីភាពសកម្មនិយមខាងសិទ្ធិមនុស្ស បើមិនដូច្នោះទេនឹងត្រូវប្រឈមនឹងការផ្សឹកការចាប់ខ្លួន និងការចោទប្រកាន់ខាងព្រហ្មទណ្ឌ។ ព្រះអង្គមិនព្រមចុះហត្ថលេខាលើឯកសារឡើយ ហើយនៅទីបំផុតក៏ត្រូវបានគេដោះលែងឲ្យមានសេរីភាពវិញ។

## ការគំរាមកំហែងនៅតែបន្តកើតមាន

ចាប់តាំងពីព្រះអង្គត្រូវបានគេចាប់បង្ខាំងព្រះកាយ និងត្រូវបានគេសាកសួរយកចម្លើយនៅឯវត្តបុទុមវតី ការគំរាមកំហែងទៅលើព្រះអង្គ មិនត្រូវបានគេបញ្ឈប់ឡើយ។ នៅថ្ងៃទី៥ ខែមិថុនា មន្ត្រីនគរបាលជាន់ខ្ពស់មួយរូប បានធ្វើការគំរាមកំហែងដោយប្រយោលទៅលើបុគ្គលិកអង្គការលីកាដូមួយរូប នៅអំឡុងពេលបាតុកម្មមួយ ដែលត្រូវបានធ្វើឡើងក្នុងនាមសកម្មជនសហគមន៍បឹងកក់ ដែលជាប់ពន្ធនាគារ។ មន្ត្រីនគរបាលរូបនោះ បានសួរបុគ្គលិកអង្គការលីកាដូនោះ ថាតើព្រះតេជគុណលួន សូវ៉ាត មានផែនការណ៍ចូលរួមការតវ៉ានោះដែរ ឬយ៉ាងណា។ បន្ទាប់ពីបុគ្គលិកអង្គការលីកាដូនោះ បានសួរមន្ត្រីនគរបាលរូបនោះវិញពីមូលហេតុ ដែលគាត់បានសួរដូច្នោះ មន្ត្រីនគរបាលរូបនោះបានឆ្លើយ ថាពួកគេត្រូវការរៀបចំបំរុង "អាហារប៊ូហ្វេ"។ ទំនងជាមានអាហារប៊ូហ្វេថ្ងៃត្រង់ ដែលត្រូវបានគេផ្តល់ឲ្យនៅឯវត្តបុទុមវតី នៅថ្ងៃដែលព្រះអង្គ ត្រូវបានគេឃុំព្រះកាយនៅទីនោះ។

នៅថ្ងៃទី៦ ខែមិថុនា វេលាម៉ោង ២០:០៩នាទីយប់ ព្រះអង្គ បានទទួលការហៅទូរស័ព្ទចូលមួយតាមរយៈលេខទូរស័ព្ទមួយមិនស្គាល់។ អ្នកហៅទូរស័ព្ទចូលនោះ បានជេរប្រមាថព្រះអង្គតាមទូរស័ព្ទជាច្រើនដងអស់រយៈពេលប្រហែល ១ នាទី។ អ្នកហៅនោះ បានបញ្ឈប់ការជេរប្រមាថដោយពោលពាក្យថា "រឹងក្បាលម្ល៉េះ ហេតុអីលោកឯងមិនឈប់។ តើលោកឯងចង់រស់ ចង់ស្លាប់ ឬចង់ជាប់គុក?"។

# ការពិនិត្យឡើងវិញនូវអនុសាសន៍នានា នៅឆ្នាំ២០០៩

ផ្នែកខាងក្រោម គឺជាការពិនិត្យឡើងវិញនូវអនុសាសន៍នានា ដែលអង្គការលីកាដូ បានធ្វើក្នុងរបាយការណ៍ កាលពីពេលមុនរបស់ខ្លួន ដែលមានចំណងជើងថា *ការវាយប្រហារ និងការគំរាមកំហែងទៅលើអ្នកការពារសិទ្ធិមនុស្សនៅប្រទេសកម្ពុជា នៅចន្លោះឆ្នាំ២០០៨ - ២០០៩។*[៣២] ដូចដែលបានរៀបរាប់ពិស្តារខាងក្រោមអនុសាសន៍ភាគច្រើនត្រូវបានគេមិនទាន់អនុវត្តៈ

- *ទប់ទល់នឹងវប្បធម៌និទ្ទណ្ឌភាព និងអំពើពុករលួយ ដោយធ្វើការចោទប្រកាន់មន្ត្រីរាជរដ្ឋាភិបាលមួយចំនួន (រាប់ទាំងមន្ត្រីតុលាការ មន្ត្រីនគរបាលកងរាជអាវុធហត្ថ ព្រមទាំងកងយោធពលខេមរភូមិន្ទផង) ដែលទទួលខុសត្រូវចំពោះ ឬសមគំនិតក្នុងការវាយប្រហារ និងការគំរាមកំហែងទៅលើអ្នកការពារសិទ្ធិមនុស្ស។ ជាពិសេសអង្គការលីកាដូ ត្រូវការឲ្យមានការស៊ើបអង្កេតមួយឲ្យបានហ្មត់ចត់ និងប្រាកដប្រជាទៅលើឃាតកម្ម ឬការបាត់ខ្លួនអ្នកសារព័ត៌មានចំនួន ១០ នាក់ ដែលមិនទាន់ដោះស្រាយចាប់តាំងតែពីទសវត្សរ៍ ឆ្នាំ១៩៩០។*

  គ្មានវិធានការហ្មត់ចត់ត្រូវបានដាក់ឲ្យមានឡើង ដើម្បីទប់ទល់នឹងវប្បធម៌និទ្ទណ្ឌភាព និងអំពើពុករលួយនៅប្រទេសកម្ពុជាឡើយ។ ផ្ទុយទៅវិញការសហការពីមន្ត្រីរាជរដ្ឋាភិបាលក្នុងការគំរាមកំហែង និងការវាយប្រហារទៅលើអ្នកការពារសិទ្ធិមនុស្ស នៅតែកើតមានជាទូទៅនៅចន្លោះឆ្នាំ២០១០ និងឆ្នាំ២០១២។ បន្ទាប់ពីមានឧប្បត្តិហេតុកាន់តែកើនឡើង ដែលមិនធ្លាប់មានពីមុនទាក់ទងនឹងការរឹបអូសយកដីធ្លីនៅប្រទេសកម្ពុជា ការសហការពីអាជ្ញាធរក្នុងអំពើហិង្សាទៅលើអ្នកការពារសិទ្ធិមនុស្សកាន់តែមានចំនួនច្រើនឡើងយ៉ាងខ្លាំង។ លើសពីនេះទៅទៀត ជនសង្ស័យដែលត្រូវគេស្គាល់អត្តសញ្ញាណ ដែលបានប្រព្រឹត្តអំពើហិង្សាទៅលើអ្នកការពារសិទ្ធិមនុស្ស មិនត្រូវបានគេធ្វើការចោទប្រកាន់ឲ្យបានត្រឹមត្រូវនៅឡើយ ហើយអាជ្ញាធរនៅតែខកខានមិនបានស៊ើបអង្កេតឲ្យហ្មត់ចត់ ទៅលើការគំរាមកំហែង និងការវាយប្រហារទៅលើអ្នកការពារសិទ្ធិមនុស្សឡើយ។ ឧប្បត្តិហេតុនៃអំពើហិង្សា និងការសម្លាប់យ៉ាងច្រើនពីអតីតកាល នៅតែមិនទាន់ដោះស្រាយបាននៅឡើយ។

- *សូមបញ្ឈប់ការចាប់ខ្លួន និងឃុំខ្លួនអ្នកការពារសិទ្ធិមនុស្ស ទាក់ទងនឹងការធ្វើសកម្មភាពរបស់ពួកអ្នកទាំងនោះ ទោះជាដោយគ្មានការចោទប្រកាន់ ឬប្រើប្រាស់ការចោទប្រកាន់មិនត្រឹមត្រូវតាមច្បាប់ក៏ដោយ ដូចជាការផ្សាយព័ត៌មានមិនពិត ឬការញុះញង់។*

---

[៣២] ការវាយប្រហារ និងការគំរាមកំហែងទៅលើអ្នកការពារសិទ្ធិមនុស្សនៅប្រទេសកម្ពុជានៅចន្លោះឆ្នាំ២០០៨ - ២០០៩ របាយការណ៍អង្គការលីកាដូ ខែកញ្ញា ឆ្នាំ ២០១០ មាននៅក្នុង http://www.licadho-cambodia.org/reports/files/1432010-HRDReport2008-2009Final-ENG.pdf។

ចំនួនអ្នកការពារសិទ្ធិមនុស្ស ដែលត្រូវចាប់ខ្លួន និង/ឬ ត្រូវឃុំខ្លួននៅពេលកំពុងធ្វើសកម្មភាពរបស់អ្នកទាំងនោះ មិនបានថយចុះឡើយ។ ប្រធានសហជីព អ្នកតំណាង សហគមន៍ក្នុងជំលោះដីធ្លី បុគ្គលិកអង្គការមិនមែនរដ្ឋាភិបាល ហើយសូម្បីតែព្រះសង្ឃក៏ត្រូវបានចាប់ខ្លួន និង/ឬ ត្រូវបានឃុំខ្លួន ដោយជួនកាលគ្មានមេធាវីការពារក្តី។ ជាញឹកញាប់អ្នកទាំងនោះមិនត្រូវបានដោះលែងឡើយ លុះត្រាតែអ្នកទាំងនោះព្រមផ្តិតម្រាមដៃលើឯកសារដោយបញ្ជាក់ថាអ្នកទាំងនោះនឹងមិនចូលរួមក្នុងភាពសកម្មនិយមសិទ្ធិមនុស្សទៀតឡើយ។ ជនរងគ្រោះពីការរឹបអូសយកដីធ្លីត្រូវបានចាប់ខ្លួន និងឃុំខ្លួនកាន់តែមានចំនួនច្រើនឡើងដោយគ្មានមូលហេតុជាក់ស្តែង ឬជួនកាលគ្មានដីកាពីតុលាការទៀតផង។ ម្យ៉ាងទៀត ការប្រើប្រាស់មណ្ឌលសង្គមកិច្ចព្រៃស្ពឺ ដែលជាមណ្ឌលគ្មានកេរ្តិ៍ឈ្មោះគ្រប់គ្រងដោយរាជរដ្ឋាភិបាល ដើម្បីបង្ខាំងអ្នកការពារសិទ្ធិមនុស្សដោយចាក់សោមិនឲ្យចេញរួច គឺជាយុទ្ធវិធីថ្មីមួយគួរឲ្យព្រួយបារម្ភ និងមិនដែលមានពីមុនមក ដែលបានកើតឡើងថ្មីៗនេះ។ តាមការស្រាវជ្រាវពីអង្គការលីកាដូ បង្ហាញថា មណ្ឌលព្រៃស្ពឺគ្មានអ្វីក្រៅពីទីកន្លែងឃុំខ្លួនក្រៅច្បាប់មួយ ដែលស្ថានភាពឃុំខ្លួនជាញឹកញាប់មានសភាពយ៉ាប់យឺនជាងនៅក្នុងពន្ធនាគារទៅទៀត។ ការរំលោភបំពានសិទ្ធិមនុស្សបានកើតមានជាញឹកញាប់។ មណ្ឌលបែបនេះ មិនបម្រើគោលបំណងស្របច្បាប់ក្នុងសង្គមមួយ ដែលគោរពនីតិរដ្ឋនោះទេ ហើយគួរតែត្រូវបិទទ្វារជាបន្ទាន់។ លើសពីនេះ ចៅក្រមបានបន្តប្រើប្រាស់ដីកាកោះ ជាអាវុធបំភិតបំភ័យតាមផ្លូវតុលាការមួយ។ លក្ខណៈនេះ គឺជាភស្តុតាងយ៉ាងច្បាស់៖ ក្រុមហ៊ុនឯកជនពាក់ព័ន្ធក្នុងជំលោះដីធ្លី បានដាក់ពាក្យបណ្តឹងមិនត្រឹមត្រូវទៅលើអ្នកការពារសិទ្ធិមនុស្ស ដែលចេញមុខចេញមាត់ជាងគេនៅពេលមានជម្លោះ។ ព្រះរាជអាជ្ញា ដែលជាអ្នកធ្វើការចោទប្រកាន់ កោះហៅសកម្មជនសិទ្ធិមនុស្សមកសាកសួរយកចម្លើយជាធម្មតាអំពី ការចោទប្រកាន់ពីបទញុះញង់ ការបំផ្លិចបំផ្លាញទ្រព្យសម្បត្តិ បទបរិហារកេរ្តិ៍ ឬ ការកាន់កាប់ដីធ្លីខុសច្បាប់ ប៉ុន្តែមិនមានការចោទប្រកាន់ ឬចេញដីកាចាប់ខ្លួនឡើយ។ ជាលទ្ធផល ភាពមិនប្រាកដប្រជានេះ ដើរតួបំភិតបំភ័យ និងត្រួតត្រាអ្នកការពារសិទ្ធិមនុស្ស ដោយធ្វើឲ្យអ្នកទាំងនោះមានលទ្ធភាពតិចតួច ដើម្បីបន្តការងាររបស់អ្នកទាំងនោះ។

- *សូមអនុញ្ញាតឲ្យមានការតវ៉ាដោយអហិង្សាប្រព្រឹត្តទៅដោយគ្មានការបន្ទច់បង្អាក់ ដោយប្រើអំពើហិង្សា ឬការរារាំងពីសំណាក់មន្ត្រីនគរបាល ដូចដែលត្រូវបានធានាការពារ ដោយរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។*

ការប្រើហិង្សាទៅលើការតវ៉ាដោយអហិង្សា មិនត្រឹមតែមានការធ្វើបន្ត ប៉ុន្តែបានឈានដល់កម្រិតខ្ពស់ថ្មីទៀតនៅអំឡុងរយៈពេល ដែលត្រូវបានសរសេរដោយរបាយការណ៍នេះ។

មន្ត្រីនគរបាល កងរាជអាវុធហត្ថ កងខេមរភូមិន្ទ និងសូម្បីតែឆ្មាំសន្តិសុខកម្រិតស្រុកបាន ប្រើប្រាស់អំពើហិង្សាជាញឹកញាប់ដើម្បីបំបែកបាតុករ។ អ្នកការពារសិទ្ធិមនុស្សមួយចំនួន ត្រូវបានគេកំណត់ជាគោលដៅក្នុងចំណោមក្រុមបាតុករ ហើយនឹងត្រូវបានកងកម្លាំង ប្រដាប់អាវុធវាយដំយ៉ាងខ្លាំងក្លា។ ហើយប្រការ ដែលគួរឲ្យព្រួយបារម្ភថែមទៀតនោះ គឺ ឧប្បត្តិហេតុយ៉ាងច្រើនទាក់ទងនឹងកងកម្លាំងប្រដាប់អាវុធ ដែលបើកការបាញ់ប្រហារទៅ លើជនស៊ីវិលប្រកាន់សន្តិភាព ត្រូវបានរាយការណ៍ឲ្យដឹងក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងទៅ នេះ រាប់ទាំងការបាញ់សម្លាប់ក្មេងស្រីស្លូតត្រង់អាយុ ១៤ ឆ្នាំម្នាក់ នៅអំឡុងការបណ្តេញ ចេញក្នុងខេត្តក្រចេះ។

- *រៀបចំដំណើរការកែសម្រួលឡើងវិញឲ្យបានហ្មត់ចត់ ទាក់ទងនឹងឯករាជ្យភាពតុលាការ ដោយជាពិសេសយកចិត្តទុកដាក់ទៅលើការតែងតាំងចៅក្រម និងព្រះរាជអាជ្ញា ព្រមទាំង ការដកហូតអ្នកទាំងនោះពីមុខតំណែង។ អង្គការលីកាដូសង្កត់ធ្ងន់ថា ចៅក្រមត្រូវបាន ធានាសម្រាប់មុខតំណែង (មិនអាចដកចេញដោយស្រួលទេ) ផ្អែកលើអាកប្បកិរិយាល្អនៅ ពេលត្រូវបានតែងតាំងមុខតំណែង ហើយនឹងមិនត្រូវទទួលឥទ្ធិពលណាមួយឡើយ ជា ពិសេសឥទ្ធិពលពីស្ថាប័ននីតិប្រតិបត្តិ។*

ករណីមួយចំនួនទាក់ទងនឹងអ្នកការពារសិទ្ធិមនុស្ស នៅចន្លោះឆ្នាំ២០១០ និងឆ្នាំ ២០១២ បានឆ្លុះបញ្ចាំងឲ្យឃើញយ៉ាងច្បាស់នូវចំណងទាក់ទងយ៉ាងជិតស្និទ្ធ ដែលបន្តកើតមាន រវាងស្ថាប័នតុលាការ និងស្ថាប័ននីតិប្រតិបត្តិ។ សេចក្តីសម្រេចតុលាការដោយនិន្នាការ នយោបាយ បាននាំឲ្យមានការកាត់ទោសបុគ្គលិកស្លូតត្រង់នៃអង្គការមិនមែនរដ្ឋាភិបាល សកម្មជនការពារសិទ្ធិដីធ្លី និងប្រធានសហជីព។ ការកាត់ទោសលោក លាង សុខជឿន ជា បុគ្គលិកអង្គការលីកាដូ ឲ្យជាប់ពន្ធនាគារ ចំនួន ២ ឆ្នាំ ទោះជាគ្មានភស្តុតាងដាក់បន្ទុក ហើយមានភស្តុតាងយ៉ាងលើសលុបបញ្ជាក់ពីភាពគ្មានទោសរបស់គាត់ក៏ដោយ គឺជាការ ប៉ះពាល់មួយគួរឲ្យព្រួយបារម្ភដល់សហគមន៍សិទ្ធិមនុស្ស។ ចាប់តាំងពីឆ្នាំ២០១០ - ២០១២ ករណីជាច្រើនបានបញ្ជាក់ដដែលៗថា ស្ថាប័នតុលាការកម្ពុជាគ្មានឯករាជ្យភាព និងមាន ភាពលំអៀង។ មានវិធានការជាក់លាក់មួយចំនួនតូច ត្រូវបានចាត់ឲ្យមានឡើងពីសំណាក់ រាជរដ្ឋាភិបាល ដើម្បីពង្រឹងស្ថាប័នតុលាការ។ ឧ: មិនទាន់មានច្បាប់ធ្វើការបញ្ញត្តិពីលក្ខន្តិ ក:ចៅក្រម ដូចដែលបានសន្យាអស់រយ:ពេលជាច្រើនឆ្នាំមកហើយនៅឡើយទេ។

- *ធ្វើឲ្យប្រាកដប្រជាថា ច្បាប់ប្រឆាំងអំពើពុករលួយថ្មី ត្រូវយកមកប្រើប្រាស់តាមគោល បំណងពិតរបស់វា (ដើម្បីធ្វើការចោទប្រកាន់អំពើពុករលួយក្នុងជួររាជរដ្ឋាភិបាល) និងមិន*

*ត្រូវយកមកប្រើប្រាស់ ដើម្បីកំណត់អ្នកការពារសិទ្ធិមនុស្ស អង្គការមិនមែនរដ្ឋាភិបាល ឬសហជីពជាគោលដៅឡើយ។*

ច្បាប់ប្រឆាំងអំពើពុករលួយបានចូលជាធរមានក្នុងខែសីហា ឆ្នាំ២០១១។ ជាទូទៅបទបញ្ញត្តិភាគច្រើននៃច្បាប់នេះ បានគំរាមកំហែងសិទ្ធិសេរីភាពខាងការបញ្ចេញមតិ និងការងាររបស់អ្នកការពារសិទ្ធិមនុស្ស។ មកទល់បច្ចុប្បន្នច្បាប់នេះ មិនទាន់ត្រូវបានគេប្រើដើម្បីបំបិទសម្លេងអ្នកការពារសិទ្ធិមនុស្សនៅឡើយទេ ប៉ុន្តែការអនុវត្តរបស់ច្បាប់នោះបានបង្ហាញថា ច្បាប់នេះ ត្រូវបានប្រើជាមធ្យោបាយមួយដើម្បីទប់ទល់គូរប្រជែងខាងនយោបាយ។ ទោះបីយ៉ាងណាក៏ដោយ ការគួរឲ្យសោកស្តាយណាស់ ដោយសារច្បាប់នេះមិនទាន់ត្រូវបានអនុវត្តជាប្រព័ន្ធ។ អាជ្ញាធរនៅតែបន្តមិនគិតគូរ នូវការចោទប្រកាន់អំពីអំពើពុករលួយ និងការជំរិតទារប្រាក់ ជាពិសេសទាក់ទងនឹងមន្ត្រីរាជរដ្ឋាភិបាលមួយចំនួន និងទាហានយោធា ដែលពាក់ព័ន្ធក្នុងអាជីវកម្មកាប់ឈើខុសច្បាប់។

- *បញ្ឈប់ប្រើការបង់ប្រាក់ធានានៅក្រៅឃុំរង់ចាំសវនាការ ជាមធ្យោបាយមួយគំរាមកំហែងអ្នកការពារសិទ្ធិមនុស្ស។ ការបង់ប្រាក់ធានានៅក្រៅឃុំរង់ចាំសវនាការជាមធ្យោបាយក្នុងការចៀសវាងការឃុំខ្លួនបណ្តោះអាសន្ន ដែលមិនចាំបាច់ មិនមែនជាយន្តការព្យួរទោសសាកល្បងដើម្បីបំភិតបំភ័យ ឬត្រួតត្រាសកម្មភាពរបស់អ្នកការពារសិទ្ធិមនុស្សទេ។ ធ្វើវិសោធនកម្មផងដែរនូវក្រមនីតិវិធីព្រហ្មទណ្ឌ ដើម្បីដាក់បញ្ចូលរយៈពេលកំណត់ជាក់លាក់សម្រាប់រយៈពេលនៃការដាក់ឲ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ហើយនឹងបញ្ឈប់ការចោទប្រកាន់ខាងព្រហ្មទណ្ឌមកលើអ្នកការពារសិទ្ធិមនុស្សតាម "ការបង់ប្រាក់ធានាក្រៅឃុំរង់ចាំសវនាការជានិច្ច"។*

ការដោះលែង ប៉ុន្តែត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ នៅតែត្រូវបានគេប្រើជាមធ្យោបាយមួយ ដើម្បីបំភិតបំភ័យ និងគ្រប់គ្រងអ្នកការពារសិទ្ធិមនុស្ស ដែលត្រូវបានចោទប្រកាន់។ តុលាការបានប្រើទោសព្យួរកាន់តែច្រើនឡើងផងដែរ ដែលជាមធ្យោបាយមួយដើម្បីរក្សាទុកការគ្រប់គ្រងទៅលើអ្នកការពារសិទ្ធិមនុស្ស ដោយមិនចាំបាច់ឃុំខ្លួនពួកគេក្នុងពន្ធនាគារ។ តាមផែនការណ៍បែបនេះ អ្នកការពារសិទ្ធិមនុស្សត្រូវបានដោះលែង ប៉ុន្តែនៅតែជាប់ពិរុទ្ធទោសព្រហ្មទណ្ឌ ហើយនិងស្ថិតក្រោមការគំរាមកំហែងដាក់ទោសកាន់តែធ្ងន់ធ្ងរថែមទៀត ប្រសិនបើពួកគេត្រូវបានចាប់ខ្លួនឡើងវិញ។

ការប្រើប្រាស់ការឃុំខ្លួនបណ្តោះអាសន្នលើសនីតិវិធី ក៏ជាកង្វល់មួយផងដែរនៅ ចន្លោះឆ្នាំ ២០១០ និងឆ្នាំ២០១២។ អ្នកការពារសិទ្ធិមនុស្សជារឿយៗ ត្រូវបានគេឃុំខ្លួនបណ្តោះ

អាសន្ន ដោយមិនគិតពីបទបញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលតម្រូវថាការឃុំខ្លួនបណ្ដោះអាសន្ន ត្រូវបានគេប្រើតែក្នុងករណីពិសេសប៉ុណ្ណោះទេ។

- *សូមបញ្ឈប់គម្រោងអនុម័តច្បាប់ស្ដីពីការបង្កើតសមាគមន៍ និងអង្គការមិនមែនរដ្ឋាភិបាល ដែលនឹងអាចត្រូវបានប្រើភាគច្រើនដើម្បីបំភិតបំភ័យ និងរឹតត្បិតសកម្មភាពរបស់អ្នកការពារសិទ្ធិមនុស្សក្នុងបណ្ដាអង្គការមិនមែនរដ្ឋាភិបាល។*

រដ្ឋាភិបាលបានបញ្ចេញសេចក្ដីព្រាងច្បាប់ចំនួន ៤ ដង ស្ដីពីការបង្កើតសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ចាប់តាំងពីមានការបោះពុម្ពផ្សាយរបាយការណ៍ចុងក្រោយរបស់អង្គការ លីកាដូ ស្ដីពីអ្នកការពារសិទ្ធិមនុស្ស។ សេចក្ដីព្រាងច្បាប់ទាំងអស់ ត្រូវបានគេរិះគន់យ៉ាងខ្លាំងទាំងនៅកម្រិតជាតិ និងកម្រិតអន្តរជាតិ។ នៅខែធ្នូ ឆ្នាំ២០១១ បន្ទាប់ពីបង្ហាញសេចក្ដីពង្រាងច្បាប់ទី៤ រាជរដ្ឋាភិបាលបានប្រកាសថា ការពិគ្រោះយោបល់បន្ថែមជាមួយសង្គមស៊ីវិល នឹងត្រូវរៀបចំឡើង។ កាលបរិច្ឆេទអនុវត្តជាគោលដៅសម្រាប់ច្បាប់នេះ ត្រូវបានពន្យារពេលរហូតដល់ឆ្នាំ២០១៤ ឬយឺតជាងនេះ។ អង្គការលីកាដូ សូមធ្វើការកោតសរសើរនូវការវិវឌ្ឍន៍នេះ។ ទោះជាយ៉ាងណាក៏ដោយច្បាប់ចំនួន ២ ផ្សេងទៀតទំនងជាកង្វល់យ៉ាងធំសម្រាប់អ្នកការពារសិទ្ធិមនុស្ស។ ច្បាប់ស្ដីពីការគ្រប់គ្រងប្រព័ន្ធអ៊ីនធឺណិត (ដែលមានពាក្យចចាមអារាមថា កំពុងស្ថិតនៅក្នុងដំណាក់ការពង្រាងលើក្រោយៗ ប៉ុន្តែមិនទាន់ត្រូវបានគេបញ្ចេញជាសាធារណៈនៅឡើយ) បានចោទជាកង្វល់យ៉ាងធ្ងន់ធ្ងរអំពីការត្រួតពិនិត្យចាប់ពិរុទ្ធប្រព័ន្ធអ៊ីនធឺណិតដោយរដ្ឋាភិបាល ជាឧបករណ៍មួយដែលបង្ហាញថាមានប្រយោជន៍កាន់តែច្រើនឡើងសម្រាប់អ្នកការពារសិទ្ធិមនុស្ស។

## អនុសាសន៍នានា

អង្គការលីកាដូ សុំជម្រុញរាជរដ្ឋាភិបាលកម្ពុជា ឲ្យចាត់វិធានការដូចខាងក្រោមនេះ ដើម្បីធ្វើឲ្យប្រសើរឡើងនូវស្ថានភាពរបស់អ្នកការពារសិទ្ធិមនុស្ស:

- កែសម្រួលក្រមព្រហ្មទណ្ឌថ្មីដើម្បីធានាថា ច្បាប់នេះ គោរពតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ហើយនិងកាតព្វកិច្ចនានាទាក់ទងនឹងសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិ ដែលប្រទេសកម្ពុជាបានផ្តល់សច្ចាប័ន។ ជាពិសេសបទបញ្ញត្តិមិនច្បាស់លាស់ និងទូលំទូលាយ ជាពិសេសបទញុះញង់ ព្រមទាំងបទបញ្ញត្តិទាំងអស់ ដែលប៉ះពាល់ដល់សេរីភាពខាងការបញ្ចេញមតិ ដូចជាបទបរិហារកេរ្តិ៍ និងការជេរប្រមាថ ត្រូវតែកែសម្រួលដើម្បីធានាថា បទបញ្ញត្តិទាំងនេះ មិនរារាំងសិទ្ធិសេរីភាពខាងការបញ្ចេញមតិ ហើយនិងមិនបង្កលក្ខណ:ឲ្យមានការចាប់ខ្លួនអ្នកការពារសិទ្ធិមនុស្សតាមទំនើងចិត្ត។
- អនុវត្តនូវអនុសាសន៍ទាំងឡាយ ដែលអ្នករាយការណ៍ពិសេសបានធ្វើជាបន្តបន្ទាប់ ស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា ដើម្បីពង្រឹងនីតិរដ្ឋ និងស្ថាប័នតុលាការ។ ប្រការនេះ ត្រូវរាប់បញ្ចូលទាំងការធ្វើសកម្មភាពដែលមានប្រសិទ្ធភាព ដើម្បីធ្វើឲ្យប្រសើរឡើងនូវឯករាជ្យភាព និងភាពមិនលំអៀងរបស់ស្ថាប័នតុលាការ។ ស្នើសុំឲ្យស្ថាប័នតុលាការលើកកំពស់ឯករាជ្យភាពរបស់ខ្លួននៅគ្រប់ករណីទាំងអស់ ប៉ុន្តែជាពិសេសករណីទាក់ទងនឹងអ្នកការពារសិទ្ធិមនុស្ស។
- ធ្វើការស៊ើបអង្កេតយ៉ាងហ្មត់ចត់ទៅលើការគំរាមកំហែង និងការវាយប្រហារទៅលើអ្នកការពារសិទ្ធិមនុស្ស។ ប្រយុទ្ធប្រឆាំងនឹងនិទ្ទណ្ឌភាព និងអំពើពុករលួយ ដោយធ្វើការចោទប្រកាន់ជនសង្ស័យទៅតាមវិសាលភាពពេញលេញនៃច្បាប់។ ជាពិសេសអង្គការលីកាដូត្រូវការឲ្យមានការស៊ើបអង្កេតយ៉ាងហ្មត់ចត់ និងយកចិត្តទុកដាក់ទៅលើការបាញ់សម្លាប់លោក ឈុត វុទ្ធី និងហេង ចន្ថា ព្រមទាំងធ្វើការចោទប្រកាន់ទៅលើ ឈូក បណ្ឌិត ទៅតាមវិសាលភាពពេញលេញបំផុតនៃច្បាប់ និងអនុលោមតាមបទបញ្ញត្តិនានានៃក្រមព្រហ្មទណ្ឌ និងក្រមនីតិវិធីព្រហ្មទណ្ឌ។
- បញ្ឈប់ការបង្ក្រាប ដែលមិនចាំបាច់ទៅលើអង្គការសង្គមស៊ីវិល សហជីព កម្មករ និងសហគមន៍ទាំងឡាយ ដែលធ្វើការតវ៉ាដើម្បីការពារសិទ្ធិជាមូលដ្ឋានរបស់ពួកគេ។ បញ្ឈប់ការប្រើប្រាស់កម្លាំងស្លាប់រស់ទៅលើបាតុកម្មដោយសន្តិវិធី និងបង្កលក្ខណ:សម្រាប់ការតវ៉ាដោយអហិង្សាទាំងអស់ប្រព្រឹត្តទៅដោយគ្មានការបន្ទច់បង្អាក់ ដោយសារអំពើហិង្សា ឬ

ការរារាំងពីមន្ត្រីនគរបាល។ បញ្ឈប់អំពើហិង្សា និងការចាប់ខ្លួនខុសច្បាប់ ដែលកំណត់ជាគោលដៅលើអ្នកតំណាងសហគមន៍នៅអំឡុងបាតុកម្មដោយអហិង្សា។

- បញ្ចប់ភាពអាថិកំបាំងជុំវិញច្បាប់ ស្តីពីការគ្រប់គ្រងប្រព័ន្ធអ៊ីនធឺណិត និងបញ្ចេញសេចក្តីព្រាងច្បាប់នេះ ជាសាធារណៈដើម្បីឲ្យការពិគ្រោះយោបល់ដ៏មានន័យ អាចកើតឡើងជាមួយសង្គមស៊ីវិល ព្រមទាំងសាធារណៈជន។ ជាទូទៅជាងនេះធានាឲ្យមានការផ្សព្វផ្សាយទាន់ពេលវេលានូវសេចក្តីព្រាងច្បាប់ទាំងអស់សម្រាប់ធ្វើការពិនិត្យ និងផ្តល់មតិយោបល់ពីតួអង្គទាំងអស់ដែលពាក់ព័ន្ធ។

- ធានានូវការការពារសមស្របសម្រាប់ការងារវិជ្ជាជីវៈសារព័ត៌មាន។ ធានាថាច្បាប់ ស្តីពីរបបសារព័ត៌មានត្រូវយកមកប្រើជំនួសឲ្យក្រមព្រហ្មទណ្ឌ ក្នុងរឿងក្តីទាក់ទងនឹងអ្នកសារព័ត៌មាន ដើម្បីលើកកំពស់កិច្ចការពារ នូវសេរីភាពខាងការបញ្ចេញមតិទៅតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។ បញ្ឈប់គ្រប់សកម្មភាពការពិនិត្យចាប់ពិរុទ្ធ ដែលកំណត់គោលដៅទៅលើអ្នកសារព័ត៌មាន។

- ផ្តល់សច្ចាប័នទៅលើពិធីសារបន្ថែមទី១ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដូចដែលបានសន្យានៅអំឡុងពេលដំណើរការពិនិត្យរបាយការណ៍រដ្ឋភាគីជាសកលតាមពេលកំណត់។ ពិធីសារបន្ថែមទី១ នេះ បង្កើតនូវយន្តការមួយសម្រាប់ដាក់ពាក្យបណ្តឹងដោយបុគ្គល។ ក្រោមពិធីសារបន្ថែមនេះ គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ ត្រូវបានផ្តល់ឲ្យនូវយុត្តាធិការ (សមត្ថកិច្ច) ដើម្បីពិនិត្យមើលពាក្យបណ្តឹងដែលត្រូវបានដាក់ដោយបុគ្គល ឬក្រុមមនុស្ស ដែលអះអាងថាសិទ្ធិរបស់ពួកគេនៅក្រោមកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ត្រូវបានរំលោភបំពានពីរដ្ឋភាគីនៃកតិកាសញ្ញានេះ។

## ឧបសម្ព័ន្ធ ១: អ្នកការពារសិទ្ធិមនុស្សនៅកម្ពុជា (ខែមករា ដល់ ខែធ្នូ ឆ្នាំ២០១០)

**ថ្ងៃទី១២ ខែមករា ឆ្នាំ២០១០**

**ករណីទី១**

*[សូមមើលករណីទី ៤០ ៩៩ និង១២៥ ផងដែរ]*

### ការបំភិតបំភ័យតាមផ្លូវតុលាការទៅលើបុគ្គលិកអង្គការសិទ្ធិមនុស្សក្រៅរដ្ឋាភិបាល [១]

*ខេត្តរតនៈគីរី*

- លោក ថោ សារ៉ន ជាចៅក្រមសាលាដំបូងខេត្តរតនៈគិរី បានគំរាមកោះហៅលោក ប៉ែន ប៊ុនណា និងលោក ឆៃ ទី ជាអ្នកសម្របសម្រួល និងជាអ្នកស៊ើបអង្កេតរបស់អង្គការអាដហុក (ADHOC) ប្រចាំខេត្តរតនៈគីរី មកសាកសួរទាក់ទងនឹងការចោទប្រកាន់ពីបទញុះញង់។ ករណីនេះ កើតចេញពីឧប្បត្តិហេតុមួយក្នុងឆ្នាំ២០០៧ នៅពេលអ្នកភូមិបានប៉ះទង្គិចគ្នាជាមួយអាជ្ញាធរ នៅអំឡុងពេលកំពុងធ្វើការតវ៉ាមួយប្រឆាំងនឹង ជម្លោះដីធ្លីមួយជាមួយក្រុមហ៊ុន DM Group ដែលជាក្រុមហ៊ុនមានខ្នងបង្អែកនៅពី ក្រោយ។ អាជ្ញាធរអះអាងថា លោក ប៉ែន ប៊ុនណា បានញុះញង់អ្នកភូមិ។
- នៅអំឡុងឆ្នាំ២០០៩ កន្លងទៅលោក ថោ សារ៉ន ជាចៅក្រមសាលាដំបូងខេត្តបានបង្ខំឲ្យលោក ប៉ែន ប៊ុនណា ចាកចេញពីខេត្តរតនៈគិរី ដោយប្រាប់សកម្មជនទាំងនេះថា គាត់នឹងប្រឈមនឹងការចោទប្រកាន់ពីបទញុះញង់ ប្រសិនបើគាត់មិនចាកចេញពីខេត្តនេះទេ។

**ថ្ងៃទី១៥ ខែមករា ឆ្នាំ២០១០**

**ករណីទី២**

### ការបំភិតបំភ័យតាមផ្លូវតុលាការទៅលើអ្នកតំណាងអាជីវករផ្សារ [២]

*ឃុំសាតពង ស្រុកឈូក ខេត្តកំពត*

- រួច ប៊ូ អ្នកតំណាងអាជីវកម្ម ត្រូវបានសាលាដំបូងខេត្តកំពត កោះហៅមកសាកសួរទាក់ទងនឹងការចោទប្រកាន់ពីបទបរិហារកេរ្តិ៍ បន្ទាប់ពីមានអាជីវករចំនួន ៣១៣ នាក់ កំពុងធ្វើការនៅឯផ្សារឈូក។ ការកោះហៅនេះ បានធ្វើឡើង បន្ទាប់ពីអាជីវករទាំងនោះ បានដាក់ពាក្យបណ្តឹងដើម្បីរារាំងមិនឲ្យក្រុមហ៊ុនអ៊ុកណារិន *(Ouk Narin Company)* រឹបអូសយកដីធ្លីនៅជិតផ្សារនោះ។

---

[១] Clancy McGilligan និងគួច ណារ៉ែន "តុលាការកោះហៅសកម្មជនការពារសិទ្ធិដីធ្លីនៅខេត្តរតនៈគីរី" កាសែត *The Cambodia Daily* ចេញផ្សាយថ្ងៃទី១២ ខែមករា ឆ្នាំ២០១០ ធ្វើបច្ចុប្បន្នភាពនៅថ្ងៃទី១៩ ខែមករា ឆ្នាំ២០១០។

[២] របាយការណ៍ឃ្លាំមើលសិទ្ធិមនុស្សអង្គការលីកាដូ ដែលមិនត្រូវបានបោះពុម្ពផ្សាយ: KP006SC10។

**ថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ ២០១០**

**ករណីទី៣**

## ការបំភិតបំភ័យតាមផ្លូវតុលាការទៅលើអ្នកសារព័ត៌មាន និងសកម្មជនសិទ្ធិមនុស្ស [៣]

***សាលាដំបូងខេត្តតាកែវ***

- លោក សុខ សេរី អ្នករាយការណ៍វិទ្យុអាស៊ីសេរី និងសកម្មជនមនុស្ស មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (CCHR) ចំនួន ២ នាក់ ឈ្មោះ ជៀប ជៀវ និងឃឹម សារ៉ុម ត្រូវបានចោទប្រកាន់ពីបទផ្សព្វផ្សាយព័ត៌មានមិនពិត និងបំផ្លិចបំផ្លាញទ្រព្យសម្បត្តិ បន្ទាប់ពីវិទ្យុអាស៊ីសេរីបានផ្សាយនូវរបាយការណ៍មួយ ស្តីពីការចាត់ចែងមិន ត្រឹមត្រូវនូវមូលនិធិ ដោយមេសាសនាម៉ូស្លិមតំបន់នោះ លោក នី សាន់ និងលោក សែប សេន ជាមេដឹកនាំសហគមន៍ក៏ត្រូវទទួលរងនូវការចោទប្រកាន់ដូចគ្នានេះដែរ។
- ករណីនេះ កើតចេញពីការធ្វើញត្តិមួយនៅឆ្នាំ២០០៧ ដែលត្រូវបានផ្តិតមេដៃ ដោយប្រជាពលរដ្ឋចំនួនប្រមាណ ២០៦ គ្រួសារ មកពីភូមិកំពង់យោល ស្រុកបូរីជលសា ដើម្បីទាមទារឲ្យមានការរៀបចំបោះឆ្នោតជាថ្មី ដើម្បីជ្រើសរើសមេដឹកនាំសម្រាប់សហគមន៍ជនជាតិភាគតិចចាម។ អ្នកភូមិបានធ្វើការចោទប្រកាន់គណៈកម្មាធិការមួយ ដែលមានប្រជាពលរដ្ឋជាសមាជិកចំនួន ៣ នាក់ រាប់ទាំងឈ្មោះ រៀម ម៉ាត់ ជាលោកសង្ឃចាមនៅមូលដ្ឋានពីបទបន្លំយកលុយវិភាគទានចំនួន ២,៥០០ ដុល្លារអាមេរិក។
- នៅថ្ងៃទី៩ខែកុម្ភៈ សាលាដំបូងខេត្តតាកែវ បានរកឃើញពិរុទ្ធភាពអ្នកភូមិម្នាក់ឈ្មោះ នី សាន់ ពីបទបំផ្លិចបំផ្លាញទ្រព្យសម្បត្តិ ហើយនឹងបានកាត់ទោសគាត់ឲ្យជាប់ពន្ធនាគារចំនួន ៥ ខែ និងពិន័យជាប្រាក់ចំនួន ១ លានរៀល ប៉ុន្តែជនត្រូវចោទផ្សេងទៀតត្រូវបានលើកលែងចោទប្រកាន់។

**ថ្ងៃទី១ ខែមីនា ឆ្នាំ២០១០**

**ករណីទី៤**

## អ្នកសារព័ត៌មានស៊ើបអង្កេតល្បែងស៊ីសងខុសច្បាប់ ត្រូវបានគេវាយដំយ៉ាងដំណំ [៤]

***ភូមិក្បាលស្ពាន ស្រុកប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ***

- លោក វង់ ថូ អ្នកសារព័ត៌មានកាសែតរស្មីកម្ពុជាត្រូវបានមនុស្ស ៣ នាក់វាយដំយ៉ាងដំណំក្នុងនោះមានទាហានកងខេមរៈភូមិន្ទ ១ នាក់ ឈ្មោះ ង៉ែម គ្រេម នៅពេលអ្នកសារព័ត៌មានរូបនោះ កំពុងធ្វើការស៊ើបអង្កេតទៅលើល្បែងស៊ីសងខុសច្បាប់។

---

[៣] Eang Mengleng "របាយការណ៍វិទ្យុអាស៊ីសេរី សកម្មជន ២ នាក់ត្រូវបានកាត់ទោសពីបទផ្សាយព័ត៌មានមិនពិតក្នុងខេត្តតាកែវ" កាសែត *The Cambodia Daily* ចេញផ្សាយនៅថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១០។ សូមមើលផងដែរ: Chhom Chansy "របាយការណ៍សកម្មជនត្រូវបានលើកលែងចោទប្រកាន់ពីបទផ្សាយព័ត៌មានមិនពិត" កាសែត *The Cambodia Daily* ចេញផ្សាយនៅថ្ងៃទី២០-២១ ខែកុម្ភៈ ឆ្នាំ២០១០។

[៤] របាយការណ៍ឃ្លាំមើលសិទ្ធិមនុស្សអង្គការលីកាដូ ដែលមិនត្រូវបានបោះពុម្ពផ្សាយ: BM041PA10។ សូមមើលផងដែរ: "សេរីភាពខាងការបញ្ចេញមតិនៅកម្ពុជា: ការបំភ័ន្តលទ្ធិប្រជាធិបតេយ្យ" របាយការណ៍អង្គការលីកាដូ នៅខែធ្នូ ឆ្នាំ២០១០ ករណីសិក្សាទី២៧។

- អ្នកវាយប្រហារទាំងនេះ ចង់រារាំងមិនឲ្យធ្វើការផ្សព្វផ្សាយរឿងរ៉ាវមួយ ដែលនិយាយពិស្តារអំពីការជាប់ពាក់ព័ន្ធរបស់ពួកគេក្នុងរង់ល្បែងស៊ីសងខុសច្បាប់មួយកន្លែង។
- ជនសង្ស័យទាំងនោះ ក្រោយមកត្រូវបាននគរបាលចាប់ខ្លួន ហើយត្រូវបានឃុំខ្លួនបណ្តោះអាសន្នអស់រយៈពេល ១ខែ។
- វង់ ចូ បានដកពាក្យបណ្តឹង ក្រោយពីទទួលបានលិខិតសុំទោសមួយច្បាប់ និងសំណង ដែលមិនដឹងចំនួនពីឈ្មោះ ង៉ែម គ្រេម និងក្រុមគ្រួសាររបស់គាត់។

**ថ្ងៃទី១១ ខែមីនា ឆ្នាំ២០១០**
**ករណីទី៥**

*[សូមមើលករណីទី៣០ និង១០៦ ផងដែរ]*

**ការបំភិតបំភ័យតាមផ្លូវតុលាការទៅលើអ្នកភូមិក្នុងជម្លោះដីធ្លី**[៥]
***ឃុំអមលាំង ស្រុកថ្ពង ខេត្តកំពង់ស្ពឺ***

- អ្នកភូមិចំនួន ៨ នាក់ក្នុងនោះមានស្ត្រី ២ នាក់ និងបុរស ៦ នាក់ ដែលមានអាយុចន្លោះពី២២ឆ្នាំ ទៅ៦០ឆ្នាំ ត្រូវបានសាលាដំបូងខេត្តកំពង់ស្ពឺហៅមកសាកសួរជុំវិញការចោទប្រកាន់ពីបទបំផ្លិចបំផ្លាញទ្រព្យសម្បត្តិ ទាក់ទងនឹងជម្លោះដីធ្លីមួយពាក់ព័ន្ធនឹងក្រុមហ៊ុនមួយរបស់ឧកញ៉ា លី យ៉ុងផាត់ ដែលជាសមាជិកព្រឹទ្ធសភាគណបក្សប្រជាជន។
- សមាជិកព្រឹទ្ធសភារូបនេះ បានធ្វើការចោទប្រកាន់អ្នកភូមិថា ជាមេខ្លោងទទួលខុសត្រូវក្នុងការលើកទឹកចិត្តឲ្យអ្នកភូមិតវ៉ាប្រឆាំងនឹងការបណ្តេញពួកគេ ចេញពីដីធ្លីដោយបង្ខំ ដើម្បីយកដីចំនួន ២០,០០០ ហិកតា ធ្វើចំការអំពៅ។

**ថ្ងៃទី៨ ខែមេសា ឆ្នាំ២០១០**
**ករណីទី៦**

**ការចាប់ខ្លួន និងការឃុំខ្លួនខុសច្បាប់នៅពេលធ្វើការតវ៉ាដីធ្លី**[៦]
***ឃុំព្រះផុស ស្រុកគាស់ក្រឡ ខេត្តបាត់ដំបង***

- ចាន់ ហឿ អ្នកតំណាងមកពីសហគមន៍មួយទាក់ទងនឹងជម្លោះដីធ្លីមួយ ត្រូវបានសាលាដំបូងខេត្តបាត់ដំបងចោទប្រកាន់ពីបទចោរកម្ម ហើយត្រូវឃុំខ្លួនបណ្តោះអាសន្ន។
- ការចោទប្រកាន់ទៅលើ ចាន់ ហឿ នេះ បានកើតចេញពីពាក្យបណ្តឹងមួយ ដែលត្រូវធ្វើឡើងដោយទាហានកងខេមរៈភូមិន្ទមួយរូបឈ្មោះ លីម ទាលៀង និងអ្នកជំនួញឈ្មោះ ហែម ហឿន និងអួន គុន ដែលទាមទារកម្មសិទ្ធិលើដីធ្លីចំនួន ១៥០ ហិកតា ដែលប្រជាពលរដ្ឋចំនួន ៣៨គ្រួសារ កំពុងធ្វើការដាំដុះអស់រយៈពេលជាច្រើន

[៥] គួច ណារ៉ែន "អ្នកភូមិនៅខេត្តកំពង់ស្ពឺត្រូវបានហៅមកសាកសួរ អំពីការតវ៉ាប្រឆាំងនឹងការបណ្តេញចេញ" កាសែត *The Cambodia Daily* ចេញផ្សាយ នៅថ្ងៃទី ១២ ខែមីនា ឆ្នាំ២០១០។

[៦] គួច ណារ៉ែន "អ្នកភូមិនៅខេត្តបាត់ដំបង ធ្វើការតវ៉ានឹងការឃុំខ្លួនអ្នកតំណាង" កាសែត The Cambodia Daily ចេញផ្សាយនៅថ្ងៃទី៨ ខែមេសា ឆ្នាំ២០១០។

ទសវត្សរ៍មកហើយ។

**ថ្ងៃទី៨ ខែមេសា ឆ្នាំ២០១០**
**ករណីទី៧**

**អ្នកសារព័ត៌មានត្រូវទទួលរងការរំខានយាយីក្រោយពីធ្វើការថតរូបភាពនូវអំពើពុករលួយ[៧]**
***ខេត្តសៀមរាប***

- លោក គេង ផុន អ្នកសារព័ត៌មានស្ថាបនាជាតិខ្មែរ ត្រូវបានតុលាការកោះហៅដើម្បីធ្វើការសាកសួរ ក្រោយពីព្យាយាមថតរូបមន្ត្រីរដ្ឋបាលព្រៃឈើចំនួន ២នាក់ ដែលកំពុងទទួលលុយកាក់ជាសំណូក។
- នៅក្នុងខែមីនា ឆ្នាំ២០១០ លោក គេង ផុន បានព្យាយាមថតរូបមន្ត្រីព្រៃឈើ ដែលបានទទួលលុយចំនួន ៨០,០០០ រៀល ជាសំណូកពីម្ចាស់រទេះចំនួន ៣ នាក់ ដែលកំពុងដឹកឈើខុសច្បាប់ចេញពីឃុំកំពង់ខ្លែង។ នៅពេលអ្នកសារព័ត៌មាននោះ សាកសួរពួកគេ មន្ត្រីទាំងនោះបានធ្វើការឃាត់ខ្លួនគាត់ ហើយនឹងលុបចោលរូបភាព ទាំងអស់ពីម៉ាស៊ីនដែលគាត់បានថត។ បន្ទាប់មក ពួកគេបានដាក់ពាក្យបណ្តឹង ដែលគ្មានមូលដ្ឋានទៅតុលាការប្រឆាំងនឹងលោក គេង ផុន។

**ថ្ងៃទី២១ ខែមេសា ឆ្នាំ២០១០**
**ករណីទី៨**

*[សូមមើលករណីទី១០ និង១៦ ផងដែរ]*

**ការប៉ុនប៉ងធ្វើឃាតសកម្មជនការពារសិទ្ធិដីធ្លី[៨]**
***ភូមិចម្លងរមាំងលើ ឃុំអូរសម្រែ ស្រុកសំឡូត ខេត្តបាត់ដំបង***

- ទាហានមិនស្គាល់អត្តសញ្ញាណ ២ នាក់ បានបាញ់កាំភ្លើងចំនួន ៨ គ្រាប់ទៅលើ ស៊ិមម៉ី ជាសកម្មជនសហគមន៍ទាក់ទងនឹងដីធ្លីកំពុងមានជម្លោះមួយជាមួយមន្ត្រីយោធាក្នុងតំបន់។ រហូតមកទល់ថ្ងៃនេះ គ្មានមន្ត្រីយោធាណាម្នាក់ត្រូវបានចាប់ខ្លួនឡើយ។

**ថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១០**
**ករណីទី៩**

**ការប៉ុនប៉ងធ្វើឃាតសកម្មជនការពារសិទ្ធិដីធ្លី[៩]**
***ភូមិសន្តិភាព ឃុំបឹងបេង ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ***

- នូ លែង ជាសកម្មជនសហគមន៍ និងប្តីរបស់គាត់ឈ្មោះ អ៊ុម គឹមសាន គឺជាជនរងគ្រោះពីការប៉ុនប៉ងធ្វើឃាត ដែលប្រព្រឹត្តដោយប្រជាពលរដ្ឋមួយក្រុមចំនួន ៥០ នាក់ ដឹកនាំដោយ សៀ ហ៊ុយ ជាប្រធានភូមិសន្តិភាព។
- ក្រុមប្រជាពលរដ្ឋនេះ បានបំផ្លិចបំផ្លាញ ហើយដុតផ្ទះសម្បែងរបស់អ្នកភូមិ ដើម្បីរឹប

---

[៧] "សេរីភាពខាងការបញ្ចេញមតិនៅកម្ពុជា: ការបំភ័ន្តលទ្ធិប្រជាធិបតេយ្យ" របាយការណ៍អង្គការលីកាដូ នៅខែធ្នូ ឆ្នាំ២០១០ ករណីសិក្សាទី២៨។ សូមមើលផងដែរ: ម៉ៃ ទិតថារ៉ា (May Titthara) "អ្នកសារព័ត៌មានត្រូវបានតុលាការកោះហៅសាកសួរជុំវិញការថតរូបភាព" កាសែត The Phnom Penh Post ចេញផ្សាយ នៅថ្ងៃទី៨ ខែមេសា ឆ្នាំ២០១០។ រ៉ាន់ រើយ (Rann Reuy) "របាយការណ៍ខេត្តសៀមរាបផ្តល់សក្ខីកម្ម" កាសែត The Phnom Penh Post ចេញផ្សាយ នៅថ្ងៃទី៩ ខែមេសា ឆ្នាំ២០១០។

[៨] របាយការណ៍ឃ្លាំមើលសិទ្ធិមនុស្សអង្គការលីកាដូ ដែលមិនត្រូវបានបោះពុម្ពផ្សាយ: BB029AK10។

[៩] របាយការណ៍ឃ្លាំមើលសិទ្ធិមនុស្សអង្គការលីកាដូ ដែលមិនត្រូវបានបោះពុម្ពផ្សាយ: BM055AK10។

អូសយកដីធ្លីរបស់ពួកគេលក់។ ដៃឆ្វេងរបស់ នូ លែង បានទទួលរងរបួសជាទម្ងន់ក្នុងការវាយប្រហារនោះ ចំណែកឯប្ដីរបស់គាត់បានទទួលរងរបួសក្បាលជាច្រើនអន្លើ។

**ថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១០**

**ករណីទី១០**

*[សូមមើលករណីទី៨ ផងដែរ]*

**សកម្មជនការពារសិទ្ធិដីធ្លី ត្រូវបានគេសម្លាប់** [១០]

***ភូមិចម្លងរមាំងលើ ឃុំសម្រែ ស្រុកសំឡូត ខេត្តបាត់ដំបង***

- ពេជ្រ សុផុន ជាតំណាងសហគមន៍មួយរូបត្រូវបានស្លាប់ បន្ទាប់ពីជនមិនស្គាល់មុខចំនួន ៣ នាក់បានបាញ់នឹងកាំភ្លើង AK-47 យ៉ាងហោចណាស់ចំនួន ៨គ្រាប់។
- នៅពេលកំពុងបាញ់សម្លាប់ ពេជ្រ សុផុន កំពុងធ្វើដំណើរដើម្បីប្រមូលស្នាមម្រាមដៃសម្រាប់ធ្វើញត្តិមួយដើម្បីគាំទ្រ ស៊ិម ម៉ី ជាអ្នកតំណាងសហគមន៍ដូចគ្នា ដែលជាអ្នករងគ្រោះពីការប៉ុនប៉ងធ្វើឃាតនៅអំឡុងដើមខែមេសា ឆ្នាំ២០១០។
- ពេជ្រ សុផុន គឺជាសកម្មជនការពារសិទ្ធិដីធ្លីយ៉ាងសកម្មមួយរូប។ បន្ថែមទៅលើការរៀបចំញត្តិសម្រាប់គាំទ្រ ស៊ិម ម៉ី។ ពេជ្រ សុផុន បានរារាំងគ្រឿងចក្រមិនឲ្យធ្វើការឈូសឆាយដីធ្លី ផ្ដល់ផ្ទះសម្បែងរបស់គាត់សម្រាប់ឲ្យសហគមន៍ធ្វើការប្រជុំពិភាក្សា ហើយគាត់ គឺជាសាក្សីតែមួយគត់ ដែលហ៊ាននិយាយទៅកាន់នគរបាលអំពីការធ្វើឃាតទៅលើ ស៊ិម ម៉ី។
- រហូតមកទល់បច្ចុប្បន្ននេះ គ្មានជនសង្ស័យណាម្នាក់ត្រូវបានចាប់ខ្លួនក្នុងករណីប៉ុនប៉ងធ្វើឃាតនេះឡើយ។

**ថ្ងៃទី៣ ខែឧសភា ឆ្នាំ២០១០**

**ករណីទី១១**

*[សូមមើលករណីទី១៥ ផងដែរ]*

**អ្នកតំណាងភូមិត្រូវបានចាប់ខ្លួន បន្ទាប់ពីបានដឹកនាំការតវ៉ាមួយ** [១១]

***ឃុំគ្រោះ ស្រុករមាសហែក ខេត្តស្វាយរៀង***

- យៀ យឿង ជាអ្នកតំណាងភូមិត្រូវបានចាប់ខ្លួន ១ថ្ងៃ បន្ទាប់ពីបានដឹកនាំអ្នកភូមិចំនួន ១០០នាក់ ដើម្បីធ្វើការប្រមូលផ្ដុំនៅមុខក្រុមហ៊ុនកៅស៊ូពាមចាំង (Peam Chaing Rubber Company) ដែលជាក្រុមហ៊ុនរបស់ឧកញ៉ា អាន ម៉ាឌី ក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីបញ្ចុះបញ្ចូលក្រុមហ៊ុននេះឲ្យបើកផ្លូវឡើងវិញ ដែលត្រូវបានកាត់ផ្ដាច់អស់រយៈពេល ៥ ថ្ងៃកន្លងមកហើយ។

[១០] របាយការណ៍ឃ្លាំមើលសិទ្ធិមនុស្សអង្គការលីកាដូ ដែលមិនត្រូវបានបោះពុម្ពផ្សាយ: BB035K10។ សូមមើលផងដែរ: "សេរីភាពខាងការបញ្ចេញមតិនៅ កម្ពុជា: ការបំភ័ន្តលទ្ធិប្រជាធិបតេយ្យ" supra ករណីសិក្សាទី២៦។

[១១] ម៉ៃ ទិតថារ៉ា "ជម្លោះដីធ្លី: អ្នកភូមិនៅខេត្តស្វាយរៀងធ្វើបាតុកម្ម" កាសែត The Phnom Penh Post ចេញផ្សាយនៅថ្ងៃទី៤ ខែឧសភា ឆ្នាំ២០១០។ សូមមើលផងដែរ: http://ki-media.blogspot.com/2010/05/land-dispute-villagers-in-svay-rieng.html។

- លោក ជុំ រី អធិការនគរបាលស្រុកបានចោទប្រកាន់ យៀ យឿង ពីបទ ***គំរាម***កំហែងមន្ត្រីកងរាជអាវុធហត្ថមួយរូប នៅអំឡុងពេលធ្វើការតវ៉ានោះ។
- អ្នកភូមិធ្វើការចោទប្រកាន់ក្រុមហ៊ុនពីបទទន្ទ្រានយកចំការដំឡូងមី និងចំការចន្ទីរបស់ប្រជាពលរដ្ឋចំនួនប្រហែលជា ៩០០គ្រួសារ។ ពួកគេបានដាក់ពាក្យបណ្តឹងជូនអភិបាលស្រុកប្រឆាំងនឹងក្រុមហ៊ុននោះនៅក្នុងខែធ្នូ ឆ្នាំ២០០៩ ប៉ុន្តែមិនបានទទួលការឆ្លើយតបណាមួយឡើយ។

**ថ្ងៃទី៥ ខែឧសភា ឆ្នាំ២០១០**
**ករណីទី១២**

*[សូមមើលករណីទី៩០ ផងដែរ]*

**ការគំរាមកំហែង ការរំខានយាយី និងការបំភិតបំភ័យទៅលើអ្នកតំណាងសហគមន៍** [១២]
***ភូមិជ័យសេនា ឃុំតាកែន ស្រុកឈូក ខេត្តកំពត***

- អ្នកតំណាងសហគមន៍ចំនួន ៦នាក់ (ចៀន មិន រុំ ណាក់ ម៉ាច ញឹក ម៉ុម នុត សឿន ស៊ិន និងកាត ទាម) ត្រូវបាន ទិត សុខ សុវណ្ណា និងតុប វីរៈ ជាអ្នកតំណាងក្រុមហ៊ុនហេងយ៉ុង ផាក *(Hengyong Phak company)* ធ្វើការគំរាមកំហែង ដោយចោទប្រកាន់ជនរងគ្រោះពីបទរំលោភបំពាន និងបំផ្លិចបំផ្លាញទ្រព្យសម្បត្តិឯកជនទាក់ទងនឹងដីធ្លី ដែលកំពុងមានជម្លោះមួយ។
- នៅថ្ងៃទី២០ ខែតុលា ឆ្នាំ២០១១ សាលាដំបូងខេត្តកំពតបានកោះហៅអ្នកតំណាងសហគមន៍ចំនួន ៦នាក់ មកធ្វើការសាកសួរទាក់ទងនឹងការចោទប្រកាន់ទាំងអស់នោះ។

**ថ្ងៃទី៧ ខែឧសភា ឆ្នាំ២០១០**
**ករណីទី១៣**

**ការចាប់ខ្លួន និងការឃុំខ្លួនខុសច្បាប់លើសកម្មជនសហគមន៍** [១៣]
***ភូមិកុយវែង ឃុំព្រះផុស ស្រុកគាស់ក្រឡ ខេត្តបាត់ដំបង***

- ចាន់ ហឿ ជាអ្នកតំណាងសហគមន៍ ត្រូវបានឃុំខ្លួនក្នុងពន្ធនាគារខេត្តបាត់ដំបង បន្ទាប់ពីត្រូវបានចោទប្រកាន់ពីបទបំផ្លិចបំផ្លាញទ្រព្យសម្បត្តិឯកជន ក្រោយពីមានពាក្យបណ្តឹងមួយដែលត្រូវបានធ្វើឡើងដោយលោក លឹម ទាលែង ជាមេបញ្ជាការយោធាមួយរូប និងកូនទាហានរបស់គាត់។
- ចាន់ ហឿ បានធ្វើជាអ្នកតំណាងឲ្យប្រជាពលរដ្ឋចំនួន ៣៨ គ្រួសារ ដែលជាប់ពាក់ព័ន្ធក្នុងជម្លោះដីធ្លីមួយជាមួយសមាជិកយោធា។

---

[១២] របាយការណ៍ឃ្លាំមើលសិទ្ធិមនុស្សអង្គការលីកាដូ ដែលមិនត្រូវបានបោះពុម្ពផ្សាយ: KP031THI10។

[១៣] របាយការណ៍ឃ្លាំមើលសិទ្ធិមនុស្សអង្គការលីកាដូ ដែលមិនត្រូវបានបោះពុម្ពផ្សាយ: BB0361AD10។

**ថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០១០**

**ករណីទី១៤**

**ឧបសគ្គនៃសេរីភាពខាងការជួបប្រជុំ និងការរំខានយាយី**[១៤]

***ភូមិបឹងស្នុក ឃុំស្វាយស ស្រុកក្រគ ខេត្តពោធិ៍សាត់***

- គុច វែង និងលួន ស៊ីវី ជាសមាជិកបណ្ដាញកសាងសន្តិភាពសហគមន៍ត្រូវបានលោក ខ្លឹម យ៉ុន ជាមេនគរបាលរដ្ឋបាលឃុំ និងលោក ហុង ថាង ជាមេឃុំព្រមទាំងសមាជិកក្រុមប្រឹក្សាឃុំចំនួន ៦នាក់ទៀត ធ្វើការរារាំងមិនឲ្យជួបប្រជុំក្នុងផ្ទះឯកជនមួយ។ ពួកអាជ្ញាធរបានចោទប្រកាន់ពួកគេថា ជាសមាជិកគណបក្សប្រឆាំង។

**ថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១០**

**ករណីទី១៥**

*[សូមមើលករណីទី១១ ផងដែរ]*

**នគរបាលរាំងខ្ទប់អ្នកភូមិមិនឲ្យទៅចូលរួមសវនាការនៅតុលាការប្រឆាំងនឹងអ្នកតំណាង**[១៥]

***ស្រុករមាសហែក ខេត្តស្វាយរៀង***

- អ្នកភូមិប្រមាណជា ៥០នាក់ បានធ្វើដំណើរទៅកាន់សាលាដំបូងខេត្តស្វាយរៀង ដើម្បីទាមទារឲ្យមានការដោះលែងមេដឹកនាំសហគមន៍របស់ពួកគេ ពីការឃុំខ្លួនបណ្ដោះអាសន្ន។
- អ្នកភូមិបានពាក់ព័ន្ធក្នុងជម្លោះដីធ្លីមួយ ជាមួយក្រុមហ៊ុនកៅស៊ូពាមចាំងរបស់ អាន ម៉ាឌី ចាប់តាំងពីឆ្នាំ២០០៧ មកម្ល៉េះ។ មេសហគមន៍ត្រូវបានគេឃុំខ្លួន បន្ទាប់ពីគាត់បានទទួលរងនូវការគំរាមកំហែង និងការបំភិតបំភ័យពីអាជ្ញាធរក្នុងតំបន់ជាច្រើនឆ្នាំមកហើយ។
- ក្រុមអ្នកភូមិ ដែលមានចំនួន ៥០នាក់ ដំបូងដឹកនាំដោយព្រះសង្ឃមួយអង្គត្រូវបានកងរាជអាវុធហត្ថឃាត់ឲ្យឈប់នៅឯស្ពានមួយក្នុងស្រុកកំពង់ត្រាច។ អាជ្ញាធរបានបង្ខំព្រះសង្ឃអង្គនោះ ឲ្យផ្ដិតម្រាមដៃលើឯកសារមួយ ដោយធ្វើការសន្យាថាលោកនឹងមិនដឹកនាំក្បួនដង្ហែរបែបនេះទៀតឡើយ។ ក្រុមអ្នកភូមិក្រោយមកក៏ត្រូវបានអាជ្ញាធរអនុញ្ញាតឲ្យធ្វើដំណើរបន្តទៅមុខ។
- ក្រោយមកអ្នកភូមិក្នុងក្រុមទី២ បានចាប់ផ្ដើមដើរទៅកាន់បន្ទប់សវនាការ។ អាជ្ញាធរបានបឈ្ឈប់ និងធ្វើការរំខានពួកគេដោយបិទផ្លូវជាលើកទី២។ នៅទីបំផុតអ្នកភូមិចំនួនប្រមាណជា ២០០នាក់ ក៏បានដើរទៅកាន់បន្ទប់សវនាការ។

---

[១៤] របាយការណ៍ឃ្លាំមើលសិទ្ធិមនុស្សអង្គការលីកាដូ ដែលមិនត្រូវបានបោះពុម្ពផ្សាយ: PS016THI10។

[១៥] "សេរីភាពខាងការបញ្ចេញមតិនៅកម្ពុជា: ការបំភ័ន្តលទ្ធិប្រជាធិបតេយ្យ" supra ករណីសិក្សាទី៣។

**ថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១០**
**ករណីទី១៦**

*[សូមមើលករណីទី៨ផងដែរ]*

**ការចាប់ខ្លួន និងការឃុំខ្លួនខុសច្បាប់ចំពោះសកម្មជនការពារសិទ្ធិដីធ្លី [១៦]**
***ភូមិអូរចម្លងរមាំងលើ ឃុំអូរសម្រែ ស្រុកសំឡូត ខេត្តបាត់ដំបង***

- ស៊ិម ម៉ី និងម៉ៃ នី ជាអ្នកតំណាងសហគមន៍ត្រូវបានលោក សាអឿន កោសល្យមុនី ជាចៅក្រមស៊ើបសួរសាលាដំបូងខេត្តបាត់ដំបងកោះហៅមកសាកសួរ។ ការកោះហៅនេះ មានជាប់ទាក់ទងនឹងជម្លោះដីធ្លីមួយជាមួយសមាជិកយោធា។
- អ្នកតំណាងសហគមន៍ទាំងនេះ ត្រូវបានចោទប្រកាន់ក្នុងបណ្តឹងព្រហ្មទណ្ឌមួយពីបទបំផ្លិចបំផ្លាញទ្រព្យសម្បត្តិឯកជន និងដុតត្រាក់ទ័រមួយគ្រឿង។ អ្នកតំណាងទាំងនេះ បដិសេធនូវការចោទប្រកាន់នេះ ហើយអះអាងថា ពួកគេបានទទួលការព្យាបាលផ្នែកវេជ្ជសាស្ត្រនៅចំថ្ងៃនៃព្រឹត្តិការណ៍ទាំងនោះ។ អ្នកភូមិ និងអ្នកធ្វើការខាងសិទ្ធិមនុស្សចំនួនប្រមាណជា ១០០នាក់ បានផ្តល់សក្ខីកម្មផងដែរថា ជនត្រូវចោទមិនមានវត្តមាននៅថ្ងៃនោះទេ។
- ម៉ៃ នី ត្រូវបានដោះលែងឲ្យមានសេរីភាពឡើងវិញ បន្ទាប់ពីតុលាការបានសាកសួរ ប៉ុន្តែ ស៊ិម ម៉ី ត្រូវបានចាប់ខ្លួន ហើយនឹងបញ្ជូនខ្លួនទៅពន្ធនាគារខេត្តបាត់ដំបង ដើម្បីឃុំខ្លួនបណ្តោះអាសន្ន។

**ថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១០**
**ករណីទី១៧**

*[សូមមើលករណីទី៤១ ផងដែរ]*

**ការបង្ក្រាបហិង្សាពីនគរបាលទៅលើការតវ៉ាដោយអហិង្សា [១៧]**
***ឃុំកំពង់សំណាញ់ ស្រុកតាខ្មៅ ខេត្តកណ្តាល***

- បាតុករចំនួនប្រមាណជា ១០០ នាក់ ដែលតំណាងឲ្យប្រជាពលរដ្ឋចំនួន ២៩២ គ្រួសារពាក់ព័ន្ធក្នុងជម្លោះដីធ្លីមួយដ៏រ៉ាំរ៉ៃជាមួយក្រុមហ៊ុនហេងអភិវឌ្ឍន៍ (Heng Development Company) ត្រូវបានមន្ត្រីនគរបាល និងមន្ត្រីកងរាជអាវុធហត្ថខ័ណ្ឌដូនពេញចំនួន ៧២នាក់ ធ្វើការបំបែកយ៉ាងហិង្សានៅអំឡុងពេលធ្វើការតវ៉ាមួយនៅមុខផ្ទះរបស់នាយករដ្ឋមន្ត្រី ហ៊ុន សែន។

**ថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១០**
**ករណីទី១៨**

**បុគ្គលិកអង្គការលីកាដូ ត្រូវបានចាប់ខ្លួន និងចោទប្រកាន់ពីបទផ្សាយព័ត៌មានមិនពិត [១៨]**
***ខណ្ឌសែនសុខ រាជធានីភ្នំពេញ***

- លោក លាង សុខជឿន ជាបុគ្គលិកអង្គការលីកាដូ ត្រូវបានចាប់ខ្លួនពីបទផ្សាយ

---

[១៦] របាយការណ៍ឃ្លាំមើលសិទ្ធិមនុស្សអង្គការលីកាដូ ដែលមិនត្រូវបានបោះពុម្ពផ្សាយ: BB045IAD10។

[១៧] របាយការណ៍ឃ្លាំមើលសិទ្ធិមនុស្សអង្គការលីកាដូ ដែលមិនត្រូវបានបោះពុម្ពផ្សាយ: PP063OFEA10។

[១៨] Saing Soenthrith "អ្នកធ្វើការក្រុមសិទ្ធិមនុស្ស ត្រូវបានចាប់ខ្លួនពីបទផ្សាយព័ត៌មានមិនពិត" កាសែត The Cambodia Daily ចេញផ្សាយនៅថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១០។

*[សូមមើលករណី ទី៣៨ និង៧៩ ផងដែរ]*

ព័ត៌មានមិនពិតសម្រាប់ការពាក់ព័ន្ធរបស់គាត់ក្នុងការចែកចាយខិត្តប័ណ្ណទាក់ទងនឹងថ្ងៃរំដោះ ៧ មករា។ តាមពិតដីកាចាប់ខ្លួនកំណត់ឈ្មោះមនុស្សផ្សេង ប៉ុន្តែនគរបាលចាប់ខ្លួន លោក សុខជឿនទៅវិញ។

- បន្ទាប់ពីការចាប់ខ្លួនគាត់ លោក លាង សុខជឿន ត្រូវបានឃុំខ្លួន ដោយគ្មានសិទ្ធិប្រាស្រ័យទាក់ទងជាមួយក្រុមគ្រួសារ ឬមេធាវីរបស់គាត់ឡើយ ហើយបានទទួលការអនុញ្ញាតឲ្យជួបមេធាវីសម្រាប់រយៈពេលតែ ២៥នាទីប៉ុណ្ណោះ មុនពេលបញ្ជូនខ្លួនទៅកាន់ពន្ធនាគារខេត្តតាកែវ ដើម្បីឃុំខ្លួនបណ្តោះអាសន្ន។
- នៅពេលកំពុងឃាត់ខ្លួន ដោយនគរបាល លោក លាង សុខជឿន បានទទួលរងនូវវិធីសាស្រ្តសួរចម្លើយផ្សេងៗ ដែលរាប់ទាំងការគំរាមកំហែង ហើយនឹងការសន្យាមិនពិតថានឹងផ្តល់ការអត់អោនក្នុងគោលដៅជម្រិតយកចម្លើយសារភាព។

**ថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១០**
**ករណីទី១៩**

## ការបង្ក្រាបពីអាជ្ញាធរទៅលើការប្រមូលផ្តុំទាមទារសិទ្ធិដីធ្លីដោយអហិង្សា [១៩]

***ស្រុកមេមត់ ខេត្តកំពង់ចាម***

- អាជ្ញាធរស្រុកបានព្យាយាមរារាំងអ្នកភូមិមួយក្រុមចំនួន ១០០នាក់ មិនឲ្យធ្វើដំណើរទៅកាន់រាជធានីភ្នំពេញ ដើម្បីប្តឹងអាជ្ញាធរឲ្យយកចិត្តទុកដាក់ទៅលើជម្លោះដីធ្លីដ៏រ៉ាំរ៉ៃរបស់ពួកគេជាមួយមន្រ្តីយោធា។
- ដើម្បីជៀសវាងពីការឃាត់ខ្លួន ក្រុមអ្នកភូមិទាំងនោះ បានចេញដំណើរជាក្រុមតូចៗនៅពេលយប់។ អ្នកភូមិចំនួនប្រហែល ១០០នាក់ បានធ្វើដំណើរទៅកាន់រាជធានីភ្នំពេញ រីឯក្រុមអ្នកភូមិខ្លះទៀតត្រូវបានអាជ្ញាធរឃាត់ខ្លួន។
- បន្ទាប់ពីពួកគេបានមកដល់រាជធានីភ្នំពេញបាន ២ថ្ងៃ អាជ្ញាធរខណ្ឌដូនពេញ បានប្រើកម្លាំងបណ្តេញអ្នកភូមិទាំងនោះចេញពីកន្លែងតវ៉ា ហើយបានប្រាប់ពួកគេឲ្យវិលត្រឡប់ទៅផ្ទះសម្បែងវិញ។

**ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១០**
**ករណីទី២០**

## ការតវ៉ាទាមទារដីធ្លី ត្រូវបានរាំងខ្ទប់ដោយនគរបាល [២០]

***រាជធានីភ្នំពេញ***

- បណ្តាញកសាងសន្តិភាពកម្ពុជា (CPN) បានរៀបចំការតវ៉ាមួយដោយមានអ្នក

[១៩] "សេរីភាពខាងការបញ្ចេញមតិនៅកម្ពុជា: ការបំភ័ន្តលទ្ធិប្រជាធិបតេយ្យ" *supra* ករណីសិក្សាទី៦។

[២០] "សេរីភាពខាងការបញ្ចេញមតិនៅកម្ពុជា: ការបំភ័ន្តលទ្ធិប្រជាធិបតេយ្យ" supra ករណីសិក្សាទី៧។

*[សូមមើលករណីទី៧៥ និង១១៤ ស្តីពីលោកសង្ឃ លួន សូវ៉ាត ផងដែរ]*

តំណាងសហគមន៍ចូលរួមចំនួនប្រហែល ៣៥០នាក់ ដែលសហគមន៍របស់ពួកគេពាក់ព័ន្ធក្នុងជម្លោះដីធ្លីទូទាំងប្រទេស។ ជម្លោះដីធ្លីទាំងអស់មានការពាក់ព័ន្ធនឹង ក្រុមហ៊ុន ដែលបានទទួលដីសម្បទានសេដ្ឋកិច្ចពីរាជរដ្ឋាភិបាល។ CPN គឺជាអង្គការក្នុងស្រុកមួយ ដែលមានគោលដៅទាក់ទាញអាជ្ញាធរឲ្យយកចិត្តទុកដាក់ទៅលើជម្លោះដីធ្លី។

- បាតុករមានផែនការណ៍ដើរជាក្បួនចេញពីវត្តបុទុមវតី ទៅកាន់ភូមិគ្រឹះនាយករដ្ឋមន្ត្រី ហ៊ុន សែន នៅជិតវិមានឯករាជ្យ។ ទោះបីយ៉ាងណាក៏ដោយ ទាហាននិងមន្ត្រីនគរបាលរាជធានីភ្នំពេញប្រដាប់ ដោយដំបង ខែល និងកាំភ្លើងបាញ់ឧស្ម័នបង្ហូរទឹកភ្នែក ព្រមទាំងកាំភ្លើងខ្លីបានរាំងខ្ទប់ផ្លូវ។
- នៅពេលកំពុងប្រមូលផ្តុំគ្នាព្រះតេជគុណ លួន សូវ៉ាត ត្រូវបានអាជ្ញាធររំខានយាយីដោយសារថតយករូបភាព។ នគរបាលបានចោទប្រកាន់ព្រះអង្គថា មិនមែនជាព្រះសង្ឃពិតប្រាកដ ហើយក៏បានរឹបអូសយករូបថតទាំងនោះ។
- អ្នកតំណាងមួយរូបមកពីការិយាល័យនាយករដ្ឋមន្ត្រី ទីបំផុតបានយល់ព្រមទទួលយកញត្តិចំនួន ៣ប្រអប់ ហើយបានប្រាប់ឲ្យអ្នកតំណាងសហគមន៍វិលត្រឡប់ទៅផ្ទះសម្បែងវិញ។ ក្រោយមកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានហៅក្រុមសិទ្ធិមនុស្ស ថាជា "អង្គការស្រមោល" ហើយចោទប្រកាន់អង្គការទាំងនោះពីបទរៀបចំដើរក្បួន។

**ថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០១០**
**ករណីទី២១**

## សកម្មជនត្រូវទទួលរងនូវការគំរាមកំហែង ដោយសារគ្រោងរៀបចំការបណ្តុះបណ្តាលសិទ្ធិដីធ្លី[២១]

### *ឃុំស្វាភី ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ*

- អាន ស៊ីលី ជាសមាជិកបណ្តាញកសាងសន្តិភាពកម្ពុជាមួយរូប ហើយជាប្រធានគណបក្សសិទ្ធិមនុស្សប្រចាំស្រុកអូរជ្រៅ បានទទួលរងនូវការគំរាមកំហែងពីលោក ខាត់ សារ៉ន ជាប្រធានការិយាល័យស្រុក និងលោក ផាត់ ញ៉ាញ់ ជាមេនគរបាលរដ្ឋបាលឃុំស្វាភី បន្ទាប់ពីបានស្នើសុំរៀបចំវគ្គបណ្តុះបណ្តាលសម្រាប់សហគមន៍ស្តីពីការការពារសិទ្ធិដីធ្លី។
- អាជ្ញាធរបានប្រាប់គាត់ជាច្រើនលើកថា អភិបាលស្រុក "ចង់ជួបរូបគាត់" ប៉ុន្តែមិនប្រាប់ឲ្យដឹងពីពេលវេលា ឬទីកន្លែងសម្រាប់ការណាត់ជួបនោះទេ។ អាន ស៊ីលី បាន

[២១] របាយការណ៍ឃ្លាំមើលសិទ្ធិមនុស្សអង្គការលីកាដូ ដែលមិនត្រូវបានបោះពុម្ពផ្សាយ: BM088THI10។

និយាយ ថាគាត់មានអារម្មណ៍ថា គេគំរាមកំហែង ហើយភ័យខ្លាចថាគាត់នឹងត្រូវចាប់ខ្លួន ប្រសិនបើគាត់ទៅជួបអភិបាលស្រុក។

**ថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០១០**
**ករណីទី២២**

**អ្នកសារព័ត៌មាន ដែលស៊ើបអង្កេតការណ៍កាប់ឈើខុសច្បាប់ ទទួលរងការគំរាមកំហែងដល់អាយុជីវិត** [២២]

***ខេត្តក្រចេះ***

- មន្ត្រីកងរាជអាវុធហត្ថម្នាក់នៅខេត្តក្រចេះ បានគំរាមសម្លាប់អ្នកសារព័ត៌មាន ២នាក់ បន្ទាប់ពីពួកគេបានថតយករូបភាពនូវប្រតិបត្តិការកាប់ឈើខុសច្បាប់។
- អក ង៉ុន និងថុន សុគង់ ជាអ្នកសារព័ត៌មាន បានស្គាល់មន្ត្រីកងរាជអាវុធហត្ថរូបនោះ ថា ជាឈ្មោះ ជា សាំងហុង។
- អ្នកសារព័ត៌មានទាំងនោះ អះអាងថា បន្ទាប់ពីពួកគេធ្វើការស៊ើបអង្កេតមន្ត្រីកងរាជអាវុធហត្ថនោះ ហើយនឹងសហការីរបស់គាត់បានមកកាន់ការិយាល័យរបស់ ពួកគេ ដាល់ លោក ថុន សុគង់ ចំផ្ទៃមុខ ហើយបានគំរាមថាពួកគេនឹង "បាត់ខ្លួន" ប្រសិនបើពួកគេបន្តធ្វើការស៊ើបអង្កេត។ មន្ទាប់មកក្រុមមន្ត្រីកងរាជអាវុធហត្ថនោះ ក៏បានវិលត្រឡប់ទៅវិញ ហើយបានគប់ដុំថ្មទៅលើការិយាល័យរបស់អ្នកសារព័ត៌មានទាំងនោះ ដោយធ្វើឲ្យខូចខាតសម្ភារៈមួយចំនួន។

**ថ្ងៃទី៩ - ១០ ខែកក្កដា ឆ្នាំ២០១០**
**ករណីទី២៣**

**បុគ្គលិកអង្គការអាដហុកទទួលការហៅទូរស័ព្ទដោយគំរាមកំហែង** [២៣]

***ឃុំប៉ោយប៉ែត ស្រុកប៉ោយបែត ខេត្តបន្ទាយមានជ័យ***

- ខៀវ បូរ៉ាយ ជាបុគ្គលិកអង្គការអាដហុក បានទទួលរងការគំរាមកំហែង និងការបំភិតបំភ័យតាមទូរស័ព្ទជាច្រើនលើកពីលោក សយ សុខន ជាប្រធានគណៈកម្មាធិការវត្តម៉ុងជិន។ ការហៅទូរស័ព្ទទាំងនេះ បានធ្វើឡើងបន្ទាប់ពី ខៀវ បូរ៉ាយ និងអ្នកសារព័ត៌មាន ២ នាក់ទៀត គឺឈ្មោះ ពៅ ហួន មកពីកាសែតសច្ចៈកម្ពុជា និងចម ពេជ្រ មកពីកាសែតមាតុភូមិបានសាកសួរប្រធានគណៈកម្មាធិការនោះ អំពីការធ្វើឲ្យខូចខាតបរិវេណវត្ត។
- នៅថ្ងៃទី២១ ខែឧសភាឆ្នាំ២០១០ ខៀវ បូរ៉ាយ ហើយនឹងអ្នកសារព័ត៌មានមូលដ្ឋាន

---

[២២] "សេរីភាពខាងការបញ្ចេញមតិនៅកម្ពុជា: ការបំភ័ន្តលទ្ធិប្រជាធិបតេយ្យ" *supra* ករណីសិក្សាទី២៩។

[២៣] របាយការណ៍ឃ្លាំមើលសិទ្ធិមនុស្សអង្គការលីកាដូ ដែលមិនត្រូវបានបោះពុម្ពផ្សាយ: BM092THI10។ សូមមើលផងដែរ: វិទ្យុអាស៊ីសេរី " សកម្មជនអង្គការអាដហុក បានទទួលរងនូវការគំរាមកំហែងដល់អាយុជីវិតតាមទូរស័ព្ទពីប្រធានគណៈកម្មាធិការវត្តប៉ោយប៉ែត" ព័ត៌មានតាមវិទ្យុផ្សាយ នៅថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១០ (ជាភាសាខ្មែរ)។

២នាក់ របស់គាត់បានធ្វើដំណើរទៅពិនិត្យមើលវត្ត ដែលមានបញ្ហាក្រោយពេលទទួលដំណឹងថាផ្នូរសពពីបុរាណមួយក្នុងវត្តនោះ ត្រូវបានទទួលរងនូវការបំផ្លិចបំផ្លាញ។

**ថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០១០**
**ករណីទី២៤**

**អតីតទាហានពិការចំនួន ៥នាក់ ត្រូវបានចាប់ខ្លួន បន្ទាប់ពីបានធ្វើបាតុកម្មទាមទារដីធ្លី**[២៤]
***ខណ្ឌដូនពេញ រាជធានីភ្នំពេញ***

- អ្នកតវ៉ាចំនួនប្រមាណ ១៦០នាក់ បានមកប្រមូលផ្តុំគ្នានៅខាងក្រៅភូមិគ្រឹះនាយករដ្ឋមន្ត្រី ហ៊ុន សែន នៅក្នុងរាជធានីភ្នំពេញ ដើម្បីទាមទារឲ្យរាជរដ្ឋាភិបាលធ្វើតាមពាក្យសន្យា ដែលថានឹងផ្តល់ដីសម្បទានចំនួន ៩,០០០ហិកតា ទៅឲ្យប្រជាពលរដ្ឋចំនួន ៦២០គ្រួសារ នៅខេត្តក្រចេះ។ ក្រុមគ្រួសារប្រជាពលរដ្ឋទាំង អស់នោះត្រូវបានអតីតទាហានពិការដឹកនាំធ្វើការប្រមូលផ្តុំគ្នា។ មន្ត្រីក្នុងតំបន់ បាននិយាយក្នុងខែមេសាថា ដីទាំងនេះនឹងក្លាយជាកម្មសិទ្ធិរបស់ក្រុមហ៊ុនឯកជនទៅវិញ។
- អ្នកតំណាងរាជរដ្ឋាភិបាលបានប្រមូលស្នាមមេដៃពីអ្នកតវ៉ា ហើយសន្យាថានឹងដោះស្រាយបញ្ហា ដែលនេះជាការបញ្ចុះបញ្ចូលអ្នកទាំងនោះឲ្យចាកចេញ។ ប៉ុន្តែអតីតទាហាន ៥នាក់ ត្រូវបានចាប់ខ្លួន នៅពេលដែលពួកគេកំពុងធ្វើដំណើរវិលត្រឡប់ទៅផ្ទះសម្បែងវិញ។
- អ្នកតំណាងអង្គការអាដហុកមួយរូបបាននិយាយថា នគរបាលបានគំរាមកំហែងអ្នកភូមិឲ្យបញ្ឈប់ធ្វើការតវ៉ាមុនពេលដោះលែងអតីតទាហានទាំងនោះ។
- នៅថ្ងៃទី៣០ ខែសីហា អតីតទាហានចំនួន ២នាក់ ត្រូវបានចាប់ខ្លួនពីភូមិរបស់ពួកគេក្នុងខេត្តក្រចេះ។ ពួកគេត្រូវបានចោទប្រកាន់ពីបទ "គំរាមកំហែងមន្ត្រី អភិរក្សសត្វព្រៃ" ហើយត្រូវឃុំខ្លួនបណ្តោះអាសន្នដើម្បីរង់ចាំធ្វើការស៊ើបអង្កេត។
- ពាក្យបណ្តឹងដែលចោទប្រកាន់អតីតទាហានទាំង ២នាក់ ចោទពីបទ "មេខ្លោង និងបានញុះញង់ប្រជាពលរដ្ឋប្រមាណជា ៥០០នាក់ឲ្យចាប់យកដីធ្លី"។

[២៤] របាយការណ៍ឃ្លាំមើលសិទ្ធិមនុស្សអង្គការលីកាដូ ដែលមិនត្រូវបានបោះពុម្ពផ្សាយ: PP082OFEA10។ សូមមើលផងដែរ: "សេរីភាពខាងការបញ្ចេញមតិនៅកម្ពុជា: ការបំភ័ន្តលទ្ធិប្រជាធិបតេយ្យ" *supra* ករណីសិក្សាទី៩។

**ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១០**
**ករណីទី២៥**

**ក្រសួងមហាផ្ទៃរាំងសេរីភាពខាងការបញ្ចេញមតិ និងសេរីភាពខាងការជួបប្រជុំ** [២៥]
***រាជធានីភ្នំពេញ***

- ក្រសួងមហាផ្ទៃមិនព្រមផ្ដល់ការអនុញ្ញាត ដល់អ្នកជាតិនិយមធ្វើការប្រមូលផ្ដុំគ្នា ដែលបានគ្រោងធ្វើ ដោយក្រុមប្រឹក្សាឃ្លាំមើលសិទ្ធិមនុស្សកម្ពុជា (CWC) ។
- ការប្រមូលផ្ដុំគ្នានេះ ត្រូវបានធ្វើឡើងនៅមុខវត្តបុទុមវត្តី និងមានគោលដៅរិះគន់ការជ្រៀតជ្រែកពីប្រទេសថៃនៅក្នុងជម្លោះប្រាសាទព្រះវិហារ។
- ការប្រមូលផ្ដុំគ្នានេះ បានកើតឡើង ថ្វីបើគ្មានការអនុញ្ញាតក៏ដោយ ប៉ុន្តែមានទាហាន និងមន្ត្រីនគរបាលចំនួន ១៥០នាក់ (ដែលចំនួននេះច្រើនជាងចំនួនអ្នកតវ៉ា) បានប្រើកម្លាំងបណ្ដេញ និងបំបែកការប្រមូលផ្ដុំនោះចេញ។ ការប្រមូលផ្ដុំគ្នានេះ ក៏បានផ្លាស់ទីទៅធ្វើនៅការិយាល័យឯកជនមួយក្នុងខ័ណ្ឌចំការមន ប៉ុន្តែនៅតែស្ថិតក្រោមការត្រួតពិនិត្យយ៉ាងរឹងតឹងពីមន្ត្រីនគរបាលដដែល។

**ថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១០**
**ករណីទី២៦**

**អ្នកតំណាងសហគមន៍ ត្រូវទទួលរងការចោទប្រកាន់មិនត្រឹមត្រូវ ពីបទជំរិតទារលុយ** [២៦]
***ភូមិអង្កាញ់ ឃុំសៀមលើ ស្រុកសៀមរាប ខេត្តសៀមរាប***

- ង៉ុក គី ជាប្រធានភូមិ និង ស សាម៉ុល ជាអ្នកតំណាងសហគមន៍ ត្រូវបានចាប់ខ្លួនដោយ ចោទប្រកាន់ពីបទឆបោក ហើយត្រូវបានឃុំខ្លួនបណ្ដោះអាសន្នក្នុងពន្ធនាគារខេត្តសៀមរាប។
- តុលាការបានចេញដីកាចាប់ខ្លួនផ្អែកលើពាក្យបណ្ដឹងមួយ ដែលបានធ្វើឡើងដោយក្រុមហ៊ុនចំការកៅស៊ូក្រែក។ .
- អ្នកតំណាងទាំងនោះ ត្រូវបានចោទប្រកាន់ពីបទបោកបញ្ឆោតអ្នកភូមិ ដោយសុំឲ្យពួកគេបង់ប្រាក់សម្រាប់ថ្លៃធ្វើដំណើរទៅកាន់រាជធានីភ្នំពេញ ដើម្បីទៅធ្វើការលើកកំពស់ការយល់ដឹងអំពីជម្លោះដីធ្លី ដែលកំពុងកើតឡើងរវាងប្រជាពលរដ្ឋចំនួន ៣៦៥ គ្រួសារ និងក្រុមហ៊ុនចំការកៅស៊ូក្រែក។

[២៥] យោងឯកសារដូចគ្នានឹងជើងទំព័រទី២៤។ ករណីសិក្សាទី៨។

[២៦] របាយការណ៍ឃ្លាំមើលសិទ្ធិមនុស្សអង្គការលីកាដូ ដែលមិនត្រូវបានបោះពុម្ពផ្សាយ: SP023IAD10 ។

**ថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១០**
**ករណីទី២៧**

**បាតុកម្មទាមទារសិទ្ធិការងារដោយអហិង្សា ត្រូវបានរារាំងពីសំណាក់អាជ្ញាធរ**[២៧]
***សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ***

- កងកម្លាំងចម្រុះដែលមានមន្ត្រីនគរបាល និងមន្ត្រីកងរាជអាវុធហត្ថចំនួន ២០០នាក់ បានធ្វើការរារាំងការប្រមូលផ្តុំគ្នាមួយ ដោយអហិង្សារបស់សមាជិកសហជីពការងារ ដែលមានចំនួន ៩,៥០០ នាក់នៅមុខវត្តបុទុមវត្តី (ហើយក្រោយមកនៅមុខរដ្ឋសភា) ដើម្បីធ្វើការទាមទារដំឡើងប្រាក់ឈ្នួល។
- នៅថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០១០ អាជ្ញាធររាជធានីភ្នំពេញបានបដិសេធនូវសំណើសុំធ្វើការតវ៉ា ដែលធ្វើឡើងដោយសហភាពការងារកម្ពុជា (CLC) ហើយនឹងសហព័ន្ធជាតិកម្ពុជា (CNC) ដោយផ្អែកលើមូលដ្ឋានថា ការតវ៉ានេះនឹងធ្វើឲ្យប៉ះពាល់សណ្តាប់ធ្នាប់សាធារណៈ គំរាមកំហែងដល់សុវត្ថិភាពសាធារណៈ ហើយនឹងបង្កឲ្យមានការខូចខាតដល់ទ្រព្យសម្បត្តិសាធារណៈ។ ការបដិសេធនេះ ត្រូវបានលុបចោលវិញភ្លាមៗ ហើយថ្មីបើ មានការបិទផ្លូវ និងមានយុទ្ធសាស្ត្រផ្សេងៗរបស់នគរបាលដើម្បីរារាំងក្រុមបាតុករមិនឲ្យធ្វើការប្រមូលផ្តុំគ្នាក៏ដោយ ក៏មិនមានសេចក្តីរាយការណ៍អំពីការខូចខាតទ្រព្យសម្បត្តិ ឬការប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈឡើយ។

**ថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១០**
**ករណីទី២៨**

**អ្នកសារព័ត៌មានត្រូវបានចោទប្រកាន់ពីបទធ្វើសេចក្តីរាយការណ៍ ស្តីពីអំពើពុករលួយ នៅសកលវិទ្យាល័យ**[២៨]
***រាជធានីភ្នំពេញ***

- ប៊ុន ថា និពន្ធនាយកកាសែតខ្មែរអមតៈ ត្រូវបានចាប់ខ្លួនមិនស្របច្បាប់ឃុំខ្លួន និងចោទប្រកាន់ពីបទផ្សាយព័ត៌មានមិនពិត និងបរិហារកេរ្តិ៍ បន្ទាប់ពីបានចុះផ្សាយរឿងរ៉ាវមួយ ដោយចោទប្រកាន់ ថាមានអំពើពុករលួយក្នុងការផ្តល់អាហារូបករណ៍នៅសាកលវិទ្យាល័យកម្ពុជា។
- នៅក្នុងឆ្នាំ២០០៩ កាសែតនេះ បានរាយការណ៍ថា មន្ត្រីសាកលវិទ្យាល័យនេះបានទារលុយពីនិស្សិតចំនួន ២០,០០០រៀលទៅ ២៥,០០០រៀល ជាថ្លៃសម្រាប់ទិញ ពាក្យស្នើសុំអាហារូបករណ៍ ដែលមានតម្លៃត្រឹមតែ ៥០០រៀល ប៉ុណ្ណោះ។ អាហារូបករណ៍នេះត្រូវបានធានាដោយរាជរដ្ឋាភិបាលប្រទេសជប៉ុន និងនាយករដ្ឋមន្ត្រី ហ៊ុន សែន។

[២៧] របាយការណ៍ឃ្លាំមើលសិទ្ធិមនុស្សអង្គការលីកាដូ ដែលមិនត្រូវបានបោះពុម្ពផ្សាយ: PP084OFEA10។ សូមមើលផងដែរ: "សេរីភាពខាងការបញ្ចេញមតិនៅកម្ពុជា: ការបំភ័ន្តលទ្ធិប្រជាធិបតេយ្យ" supra ករណីសិក្សាទី១០។
[២៨] របាយការណ៍ឃ្លាំមើលសិទ្ធិមនុស្សអង្គការលីកាដូ "សេរីភាពខាងការបញ្ចេញមតិនៅកម្ពុជា: ការបំភ័ន្តលទ្ធិប្រជាធិបតេយ្យ" ខែធ្នូ ឆ្នាំ២០១០ ករណីសិក្សាទី២២។

- បណ្ឌិត កៅ គឹមហួន ជាសាកលវិទ្យាធិការនៃសាកលវិទ្យាល័យនេះ (ដែលបំរើការជារដ្ឋលេខាធិការក្រសួងការបរទេស) បានប្តឹងលោក ប៊ុន ថា ពីបទបរិហារកេរ្តិ៍ ដោយស្នើសុំឲ្យបង់សំណងជាប្រាក់ចំនួន ១០០,០០០ ដុល្លារអាមេរិក។ លោក ប៊ុន ថា ក៏ប្រឈមនឹងការចោទប្រកាន់ពីបទផ្សាយព័ត៌មានមិនពិត ដែលជាទោសពន្ធនាគារក្នុងរឿងព្រហ្មទណ្ឌផងដែរ។

**ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១០**
**ករណីទី២៩**

**កម្មកររោងចក្រកាត់ដេរ ត្រូវទទួលរងរបួសនៅអំឡុងពេល ដែលនគរបាលធ្វើការរារាំងកូដកម្ម** [២៩]

***សង្កាត់ទឹកថ្លា ខ័ណ្ឌសែនសុខ រាជធានីភ្នំពេញ***

- កម្មការិនីរោងចក្រកាត់ដេរ PCCS ចំនួន ៩នាក់ ត្រូវទទួលរងរបួសនៅអំឡុងពេលធ្វើបាតុកម្មមួយ ដើម្បីទាមទារឲ្យរោងចក្រទទួលយក ម៉ុន ចាន់ណា ជាប្រធានសហជីពភេទស្រី ដែលត្រូវបានបណ្តេញចេញពីការងារឲ្យចូលធ្វើការវិញ។
- មន្ត្រីនគរបាលខ័ណ្ឌចំនួនប្រមាណជា ៥០នាក់ ប្រដាប់ដោយដំបងឆក់ និងខែលបានបំបែកការប្រមូលផ្តុំយ៉ាងហិង្សា តាមបទបញ្ជារបស់លោក ម៉ុក ហុង ជាអធិការនគរបាលខ័ណ្ឌ ដែលបានដឹកនាំកម្លាំងអនុវត្តដីកាតុលាការ ដើម្បីបោសសំអាតផ្លូវ ហើយប្រើកម្លាំងបង្ខំឲ្យស្ត្រីត្រឡប់ទៅធ្វើការវិញ។

**ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១០**
**ករណីទី៣០**

*[សូមមើលករណីទី៥ និង១០៦ ផងដែរ]*

**អ្នកភូមិពាក់ព័ន្ធក្នុងជម្លោះដីធ្លី ប្រឈមនឹងការចោទប្រកាន់ខាងព្រហ្មទណ្ឌ** [៣០]

***ភូមិអូរអង្គុំ ឃុំអំលាំង ស្រុកថ្ពង ខេត្តកំពង់ស្ពឺ***

- អ្នកភូមិចំនួន ៨នាក់ ត្រូវបានចោទប្រកាន់ ដោយសាលាដំបូងខេត្តពីបទប៉ុនប៉ងមនុស្សឃាត និងការរំលោភបំពានទៅលើទ្រព្យសម្បត្តិឯកជន ទាក់ទងនឹងការតវ៉ាមួយ ដែលបានធ្វើឡើងនៅថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០០៨។ ការតវ៉ានោះ ត្រូវបានរៀបចំឡើងដើម្បីបញ្ឈប់ក្រុមហ៊ុនកម្ពុជា HLH មិនឲ្យធ្វើការឈូសឆាយដីស្រែចំការរបស់អ្នកភូមិ។ បងប្អូនស្រីរបស់នាយករដ្ឋមន្ត្រី គឺជាម្ចាស់ភាគហ៊ុនម្នាក់នៅក្នុងក្រុមហ៊ុននោះ។
- អ្នកភូមិទាំងនោះ មានការពាក់ព័ន្ធក្នុងជម្លោះដីធ្លីជាមួយក្រុមហ៊ុនកម្ពុជា HLH បន្ទាប់ពីលោក ព្រុំ ឌិម ជាមេបញ្ជាការយោធភូមិភាគពិសេស និងលោក ពាង សាវិនជា នាយសេនាធិការបានលក់ដីចំនួន ១,៨៥៦ហិកតា ទៅឲ្យក្រុមហ៊ុននេះដាំពោត

[២៩] របាយការណ៍ឃ្លាំមើលសិទ្ធិមនុស្សអង្គការលីកាដូ ដែលមិនត្រូវបានបោះពុម្ពផ្សាយ: PP085OFEA10 ។ សូមមើលផងដែរ: របាយការណ៍អង្គការលីកាដូ "សេរីភាពខាងការបញ្ចេញមតិនៅកម្ពុជា: ការបំភ័ន្តលទ្ធិប្រជាធិបតេយ្យ" ខែធ្នូ ឆ្នាំ២០១០ ករណីសិក្សាទី១១។

[៣០] របាយការណ៍ឃ្លាំមើលសិទ្ធិមនុស្សអង្គការលីកាដូ ដែលមិនត្រូវបានបោះពុម្ពផ្សាយ: KS022LG10។

ក្រហម ដែលដីទាំងនេះប្រជាពលរដ្ឋចំនួន ៨១៧គ្រួសារ កំពុងប្រើប្រាស់។

**ថ្ងៃទី៦ ខែសីហា ឆ្នាំ២០១០**
**ករណីទី៣១**

*[សូមមើលករណីទី៨៣ និង៩៣ ផងដែរ]*

**អ្នកតំណាងសហគមន៍ត្រូវបានចាប់ខ្លួន ទាក់ទងនឹងជម្លោះដីធ្លី** [៣១]
***ភូមិត្បែងលិច ឃុំត្បែង ស្រុកបន្ទាយស្រី ខេត្តសៀមរាប***

- អ្នកតំណាងសហគមន៍ចំនួន ៣ នាក់ ត្រូវបានចាប់ខ្លួន ហើយក្រោយមកត្រូវបានដោះលែងវិញ បន្ទាប់ពីបានធ្វើការតវ៉ាមួយដើម្បីគាំទ្រប្រជាពលរដ្ឋចំនួន ១០៥ គ្រួសារ ដែលពាក់ព័ន្ធក្នុងជម្លោះដីធ្លីជាមួយមន្ទីររដ្ឋបាលព្រៃឈើថ្នាក់ខេត្ត។

**ថ្ងៃទី៨ ខែសីហា ឆ្នាំ២០១០**
**ករណីទី៣២**

*[សូមមើលករណីទី៣៤ និង ៩៧ ផងដែរ]*

**មន្ត្រីនគរបាលបំបែកការប្រមូលផ្តុំ នៅមុខភូមិគ្រឹះលោកនាយករដ្ឋមន្ត្រី** [៣២]
***សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ***

- អ្នកភូមិចំនួន ៧០ នាក់ឈរតំណាងឲ្យប្រជាពលរដ្ឋចំនួន ៨១៥ គ្រួសារដែលប្រឈមនឹងការបាត់បង់ដីធ្លីរបស់ពួកគេនៅខេត្តបាត់ដំបង ត្រូវទទួលរងការគំរាមកំហែង និងត្រូវបានរារាំងដោយកងកម្លាំងចំរុះមួយក្រុមដែលមានមន្ត្រីកងរាជអាវុធហត្ថមន្ត្រីនគរបាល ព្រមទាំងបុគ្គលិកសន្តិសុខខណ្ឌចំនួន ១០០នាក់ មិនឲ្យធ្វើការប្រមូលផ្តុំគ្នានៅមុខភូមិគ្រឹះនាយករដ្ឋមន្ត្រី ហ៊ុន សែននៅរាជធានីភ្នំពេញ។
- អ្នកតវ៉ាទាំងនោះ រាប់ទាំងកុមារផង ត្រូវបានគេប្រើកម្លាំងរុញបញ្ចូលទៅក្នុងឡាន ហើយដឹកទៅកាន់ខេត្តបាត់ដំបងវិញ។
- ការតវ៉ាដោយអហិង្សានេះ ត្រូវបានរៀបចំឡើង ដើម្បីឲ្យមានការយល់ដឹងអំពីជម្លោះដីធ្លីដ៏រ៉ាំរ៉ៃមួយរវាងអ្នកភូមិ និងអាជ្ញាធរមូលដ្ឋាន រាប់ទាំងសមាជិកកងយោធពល ខេមរៈភូមិន្ទនៅក្នុងឃុំដូនបា ស្រុកគាស់ក្រឡ ខេត្តបាត់ដំបង។

---

[៣១] របាយការណ៍ឃ្លាំមើលសិទ្ធិមនុស្សអង្គការលីកាដូ ដែលមិនត្រូវបានបោះពុម្ពផ្សាយ: SP029LG10។

[៣២] របាយការណ៍ឃ្លាំមើលសិទ្ធិមនុស្សអង្គការលីកាដូ ដែលមិនត្រូវបានបោះពុម្ពផ្សាយ: PP091OFEA10។ មើលផងដែរ: របាយការណ៍ឃ្លាំមើលសិទ្ធិមនុស្ស អង្គការលីកាដូ ដែលមិនត្រូវបានបោះពុម្ពផ្សាយ: PP085OFEA10។ មើលផងដែរ: របាយការណ៍អង្គការលីកាដូ "សេរីភាពខាងការបញ្ចេញមតិនៅកម្ពុជា: ការបំភ័ន្តលទ្ធិប្រជាធិបតេយ្យ" ខែធ្នូ ឆ្នាំ២០១០ ករណីសិក្សាទី១២។

**ថ្ងៃទី១១ ខែសីហា ឆ្នាំ២០១០**
**ករណីទី៣៣**

**ការចាប់ខ្លួន និងការឃុំខ្លួនអ្នកតំណាងសហគមន៍** [៣៣]
***ភូមិលាបតុង ឃុំទ្រា ស្រុកស្ទោង ខេត្តកំពង់ធំ***

- ណាត ឡេម ជាអ្នកតំណាងសហគមន៍ភេទស្រី ត្រូវបានចាប់ខ្លួន ដោយមន្ត្រីនគរបាលស្រុកមួយក្រុម ដែលមានគ្នាចំនួន ១១នាក់ បន្ទាប់ពីគាត់បានដើរប្រមូលស្នាមមេដៃសម្រាប់ធ្វើញត្តិទាក់ទងនឹងជម្លោះដីធ្លី ដែលកំពុងកើតឡើងជាមួយលោក ហេង សនថៃ ជាឈ្មួញម្នាក់។ ណាត ឡេម ត្រូវបានឃុំខ្លួនបណ្តោះអាសន្ននៅក្នុងពន្ធនាគារខេត្តកំពង់ធំ។

**ថ្ងៃទី១២ ខែសីហា ឆ្នាំ២០១០**
**ករណីទី៣៤**

*[សូមមើលករណីទី៣២ និង៩៦ ផងដែរ]*

**អ្នកតំណាងសហគមន៍ រត់គេចពីការចាប់ខ្លួនចូលក្នុងព្រៃស្បាត** [៣៤]
***ឃុំដូនបា ស្រុកគាស់ក្រឡ ខេត្តបាត់ដំបង***

- អ្នកតំណាងសហគមន៍ចំនួន ៣ នាក់ បានគេចខ្លួនចូលទៅក្នុងព្រៃ បន្ទាប់ពីអាជ្ញាធរនគរបាលស្រុក ដែលបានគំរាមចាប់ខ្លួនពួកគេបានឡោមព័ទ្ធផ្ទះសម្បែងរបស់ពួកគេ។
- សាលាដំបូងខេត្ត បានចេញដីកាចាប់ខ្លួនអ្នកតំណាងសហគមន៍ទាំង ៣ នាក់នេះ ដោយចោទប្រកាន់ពួកគេពីបទ "ប្លន់ និងបំផ្លិចបំផ្លាញទ្រព្យសម្បត្តិសាធារណៈ"។ ពុំមានមូលដ្ឋានសម្រាប់ការចោទប្រកាន់នេះទេ។
- សហគមន៍នោះ គឺមានការពាក់ព័ន្ធនឹងជម្លោះដីធ្លីជាមួយលោក ឡុង ស៊ីថា ជាមន្ត្រីកងរាជអាវុធហត្ថមួយ ដែលជម្លោះនេះ បានផ្តើមកើតឡើងបន្ទាប់ពីមន្ត្រីរូបនេះ បានទទួលដីសម្បទានចំនួន ១,៦៧២ហិកតា ពីរដ្ឋាភិបាលដើម្បីធ្វើចំការកៅស៊ូ។

**ថ្ងៃទី១៩-២៦ ខែសីហា ឆ្នាំ២០១០**
**ករណីទី៣៥**

**អាជ្ញាធរធ្វើការបង្ក្រាបទៅលើកម្មករ ដែលកំពុងធ្វើកូដកម្ម** [៣៥]
***ខ័ណ្ឌមានជ័យ រាជធានីភ្នំពេញ***

- យ៉ាងហោចណាស់មានកម្មករកាត់ដេរចំនួន ១៦០នាក់ មកពីរោងចក្រ Sunly Fong បានដើរចេញពីការងារនៅថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១០ ដើម្បីទាមទារឲ្យមានការកែលំអលក្ខខ័ណ្ឌការងារ។
- នៅពេលកំពុងធ្វើការតវ៉ាអស់រយៈពេល ៩ថ្ងៃ ហើយមុនពេលតុលាការចេញដីកា

[៣៣] របាយការណ៍ឃ្លាំមើលសិទ្ធិមនុស្សអង្គការលីកាដូ ដែលមិនត្រូវបានបោះពុម្ពផ្សាយ: KT050IAD10។

[៣៤] ជា វង់សុឃារិទ្ធ " អ្នកតំណាងសហគមន៍ស្រុកគាស់ក្រឡ បានរត់គេចខ្លួនចូលទៅក្នុងព្រៃស្បាតម្តងទៀត" កាសែត The Phnom Penh Post ចេញផ្សាយនៅថ្ងៃទី២០ ខែសីហា ឆ្នាំ២០១០។

[៣៥] របាយការណ៍អង្គការលីកាដូ "សេរីភាពខាងការបញ្ចេញមតិនៅកម្ពុជា: ការបំភ័ន្តលទ្ធិប្រជាធិបតេយ្យ" ខែធ្នូ ឆ្នាំ២០១០ ករណីសិក្សាទី១៩។

មន្ត្រីនគរបាលបានគំរាមអ្នកតវ៉ាថា សន្តិសុខរបស់ពួកគេមិនអាចត្រូវបាន"ធានាការពារ" ឡើយ ប្រសិនបើនៅតែបន្តធ្វើកូដកម្ម។ ទោះបីយ៉ាងណាក៏ដោយកូដកម្មនោះនៅតែបន្តរហូតដល់ថ្ងៃទី២៦ ខែសីហា ជាពេលដែលអាជ្ញាធរបានបង្ហាញដីកាតុលាការ ដោយប្រកាសថា កូដកម្មនោះជាកូដកម្មខុសច្បាប់ ហើយបង្គាប់ឲ្យកម្មករចូលធ្វើការវិញ។ ដីកានោះ បានផ្តល់ការអនុញ្ញាតឲ្យរោងចក្របណ្តេញអ្នករៀបចំសហជីព ដែលទទួលខុសត្រូវចំពោះកូដកម្មនោះផងដែរ។

- ប្រធានសហជីពចំនួន ៣ នាក់ ដែលមានឈ្មោះ អៀន ពៅ ហេង បូរ៉ា និងនុន ចំណាន ក្រោយមកបានប្រឈមមុខនឹងការចោទប្រកាន់ខាងព្រហ្មទណ្ឌពីបទញុះញង់ និងបំផ្លិចបំផ្លាញទ្រព្យសម្បត្តិឯកជន។

**ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១០**
**ករណីទី៣៦**

### មន្ត្រីនគរបាលរារាំងកិច្ចប្រជុំរបស់ប្រជាពលរដ្ឋ ដែលកំពុងប្រឈមនឹងការបណ្តេញចេញនៅសហគមន៍បឹងកក់ [៣៦]

***រាជធានីភ្នំពេញ***

*[សូមមើលករណីទី៥១ ៦៧ ៦៩ ៧០ ៧៨ ៩១ ៩២ ៩៩ ១១៤ ១១៥ និង ១២២ ផងដែរ]*

- មន្ត្រីនគរបាលរាជធានីចំនួនប្រហែល២០០នាក់ បានបំបែកកិច្ចប្រជុំមួយរបស់អ្នករស់នៅសហគមន៍បឹងកក់ ដែលបានប្រមូលផ្តុំគ្នាដើម្បីពិភាក្សាពីផលប៉ះពាល់ បរិស្ថានដោយសារការអភិវឌ្ឍន៍បឹងកក់នេះ។
- កិច្ចប្រជុំនោះ ត្រូវបានគ្រោងធ្វើឡើងនៅក្នុងបរិវេណវិជ្ជាស្ថានបណ្តុះបណ្តាលថ្នាក់ជាតិនៅជាប់នឹងភូមិគ្រឹះរបស់នាយករដ្ឋមន្ត្រី។ លោក ទូច ណារ័ត្ន ស្នងការនគរបាលរាជធានីបានលើកយកការរារាំងនេះ មកសំអាងថា ការពារសណ្តាប់ធ្នាប់សាធារណៈ។ .
- នៅពេលកំពុងតវ៉ាអ្នករស់នៅសហគមន៍បឹងកក់ប្រមាណជា ១០០នាក់ បានប្រមូលផ្តុំគ្នានៅវិមានឯករាជ្យ ជាទីដែលពួកគេបានប្រឈមមុខនឹងកងកម្លាំងប្រដាប់អាវុធចម្រុះ ដោយមានកាន់ខែល ដំបងនិងកាំភ្លើងវែង។

**ថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១០**
**ករណីទី៣៧**

### ព្រះសង្ឃខ្មែរក្រោមទទួលរងការគំរាមកំហែង ជុំវិញការបោះពុម្ពផ្សាយព័ត៌មាន [៣៧]

***រាជធានីភ្នំពេញ***

- ព្រះសង្ឃខ្មែរក្រោម ព្រះនាម ថាច់ ប្រើយជាខឿន បានទទួលរងការគំរាមកំហែងពី

---

[៣៦] របាយការណ៍អង្គការលីកាដូ "សេរីភាពខាងការបញ្ចេញមតិនៅកម្ពុជា: ការបំភ័ន្តលទ្ធិប្រជាធិបតេយ្យ" ខែធ្នូ ឆ្នាំ២០១០ ករណីសិក្សាទី១៥។

[៣៧] របាយការណ៍អង្គការលីកាដូ "សេរីភាពខាងការបញ្ចេញមតិនៅកម្ពុជា: ការបំភ័ន្តលទ្ធិប្រជាធិបតេយ្យ" ខែធ្នូ ឆ្នាំ២០១០ ករណីសិក្សាទី៣៣ ។ សូមមើលផងដែរ: របាយការណ៍ឃ្លាំមើលសិទ្ធិមនុស្សអង្គការលីកាដូ ដែលមិនត្រូវបានបោះពុម្ពផ្សាយ: PP115THI10។

ប្រធានសង្ឃ និងអ្នកតំណាងពីក្រសួងមហាផ្ទៃ ជុំវិញការពាក់ព័ន្ធរបស់ព្រះអង្គ ក្នុងការបោះពុម្ពផ្សាយព័ត៌មាន តាមរយៈកាសែតខ្មែរក្រោមឈ្មោះព្រៃនគរ។ លិខិតឆ្លងដែនរបស់ព្រះ អង្គ ក៏ត្រូវបានប្រធានសង្ឃរឹបអូសយកផងដែរ។ .

- មុនពេលមានការគំរាមកំហែង អាជ្ញាធរបានរឹបអូសយកកាសែតជាច្រើនច្បាប់ ដែលកំពុងដាក់លក់ដោយអ្នកលក់កាសែតនៅរាជធានីភ្នំពេញ។

**ថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១០**
**ករណីទី៣៨**

*[សូមមើលករណីទី១៨ និង៧៩ ផងដែរ]*

**បុគ្គលិកអង្គការលីកាដូ ត្រូវបានកាត់ទោសពីបទផ្សាយព័ត៌មានមិនពិត បន្ទាប់ពីមានសវនាការបែបឆាកល្ខោន** [៣៨]

***រាជធានីភ្នំពេញ***

- លាង សុខជឿន ជាបុគ្គលិកអង្គការលីកាដូមួយរូប ត្រូវបានកាត់ទោសឲ្យជាប់ពន្ធនាគារចំនួន ២ ឆ្នាំពីបទផ្សាយព័ត៌មានមិនពិត។
- លាង សុខជឿន ត្រូវបានចោទប្រកាន់ពីបទចែកចាយខិត្តប័ណ្ណប្រឆាំងរាជរដ្ឋាភិបាល នៅក្នុងខេត្តតាកែវកាលពីថ្ងៃទី៤ ខែមករា ឆ្នាំ២០១០។ ទោះជាគ្មានភស្តុតាង និងមានភាពមិនប្រក្រតីជាច្រើនក្នុងការកាត់ក្តីក៏ដោយ ក៏លោក លាង សុខជឿន ត្រូវបានគេរកឃើញពិរុទ្ធភាពពីបទផ្សាយព័ត៌មានមិនពិត ក្នុងសេចក្តីសម្រេចមួយ ដោយមូលហេតុនយោបាយ ដែលគ្មានមូលដ្ឋានក្នុងអង្គហេតុ និងក្នុងអង្គច្បាប់។

**ថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១០**
**ករណីទី៣៩**

**អ្នកភូមិត្រូវបានចោទប្រកាន់ពីបទញុះញង់ជុំវិញការតវ៉ា** [៣៩]

***ស្រុកជាំក្សាន ខេត្តព្រះវិហារ***

- អ្នកភូមិចំនួន ៣នាក់ ឈ្មោះ ស្រី សុភ័ណ្ឌ សាត រឿន និងគឹម សុផល ត្រូវបានឃុំខ្លួនបណ្តោះអាសន្ន និងចោទប្រកាន់ពីបទផ្សាយព័ត៌មានមិនពិត ក្លែងបន្លំឯកសារ និងញុះញង់ឲ្យមានការតវ៉ាប្រឆាំងនឹងអង្គការបង្ការ និងស្រាវជ្រាវមេរោគ AIDS និងថ្នាំញៀន (DARPO) បន្ទាប់ពីដើរប្រមូលស្នាមមេដៃ ដើម្បីដាក់ពាក្យបណ្តឹងទៅក្រសួងមហាផ្ទៃ។
- អង្គការ DARPO ដែលមានឧត្តមសេនីយ៍យោធាមួយរូបជាប្រធាន គឺជាអង្គការមិនមែនរដ្ឋាភិបាលមួយ ដែលបានទទួលដីសម្បទានចំនួន ៥៥៦ហិកតា ដើម្បីធ្វើជាជួយក្រុមគ្រួសារប្រជាពលរដ្ឋនៅក្នុងតំបន់នោះ ប៉ុន្តែអ្នកភូមិ និងអង្គការមិនមែនរដ្ឋា

---

[៣៨] សេចក្តីប្រកាសព័ត៌មានអង្គការលីកាដូ "បុគ្គលិកអង្គការលីកាដូ ត្រូវបានកាត់ទោសពីបទផ្សាយព័ត៌មានមិនពិត បន្ទាប់ពីមានការកាត់ក្តីបែបឆាកល្ខោនមួយ" ចេញផ្សាយនៅថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០១០: http://www.licadho-cambodia.org/pressrelease.php?perm=226។

[៣៩] របាយការណ៍អង្គការលីកាដូ "សេរីភាពខាងការបញ្ចេញមតិនៅកម្ពុជា: ការបំភ័ន្តលទ្ធិប្រជាធិបតេយ្យ" ខែធ្នូ ឆ្នាំ២០១០ ករណីសិក្សាទី២៣។

ភិបាលដទៃទៀតបានអះអាងថា អង្គការ DARPO បានប្រើកម្លាំងបណ្តេញគ្រួសារប្រជាពលរដ្ឋ ដែលកំពុងរស់នៅលើដីជម្លោះ ក្រោមការភ័យខ្លាចការគំរាមកំហែង ការរំលោភសេពសន្ថវៈ និងធ្វើទារុណកម្ម។

- នៅអំឡុងពេលធ្វើសន្និសីទកាសែតមួយនៅរាជធានីភ្នំពេញ អ្នកភូមិជាស្ត្រីមួយរូបបានចោទប្រកាន់ឆ្មាំសន្តិសុខរបស់អង្គការ DARPO ពីបទចាប់កូនស្រីរបស់គាត់ អាយុ ១៣ឆ្នាំ រំលោភសេពសន្ថវៈនៅឆ្នាំ២០០៧ ព្រមទាំងនិយាយថា បុរសមិនស្គាល់អត្តសញ្ញាណបានវាយដំគាត់ ក្រោយពេលគាត់ដាក់ពាក្យបណ្តឹងនៅថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១០។

**ថ្ងៃទី៧ ខែកញ្ញា ឆ្នាំ ២០១០**

**ករណីទី៤០**

*[សូមមើលករណីទី១៩៤ និង១២៥ ផងដែរ]*

**អ្នកភូមិត្រូវបានតុលាការកោះហៅទាក់ទងនឹងការប្រើប្រាស់ដីធ្លី** [៤០]

***ស្រុកលំផាត់ ខេត្តរតនគីរី***

- អ្នកភូមិជនជាតិភាគតិចតាំពួនចំនួន ១០នាក់ ពាក់ព័ន្ធក្នុងជម្លោះដីធ្លីជាមួយក្រុមហ៊ុន DM Group ត្រូវបានតុលាការកោះហៅមកសាកសួរស្តីពីការចោទប្រកាន់ថា ពួកគេបានវាយប្រហារទៅលើនគរបាលនៅអំឡុងមានជម្លោះវាយតប់គ្នាមួយ នៅក្នុងខែវិច្ឆិកា ឆ្នាំ២០០៧។ នៅក្នុងឧប្បត្តិហេតុនោះ មន្រ្តីនគរបាលចំនួន ២០នាក់ បានប៉ះទង្គិចគ្នាជាមួយអ្នកភូមិជនជាតិភាគតិចតាំពួនចំនួន៤០នាក់ ដែលប៉ុនប៉ងដោះលែងអ្នកតំណាងភូមិចំនួន ២នាក់ ដែលត្រូវបានឃុំខ្លួន។
- លោក ប៉ែន ប៊ុនណា ជាបុគ្គលិកអង្គការអាដហុក ត្រូវទទួលរងការគំរាមកំហែងចោទប្រកាន់ក្នុងករណីដូចគ្នានេះ ពីបទញុះញង់អ្នកភូមិទាំងនោះ។
- អ្នកភូមិចំនួន ៤ នាក់ផ្សេងទៀត ដែលមានឈ្មោះ ស្វេន វ៉េវ យ៉ាង ថាង និត ថាន និង សាយ ខាមមៀ ត្រូវបានកោះហៅមកសាកសួរផងដែរដើម្បីកំណត់ ថាតើពួកគេបានរំលោភបំពានទៅលើលក្ខខ័ណ្ឌដោះលែងក្រៅឃុំ ឬយ៉ាងណា។ បុរសទាំង ៤ នាក់បានជាប់ឃុំបណ្តោះអាសន្នអស់រយៈពេល៦ខែ មកហើយពីបទចូលក្នុងតំបន់ហាមឃាត់ និងបំផ្លិចបំផ្លាញទ្រព្យសម្បត្តិតាមរយៈការដកដើមកៅស៊ូដែលក្រុមហ៊ុន DM Group បានដាំនៅលើដីទំនាស់។ ពួកគេត្រូវបានដោះលែងដោយមានលក្ខខ័ណ្ឌក្នុងខែកក្កដា ឆ្នាំ២០០៩។

[៤០] គួច ណាវ៉ែន"សាលាដំបូងខេត្តរតនៈគិរីសាកសួរអ្នកភូមិចំនួន ១០ នាក់ក្នុងករណីដីធ្លី" កាសែត *The Cambodia Daily* ចេញផ្សាយនៅថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១០។

**ថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១០**
**ករណីទី៤១**

*[សូមមើលករណីទី១៧ ផងដែរ]*

**មេដឹកនាំអ្នកភូមិត្រូវបានចាប់ខ្លួន ជុំវិញការតវ៉ាដីធ្លី** [៤១]
***ស្រុកស្អាង ខេត្តកណ្តាល***

- វ៉ន វិន អ្នកតំណាងសហគមន៍ត្រូវបានចាប់ខ្លួន និងចោទប្រកាន់ពីបទកាន់កាប់ដីធ្លីដោយខុសច្បាប់ និងញុះញង់ឲ្យមានអំពើហិង្សា បន្ទាប់ពីមានការដឹកនាំបាតុកម្មប្រឆាំងនឹងក្រុមហ៊ុនហេងអភិវឌ្ឍន៍ (Heng Development company) ដែលជាក្រុមហ៊ុនមួយដែលបានទទួលដីចំនួន ១៥០ ហិកតាក្នុងឆ្នាំ២០០៥ ហើយបន្ទាប់មកក៏បានធ្វើការបណ្តេញប្រជាពលរដ្ឋចំនួន ១៩២ គ្រួសារចេញ។
- ក្រុមហ៊ុននោះបានដាក់ពាក្យបណ្តឹងប្រឆាំងនឹង វ៉ន វិន នៅក្នុងខែវិច្ឆិកា ឆ្នាំ២០០៩។

**ថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១០**
**ករណីទី៤២**

**ការចាប់ខ្លួន និងការឃុំខ្លួនប្រធានសហជីពខុសច្បាប់នៅពេលកូដកម្ម** [៤២]
***ភូមិត្នោតមួយដើម ឃុំបែកចាន ស្រុកអង្គស្នួល ខេត្តកណ្តាល***

- សាត វិច្ឆិកា អនុប្រធានសហជីពរោងចក្រ Darong factory និង ឡឹង ធីម ជាប្រធានសហជីពរោងចក្រតៃ យ៉ាង ត្រូវបានចាប់ខ្លួន និងឃុំខ្លួនដោយនគរបាលស្រុកអស់រយៈពេល ២ម៉ោង បន្ទាប់ពីបានដឹកនាំកូដកម្មស្របច្បាប់មួយ ដោយទាមទារដំឡើងប្រាក់ឈ្នួល។
- ឡឹង ធីម ជាមួយនឹងសមាជិកសហជីព ២នាក់ ផ្សេងទៀត មិនត្រូវបានអនុញ្ញាតឲ្យវិលត្រឡប់ទៅធ្វើការងារវិញឡើយ បន្ទាប់ពីឧប្បត្តិហេតុនេះ។

**ថ្ងៃទី១៥ ខែញ្ញា ឆ្នាំ២០១០**
**ករណីទី៤៣ ៤៤ ៤៥**

**ប្រធានសហជីពទទួលរងការគំរាមកំហែងចាប់ខ្លួនពីសំណាក់មេនគរបាល** [៤៣]
***ភូមិត្នោតជ្រុំ សង្កាត់បឹងទំពុន ខ័ណ្ឌមានជ័យ រាជធានីភ្នំពេញ***

- នៅថ្ងៃទី១៣ ខែកញ្ញា កម្មករចំនួនប្រមាណជា ៦០,០០០នាក់ ដឹកនាំដោយអ្នកតំណាងសហជីពចំនួន ៩រូប បានដើរចេញពីការងារដើម្បីទាមទារដំឡើងប្រាក់ឈ្នួលអប្បបរមា។ ការដើរចេញពីការងារនេះ បានកើតឡើងដើម្បីឆ្លើយតបទៅនឹងសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលក្នុងខែកក្កដា ក្នុងគោលបំណងដំឡើងប្រាក់ឈ្នួលអប្បបរមាដល់ ៦១ដុល្លារអាមេរិកក្នុង ១ខែ ដែលត្រូវដំឡើងចំនួន ៥ដុល្លារអាមេរិក ប៉ុន្តែការដំឡើងនេះ មានកំរិតទាបជាងប្រាក់ឈ្នួលចិញ្ចឹមជីវភាពអប្បបរមា ដែលស្មើ

---

[៤១] Neou Vannarin "អ្នកភូមិតវ៉ានឹងការចាប់ខ្លួនមេដឹកនាំក្នុងជម្លោះដីធ្លី" កាសែត The Cambodia Daily ចេញផ្សាយថ្ងៃទី៨ ខែកញ្ញា ឆ្នាំ២០១០។

[៤២] របាយការណ៍ឃ្លាំមើលសិទ្ធិមនុស្សអង្គការលីកាដូ ដែលមិនត្រូវបានបោះពុម្ពផ្សាយ: KS027OFEA10។

[៤៣] របាយការណ៍ឃ្លាំមើលសិទ្ធិមនុស្សអង្គការលីកាដូ ដែលមិនត្រូវបានបោះពុម្ពផ្សាយ: PP113THI10 & PP121OFEA10។ របាយការណ៍ អង្គការលីកាដូ "សេរីភាពខាងការបញ្ចេញមតិនៅកម្ពុជា: ការបំភ័ន្តលទ្ធិប្រជាធិបតេយ្យ" ខែធ្នូ ឆ្នាំ២០១០ ករណីសិក្សាទី១៦។

ឡើងដោយអ្នកជំនាញឯករាជ្យឆ្ងាយណាស់។ សហជីពភាគច្រើនបំផុតកំពុងស្វែងរកការដំឡើងប្រាក់ឈ្នួលរហូតដល់ ៩៣ដុល្លារអាមេរិកក្នុង១ខែ។ ប្រធានសហជីពបានជម្រាបប្រាប់រោងចក្រ និងរាជរដ្ឋាភិបាលអំពីផែនការណ៍របស់ពួកគេរយៈពេលជាង ២ខែ ខាងមុខនេះ។

- អ្នកតំណាងសហជីពចំនួន ៩រូប រាប់ទាំង អាត់ ធន់ ម៉ុម ញឹម និងមឿន តុលា ត្រូវទទួលរងការគំរាមកំហែងចាប់ខ្លួននៅពេលកំពុងធ្វើកូដកម្ម។ លោក ទូច ណារ័ត្ន ជាស្នងការនគរបាលរាជធានីភ្នំពេញ បានចោទពួកគេពីបទញុះញង់ឲ្យកម្មករធ្វើកូដកម្ម។
- កូដកម្មនោះគ្រោងនឹងធ្វើរយៈពេល ៥ថ្ងៃ ប៉ុន្តែប្រធានសហជីពបានផ្អាកកូដកម្មនេះនៅថ្ងៃទី១៦ ខែកញ្ញាទៅវិញ បន្ទាប់ពីក្រសួងសង្គមកិច្ចបានអញ្ជើញនិយោជក និងអ្នកតំណាងសហជីពឲ្យមកចូលរួមប្រជុំនៅថ្ងៃទី២៧ ខែកញ្ញា ដើម្បីពិភាក្សាអំពីផលប្រយោជន៍ទៅលើប្រាក់ឈ្នួលអប្បបរមា។
- ភាគច្រើនការតវ៉ាបានប្រព្រឹត្តទៅដោយអហិង្សា ប៉ុន្តែយ៉ាងហោចណាស់មានកម្មករចំនួន ២ នាក់បានទទួលរងរបួស គឺកម្មការិនីមួយនាក់អាយុ ២៨ឆ្នាំ មកពីរោងចក្រ Top World Factory នៅខេត្តកណ្ដាល និងកម្មករភេទប្រុសអាយុ ២៩ ឆ្នាំ និងជាមន្ត្រីសហជីពមួយរូបមកពីរោងចក្រ Kbal Koh factory នៅខេត្តកណ្ដាល។ កម្មករភេទប្រុសអាយុ ២៩ នេះ ត្រូវបានចាប់ខ្លួនផងដែរ។
- កម្មករបានវិលត្រឡប់ទៅកាន់រោងចក្ររបស់ពួកគេវិញនៅថ្ងៃបន្ទាប់ ដើម្បីរកឲ្យឃើញថា អ្នករៀបចំសហជីពរាប់រយនាក់ត្រូវបានគេព្យួរពីការងារ។ ម្ចាស់រោងចក្របានចាត់ទុកកូដកម្មនេះ ថាជាកូដកម្មខុសច្បាប់។
- ការព្យួរការងារសហជីពត្រូវបានគាំទ្រដោយដីកាពីតុលាការ។ នៅក្នុងរលកដំបូងនៃការព្យួរការងារ យ៉ាងហោចណាស់ចៅក្រមកម្ពុជាចំនួន ៦នាក់ បានចេញដីកាផ្សេងៗគ្នា ដោយអនុញ្ញាតឲ្យម្ចាស់រោងចក្រព្យួរការងារអ្នកតំណាងសហជីពចំនួនជិត ២០០ នាក់។ ដីកាទាំងនោះ ត្រូវបានចេញបន្ទាប់ពីប្រធានសហជីព បានធ្វើការចរចារដោយសន្តិវិធីអំពីការបញ្ចប់កូដកម្មរបស់ពួកគេមុនពេលកំណត់។
- យ៉ាងហោចណាស់រោងចក្រចំនួន ១០ បានដាក់ពាក្យបណ្ដឹងប្រឆាំងនឹងសហជីពដោយទាមទារឲ្យទូទាត់ប្រាក់ចំណូលដែលបាត់បង់ចំនួនប្រមាណជា ១៥លានដុល្លារអាមេរិក។

- របត់នៃព្រឹត្តិការណ៍ទាំងនេះបានធ្វើឲ្យកម្មករចំនួនរាប់ពាន់នាក់ បានដើរចេញពីការងារលើកទី២ ភ្លាមៗ ដោយពួកគេទាមទារឲ្យប្រធានសហជីព ត្រូវបានអនុញ្ញាតឲ្យចូលធ្វើការវិញ។
- រោងចក្រទាំងនោះ បានទទួលដីកាពីតុលាការផងដែរ ដោយប្រកាសថាការធ្វើកូដកម្មលើកទី២ នេះជាកូដកម្មខុសច្បាប់ ហើយតម្រូវឲ្យកម្មករត្រឡប់ចូលធ្វើការវិញ បើមិនដូច្នោះទេ ពួកគេនឹងប្រឈមនឹងការបញ្ឈប់ពីការងារ។ នៅថ្ងៃទី២១ ខែកញ្ញា កម្មកររាប់ពាន់នាក់បានចំអកឡកឡឺយ និងមិនគោរពដីកាពីតុលាការឡើយ។ ពួកគេត្រូវបានគេទុកពេលឲ្យចំនួន ៤៨ ម៉ោង ដើម្បីវិលត្រឡប់ទៅធ្វើការវិញ បើមិនដូច្នោះទេនឹងត្រូវបណ្តេញចេញពីការងារ។

### *ការគំរាមកំហែង និងការបំភិតបំភ័យ*

- នគរបាលបានប្រើកម្លាំងបង្ក្រាបទៅលើរលកលើកទី២ នៃកូដកម្ម។ នៅថ្ងៃទី១៨ ខែកញ្ញា កម្មករចំនួន ១២នាក់ បានទទួលរងរបួសក្នុងការប៉ះទង្គិចគ្នាជាមួយនគរបាលនៅខាងក្រៅរោងចក្រមួយចំនួននៅរាជធានីភ្នំពេញ និងខេត្តកណ្តាល។ កម្មការិនីមួយរូបមកពីរោងចក្រ the River Rich factory បានដេកព្យាបាលក្នុងមន្ទីរពេទ្យដោយសារមានបញ្ហាបេះដូង បន្ទាប់ពីនគរបាលបានវាយ និងឆក់គាត់នឹងដំបងឆក់។
- បន្ទាប់ពីមានកូដកម្មយ៉ាងតិចណាស់អ្នកដឹកនាំកម្មករចំនួន ៣នាក់ អះអាងថា ពួកគេបានទទួលការគំរាមកំហែងតាមទូរស័ព្ទ និងសារទូរស័ព្ទ។ ពួកគេអះអាងផងដែរថា ពួកគេបានទទួលរងការយាយីរំខាន និងតាមដោយបុរសមិនស្គាល់អត្តសញ្ញាណជិះម៉ូតូ។

### *ដំណើរឆ្ពោះទៅរកដំណោះស្រាយ*

- នៅក្នុងកិច្ចប្រជុំថ្ងៃទី២៧ ខែកញ្ញា ដែលស្នើឡើងដោយក្រសួងសង្គមកិច្ច រាជរដ្ឋាភិបាលបានអំពាវនាវឲ្យបណ្តារោងចក្រទទួលយកនិយោជិត ដែលត្រូវបានព្យួរពីការងារឲ្យចូលធ្វើការវិញ ហើយនឹងលើកលែងការចោទប្រកាន់ជាថ្នូរនឹងការសន្យាពីសហជីពថានឹងមិនធ្វើកូដកម្ម។ ជាគោលការណ៍សហជីពបានយល់ព្រម ចំពោះចំណុចនេះ។
- ក្រោយមកកម្មករកាត់ដេរចំនួន ៣,០០០នាក់ នៅខេត្តកណ្តាលត្រូវបានរោងចក្របណ្តេញចេញ ដោយសារតែពួកគេចូលរួមក្នុងរលកទី២ នៃកូដកម្ម បើទុកជាតាមសេចក្តីរាយការណ៍ពួកគេភាគច្រើនត្រូវបានអនុញ្ញាតឲ្យចូលធ្វើការវិញក៏ដោយ។

ប៉ុន្តែសម្ព័ន្ធសហជីពលទ្ធិប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា (Coalition of Cambodian Apparel Workers Democratic Union) បានរាយការណ៍ថា គិតមកត្រឹមពាក់កណ្តាលខែតុលា មានអ្នកតំណាងសហជីពចំនួន ១០៦នាក់ និងកម្មករ-កម្មការិនីចំនួន ៦៧៧ នាក់ មកពីរោងចក្រចំនួន ១៦ ដែលត្រូវបានគេព្យួរពីការងារមិនត្រូវបានអនុញ្ញាតឲ្យចូលធ្វើការងារវិញឡើយ។

**ថ្ងៃទី២៩ ខែ កញ្ញា ឆ្នាំ២០១០**

**ករណីទី៤៦**

**ការវាយដំជាទម្ងន់ទៅលើប្រធានសហជីព** [៤៤]

***ឃុំត្រពាំងគង ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ***

- ផៅ សាក់ ជាអ្នកតំណាងសហជីពត្រូវបានបុរស ២នាក់ វាយដំនៅថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១០ បន្ទាប់ពីគាត់បានព្យាយាមចរចាប្រាក់បន្ថែមឲ្យកម្មករសម្រាប់ថ្ងៃបុណ្យភ្ជុំបិណ្ឌ។
- ផៅ សាក់ ដែលកំពុងព្យាយាមចរចាប្រាក់បន្ថែមសម្រាប់កម្មករនៅរោងចក្រ the Generation clothing factory ក្នុងខេត្តកំពង់ស្ពឺត្រូវទទួលរងនូវការវាយប្រហារ ខណៈគាត់កំពុងជិះម៉ូតូរបស់គាត់ទៅកាន់រោងចក្រ។ បុរសមិនស្គាល់មុខចំនួន ២ នាក់បានវាយក្បាលរបស់គាត់នឹងបន្ទះក្តារជាច្រើនដង។
- ផៅ សាក់ បានដេកព្យាបាលក្នុងមន្ទីរពេទ្យបន្ទាប់ពីមានការវាយប្រហារ។ គាត់មាននិន្នាការទៅរកសហជីពកម្មករសេរី មេដឹកនាំសហជីពនេះ គឺលោក ជា វិជ្ជា ដែលត្រូវបានគេធ្វើឃាតក្នុងឆ្នាំ២០០៤។ លោក ជា មុន្នី ដែលបច្ចុប្បន្នជាប្រធានសហជីពនេះ បានហៅការវាយប្រហារនេះថាជា "ការប៉ុនប៉ងធ្វើឃាតទៅលើអ្នកតំណាងសហជីពកម្មករសេរី"។
- គ្មានជនសង្ស័យណាម្នាក់ ត្រូវបានចាប់ខ្លួនឡើយ ប៉ុន្តែលោក យុត សុផល ជាអធិការនគរបាលស្រុកបានបដិសេធដែលថា ករណីនេះជាការប៉ុនប៉ងធ្វើឃាត។ គាត់បានលើកឡើងថាករណីនេះ គឺជាករណី "វិវាទជាមួយជនប្រមឹក"។

[៤៤] របាយការណ៍ឃ្លាំមើលសិទ្ធិមនុស្សអង្គការលីកាដូ ដែលមិនត្រូវបានបោះពុម្ពផ្សាយ: KS029AK10។ សូមមើលផងដែរ: របាយការណ៍ អង្គការលីកាដូ "សេរីភាពខាងការបញ្ចេញមតិនៅកម្ពុជា: ការបំភ័ន្តលទ្ធិប្រជាធិបតេយ្យ" ខែធ្នូ ឆ្នាំ២០១០ ករណីសិក្សាទី៣៩។

**ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១០**
**ករណីទី៤៧**

**តុលាការបានកោះហៅបុគ្គលិកទូរទស្សន៍ CTN ទាក់ទងនឹងការចោទប្រកាន់ពីបទផ្សាយព័ត៌មានមិនពិត**[៤៥]

***ឃុំប៉ោយប៉ែត ស្រុកប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ***

- ឡាយ លី អ្នកសារព័ត៌មានទូរទស្សន៍ CTN ត្រូវបានកោះហៅមកសាកសួរអំពីការចោទប្រកាន់ពីបទផ្សាយព័ត៌មានមិនពិត ក្រោយពីស្ថានីយទូរទស្សន៍របស់គាត់បានធ្វើសេចក្ដីរាយការណ៍អំពីជម្លោះដីធ្លីមួយពាក់ព័ន្ធនឹងក្រុមហ៊ុន ARP-OITIC Group។
- ក្រុមហ៊ុននេះ បានដាក់ពាក្យបណ្ដឹងដោយអះអាងថា សេចក្ដីរាយការណ៍នេះបានធ្វើឲ្យខូចខាតដល់កិត្តិយសក្រុមហ៊ុន ពីព្រោះក្រុមហ៊ុនបានទិញដីពីអ្នកភូមិ ហើយនៅតែអនុញ្ញាតឲ្យអ្នកភូមិធ្វើស្រែលើដីនោះ។

**ថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១០**
**ករណីទី៤៨**

*[សូមមើលករណីទី៦០ ផងដែរ]*

**បុគ្គលិកអង្គការអាដហុក ត្រូវបានចោទប្រកាន់ពីបទផ្សាយព័ត៌មានមិនពិត និងបទបរិហារកេរ្តិ៍**[៤៦]

***ភូមិឡពាង ឃុំតាជេស ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង***

- សោម ចាន់គា បុគ្គលិកអង្គការអាដហុកត្រូវបានចោទប្រកាន់ពីបទផ្សាយព័ត៌មានមិនពិត និងបទបរិហារកេរ្តិ៍ទាក់ទងនឹងជម្លោះដីធ្លីរវាងសហគមន៍ក្នុងតំបន់ និងក្រុមហ៊ុន KDC International Company។
- ផេង រុំ និងរាជ ស៊ីម៉ា អ្នកទាំង ២នាក់ ជាសមាជិកសហគមន៍ត្រូវបានចោទប្រកាន់ពីបទបំផ្លិចបំផ្លាញទ្រព្យសម្បត្តិក្រុមហ៊ុន និងបទបរិហារកេរ្តិ៍ផងដែរទាក់ទងនឹងជម្លោះដីធ្លី។ ហៃ ហ៊ី ជាមេភូមិតាជេស បានដាក់ពាក្យបណ្ដឹងក្នុងនាមក្រុមហ៊ុន KDC International Company។

[៤៥] របាយការណ៍ឃ្លាំមើលសិទ្ធិមនុស្សអង្គការលីកាដូ ដែលមិនត្រូវបានបោះពុម្ពផ្សាយ: BM120THI10។ សូមមើលផងដែរ: របាយការណ៍អង្គការលីកាដូ “សេរីភាពខាងការបញ្ចេញមតិនៅកម្ពុជា: ការបំភ័ន្តលទ្ធិប្រជាធិបតេយ្យ” ខែធ្នូឆ្នាំ២០១០ ករណីសិក្សាទី២៥។

[៤៦] របាយការណ៍ឃ្លាំមើលសិទ្ធិមនុស្សអង្គការលីកាដូ ដែលមិនត្រូវបានបោះពុម្ពផ្សាយ: KN049THI10។

ថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១០
ករណីទី៤៩

**កម្មករត្រូវបានតុលាការកោះហៅពីបទញុះញង់ នៅពេលធ្វើកូដកម្មស្របច្បាប់** [៤៧]
***ឃុំពុតស ស្រុកបាទី ខេត្តតាកែវ***

- អ៊ុន ផល្លី និងហង់ គិនសៀក ជាអ្នកតំណាងកម្មករក្រុមហ៊ុន Blue Sam Century factory ត្រូវបានលោក មាស សុភ័ក្រ្ត ជាព្រះរាជអាជ្ញាអមសាលាដំបូងខេត្តតាកែវ ដែលបានចោទប្រកាន់ជនរងគ្រោះមិនត្រឹមត្រូវពីបទញុះញង់កម្មករ ធ្វើការកោះហៅមកសាកសួរ នៅអំឡុងពេលធ្វើកូដកម្មទាមទារសិទ្ធិការងារស្របច្បាប់មួយនៅក្នុងខែកញ្ញា ឆ្នាំ២០១០។

ថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១០
ករណីទី៥០

**អ្នកតំណាងកម្មករជាជនរងគ្រោះពីការគំរាមកំហែងតាមទូរស័ព្ទ** [៤៨]
***ខណ្ឌមានជ័យ រាជធានីភ្នំពេញ***

- អ្នកតំណាងសហជីពកម្មករ ដែលមិនស្គាល់ឈ្មោះនៅរោងចក្រកាត់ដេរផ្កាយ ៨ (Eight Stars Garment Factory) បានទទួលរងការគំរាមកំហែងតាមទូរស័ព្ទពីបុគ្គលមួយចំនួនមិនស្គាល់អត្តសញ្ញាណ ដែលបានប្រាប់ថាពួកគេនឹងសម្លាប់រូបគាត់ប្រសិនបើគាត់មិនព្រមបញ្ឈប់សកម្មភាពសហជីពរបស់គាត់។

ថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១០
ករណីទី៥១

*[សូមមើលករណីទី៣៦ ៦៧ ៦៩ ៧០ ៧៨ ៩១ ៩២ ៩៩ ១១៤ ១១៥ និង ១២២ ផងដែរ]*

**អំពើហិង្សាទៅលើការតវ៉ាដោយអហិង្សា នៅពេលដំណើរទស្សនកិច្ចរបស់លោកអគ្គលេខាធិការអង្គការសហប្រជាជាតិ** [៤៩]
***មន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀតនៅរាជធានីភ្នំពេញ***

- អ្នកតវ៉ាមួយក្រុមមានគ្នាចំនួន ៥០ នាក់ ដែលមកប្រមូលផ្តុំគ្នាដើម្បីស្វែងរកអន្តរាគមន៍ពីលោកអគ្គលេខាធិការអង្គការសហប្រជាជាតិក្នុងជម្លោះដីធ្លី ដែលកំពុងប្រព្រឹត្តិទៅនៅសហគមន៍បឹងកក់ ត្រូវបានបំបែកយ៉ាងហិង្សាពីសំណាក់កងកម្លាំងប្រដាប់អាវុធចំរុះមួយក្រុម ដែលមានមន្ត្រីនគរបាលរដ្ឋបាល និងប្រឆាំងកូដកម្មចំនួនជាង ១០០នាក់។
- លោក សួង សុភ័ណ្ឌ ជាសកម្មជនសហគមន៍ត្រូវបានគេវាយដំជាទម្ងន់ ហើយនឹងត្រូវបានចាប់ខ្លួននៅអំឡុងប៉ះទង្គិចគ្នា។ បន្ទាប់ពីបានចាប់ខ្លួនលោក សួង សុភ័ណ្ឌ

---

[៤៧] របាយការណ៍ឃ្លាំមើលសិទ្ធិមនុស្សអង្គការលីកាដូ ដែលមិនត្រូវបានបោះពុម្ពផ្សាយ:PP123SC10។

[៤៨] Deu Ayuth Chea "អ្នកតំណាងកម្មករពីរោងចក្រកាត់ដេរផ្កាយ ៨ ទទួលរងនូវការគំរាមកំហែងដល់អាយុជីវិត ពីអ្នកហៅទូរស័ព្ទមិនស្គាល់អត្តសញ្ញាណ" វិទ្យុអាស៊ីសេរី ចេញផ្សាយថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១០ វេលាម៉ោង ៨:៣០ យប់។

[៤៩] សេចក្តីប្រកាសព័ត៌មានអង្គការលីកាដូ "ការបង្ក្រាបហិង្សាទៅលើអ្នកតវ៉ា នៅអំឡុងទស្សនកិច្ចរបស់អគ្គលេខាធិការអង្គការសហប្រជាជាតិ" ចេញផ្សាយថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១០: http://www.licadho-cambodia.org/pressrelease.php?perm=229។ សូមមើលផងដែរ: ខ្សែវីដេអូអង្គការលីកាដូ: http://www.licadho-cambodia.org/video.php?perm=20។ សូមមើលផងដែរ: របាយការណ៍ឃ្លាំមើលសិទ្ធិមនុស្សអង្គការលីកាដូ ដែលមិនត្រូវបានបោះពុម្ពផ្សាយ: PP14OFEA10

បានសន្លប់បាត់ស្មារតីដោយសារខ្សែរះឈាម ដែលហូរចេញពីមុខរបួសនៅលើក្បាលរបស់គាត់។ ខ្សែវីឌីអូអំពីឧប្បត្តិហេតុនេះបានបង្ហាញថា នគរបាលបន្តអូស និងវាយដំ លោក សួង សុភ័ណ្ឌ នៅពេលដែលគាត់កំពុងបាត់បង់ស្មារតី។

**ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១០**
**ករណីទី៥២**

**អ្នកតំណាងភូមិត្រូវបានរារាំងមិនឲ្យប្រគល់ញត្តិ** [៥០]
***ឃុំគោកចាក់ ស្រុកសៀមរាប ខេត្តសៀមរាប***

- ប៊ិក ងំ ជាអ្នកតំណាងសហគមន៍ និងអ្នកភូមិចំនួន ១៧នាក់ បានព្យាយាមប្រគល់ញត្តិទាក់ទងនឹងជម្លោះដីធ្លីមួយជូនលោកស្រី ហ៊ីលឡារី គ្លិនតុន (Hillary Clinton) ជារដ្ឋមន្ត្រីក្រសួងការបរទេសសហរដ្ឋអាមេរិក ខណៈលោកស្រីបានធ្វើដំណើរទស្សនកិច្ចទៅកាន់ខេត្តសៀមរាប។ ក្រុមមនុស្សទាំងនេះ ត្រូវបានមន្ត្រីនគរបាលការពារបេតិកភ័ណ្ឌខេត្ត ចំនួន ៦នាក់ ឃាត់ខ្លួន និងរារាំងមិនឲ្យដាក់ញត្តិ។ អ្នកភូមិទាំងនោះត្រូវបានដោះ លែងវិញបន្ទាប់ពីមានកិច្ចអន្តរាគមន៍ពីបុគ្គលិកអង្គការលីកាដូប្រចាំខេត្តសៀមរាប។

**ថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០១០**
**ករណីទី៥៣**

**អ្នកតំណាងអ្នកភូមិគេចខ្លួនចូលទៅក្នុងព្រៃ ដើម្បីរត់គេចពីការចាប់ខ្លួនមិនត្រឹមត្រូវ** [៥១]
***ភូមិសង្គមថ្មី ឃុំថ្មដា ស្រុកវាលវែង ខេត្តពោធិសាត់***

- ពៅ, បេ បុន, ផៃ និងគាយ ដំឡូងមី ជាតំណាងអ្នកភូមិបានគេចខ្លួនចូលទៅក្នុងព្រៃក្រោយពីបានដឹងថាតុលាការបានចេញដីកាចាប់ខ្លួន ដោយចោទប្រកាន់ពួកគេពីបទញុះញង់ប្រជាពលរដ្ឋឲ្យធ្វើការតវ៉ាប្រឆាំងនឹងក្រុមហ៊ុន MDS របស់ឧកញ៉ា ទ្រី ភាព។ ភូមិរបស់ពួកគេ គឺមានការពាក់ព័ន្ធក្នុងជម្លោះដីធ្លី ជាមួយក្រុមហ៊ុននេះ។
- នៅថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០១០ ក្រុមហ៊ុន MDS បានដឹកជញ្ជូនឧបករណ៍គ្រឿងចក្រទៅកាន់ភូមិនោះ ដើម្បីឈូសឆាយព្រៃឈើ ដីស្រែចំការ និងផ្ទះសម្បែង។ ដំណើរការនេះត្រូវបានគ្រប់គ្រងដោយកងកម្លាំងប្រដាប់អាវុធរបស់រាជរដ្ឋាភិបាល។

---

[៥០] របាយការណ៍ឃ្លាំមើលសិទ្ធិមនុស្សអង្គការលីកាដូ ដែលមិនត្រូវបានបោះពុម្ពផ្សាយ: SP039IAD10។

[៥១] កាសែតកោះសន្តិភាព “តំណាងអ្នកភូមិដែលធ្វើការតវ៉ានឹងការរឹបអូសយកដីធ្លីពីក្រុមហ៊ុន MDS ប្រឈមនឹងការឃុំខ្លួន” ព័ត៌មានកាសែតមនសិការខ្មែរ ចេញផ្សាយថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០១០។

**ថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១០**
**ករណីទី៥៤**

### ការរារាំងមិនឲ្យបញ្ចាំងខ្សែភាពយន្ត ស្ដីពីឃាតកម្មលើរូប លោក ជា វិជ្ជា [៥២]

*រាជធានីភ្នំពេញ*

- លោក រ៉ុង ឈុន ជាប្រធានសមាគមន៍គ្រូបង្រៀនឯករាជ្យកម្ពុជា (CITA) ត្រូវបានមន្ត្រីនគរបាលចំនួន ៧០ នាក់ រារាំងមិនឲ្យបង្ហាញភាពយន្តឯកសារ ដែលមានចំណងជើងថា *នណាជាអ្នកសម្លាប់លោក ជា វិជ្ជា?* នៅក្នុងទីលានសេរីភាព ដែលទើបតែបើកសម្ពោធថ្មី ៗ។ លោក សុខ ពេញវុធ ជាអភិបាលរងខ័ណ្ឌដូនពេញបានបញ្ជាមន្ត្រីនគរបាលទាំងនោះ ដើម្បីរារាំងមិនឲ្យបញ្ចាំងភាពយន្តឯកសារនោះ។

**ថ្ងៃទី១៨ ខែ វិច្ឆិកា ឆ្នាំ២០១០**
**ករណីទី៥៥**

### ប្រធានសហជីពត្រូវបានចាប់ខ្លួន ហើយនឹងត្រូវគេទម្លាក់កំហុសដាក់ពីបទជួញដូរគ្រឿងញៀន [៥៣]

*សង្កាត់ទឹកថ្លា ខ័ណ្ឌសែនសុខ រាជធានីភ្នំពេញ*

- សួស ចន្ថា ជាប្រធានសហជីពរោងចក្រ United Apparel Garment Factory ត្រូវបានចាប់ខ្លួនពីបទជួញដូរគ្រឿងញៀន តែប៉ុន្មានម៉ោងប៉ុណ្ណោះបន្ទាប់ពីគាត់បានដឹកនាំការផ្ទេរកម្មករចំនួនប្រហែល ១,០០០ នាក់ចេញពី IDUF ដែលគាំទ្ររាជរដ្ឋាភិបាល ទៅកាន់ CCAWDU។ សួស ចន្ថា ត្រូវបានឃាត់ខ្លួន ដោយកងរាជអាវុធហត្ថ ដែលអះអាងថា ពួកគេបានរកឃើញសារជាតិមិនស្គាល់មួយចំនួនតូចក្នុងម៉ូតូរបស់គាត់។
- ការចាប់ខ្លួននេះ មានភាពមិនប្រក្រតីជាច្រើន ហើយប្រវត្តិរឿងពីអាជ្ញាធរមានភាពមិនស៊ីសង្វាក់គ្នាយ៉ាងច្រើន។ ឧ: មន្ត្រីនគរបាលបានប្រាប់ សួស ចន្ថា ថាពួកគេបានទទួលព័ត៌មានអំពីសារជាតិញៀននេះ ហើយថាអាជ្ញាធរបានតាមដានគាត់អស់រយៈពេល ៣ថ្ងៃ។ ប៉ុន្តែរបាយការណ៍របស់មន្ត្រីនគរបាលទាំងនេះ បាននិយាយថា ពួកគេបានដាក់របាំងរាំងផ្លូវថ្នល់ ដើម្បីត្រួតពិនិត្យរថយន្តរកអាវុធ ហើយបានឃាត់ខ្លួនលោក សួស ចន្ថា ដោយសារតែគាត់គួរឲ្យសង្ស័យ។ តាមការស៊ើបអង្កេតពីអង្គការលីកាដូបាន បង្ហាញថា ពុំមានការដាក់របាំងផ្លូវការឡើយនៅពេលចាប់ខ្លួនលោក សួស ចន្ថា។ លោក សួស ចន្ថា ត្រូវបានគេនាំខ្លួនចេញឆ្ងាយពីម៉ូតូរបស់គាត់ ដោយបង្ខំផងដែរ ហើយគេឲ្យគាត់បែរខ្នងត្រឡប់មកក្រោយ នៅពេលមន្ត្រីរកឃើញសារជាតិញៀននោះ។ លើសពីនេះទៀត សារធាតុញៀនទាំងនេះ ត្រូវបានគេញាត់ដោយ

---

[៥២] របាយការណ៍ឃ្លាំមើលសិទ្ធិមនុស្សអង្គការលីកាដូ ដែលមិនត្រូវបានបោះពុម្ពផ្សាយ: PP140ODFEA10។

[៥៣] របាយការណ៍ឃ្លាំមើលសិទ្ធិមនុស្សអង្គការលីកាដូ ដែលមិនត្រូវបានបោះពុម្ពផ្សាយ: PP143IAD10។ សូមមើលផងដែរ: បណ្ណសារដ្ឋាន ព័ត៌មានអង្គការលីកាដូ "អ្នកគាំទ្រប្រមូលផ្ដុំគ្នានៅខាងក្រៅពន្ធនាគារជាតិកម្ពុជា ដើម្បីស្វែងរកការដោះលែងប្រធានសហជីព" ចេញផ្សាយថ្ងៃទី២១ ខែមករា ឆ្នាំ២០១១: http://www.licadho-cambodia.org/articles/20110121/130/index.html។

មិនទំនងបញ្ចូលក្នុងប្រឡោះកែប និងសាក់ហ្ស៊ីម៉ូតូ ដោយបញ្ជាក់ថាសារធាតុទាំងនេះ ត្រូវបានគេញាត់នៅពេលបិទកែបម៉ូតូ។ លោក សួស ចន្ថា បានបដិសេធដោយសមស្របថា គាត់មិនបានកាន់កាប់សារធាតុញៀនឡើយ។

- ការជុំនំជម្រះត្រូវបានធ្វើឡើងអស់រយៈពេល ២ម៉ោង នៅថ្ងៃទី២៤ ខែមិថុនា ឆ្នាំ ២០១១ ក្រោយពីមានសម្ពាធកើនឡើងពីក្រុមហ៊ុនទិញសំលៀកបំពាក់អន្តរជាតិ។ នៅអំឡុងពេលជុំនំជម្រះបានបន្សល់ទុកនូវភាពមិនស្របគ្នាជាច្រើន ដែលមិនបានលើកយកមកដេញដោល ហើយគ្មានភ័ស្តុតាងគួរឲ្យជឿជាក់ ដែលបញ្ជាក់ពីពិរុទ្ធភាពរបស់ សួស ចន្ថា ត្រូវបានលើកមកបង្ហាញឡើយ។ ទីបំផុតចៅក្រមបានរកឃើញថា សួស ចន្ថា មានពិរុទ្ធភាព ហើយត្រូវបានកាត់ទោសតម្រឹមឲ្យជាប់ពន្ធនាគារចំនួន ១០ខែ។

**ថ្ងៃទី១៩-២១ ខែវិច្ឆិកា ឆ្នាំ២០១០**
**ករណីទី៥៦**

**អ្នកភូមិ និងសកម្មជនត្រូវបានតុលាការកោះហៅទាក់ទងនឹងករណីដីធ្លី [៥៤]**
***ឃុំអន្លង់ត្នោត ស្រុកក្រគរ ខេត្តពោធិ៍សាត់***

- អ្នកភូមិចំនួន ១២ នាក់រាប់ទាំងសកម្មជនបណ្តាញសន្តិភាពកម្ពុជា ត្រូវបានលោក គុប ចាន់សេរីវុទ្ធ ជាព្រះរាជអាជ្ញាអមសាលាដំបូងខេត្ត កោះហៅមកសាកសួរជុំវិញការចោទប្រកាន់ ដែលថាពួកគេបានញុះញង់ប្រជាពលរដ្ឋឲ្យបំផ្លិចបំផ្លាញទ្រព្យសម្បត្តិឯកជនរបស់ក្រុមហ៊ុន Pheapimex ហើយនឹងធ្វើការរារាំងការងារអាជ្ញាធររាជរដ្ឋាភិបាល។ អ្នកភូមិទាំងនោះ មានពាក់ព័ន្ធក្នុងជម្លោះដីធ្លីជាមួយក្រុមហ៊ុន Pheapimex នេះ។

---

[៥៤] របាយការណ៍ឃ្លាំមើលសិទ្ធិមនុស្សអង្គការលីកាដូ ដែលមិនត្រូវបានបោះពុម្ពផ្សាយ: PS044SC10។

## ឧបសម្ព័ន្ធ ២: អ្នកការពារសិទ្ធិមនុស្សនៅកម្ពុជា (ខែមករា ដល់ខែធ្នូ ឆ្នាំ២០១១)

**ថ្ងៃទី១៤ ខែមករា ឆ្នាំ២០១១**
**ករណីទី៥៧**

### នគរបាលឃុំខ្លួនអ្នកថតរូប ហើយលុបរូបភាពចោល [៥៥]
***រាជធានីភ្នំពេញ***

- អ្នកថតរូបម្នាក់មកពីកាសែតភ្នំពេញប៉ុស្ដិ៍ *(The Phnom Penh Post)* កំពុងថតប្រជាពលរដ្ឋ ដែលកំពុងត្រូវបានគេបណ្ដេញចេញដោយបង្ខំពីតំបន់បឹងកក់ ហើយគាត់ត្រូវបានឃុំខ្លួន ដោយនគរបាល ដែលបន្ទាប់មកនគរបាលបានលុបរូបភាពចេញពីម៉ាស៊ីនថតរបស់គាត់។

**ថ្ងៃទី២២ ខែមករា ឆ្នាំ២០១១**
**ករណីទី៥៨**

### អាជ្ញាធររឹបអូសម៉ាស៊ីនថតសម្លេងអ្នកសារព័ត៌មាន [៥៦]
***រាជធានីភ្នំពេញ***

- អ្នកសារព័ត៌មានចំនួន ៤ រូប ដែលមានឈ្មោះ ផាន់ អាណា *(កាសែត The Cambodia Daily)* វង់ សុខហេង *(កាសែត The Phnom Penh Post)* ហៃ ស៊ីណា *(គេហទំព័រ Sabay Sabay)* ហើយនឹង សុខ គុញ (*Chinese Sieng Huor*) ត្រូវបានអាជ្ញាធររាជរដ្ឋាភិបាលរឹបអូសយកម៉ាស៊ីនថតសម្លេងរបស់ពួកគេ នៅអំឡុងពេលសន្និសីទកាសែតមួយ ដែលរៀបចំឡើងដោយអង្គភាពប្រឆាំងអំពើពុករលួយ ។
- ការរឹបអូសនេះ បានកើតឡើងបន្ទាប់ពីអ្នកសារព័ត៌មានរបស់កាសែត *The Cambodia Daily* មួយរូប បានចោទសួរអំពីការស៊ើបអង្កេតរបស់ FBI ទៅលើការវាយប្រហារដោយគ្រាប់បែកដៃនៅឆ្នាំ១៩៩៧ ដែលទុកចោលមិនទាន់បានដោះស្រាយនៅអំឡុងពេលបាតុកម្ម ដោយគណបក្សប្រឆាំង ដែលបានសម្លាប់ប្រជាពលរដ្ឋចំនួនយ៉ាងតិចណាស់ ១៦នាក់ ហើយនឹងរបួសជាង ១០០ នាក់។
- ម៉ាស៊ីនថតសម្លេងត្រូវបានរឹបអូសដោយលោក សេង បូរ័ត្ន ជាអនុប្រធានអង្គភាពប្រឆាំងអំពើពុករលួយ ដែលធ្វើតាមបញ្ជារបស់ឯកឧត្ដម ឱម យ៉ិនទៀង ជាប្រធានអង្គភាពប្រឆាំងអំពើពុករលួយ។

---

[៥៥] សូមមើលផងដែរ: របាយការណ៍អង្គការលីកាដូ (ខែតុលា ឆ្នាំ២០១១) "ការបំភ័ន្តភាពជឿនលឿន: ការរំលោភបំពានពីអង្គនីតិបញ្ញត្តិកម្ពុជា ទៅលើសេរីភាពខាងការបញ្ចេញមតិ": http://www.licadho-cambodia.org/reports/files/162LICADHOReport-Legislative Assault FreedomExpression2011-English.pdf។

[៥៦] របាយការណ៍ឃ្លាំមើលសិទ្ធិមនុស្សអង្គការលីកាដូ ដែលមិនត្រូវបានបោះពុម្ពផ្សាយ: PP011OFEA11។ សូមមើលផងដែរ: របាយការណ៍អង្គការលីកាដូ (ខែតុលា ឆ្នាំ២០១១) "ការបំភ័ន្តភាពជឿនលឿន: ការរំលោភបំពានពីអង្គនីតិបញ្ញត្តកម្ពុជាទៅលើសេរីភាពខាងការបញ្ចេញមតិ": http://www.licadho-cambodia.org/reports/files/162LICADHOReport-LegislativeAssaultFreedomExpression2011-English.pdf។

**ថ្ងៃទី២៥ ខែមករា ឆ្នាំ២០១១**
**ករណីទី៥៩**

**[សូមមើលករណីទី៦២ និង៧៦ ផងដែរ]**

**នគរបាលធ្វើឲ្យអ្នកភូមិរបួសជាទម្ងន់ នៅអំឡុងពេលតវ៉ាដោយអហិង្សា** [៥៧]
***ឃុំសំរោងទង ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ***

- អ្នកភូមិចំនួន ៣០នាក់ ដែលមានក្នុងជម្លោះដីធ្លីជាមួយក្រុមហ៊ុនឯកជន ត្រូវបានកងកម្លាំងប្រដាប់អាវុធចម្រុះមួយក្រុម ដែលមានគ្នាចំនួន ៨០នាក់ ធ្វើឲ្យរបួសជាទម្ងន់ នៅអំឡុងពេលបាតុកម្មមួយដើម្បីការពារដីចំនួន៩៥០ហិកតា។ ក្រុមហ៊ុនសហប្រតិបត្តិការអន្តរជាតិ (Master International Cooperation Group) គឺជាក្រុមហ៊ុនមួយដែលទាមទារដីមានការប៉ុនប៉ងឈូសឆាយលើដីនោះ។

**ថ្ងៃទី២៥ ខែមករា ឆ្នាំ២០១១**
**ករណីទី៦០**

***[សូមមើលករណី៤៨ ផងដែរ]***

**សកម្មជនដីធ្លីត្រូវបានកាត់ទោសពីបទបរិហារកេរ្តិ៍ បន្ទាប់ពីផ្តល់កិច្ចសម្ភាសន៍តាមវិទ្យុ** [៥៨]
***ភូមិឡពាង ឃុំតាជេស ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង***

- រាជ សីម៉ា ជាតំណាងសហគមន៍ និងសួម ចាន់គា ជាបុគ្គលិកអង្គការអាដហុក ត្រូវបានរកឃើញពិរុទ្ធភាពពីបទបរិហារកេរ្តិ៍ បន្ទាប់ពីក្រុមហ៊ុន KDC International Co.,Ltd. បានដាក់ពាក្យបណ្តឹងទាក់ទងនឹងកិច្ចសម្ភាសន៍មួយ ដែលបានចាក់ផ្សាយតាមវិទ្យុអាស៊ីសេរី កាលពីថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០០៩។ ជនរងគ្រោះទាំង ២ នាក់ នេះបានផ្តល់មតិផ្លូវច្បាប់សមស្រប ស្តីពីនីតិវិធីតុលាការទាក់ទងនឹងជម្លោះដីធ្លីនៅភូមិឡពាង។
- ជម្លោះដីធ្លីនេះធ្វើឲ្យអ្នកភូមិប្រឆាំងនឹងក្រុមហ៊ុន KDC International Co. ដែលជា កម្មសិទ្ធិរបស់ជំទាវ ជា ខេង ជាភរិយារបស់រដ្ឋមន្ត្រីក្រសួងឧស្សាហកម្មរ៉ែ និង ថាមពល។

**ថ្ងៃទី២៦ ខែមករា ឆ្នាំ២០១១**
**ករណីទី៦១**

**ការបំភិតបំភ័យតាមផ្លូវតុលាការ ទៅលើតំណាងសហគមន៍** [៥៩]
***ឃុំស្ទឹងឆាយ ស្រុកកំពង់សីលា ខេត្តព្រះសីហនុ***

- អ្នកតំណាងចំនួន ២ នាក់ដែលធ្វើការតស៊ូដើម្បីរារាំងមិនឲ្យក្រុមហ៊ុនម៉ុង រិទ្ធី រឹបអូសយកដីធ្លីរបស់ពួកគេ ត្រូវបានកោះហៅមកសួចម្លើយ ដោយប្រឈមនឹងការចោទប្រកាន់ថា ពួកគេបានក្លែងបន្លំឯកសារទាក់ទងនឹង ជម្លោះដីធ្លីនោះ។ ដីទំនាស់នេះមានទំហំ ១៧០ ហិកតារដែលជាដី កម្មសិទ្ធិរបស់ប្រជាពលរដ្ឋចំនួន ៤២គ្រួសារ។

---

[៥៧] របាយការណ៍ឃ្លាំមើលសិទ្ធិមនុស្សអង្គការលីកាដូ ដែលមិនត្រូវបានបោះពុម្ពផ្សាយ: KS005LG11។

[៥៨] FIDH "សង្គមស៊ីវិលអាស៊ីថ្កោលទោសការកាត់ទោស លោក សោម ចាន់គា ជាអ្នកការពារសិទ្ធិមនុស្សកម្ពុជា ដោយសារការអនុវត្តសិទ្ធិរបស់គាត់ខាងការបញ្ចេញមតិ" ចេញផ្សាយថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១១: http://www.fidh.org/Asian-civil-society-condemns-the។

[៥៩] របាយការណ៍ឃ្លាំមើលសិទ្ធិមនុស្សអង្គការលីកាដូ ដែលមិនត្រូវបានបោះពុម្ពផ្សាយ: SV008LG11។

**ថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១១**
**ករណីទី៦២**

*[សូមមើលករណីទី៥៩ និង៧៦ ផងដែរ]*

**ការបង្ក្រាបហិង្សាពីនគរបាល ទៅលើការតវ៉ាដោយអហិង្សា** [៦០]
***ឃុំតាំងសំរោង ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ***

- អ្នកភូមិប្រមាណជា ៣៥នាក់ ត្រូវបានកងកម្លាំងប្រដាប់អាវុធចម្រុះ រួមមានមន្ត្រីនគរបាលខេត្ត កងរាជអាវុធហត្ថខេត្ត និងទាហានយោធភូមិភាគទី៣ វាយដំឲ្យរបួសជាទម្ងន់នៅអំឡុងពេលធ្វើការតវ៉ាមួយ។
- អ្នកភូមិទាំងនោះ បានធ្វើការតវ៉ាប្រឆាំងនឹងការប្រើប្រាស់គ្រឿងចក្រដើម្បីឈូសឆាយលើដីរបស់ពួកគេ ដែលក្រុមហ៊ុន Master International Group បានទាមទារយក។

**ថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១១**
**ករណីទី៦៣**

**កម្មករសំណង់ត្រូវបានបញ្ឈប់ពីការងារ បន្ទាប់ពីប៉ុនប៉ងចូលរួមសហជីព** [៦១]
***ឃុំត្រពាំងធំ ស្រុកទឹកឈូ ខេត្តកំពត***

- ប៉ែន ផល្លា ជាប្រធានសហជីព និងកម្មករសំណង់ចំនួន ៧១នាក់ ត្រូវបានលោក ជី មាត ជាតំណាងក្រុមហ៊ុន TSO Cambodia Railway ធ្វើការបញ្ឈប់ពីការងារ បន្ទាប់ពីពួកគេព្យាយាមចូលរួមសហជីព។
- ក្រុមហ៊ុននេះ ធ្វើការជួសជុលបណ្តាញផ្លូវរថភ្លើងកម្ពុជា ជាគម្រោងមួយដែលទទួលហិរញ្ញប្បទានមួយផ្នែកពីធនាគារអភិវឌ្ឍន៍អាស៊ី។

**ថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១១**
**ករណីទី៦៤ និង៦៥**

*[សូមមើលករណីទី៧៥ ៨៧ ៨៩ និង៩៧ ផងដែរ]*

**អាជ្ញាធររារាំងការតវ៉ាដោយអហិង្សារបស់សកម្មជនព្រៃឡង់** [៦២]
***ស្រុកសណ្តាន់ ខេត្តកំពង់ធំ***

- អ្នកភូមិចំនួនជាង ៣៦៥ ដែលរស់នៅជុំវិញព្រៃឡង់ បានមកប្រមូលផ្តុំគ្នាអស់រយៈពេលជាង ៤៨ម៉ោង ដើម្បីធ្វើការតវ៉ានឹងការកាប់ឈើយ៉ាងខ្លាំងក្លា ដែលប្រព្រឹត្តដោយក្រុមហ៊ុន CRCK ជាក្រុមហ៊ុនវៀតណាម និងក្រុមហ៊ុន PNT។ ក្រុមហ៊ុនទាំង ២ នេះ បានធ្វើអាជីវកម្មកាប់ឈើលើដី ដែលបានទទួលជាផ្នែកនៃដីសម្បទានសេដ្ឋកិច្ចចំនួន ៦,០៩៤ហិកតា។ កងកម្លាំងប្រដាប់អាវុធចម្រុះមួយក្រុម បានរារាំងអ្នកតវ៉ាមិនឲ្យចូលដល់ទីកន្លែងអាជីវកម្មកាប់ឈើ។
- អ្នកភូមិចំនួន ៤ នាក់ត្រូវ បានចោទប្រកាន់ពីបទញុះញង់។

[៦០] របាយការណ៍ឃ្លាំមើលសិទ្ធិមនុស្សអង្គការលីកាដូ ដែលមិនត្រូវបានបោះពុម្ពផ្សាយ: KS008PA11។
[៦១] របាយការណ៍ឃ្លាំមើលសិទ្ធិមនុស្សអង្គការលីកាដូ ដែលមិនត្រូវបានបោះពុម្ពផ្សាយ: KP005SC11។
[៦២] របាយការណ៍ឃ្លាំមើលសិទ្ធិមនុស្សអង្គការលីកាដូ ដែលមិនត្រូវបានបោះពុម្ពផ្សាយ: KT014LG11។

**ថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១១**
**ករណីទី៦៦**

**ប្រធានរដ្ឋបាលព្រៃឈើគំរាមកំហែងសកម្មជន** [៦៣]
***ឃុំអូរបីជាន់ ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ***

- តំណាងសហគមន៍ចំនួន ៩នាក់ ឈ្មោះ កែវ សុង ហ៊ិល ព្រឹល ប៊ុន ស៊ីណាត និង កត ឡុន ត្រូវបានប្រធានរដ្ឋបាលព្រៃឈើឈ្មោះ សួង ម៉ារិន ធ្វើការគំរាមកំហែងនៅអំឡុងពេលប្រជុំមួយ ស្តីពីជម្លោះដីធ្លីដ៏រាំរ៉ៃរវាងប្រជាពលរដ្ឋចំនួន ៨៩គ្រួសារ និងក្រុមហ៊ុន Hai Sou Company។

**ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១១**
**ករណីទី៦៧**

*[សូមមើលករណីទី៣៦ ៥១ ៦៩ ៧០ ៧៨ ៩១ ៩២ ៩៩ ១១៨ ១១៥ និង ១២២ ផងដែរ]*

**សកម្មជនសហគមន៍បឹងកក់ ត្រូវបានចាប់ខ្លួននៅអំឡុងពេលបាតុកម្មដោយអហិង្សា** [៦៤]
***សង្កាត់ស្រះចក ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ***

- តំណាងសហគមន៍ចំនួន ៣នាក់ មកពីសហគមន៍បឹងកក់ ត្រូវបានចាប់ខ្លួន នៅអំឡុងពេលបាតុកម្មមួយ ប្រឆាំងនឹងផែនការណ៍សាងសង់ផ្លូវថ្មីមួយចូលទៅកាន់តំបន់បឹងកក់។
- ការចាប់ខ្លួននេះបានកើតឡើង នៅពេលមន្ត្រីនគរបាលមួយក្រុមមានគ្នាចំនួន ៥០០ នាក់ ដឹកនាំដោយលោក សុខ សម្បត្តិ ជាអភិបាលខ័ណ្ឌដូនពេញ បានធ្វើការរារាំងបាតុកម្មដោយអហិង្សាមួយ។
- អាជ្ញាធរបានកំទេចផ្ទះសម្បែងចំនួន ១៩ខ្នងនៅភូមិបឹងកក់៣ ដើម្បីសាងសង់ផ្លូវថ្មី។

**ថ្ងៃទី១៤ ខែមិនា ឆ្នាំ២០១១**
**ករណីទី៦៨**

**តំណាងសហគមន៍ត្រូវបានចាប់ខ្លួន បន្ទាប់ពីបានរៀបចំការតវ៉ា** [៦៥]
***ឃុំព្រែកខ្សាច់ ស្រុកគីរីសាគរ ខេត្តកោះកុង***

- ព្រាប ណារិន ជាតំណាងសហគមន៍ត្រូវបានចាប់ខ្លួនដោយកងរាជអាវុធហត្ថ និងមន្ត្រីបរិស្ថានចំនួន ១៥នាក់ ដឹកនាំដោយតំណាងក្រុមហ៊ុន Chinese Union Development Group Company Ltd។ ការចាប់ខ្លួននេះ បានធ្វើឡើងបន្ទាប់ពី លោក ណារិន បានដឹកនាំប្រជាពលរដ្ឋចំនួន ៣០គ្រួសារ ធ្វើការតវ៉ា ដែលពួកគេបានទទួលរងផលប៉ះពាល់ពីជម្លោះដីធ្លីជាមួយក្រុមហ៊ុននេះ ដែលទទួលបានដីសម្បទានទំហំ ៣៦,០០០ ហិកតា ក្នុងតំបន់នោះ។
- ព្រាប ណារិន ត្រូវបានដោះលែងវិញ បន្ទាប់ពីគាត់ត្រូវបានគេដាក់សម្ពាធឲ្យទទួល

[៦៣] របាយការណ៍ឃ្លាំមើលសិទ្ធិមនុស្សអង្គការលីកាដូ ដែលមិនត្រូវបានបោះពុម្ពផ្សាយ: BM019THI11។
[៦៤] របាយការណ៍ឃ្លាំមើលសិទ្ធិមនុស្សអង្គការលីកាដូ ដែលមិនត្រូវបានបោះពុម្ពផ្សាយ: PP031OFEA11។
[៦៥] របាយការណ៍ឃ្លាំមើលសិទ្ធិមនុស្សអង្គការលីកាដូ ដែលមិនត្រូវបានបោះពុម្ពផ្សាយ: KK009IAD11។

យកគោលនយោបាយសំណងមិនគ្រប់គ្រាន់ សម្រាប់ដីធ្លីក្នុងនាមអ្នកភូមិ ដែលត្រូវបានគេបណ្តេញចេញ។ លោក វុទ្ធ ជាមេបញ្ជាការកងរាជអាវុធហត្ថស្រុកគីរីសាគរ គឺជាអ្នកសម្របសម្រួលនូវកិច្ចចរចា។

**ថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១១**

**ករណីទី៦៩**

*[សូមមើលករណីទី៣៦ ៥១ ៦៧ ៧០ ៧៨ ៩១ ៩២ ៩៩ ១១៤ ១១៥ និង ១២២ ផងដែរ]*

**តំណាងសហគមន៍បឹងកក់ ត្រូវបានគេវាយដំ និងចាប់ខ្លួននៅអំឡុងពេលបំបែកអ្នកតវ៉ា** [៦៦]

*សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ*

- គង់ ចន្ថា ជាតំណាងសហគមន៍បឹងកក់ ត្រូវបានគេវាយដំ និងចាប់ខ្លួន បន្ទាប់ពីអ្នករស់នៅសហគមន៍បឹងកក់ បានប្រមូលផ្តុំគ្នានៅខាងក្រៅសាលាក្រុងរាជធានីភ្នំពេញ ដើម្បីទាញការចាប់អារម្មណ៍ចំពោះជម្លោះដីធ្លីរបស់ពួកគេ។ អ្នករស់នៅសហគមន៍បឹងកក់ចំនួនប្រហែល ៣០០នាក់ បានបន្តធ្វើការតវ៉ារហូតដល់ពួកគេ ត្រូវ បានមន្ត្រីកងរាជអាវុធហត្ថ និងមន្ត្រីនគរបាលមួយក្រុម ដែលមានគ្នាចំនួន ១២០ នាក់ធ្វើការបំបែក។ អាជ្ញាធរទាំងនេះ ត្រូវបានដឹកនាំដោយលោក ទូច ណារ័ត្ន ជាស្នងការនគរបាលរាជធានីភ្នំពេញ។

**ថ្ងៃទី២១ ខែមេសា ឆ្នាំ២០១១**

**ករណីទី៧០**

*[សូមមើលករណីទី៣៦ ៥១ ៦៧ ៦៩ ៧៨ ៩១ ៩២ ៩៩ ១១៤ ១១៥ និង ១២២ ផងដែរ]*

*សកម្មជន និងកុមារ ត្រូវបាននគរបាលធ្វើឲ្យរបួស នៅអំឡុងពេលតវ៉ាដោយអហិង្សា* [៦៧]

*សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ*

- អ្នកភូមិសហគមន៍បឹងកក់ចំនួនប្រហែល ១០០ នាក់ ត្រូវបានកងកម្លាំងនគរបាលមួយចំនួនធ្វើការបំបែកយ៉ាងហិង្សា បន្ទាប់ពីបានធ្វើការតវ៉ាដោយអហិង្សាមួយនៅមុខសាលាក្រុងរាជធានីភ្នំពេញ។
- អ្នកភូមិចំនួន ១១នាក់ ដែលត្រូវបានចាប់ខ្លួន និងឃុំខ្លួនអស់រយៈពេលមួយយប់ រួមមាន អាន គ្រីន ជា ដារ៉ា គឹម វណ្ណី គង់ សុភាព លី ម៉ុន រស់ ស្រីនាង សាន សុផាន់ ទេព វន្នី និងតុល ស្រីពៅ ដែលពួកគេជាតំណាងសហគមន៍ ព្រមទាំងកុមារចំនួន ២ នាក់ ឈ្មោះ ហែម វីរៈយុទ្ធ និងលឹម សុទ្ធារិទ្ធិ។ មនុស្សភាគច្រើនទទួលរងរបួស រាប់ទាំងអ្នកស្រី ទេព វន្នី ដែលមេដៃរបស់គាត់បែក ដោយសារកៀបនឹងទ្វារឡានរបស់នគរបាល។ ស្ត្រីមានគត៌ម្នាក់ទទួលរងការរលូតកូនផងដែរ ក្រោយពីត្រូវបាននគរបាលចាប់អូសរូបគាត់។

---

[៦៦] របាយការណ៍ឃ្លាំមើលសិទ្ធិមនុស្សអង្គការលីកាដូ ដែលមិនត្រូវបានបោះពុម្ពផ្សាយ: PP035OFEA11។

[៦៧] របាយការណ៍ឃ្លាំមើលសិទ្ធិមនុស្សអង្គការលីកាដូ ដែលមិនត្រូវបានបោះពុម្ពផ្សាយ: PP049OFEA11។ សូមមើលផងដែរ: ខ្សែវីដេអូអង្គការលីកាដូ "អ្នកភូមិត្រូវបានចាប់ខ្លួន និងវាយដំ នៅអំឡុងពេលតវ៉ាដោយសន្តិវិធី" ចេញផ្សាយនៅថ្ងៃទី២១ ខែមេសា ឆ្នាំ២០១១: http://www.licadho-cambodia.org/video.php?perm=23។

| | |
|---|---|
| **ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១១**<br>**ករណីទី៧១** | **អ្នកភូមិត្រូវបានកងរាជអាវុធហត្ថធ្វើឲ្យរបួស នៅអំឡុងពេលរាំងខ្ទប់ផ្លូវ** [៦៨]<br>***ឃុំស្រែឃុំ ស្រុកកែវសីមា ខេត្តមណ្ឌលគិរី***<br>▪ កងរាជអាវុធហត្ថបានប្រើកាំភ្លើងវាយទៅលើអ្នកភូមិចំនួន ៣នាក់ នៅអំឡុងពេលតវ៉ាចំនួន ២ថ្ងៃជុំវិញជម្លោះដីធ្លីរវាងអ្នកភូមិ និងក្រុមហ៊ុន ម៉ុង រិទ្ធី។ ក្រុមហ៊ុននេះ បានទទួលដីសម្បទានសេដ្ឋកិច្ចចំនួន ៥,០០០ ហិកតា ក្នុងតំបន់នោះ ដែលអ្នកភូមិអះអាងថា ជាដីរបស់ពួកគេ។<br>▪ ការតវ៉ានេះ គេបានឃើញអ្នកភូមិចំនួន ២,០០០ នាក់ រាំងខ្ទប់ផ្លូវថ្នល់រហូតដល់មន្ត្រីកងរាជអាវុធហត្ថប្រដាប់អាវុធចំនួន ១០០នាក់ បានបំបែកអ្នកតវ៉ាទាំងនោះ នៅពេលយប់ ដោយមានបាញ់កាំភ្លើងទៅលើអាកាស។ អ្នកភូមិចំនួន ៣នាក់ត្រូវបានមន្ត្រីកងរាជអាវុធហត្ថវាយនឹងស្នាយកាំភ្លើង។ |
| **ថ្ងៃទី៨ ខែឧសភា ឆ្នាំ២០១១**<br>**ករណីទី៧២** | **ការបង្ក្រាបហិង្សាពីនគរបាល នៅពេលកម្មកររោងចក្រធ្វើកូដកម្ម** [៦៩]<br>***សង្កាត់ទឹកថ្លា ខ័ណ្ឌសែនសុខ រាជធានីភ្នំពេញ***<br>▪ សមាជិកសហជីពរោងចក្រកាត់ដេរមិថុនា ចំនួន ១,០០០នាក់ ត្រូវបានមន្ត្រីនគរបាល និងកងរាជអាវុធហត្ថប្រដាប់អាវុធចំនួនជាង ១០០នាក់ ធ្វើការបំបែកយ៉ាងហិង្សា នៅអំឡុងពេលធ្វើកូដកម្ម ជុំវិញការមិនបើកប្រាក់ឈ្នួល។<br>▪ កម្មករចំនួន ១០នាក់ត្រូវទទួលរងរបួសជាទម្ងន់ ហើយមេដឹកនាំសហជីព FTU ឈ្មោះ ផេង ជូ ត្រូវបានឃុំខ្លួនចំនួនមួយយប់នៅស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ។ |
| **ថ្ងៃទី៩ ខែឧសភា ឆ្នាំ២០១១**<br>**ករណីទី៧៣** | **អ្នកសារព័ត៌មាន ដែលរាយការណ៍អំពីការជំរិតទារប្រាក់ ដោយនគរបាល ត្រូវទទួលរងការគំរាមកំហែង** [៧០]<br>***ឃុំផុនរ៉ាំងស្រុក ស្រុកបរិបូរ ខេត្តកំពង់ឆ្នាំង***<br>▪ នូ ចាន់ អ្នកសារព័ត៌មានខ្មែរស្ថាបនាសោភ័ណ្ឌ ត្រូវទទួលរងការគំរាមកំហែងចាប់ខ្លួនពីមេប៉ុស្ដិ៍នគរបាលរដ្ឋបាលឃុំឈ្មោះ ប៉ាង ពុំសែន បន្ទាប់ពីគាត់បានបោះពុម្ពផ្សាយនូវការចោទប្រកាន់ថា នគរបាលបានជំរិតទារប្រាក់ពីអ្នកភូមិ ដែលកំពុងនេសាទត្រីតាមមាត់ទន្លេ។ ប៉ាង ពុំសែន បានដាក់ពាក្យបណ្ដឹងពីបទបរិហារកេរ្ដិ៍ប្រឆាំងនឹង នូ ចាន់ ផងដែរ ដែលកាសែតនេះ បានអះអាងផងដែរថា នគរបាលកំពុងរកលុយ |

[៦៨] របាយការណ៍ឃ្លាំមើលសិទ្ធិមនុស្សអង្គការលីកាដូ ដែលមិនត្រូវបានបោះពុម្ពផ្សាយ: PP064LG11។

[៦៩] របាយការណ៍ឃ្លាំមើលសិទ្ធិមនុស្សអង្គការលីកាដូ ដែលមិនត្រូវបានបោះពុម្ពផ្សាយ: PP063OFE11។

[៧០] របាយការណ៍ឃ្លាំមើលសិទ្ធិមនុស្សអង្គការលីកាដូ ដែលមិនត្រូវបានបោះពុម្ពផ្សាយ: KN024THI11។

បានពីការលក់ដីធ្លីខុសច្បាប់។

**ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១១**
**ករណីទី៧៤**

**សកម្មជនត្រូវបានចាប់ខ្លួន បន្ទាប់ពីបានចូលរួមសន្និសីទអាស៊ាន** [៧១]
***ឃុំជប់វារី ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ***

- សកម្មជនខ្មែរកម្ពុជាក្រោមនៅក្រុងបាងកក ត្រូវបានចាប់ខ្លួន ឃុំខ្លួន និងចោទប្រកាន់ពីបទចែកចាយខិត្តប័ណ្ណប្រឆាំងរាជរដ្ឋាភិបាល ក្រោយពីបានមកកាន់ប្រទេសកម្ពុជា ដើម្បីសុំបន្តទិដ្ឋាការថៃរបស់គាត់។ កូនប្រុសរបស់គាត់ម្នាក់ក៏ត្រូវបានចាប់ខ្លួនផងដែរ។
- លាង សុខា ភេទប្រុស ជាតំណាងឧត្តមក្រុមប្រឹក្សាជាតិកម្ពុជាក្រោម (SNCKK) និងកូនប្រុសរបស់គាត់ឈ្មោះ លាង រតនៈ ត្រូវបានចាប់ខ្លួនភ្លាមៗបន្ទាប់ពី លាង សុខា បានចូលរួមសន្និសីទសង្គមស៊ីវិលអាស៊ាន នៅទីក្រុង Jakarta នៅដើមខែឧសភា ឆ្នាំ ២០១១។ ការចាប់ខ្លួននេះ ទំនងជាធ្វើឡើងដើម្បីសងសឹកដោយផ្ទាល់ទៅនឹងការចូលរួមរបស់គាត់ក្នុងសន្និសីទនោះ ដែលជាទីដែលគាត់បានចែកចាយព័ត៌មាន ស្ដីពីការរំលោភបំពានទៅលើខ្មែរក្រោមនៅក្នុងប្រទេសវៀតណាម។
- អ្នកទាំងពីរនេះ ត្រូវបានឃុំខ្លួនចំនួន ១យប់ ក្នុងអង្គភាពឃាត់ខ្លួននគរបាលខេត្ត មុនពេលផ្ទេរទៅកាន់នាយកដ្ឋានសន្តិសុខក្រសួងមហាផ្ទៃ។ នៅពេលកំពុងចាប់ខ្លួន នគរបាល បានរឹបអូសយកលិខិតឆ្លងដែនរបស់ពួកគាត់ អត្តសញ្ញាណប័ណ្ណកម្ពុជារបស់ លាង សុខា លុយចំនួន ៤០០ដុល្លារ កុំព្យូទ័រមួយគ្រឿង និងទូរស័ព្ទដៃរបស់ពួកគេ។ កូនរបស់គាត់ត្រូវបានដោះលែងនៅថ្ងៃបន្ទាប់ ប៉ុន្តែ លាង សុខា ជាឪពុកត្រូវបានផ្ទេរទៅកាន់ពន្ធនាគារខេត្តតាកែវ ជាទីដែលគាត់ត្រូវបានឃុំខ្លួនបណ្ដោះអាសន្នជាច្រើនសប្ដាហ៍មុនពេលដោះលែង។

**ថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១១**
**ករណីទី៧៥**

*[សូមមើលករណីទី៦៤ ៦៥ ៨៧*

**លោកសង្ឃកាន់ព្រះពុទ្ធសាសនា ត្រូវបានគេបង្ខំឲ្យភៀសព្រះកាយចេញពីការតវ៉ា បន្ទាប់ពីទទួលរងការគំរាមកំហែងចាប់ខ្លួន** [៧២]
***ព្រៃឡង់***

- ព្រះតេជគុណ លួនសូវ៉ាត ត្រូវបានគេបង្ខំឲ្យភៀសព្រះកាយចេញពីការតវ៉ាប្រឆាំងនឹងការរឹបអូសយកដីធ្លី និងការកាប់បំផ្លាញព្រៃឈើនៅសហគមន៍ព្រៃឡង់បន្ទាប់ពីអាជ្ញាធរមូលដ្ឋានគំរាមចាប់ព្រះកាយព្រះអង្គ។

---

[៧១] របាយការណ៍ឃ្លាំមើលសិទ្ធិមនុស្សអង្គការលីកាដូ ដែលមិនត្រូវបានបោះពុម្ពផ្សាយ: PP065IAD11។

[៧២] តារាងអង្គហេតុមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា "ករណីសិក្សា: លួន សូវ៉ាត" ខែកក្កដា ឆ្នាំ២០១១: http://www.cchrcambodia.org/index_old.php?url=media/media.php &p=factsheet_detail.php&fsid=5&id=5។

*៨៩ ៩៧ ផងដែរ]*

*[សូមមើលករណី ទី២០ និង១១៤ ទាក់ទងនឹងព្រះអង្គ លួន សូវ៉ាត]*

- នៅថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១១ ព្រះអង្គ នួន ង៉ែត ជាសម្តេចសង្ឃព្រះពុទ្ធសាសនា នៅរាជធានីភ្នំពេញ បានចេញលិខិតជាផ្លូវការមួយ ដោយចោទប្រកាន់ព្រះតេជគុណ លួន សូវ៉ាត ពីបទបង្កឲ្យអ្នកភូមិ "មានគំនិតអាក្រក់" ពីព្រះពុទ្ធសាសនា។
- លិខិតនោះ បានហាមប្រាមព្រះតេជគុណ លួន សូវ៉ាត មិនឲ្យនិមន្តចេញពីកុដិរបស់ព្រះអង្គនៅវត្តឧណ្ណាលោម ហើយនឹងហាមព្រះអង្គមិនឲ្យនិមន្តចូលទៅក្នុងវត្តផ្សេងៗទៀតទាំងអស់នៅរាជធានីភ្នំពេញ។

**ថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១១**
**ករណីទី៧៦**

*[សូមមើលករណី ទី៥៩ និង៦២ ផងដែរ]*

### *សកម្មជនសហគមន៍ត្រូវបានវាយដំយ៉ាងឃោរឃៅពីទាហាន* [៧៣]
### *ឃុំតាំងសំរោង ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ*

- ស៊ិម ស៊ុន ជាតំណាងអ្នកភូមិត្រូវបានគេវាយនឹងកាំភ្លើង និងទទួលការគំរាមកំហែងនឹងសម្លាប់ ពាក់ព័ន្ធនឹងជម្លោះដីធ្លីជាមួយអាជ្ញាធរ។
- ការរំលោភបំពានលើរាងកាយ និងការគំរាមកំហែងនេះ ត្រូវបានប្រព្រឹត្តជាហូរហែពីសំណាក់ជនពាលស៊ីឈ្នួលមួយក្រុម ដែលដឹកនាំដោយ ទូច សុភ័ក្រ្ត ជាយោធា ACO និង ពីវ ឡុន ជាសមាជិកក្រុមប្រឹក្សាឃុំ។
- នៅពេល ស៊ិម ស៊ុន កំពុងត្រូវបានគេវាយ អាជ្ញាធរបានដុតបំផ្លាញ ផ្ទះចំនួន ១០ខ្នង និងទ្រព្យសម្បត្តិផ្សេងៗទៀតរបស់ប្រជាពលរដ្ឋចំនួន ១០០គ្រួសារ។

**ថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០១១**
**ករណីទី៧៧**

### ការប៉ុនប៉ងសម្លាប់សកម្មជនអភិរក្សធនធានជលផល [៧៤]
### *ឃុំអណ្តូងទឹក ស្រុកបុទុមសាគរ ខេត្តកោះកុង*

- ជនមិនស្គាល់អត្តសញ្ញាណមួយរូប បានបាញ់កាំភ្លើងជាច្រើនគ្រាប់ទៅលើ នេត សួង ជាសកម្មជនអភិរក្សធនធានជលផល នៅពេលគាត់កំពុងស្តាប់វិទ្យុក្នុងផ្ទះរបស់គាត់។
- នេត សួង បានធ្វើសកម្មភាពយ៉ាងសកម្ម ក្នុងការផ្សព្វផ្សាយព័ត៌មានស្តីពីការអភិរក្សជលផលនៅក្នុងសហគមន៍របស់គាត់។

---

[៧៣] របាយការណ៍ឃ្លាំមើលសិទ្ធិមនុស្សអង្គការលីកាដូ ដែលមិនត្រូវបានបោះពុម្ពផ្សាយ: KS021DAP11។

[៧៤] របាយការណ៍ឃ្លាំមើលសិទ្ធិមនុស្សអង្គការលីកាដូ ដែលមិនត្រូវបានបោះពុម្ពផ្សាយ: PP103IAD11។

| | |
|---|---|
| **ថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០១១**<br>**ករណីទី៧៨**<br><br>***[សូមមើលករណីទី៣៦ ៥១ ៦៧ ៦៩ ៧០ ៩១ ៩២ ៩៩ ១១៤ ១១៥ និង១២២ ផងដែរ]*** | **សកម្មជនសហគមន៍បឹងកក់ត្រូវបានចាប់ខ្លួន និងឃុំខ្លួនតាមទំនើងចិត្តចំនួន ១យប់** [៧៥]<br>***រាជធានីភ្នំពេញ***<br><br>▪ អ្នកស្រី ទេព វន្នី និងអ្នកស្រី ណុន សុខេង ជាតំណាងសហគមន៍ត្រូវបានផ្ទាំសន្តិសុខខណ្ឌដូនពេញធ្វើការចាប់ខ្លួន និងឃុំខ្លួនចំនួន១យប់ នៅស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ តាមបទបញ្ជារបស់លោក ទូច ណារ័ត្ន ជាស្នងការនគរបាលរាជធានី។<br>▪ សកម្មជនទាំងពីរ គឺជាមនុស្សក្នុងចំនោមពលរដ្ឋអ្នករស់នៅសហគមន៍បឹងកក់ ដែលបានមកប្រមូលផ្តុំគ្នានៅជិតស្ថានទូតបារាំង ដើម្បីធ្វើការតវ៉ានឹងការរឹបអូសយកដីធ្លី។ |
| **ថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១១**<br>**ករណីទី៧៩**<br><br>***[សូមមើលករណីទី១៨ និង៣៨ ផងដែរ]*** | **សាលាឧទ្ធរណ៍សម្រេចតម្កល់ការផ្តន្ទាទោស ដោយគ្មានមូលដ្ឋានទៅលើបុគ្គលិកអង្គការលីកាដូ** [៧៦]<br>***រាជធានីភ្នំពេញ***<br><br>▪ សាលាឧទ្ធរណ៍បានសម្រេចដម្កល់ការផ្តន្ទាទោសដោយគ្មានមូលដ្ឋាន និងការកាត់ទោសឲ្យជាប់ពន្ធនាគារចំនួន ២ឆ្នាំ ទៅលើលោក លាង សុខជឿន ជាបុគ្គលិកអង្គការលីកាដូ ពីបទជាប់ពាក់ព័ន្ធក្នុងការចែកចាយខិត្តប័ណ្ណប្រឆាំងនឹងរដ្ឋាភិបាល ក្នុងឆ្នាំ២០១០។<br>▪ នៅក្នុងដំណើរការនីតិវិធីមិនធម្មតាមួយ តុលាការបានធ្វើការកែប្រែការផ្តន្ទាទោសលោក លាង សុខជឿន ពីបទផ្សាយព័ត៌មានមិនពិតឲ្យទៅជាបទញុះញង់តាមក្រមព្រហ្មទណ្ឌថ្មី ដែលមិនទាន់ចូលជាធរមាននៅឡើយ នៅពេលដែលមានការចោទប្រកាន់បទល្មើសនេះ។ |
| **ថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១១**<br>**ករណីទី៨០** | **ការចាប់ខ្លួន និងការឃុំខ្លួនបុគ្គលិកអង្គការមិនមែនរដ្ឋាភិបាលខុសច្បាប់** [៧៧]<br>***សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ***<br><br>▪ ញ៉ូវ ដែន និងឡោះ ស្រេន ជាបុគ្គលិកសមាគមន៍ធាងត្នោត ត្រូវបានអង្គរក្សសម្តេចជា ស៊ីម ជាប្រធានព្រឹទ្ធសភា និងជាមន្ត្រីជាន់ខ្ពស់គណបក្សកាន់អំណាចធ្វើការចាប់ខ្លួន។ ពួកគេត្រូវបានឃុំខ្លួនជាច្រើនម៉ោង នៅឯប៉ុស្តិ៍នគរបាលរដ្ឋបាលសង្កាត់ |

[៧៥] របាយការណ៍ឃ្លាំមើលសិទ្ធិមនុស្សអង្គការលីកាដូ ដែលមិនត្រូវបានបោះពុម្ពផ្សាយ: PP103IAD11។

[៧៦] សេចក្តីប្រកាសព័ត៌មានអង្គការលីកាដូ "សាលាឧទ្ធរណ៍សម្រេចដំកល់ការផ្តន្ទាទោស ដោយគ្មានមូលដ្ឋានទៅលើបុគ្គលិកអង្គការលីកាដូ" ចេញផ្សាយនៅថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១១: http://www.licadho-cambodia.org/pressrelease.php?perm=254។

[៧៧] របាយការណ៍ឃ្លាំមើលសិទ្ធិមនុស្សអង្គការលីកាដូ ដែលមិនត្រូវបានបោះពុម្ពផ្សាយ: PP101THI11។

ទន្លេបាសាក់។

- បុគ្គលិកអង្គការមិនមែនរដ្ឋាភិបាល បានថតផ្ទះជាច្រើនខ្នងនៅជិតភូមិគ្រឹះ សម្តេច ជា ស៊ីម ដែលបានទទួលសេចក្តីជូនដំណឹងអំពីការបណ្តេញចេញ។

**ថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១១**
**ករណីទី៨១**

**ប្រធានសហជីពត្រូវបានចាប់ខ្លួន នៅពេលចែកចាយខិត្តប័ណ្ណព័ត៌មាន** [៧៨]
***សង្កាត់អូរឡាំពិកខ័ណ្ឌចំការមន រាជធានីភ្នំពេញ***

- ប្រធានសហជីពចំនួន ៤ នាក់ ដែលមាន លោក អឿ ទី ជាប្រធានសហព័ន្ធនៃកិច្ចសហប្រតិបត្តិការសម្រាប់កម្ពុជា លោក សាត ឈៀងហួ ជាប្រធានសហជីពជាតិកម្ពុជាសម្រាប់ការពារកម្មករ លោក ស្រៀង ណារិទ្ធ ជាប្រធានសហជីពសហព័ន្ធសេដ្ឋកិច្ចកម្មករកម្ពុជា និងលោក អ៊ុន ដារ៉ា ជាប្រធានសហជីពសហព័ន្ធស្មារតីកម្មករឯករាជ្យ ត្រូវបានចាប់ខ្លួនដោយមន្ត្រីនគរបាលរាជធានីភ្នំពេញ។
- នៅពេលកំពុងចាប់ខ្លួន សកម្មជនទាំងនេះ កំពុងចែកចាយខិត្តប័ណ្ណ សហជីពស្តីពីតម្លៃទ្រទ្រង់ជីវភាពរស់នៅខ្ពស់ ហើយត្រូវការដំឡើងប្រាក់ឈ្នួលខ្ពស់ជាងនេះ។

**ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១១**
**ករណីទី៨២**

**នគរបាលធ្វើការបង្ក្រាបទៅលើការតវ៉ាដីធ្លីដោយអហិង្សា** [៧៩]
***ឃុំក្រសាំង ស្រុករមាសហែក ខេត្តស្វាយរៀង***

- អ្នកភូមិចំនួន ២០០នាក់ តំណាងឲ្យប្រជាពលរដ្ឋចំនួន ៥៤៣គ្រួសារ ដែលទទួលផលប៉ះពាល់ពីដីសម្បទាន ដែលផ្តល់ទៅឲ្យក្រុមហ៊ុនមិត្តភាព កំពុងធ្វើការតវ៉ាប្រឆាំង នឹងការឈូសឆាយលើដីធ្លីរបស់ពួកគេ នៅពេលកងកម្លាំងប្រដាប់អាវុធចម្រុះមួយក្រុមដែលដឹកនាំដោយ លោក ឡឹក សារ៉ាន់ ជាអភិបាលរងស្រុក បានបំបែកពួក គេដោយបង្ខំ។
- ការផ្តល់សម្បទាននេះ ជាន់គ្នានឹងដីព្រៃឈើសហគមន៍ ដែលត្រូវបានទទួលស្គាល់ជាផ្លូវការ។

---

[៧៨] របាយការណ៍ឃ្លាំមើលសិទ្ធិមនុស្សអង្គការលីកាដូ ដែលមិនត្រូវបានបោះពុម្ពផ្សាយ: PP102OFEA11។

[៧៩] របាយការណ៍ឃ្លាំមើលសិទ្ធិមនុស្សអង្គការលីកាដូ ដែលមិនត្រូវបានបោះពុម្ពផ្សាយ: SR031LG11។

**ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១១**

**ករណីទី៨៣**

*[សូមមើលករណីទី៣១ និង៩៤ ផងដែរ]*

**គ្រាប់កាំភ្លើងត្រូវបានគេបាញ់សំដៅផ្ទះសកម្មជនសហគមន៍** [៨០]

***ឃុំតែ្បង ស្រុកបន្ទាយស្រី ខេត្តសៀមរាប***

- គុន អេង ជាសកម្មជនសហគមន៍ គឺជាជនរងគ្រោះពីការប៉ុនប៉ងធ្វើឃាត នៅពេលខ្មាន់កាំភ្លើងម្នាក់មិនស្គាល់អត្តសញ្ញាណ បានបាញ់សំដៅផ្ទះរបស់គាត់។ គុន អេង កំពុងតែនៅផ្ទះជាមួយប្រពន្ធគាត់ និងកូនស្រីគាត់អាយុ ៨ខែ នៅពេលកំពុងវាយប្រហារ។ គ្រួសារនេះ បានភៀសខ្លួនចេញពីផ្ទះភ្លាមៗ ដោយភ័យខ្លាចនឹងសុវត្ថិភាពរបស់ពួកគេ។
- គុន អេង គឺជាសកម្មជនសិទ្ធិដីធ្លីមួយរូបប្រចាំសហគមន៍ ដែលបានធ្វើការតស៊ូមតិសម្រាប់ការពារសិទ្ធិរបស់អ្នកភូមិរបស់គាត់ ដែលពាក់ព័ន្ធក្នុងជម្លោះដីធ្លីជាមួយរដ្ឋបាលព្រៃឈើ។
- មិនយូរប៉ុន្មាន មុនប៉ុនប៉ងធ្វើឃាតទៅលើរូបគាត់ គុន អេង បានសម្តែងមតិជាសាធារណៈ អំពីផលប៉ះពាល់ជាអវិជ្ជមានពីគម្រោងដាំកូនឈើឡើងវិញ ដោយរដ្ឋបាលព្រៃឈើ ដែលធ្វើឲ្យប៉ះពាល់ប្រជាពលរដ្ឋចំនួន ១០៥គ្រួសារ។
- រហូតមកទល់ពេលនេះ គ្មានជនសង្ស័យណាម្នាក់ត្រូវបានចាប់ខ្លួនក្នុងឧប្បត្តិហេតុបាញ់នេះនៅឡើយទេ។

**ថ្ងៃទី២ ខែសីហា ឆ្នាំ២០១១**

**ករណីទី៨៤**

**អង្គការមិនមែនរដ្ឋាភិបាលខាងសិទ្ធិដីធ្លី ត្រូវបានព្យួរសកម្មភាព ដោយក្រសួងមហាផ្ទៃ** [៨១]

***រាជធានីភ្នំពេញ***

- សមាគមធាងត្នោត ជាអង្គការមិនមែនរដ្ឋាភិបាលមួយ (STT) ត្រូវបានបិទទ្វារបណ្តោះអាសន្ន ដោយឯកឧត្តម នុត សាអាន ជារដ្ឋលេខាធិការក្រសួងមហាផ្ទៃតាមបទបញ្ជារបស់ឯកឧត្តមរដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ គាត ឈុន។ គ្មានហេតុផលស្របច្បាប់ ត្រូវបានពន្យល់ពីអាជ្ញាធរចំពោះការបិទទ្វារបណ្តោះអាសន្ននេះឡើយ។
- មិនយូរប៉ុន្មានមុនពេលបិទទ្វារដោយបង្ខំ សមាគមធាងត្នោតបានបោះពុម្ពផ្សាយរបាយការណ៍មួយ ដែលបានប្រើទិន្នន័យអាចប៉ាន់បរិមាណជាសត្យានុម័តបាន ដើម្បីបង្ហាញវិបត្តិជាក់ស្តែង ក្នុងកញ្ចប់ទូទាត់សំណងធានារ៉ាប់រងពីធនាគារអភិវឌ្ឍន៍អាស៊ី

---

[៨០] មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា "គ្រាប់កាំភ្លើងត្រូវបានគេបាញ់សំដៅផ្ទះសកម្មជនសហគមន៍" IFEX ចេញផ្សាយថ្ងៃទី៣ ខែសីហា ឆ្នាំ២០១១: http://www.ifex.org/cambodia/2011/08/03/eng_attack/។

[៨១] របាយការណ៍ឃ្លាំមើលសិទ្ធិមនុស្សអង្គការលីកាដូ ដែលមិនត្រូវបានបោះពុម្ពផ្សាយ: PP107SC11។ សូមមើលផងដែរ: សេចក្តីប្រកាសព័ត៌មានអង្គការលីកាដូ "យើងទាំងអស់គ្នាជាសមាគមន៍ធាងត្នោត: សង្គមស៊ីវិល និងក្រុមវិស័យឯកជន ថ្កោលទោសចំពោះការព្យួរសកម្មភាពអង្គការមិនមែនរដ្ឋាភិបាលក្នុងតំបន់តាមទំនើងចិត្តពីរដ្ឋាភិបាល" ចេញផ្សាយថ្ងៃទី២១ ខែសីហា ឆ្នាំ២០១១: http://www.licadho-cambodia .org/pressrelease.php?perm=256។

ដែលត្រូវផ្តល់ទៅឲ្យគ្រួសារប្រជាពលរដ្ឋ ដែលត្រូវបណ្តេញចេញដោយសារគម្រោងស្តារផ្លូវរថភ្លើងឡើងវិញនៅរាជធានីភ្នំពេញ។

- ចំពោះសេចក្តីពិស្តារថែមទៀត សូមមើលករណីសិក្សាក្នុងតួសេចក្តីនៃរបាយការណ៍នេះ។

**ថ្ងៃទី៣ ខែសីហា ឆ្នាំ២០១១**
**ករណីទី៨៥**

**រដ្ឋមន្ត្រីក្រសួងព័ត៌មានបិទទ្វារកាសែតចំនួន ២** [៨២]
***រាជធានីភ្នំពេញ***

- ក្រសួងព័ត៌មានកម្ពុជាបានលុបចោលអាជ្ញាប័ណ្ណកាសែតចំនួន ២គឺ *កាសែតទឹក និងភ្លើង (The Water and Fire News)* *ព្រមទាំងកាសែតពិភពលោក (The World News)* ហើយបញ្ជាឲ្យកាសែតទាំង ២ នេះ ឈប់បោះពុម្ពផ្សាយ។ សេចក្តីជូនដំណឹង ដែលគូសបញ្ជាក់ពីសេចក្តីសម្រេចនេះ ត្រូវបានចុះហត្ថលេខា ដោយឯកឧត្តម ខៀវ កាញារិទ្ធ ជារដ្ឋមន្ត្រីក្រសួងព័ត៌មាន។
- កាសែតទាំង ២ នេះ មានភាពឯករាជ្យខាងនយោបាយ ប៉ុន្តែមានឆន្ទៈសរសេរអត្ថបទកាសែតរិះគន់គណបក្សប្រជាជន ដែលជាគណបក្សកាន់អំណាច។

**ថ្ងៃទី៤ ខែសីហា ឆ្នាំ២០១១**
**ករណីទី៨៦**

**សកម្មជនចំនួន ៥នាក់ ត្រូវបានកាត់ទោសពីបទចែកចាយខិត្តប័ណ្ណ** [៨៣]
***រាជធានីភ្នំពេញ***

- សាលាដំបូងរាជធានីភ្នំពេញបានផ្តន្ទាទោស លោក ផុន សំអាត សុខ ហៃម៉ារ៉ាក់ ដោម៉េងហុង អៀង សាម៉ន និងចិម បុល ពីបទញុះញង់ឲ្យប្រព្រឹត្តបទឧក្រិដ្ឋ ដោយចែកចាយខិត្តប័ណ្ណ ដែលរិះគន់ជីសម្បទាន និងរិះគន់រដ្ឋាភិបាលចំពោះចំណងទាក់ទងយ៉ាងជិតស្និទ្ធរបស់ខ្លួនជាមួយប្រទេសវៀតណាម។
- បុរសទាំង ៥នាក់ នេះត្រូវបានចាប់ខ្លួនក្នុងខែមករា និងខែកុម្ភៈ ហើយត្រូវបានឃុំខ្លួនបណ្តោះអាសន្នអស់រយៈពេល ៥-៦ ខែ ដែលជាការរំលោភបំពានយ៉ាងជាក់ស្តែងទៅលើច្បាប់ជាតិ ដែលហាមមិនឲ្យឃុំខ្លួនបណ្តោះអាសន្នចំពោះបទល្មើសមជ្ឈិមលើសពីពាក់កណ្តាលនៃទោសអប្បបរមាដែលច្បាប់បានកំណត់។ នៅក្នុងករណីញុះញង់ទោសជាប់ពន្ធនាគារអប្បបរមាន គឺមានរយៈពេលតែ ៦ខែ។

---

[៨២] ការប្រកាសព័ត៌មានរបស់អ្នកការពារសិទ្ធិមនុស្សនៃមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា "កាសែតបារចនាដែលកត់សម្គាល់ចំនួនផ្ទៃដីប្រទេសកម្ពុជា ត្រូវបានចាត់ទុកជាការជេរប្រមាថកាសែតចំនួន ២ ត្រូវបានបិទទ្វារ" ថ្ងៃទី៨ ខែសីហា ឆ្នាំ២០១១: http://www.cchrcam bodia.org/index_old.php? url=media/media.php&p=alert_detail.php&alid=3&id=5។

[៨៣] ការប្រកាសព័ត៌មានរបស់អ្នកការពារសិទ្ធិមនុស្សនៃមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា "បុរសចំនួន ៥ នាក់ត្រូវបានកាត់ទោសពីបទចែកចាយខិត្តប័ណ្ណប្រឆាំងរាជរដ្ឋាភិបាល" ថ្ងៃទី៨ ខែសីហា ឆ្នាំ២០១១: http://www.ifex.org/cambodia/2011/08/05/leaflets_conviction/។

- ផុន សំអាត និងអៀង សាម៉ន ត្រូវទទួលទោសជាប់ពន្ធនាគារចំនួន ២ ឆ្នាំ ចំពោះបុរស ៣ នាក់ផ្សេងទៀតត្រូវទទួលទោសជាប់ពន្ធនាគារចំនួន ១៨ខែ។ អ្នកទាំង ៥ នាក់ ត្រូវបានពិន័យជាប្រាក់ចំនួន ២លានរៀល (ប្រហែល ៥០០ ដុល្លារអាមេរិក)។

**ថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១១**
**ករណីទី៨៧**
*[សូមមើលករណីទី៦៤ ៦៥ ៧៥ ៨៩ និង៩៧ ផងដែរ]*

**សកម្មជនព្រៃឈើត្រូវបានឃុំខ្លួន ដើម្បីធ្វើការអប់រំ បន្ទាប់ពីបានចែកចាយខិត្តប័ណ្ណ**[៨៤]
***ខ័ណ្ឌចំការមន រាជធានីភ្នំពេញ***

- សកម្មជនព្រៃឈើប្រមាណជា ៣០០ នាក់មកពីខេត្តចំនួន ៤ (កំពង់ធំ ព្រះវិហារ ស្ទឹងត្រែង និងក្រចេះ) ត្រូវបានឃុំខ្លួនរយៈពេលខ្លី ដោយនគរបាល និងអាជ្ញាធររដ្ឋ បាលសម្រាប់ធ្វើការអប់រំ។
- ក្រុមសកម្មជន បានធ្វើការចែកចាយខិត្តប័ណ្ណអប់រំ ស្តីពីព្រៃឡង់ និងសារៈសំខាន់ជីវៈចំរុះនៃព្រៃនៅតាមទីកន្លែងប្រសព្វសំខាន់ៗក្នុងរាជធានីភ្នំពេញ។

**ថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១១**
**ករណីទី៨៨**

**ការចាប់ខ្លួន និងការឃុំខ្លួនតំណាងសហគមន៍ ២ រូបដោយខុសច្បាប់**[៨៥]
***ភូមិមណ្ឌល ២ សង្កាត់ ១ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ***

- ផាន់ ញី និងខៀង ចាន់តន ជាតំណាងសហគមន៍ ត្រូវបានចាប់ខ្លួនខុសច្បាប់ ដោយមន្រ្តីកងរាជអាវុធហត្ថខេត្ត ដោយគ្មានដីកា។ ក្រុមមន្រ្តីដែលមានគ្នា ៤០ នាក់ ត្រូវបានដឹកនាំដោយ លោក ហេង និន ជាមេបញ្ជាការកងរាជអាវុធហត្ថខេត្ត។
- តំណាងសហគមន៍ទាំង ២ នាក់ ត្រូវបានឃុំខ្លួនពីបទប្រើអំពើហិង្សា ដើម្បីកាន់កាប់ទ្រព្យសម្បត្តិទាក់ទងនឹងដីកំពុងមានជម្លោះរវាងប្រជាពលរដ្ឋចំនួន ១៨៧ គ្រួសារ និងឧកញ៉ា ជា សឿន។ ការចោទប្រកាន់នេះ ត្រូវបានធ្វើឡើងដោយ រៀម ចន្ទម្នី ជាព្រះរាជអាជ្ញា។

**ថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១១**
**ករណីទី៨៩**

**អាជ្ញាធរបានរាំងវគ្គបណ្តុះបណ្តាលសិទ្ធិដីធ្លី**[៨៦]
***ឃុំអណ្តូងទឹក ស្រុកបុទុមសាគរ ខេត្តកោះកុង***

- លោក ឈុត វុទ្ធី ជាប្រធាន NRPG និងឈិម សាវុទ្ធ ជាបុគ្គលិកមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ត្រូវបានមន្រ្តីកងរាជអាវុធហត្ថស្រុកចំនួន ១០ នាក់ នៅខេត្តកំពង់ធំ គំរាមចាប់ខ្លួន និងហាមមិនឲ្យរៀបចំវគ្គបណ្តុះបណ្តាល ស្តីពីច្បាប់ព្រៃឈើ និងច្បាប់

---

[៨៤] របាយការណ៍ឃ្លាំមើលសិទ្ធិមនុស្សអង្គការលីកាដូ ដែលមិនត្រូវបានបោះពុម្ពផ្សាយ: PP108OFE11។ សូមមើលផងដែរ: សេចក្តីប្រកាសព័ត៌មានអង្គការលីកាដូ "អាជ្ញាធរឃុំខ្លួនសកម្មជនព្រៃឈើនៅរាជធានីភ្នំពេញ" ថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១១:http://www.licadho-cambodia.org/pressrelease.php?perm=255

[៨៥] របាយការណ៍ឃ្លាំមើលសិទ្ធិមនុស្សអង្គការលីកាដូ ដែលមិនត្រូវបានបោះពុម្ពផ្សាយ: SV030IAD11។

[៨៦] របាយការណ៍ឃ្លាំមើលសិទ្ធិមនុស្សអង្គការលីកាដូ ដែលមិនត្រូវបានបោះពុម្ពផ្សាយ: KT061OFEA11។

*[សូមមើលករណីទី៦៤ ៦៥ ៧៥ ៨៧ និង៩៧ ផងដែរ]*

ភូមិបាល។

- មន្ត្រីទាំងនេះ ត្រូវបានដឹកនាំដោយ អ៊ុង ម៉ូលី ជាអធិការនគរបាលស្រុកសណ្ដាន់ ទាវ ហុក ជាអភិបាលរងស្រុក និងឈិម ខុន ជាប្រធានឃុំមានរិទ្ធ។

**ថ្ងៃទី៨ ខែកញ្ញា ឆ្នាំ២០១១**

**ករណីទី៩០**

*[សូមមើលករណីទី១២ ផងដែរ]*

**តំណាងសហគមន៍ត្រូវបានគេបង្ខំឲ្យរើផ្ទះចេញ**[៨៧]

***ភូមិជ័យសេនា ឃុំតាកែន ស្រុកឈូក ខេត្តកំពត***

- អ្នកភូមិចំនួន ៤ នាក់ (ពែក ចន អ៊ុក ម៉ោក ជ័យ ស៊ិន និងកូក រិន) ជាតំណាងឲ្យប្រជាពលរដ្ឋចំនួន ៧០ គ្រួសារ ដែលពាក់ព័ន្ធក្នុងជម្លោះដីធ្លី ត្រូវបានគេគម្រាម និងបង្ខំឲ្យរុះរើផ្ទះសម្បែងក្នុងភូមិ នៅអំឡុងការចរចារជុំវិញជម្លោះដីធ្លីនេះ។ ផ្ទះសម្បែងទាំងនេះ ស្ថិតនៅលើដីដែលជាន់លើដីសម្បទានសេដ្ឋកិច្ច ដែលត្រូវផ្ដល់ទៅឲ្យក្រុមហ៊ុន Camtree Corporation។

**ថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១១**

**ករណីទី៩១**

*[សូមមើលករណីទី៣៦ ៥១ ៦៧ ៦៩ ៧០ ៧៨ ៩២ ៩៩ ១១៤ ១១៥ និង ១២២ ផងដែរ]*

***នគរបាលបានវាយសកម្មជនយ៉ាងឃោរឃៅ នៅអំឡុងពេលបណ្ដេញចេញដោយបង្ខំ***[៨៨]

***សហគមន៍បឹងកក់ រាជធានីភ្នំពេញ***

- លោក សួង សុភ័ណ្ឌ ជាសកម្មជនដីធ្លី ត្រូវបាននគរបាលអន្តរាគមន៍មួយក្រុម វាយដំយ៉ាងឃោរឃៅ ហើយបានទុកគាត់ចោលឲ្យហូរឈាម និងសន្លប់បាត់ស្មារតី បន្ទាប់ពីពួកគេបានទាត់ធាក់ និងវាយដំគាត់នឹងដុំឥដ្ឋព្រមទាំងដំបង។ នេះ ជាលើកទី២ ហើយក្នុងរយៈពេលមិនដល់ ១ ឆ្នាំផង ដែលលោកត្រូវបាននគរបាលវាយយ៉ាងឃោរឃៅនៅអំឡុងពេលការតវ៉ាមួយ។ នគរបាលបានបន្តវាយ នៅអំឡុងពេលទាំង ២ លើកនេះ បន្ទាប់ពីគាត់បានសន្លប់បាត់ស្មារតីទៅហើយ ឬមិនអាចការពារខ្លួនបាន។
- ការវាយប្រហារនេះ បានកើតឡើង ខណៈពេលនគរបាលអន្តរាគមន៍ និងឆ្មាំសន្តិសុខខណ្ឌដូនពេញ កំពុងការពារគ្រឿងចក្រចំនួន ២ គ្រឿង ដែលបានបញ្ជូនចេញទៅសហគមន៍បឹងកក់ ដើម្បីកំទេចផ្ទះសម្បែង ដោយមិនបានដឹងខ្លួនជាមុន។

---

[៨៧] របាយការណ៍ឃ្លាំមើលសិទ្ធិមនុស្សអង្គការលីកាដូ ដែលមិនត្រូវបានបោះពុម្ពផ្សាយ: KP046THI11។

[៨៨] ខ្សែវីដេអូអង្គការលីកាដូ "សកម្មជនសហគមន៍បឹងកក់ ត្រូវបានមន្ត្រីនគរបាលមួយក្រុមវាយដំយ៉ាងឃោរឃៅ នៅពេលមានការបណ្ដេញចេញដោយបង្ខំ" ថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១១: http://www.licadho-cambodia.org/video.php?perm=25។ សូមមើលផងដែរ: សេចក្ដីប្រកាសព័ត៌មានអង្គការលីកាដូ "អាជ្ញាធររាជធានីភ្នំពេញត្រូវតែគោរពតាមបទបញ្ជារដ្ឋាភិបាលក្នុងការផ្ដល់ដីធ្លីទៅឲ្យគ្រួសារប្រជាពលរដ្ឋសហគមន៍បឹងកក់ ដែលនៅសេសសល់" ថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១១: http://www.licadho-cambodia.org/pressrelease. php?perm =259។

**ថ្ងៃទី៥ ខែតុលា ឆ្នាំ២០១១**
**ករណីទី៩២**

*[សូមមើលករណីទី៣៦ ៥១ ៦៧ ៦៩ ៧០ ៧៨ ៩១ ៩៩ ១១៤ ១១៥ និង ១២២ ផងដែរ]*

## ការបំភិតបំភ័យតាមផ្លូវតុលាការ ទៅលើសកម្មជនសហគមន៍[៨៩]
***រាជធានីភ្នំពេញ***

- តំណាងសហគមន៍បឹងកក់ចំនួន ៦ នាក់ (ទេព វន្នី ហេង មុំ ង៉ែត យុន ដួង គា គង់ ចន្ថា និងតុល ស្រីពៅ) ត្រូវបានសាលាដំបូងរាជធានីភ្នំពេញ កោះហៅមកសាកសួរពីបទជេរប្រមាថ និងបំភិតបំភ័យ លោក ឆាយ ធីរិទ្ធិ ជាប្រធានសង្កាត់ស្រះចក។ ដីកាមិនបានផ្តល់សេចក្តីពិស្តារអំពីពេលវេលា ទីកន្លែង និងអ្នករស់នៅបឹងកក់បានជេរប្រមាថ ឬបានបំភិតបំភ័យ លោក ឆាយ ធីរិទ្ធ បែបណានោះទេ។
- ដីកាតុលាការបានធ្វើឡើងភ្លាមៗ បន្ទាប់ពីប្រជាពលរដ្ឋសហគមន៍បឹងកក់ចំនួន ៨ គ្រួសារ បានដាក់ពាក្យបណ្តឹងទៅសាលាដំបូងរាជធានីភ្នំពេញ ដោយចោទប្រកាន់ថា ក្រុមហ៊ុន ស៊ូកាគូ (Shukaku Inc.) អភិបាលរងខណ្ឌដូនពេញ និងសមាជិកជាន់ខ្ពស់នៃនគរបាលប្រឆាំងភូដកម្មរាជធានីភ្នំពេញចំនួន ៣ នាក់ ត្រូវទទួលខុសត្រូវចំពោះការបំផ្លិចបំផ្លាញផ្ទះសម្បែងរបស់ពួកគេ ដោយខុសច្បាប់កាលពីថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ ២០១១។

**ថ្ងៃទី៦ ខែតុលា ឆ្នាំ២០១១**
**ករណីទី៩៣**

*[សូមមើលករណីទី៣១ និង៨៣ ផងដែរ]*

## *ការបំភិតបំភ័យតាមផ្លូវតុលាការ ទៅលើសកម្មជនសហគមន៍*[៩០]
***ភូមិស្ពុន ឃុំត្បែង ស្រុកបន្ទាយស្រី ខេត្តសៀមរាប***

- តំណាងសហគមន៍ចំនួន ៤ នាក់ (វេច វី ប៉ាក រិន នា គ្លិក និងអ៊ិន ស៊ិន) ត្រូវបានតុលាការកោះហៅទាក់ទងនឹងជម្លោះដីធ្លីចំនួនជាង ១៧៣ ហិកតា។ ជម្លោះនេះ បានធ្វើឲ្យប៉ះពាល់ប្រជាពលរដ្ឋចំនួន ២២២ គ្រួសារ នៅក្នុងភូមិចំនួន ២ ផ្សេងគ្នាក្នុងឃុំត្បែង។
- តំណាងសហគមន៍ទាំងនេះ ត្រូវបានចោទប្រកាន់ពីបទកាន់កាប់ទ្រព្យសម្បត្តិ ដោយខុសច្បាប់តាមមាត្រា ៣៤ នៃច្បាប់ភូមិបាល។

---

[៨៩] ការប្រកាសព័ត៌មានរបស់អ្នកការពារសិទ្ធិមនុស្សនៃមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា "សកម្មជនសហគមន៍ក្នុងខេត្តចំនួន ២ ទទួលរងនូវការរំខានយាយីពីតុលាការ" ថ្ងៃទី៥ ខែតុលា ឆ្នាំ២០១១: http://www.cchrcambodia.org/index_old.php?url=media/media. php&p=alert_detail.php&alid=7&id=5។

[៩០] ការប្រកាសព័ត៌មានរបស់អ្នកការពារសិទ្ធិមនុស្សនៃមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា "សកម្មជនសហគមន៍ក្នុងខេត្តចំនួន ២ ទទួលរងនូវការរំខានយាយីពីតុលាការ" ថ្ងៃទី៥ ខែតុលា ឆ្នាំ២០១១:, http://www.cchrcambodia.org/index_old.php?url=media/ media. php&p=alert_detail.php&alid=7&id=5 ។

**ថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១១**
**ករណីទី៩៤**

*[សូមមើលករណីទី១ ៤០ និង១២៥ ផងដែរ]*

**ការបំភិតបំភ័យតាមផ្លូវតុលាការទៅលើបុគ្គលិកអង្គការអាដហុក និងអ្នកសារព័ត៌មានវិទ្យុអាស៊ីសេរី** [៩១]
***ភូមិប៉ាតាង ស្រុកលំផាត់ ខេត្តរតនៈគិរី***

- បុគ្គលិកអង្គការអាដហុកចំនួន ២ នាក់ គឺលោក ប៉ែន ប៊ុនណា និងលោក ឆាយ ធី ព្រមទាំងអ្នកសារព័ត៌មានវិទ្យុអាស៊ីសេរីឈ្មោះ រដ្ឋា វិសាល ត្រូវបានតុលាការកោះហៅមកសាកសួរ អំពីការចោទប្រកាន់ពីបទញុះញង់ទាក់ទងនឹងដីធ្លីកំពុងមានជម្លោះរវាងក្រុមហ៊ុនឯកជន DM Group និងជនជាតិភាគតិចទំពួនចំនួន ១៣៦ គ្រួសារ។ បុគ្គលិកអង្គការអាដហុក និងអ្នកសារព័ត៌មាន ព្រមទាំង លោក អ៊ូ វីរៈ ជានាយកមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ត្រូវបានតុលាការកោះហៅមកសាកសួរម្តងទៀតទាក់ទងនឹងការចោទប្រកាន់ពីបទញុះញង់ក្នុងខែតុលា ឆ្នាំ២០១២។

**ថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១១**
**ករណីទី៩៥**

**សកម្មជនជាព្រះសង្ឃ ត្រូវបានអាជ្ញាធរសាសនាផ្សឹកដោយបង្ខំ** [៩២]
***ភូមិបាយដំរាំ ឃុំបាយដំរាំ ស្រុកបាណន់ ខេត្តបាត់ដំបង***

- ព្រះតេជគុណ គ្រឿន រ៉ាវី ជាព្រះសង្ឃកាន់ព្រះពុទ្ធសាសនា ត្រូវបានប្រធានសង្ឃ ព្រះនាម យុត ថុន គង់នៅវត្តបាយដំរាំផ្សឹកតាមបទបញ្ជាប្រធានសង្ឃថ្នាក់ខេត្តព្រះនាម អ៊ិក មុត។
- ព្រះតេជគុណ គ្រឿន រ៉ាវី ត្រូវបានចោទប្រកាន់ពីបទប្រព្រឹត្តអំពើពុករលួយ ប៉ុន្តែទំនងជាគោលដៅរបស់គេ ដោយសារព្រះអង្គមានប្រជាប្រិយភាពក្នុងចំណោមអ្នកភូមិមូលដ្ឋាន និងមានជំហរប្រឆាំងអំពើពុករលួយ។

**ថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០១១**
**ករណីទី៩៦**

**ការបំភិតបំភ័យតាមផ្លូវតុលាការទៅលើសកម្មជនសហគមន៍** [៩៣]
***ភូមិអណ្តូងកន្ទួត ឃុំដូនបា ស្រុកគាស់ក្រឡ ខេត្តបាត់ដំបង***

- សកម្មជនសហគមន៍ចំនួន ៦ នាក់ (សំ អឿន ម៉ែន ផន ចាន់ ឈិវ ម៉ុក ភួក ឡាច ទូន និងប៉ូ ឡែន) ត្រូវបានកោះហៅមកសាកសួរទាក់ទងនឹង ការចោទប្រកាន់ថា ពួកគេបានធ្វើឲ្យខូចខាតទ្រព្យសម្បត្តិឯកជន។ ពាក្យបណ្តឹងត្រូវបានធ្វើឡើង ដោយវរៈ

---

[៩១] ការប្រកាសព័ត៌មានរបស់អ្នកការពារសិទ្ធិមនុស្សនៃមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា "សកម្មជនសិទ្ធិមនុស្ស និងអ្នកសារព័ត៌មាន ត្រូវបានតុលាការកោះហៅមកឆ្លើយបំភ្លឺចំពោះការចោទប្រកាន់ ដែលបានធ្វើឡើងតាំងតែពី ២ឆ្នាំកន្លងទៅ" ថ្ងៃទី១២ ខែតុលា ឆ្នាំ២០១១: http://www.cchrcambodia.org/index_old.php?url=media/media.php&p=alert_detail.php&alid=12&id=5។

[៩២] របាយការណ៍ឃ្លាំមើលសិទ្ធិមនុស្សអង្គការលីកាដូ ដែលមិនត្រូវបានបោះពុម្ពផ្សាយ: BB100SC11។

[៩៣] តារាងអង្គហេតុមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា "ករណីសិក្សាភូមិអណ្តូងកន្ទួត" ថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១១ http://cchrcambodia. org/index_old.php?url=media/media.php&p=factsheet_detail.php&fsid=22&id=5។

*[សូមមើលករណីទី៣២ និង៣៤ ផងដែរ]*

សេនីយទោ ឡុង ស៊ីនៀ ជាមន្ត្រីកងរាជអាវុធហត្ថ។

- ដីកាកោះរបស់ពួកគេត្រូវបានធ្វើឡើងមិនដល់ ៣ សប្តាហ៍ផងបន្ទាប់ពី ឈ្មោះ ដៀង ភេទប្រុស (ជាតំណាងម្នាក់ទៀតមកពីសហគមន៍ដូចគ្នា) ត្រូវបានចាប់ខ្លួន ដោយគ្មានដីកា ដោយចោទប្រកាន់ពីបទកាន់កាប់ដីធ្លី បន្ទាប់ពីបាននិយាយនៅឯវេទិកាសាធារណៈមួយ ដែលត្រូវបានរៀបចំឡើង ដោយមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា។ គាត់ត្រូវបានដោះលែងវិញ បន្ទាប់ពីបានឃុំខ្លួនបាន ២ ម៉ោងដើម្បីសួរចម្លើយដោយចៅក្រមស៊ើបសួរ ប៉ុន្តែគាត់ត្រូវបានបង្គាប់ឲ្យចូលខ្លួនមកចំពោះមុខតុលាការម្តងទៀតនៅពេលក្រោយ។

**ថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០១១**
**ករណីទី៩៧**

*[សូមមើលករណីទី៦៤ ៦៥ ៧៥ ៨៧ និង៨៩ ផងដែរ]*

***ការបំភិតបំភ័យតាមផ្លូវតុលាការ ទៅលើសកម្មជនព្រៃឡង់[៩៤]***
***ភូមិត្បូងទឹក ឃុំមានរិទ្ធិ ស្រុកសណ្តាន់ ខេត្តកំពង់ធំ***

- លោក ឈុត វុទ្ធី ជាប្រធាន NRPG និងឈឹម សាវុទ្ធ ជាមន្ត្រីមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ព្រមទាំងអ្នកភូមិចំនួន ៣ នាក់ទៀត(សូម៉េ សៀន ហឿន សុភាព និង ម៉ៅ ចាន់ធឿន)ត្រូវបានគេគំរាមកំហែងចាប់ខ្លួនតាមទំនើងចិត្ត ទាក់ទងនឹងការដើរល្បាតឃ្លាំមើលព្រៃឡង់ដោយអហិង្សា។ អ្នកទាំង ៥ នាក់នេះ បានជួយរៀបចំការដើរល្បាតនេះ ជាមួយអ្នកភូមិមូលដ្ឋានដើម្បីទប់ស្កាត់អាជីវកម្មកាប់ឈើខុសច្បាប់ ហើយនឹង ពិនិត្យមើលការងាររបស់ក្រុមហ៊ុនចំការកៅស៊ូវៀតណាម (CRCK Rubber) ដែលទទួលបានសម្បទានលើដីនោះ។
- ការគំរាមកំហែងទាំងនេះ បានកើតឡើងពីអាជ្ញាធរមួយក្រុម រាប់ទាំង អ៊ុត សំអុន ជាអភិបាលរងខេត្ត ស៊ឹម វណ្ណា ជាអភិបាលស្រុកសណ្តាន់ ទូច ម៉ារី ជាអភិបាលរងស្រុកសណ្តាន់ និង អ៊ុង ម៉ូលី ជាអធិការនគរបាលស្រុក។

**ថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០១១**
**ករណីទី៩៨**

**នគរបាលបានធ្វើការបង្ក្រាបយ៉ាងហិង្សាទៅលើបាតុកម្មដោយអហិង្សា[៩៥]**
***ភូមិទីបី ឃុំត្រែងត្រយឹង ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ***

- បាតុករចំនួនប្រហែល ១០០ នាក់តំណាងឲ្យប្រជាពលរដ្ឋចំនួន ៦៦ គ្រួសារពាក់ព័ន្ធក្នុងជម្លោះដីធ្លី ត្រូវបានមន្ត្រីកងរាជអាវុធហត្ថ និងនគរបាលប្រដាប់អាវុធចំរុះចំនួន ៩០ នាក់ធ្វើការបំបែកយ៉ាងហិង្សា ដោយបានបាញ់កាំភ្លើងទៅលើអាកាសដើម្បីគំរាមពួកបាតុករ។

---

[៩៤] របាយការណ៍ឃ្លាំមើលសិទ្ធិមនុស្សអង្គការលីកាដូ ដែលមិនត្រូវបានបោះពុម្ពផ្សាយៈ KT076THI11។

[៩៥] របាយការណ៍ឃ្លាំមើលសិទ្ធិមនុស្សអង្គការលីកាដូ ដែលមិនត្រូវបានបោះពុម្ពផ្សាយៈ KS054OFEA11។

- ការបង្ក្រាបនេះ ត្រូវបានដឹកនាំដោយ មុត ដារ៉ា ជាព្រះរាជអាជ្ញាអមសាលាដំបូងខេត្ត ជាការព្យាយាមមួយដើម្បីអនុវត្តសាលដីកាកំពូល ដោយផ្តល់ដីមានជម្លោះចំនួន ១៧៥ ហិកតា ទៅឲ្យសមាគមន៍កសិករមួយមិនច្បាស់លាស់ ដែលត្រូវបានតំណាងដោយលោកវរៈសេនីយឯកយោធាមួយរូប។
- ដីនេះ មិនត្រូវបានកំណត់ឲ្យច្បាស់លាស់ក្នុងដីកា ដែលត្រូវបានប្រើដោយអាជ្ញាធរនៅអំឡុងពេលរឹបអូសយកនោះទេ។

**ថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១១**
**ករណីទី៩៩**

*[សូមមើលករណីទី៣៦ ៥១ ៦៧ ៦៩ ៧០ ៧៨ ៩១ ៩២ ១១៤ ១១៥ និង ១២២ ផងដែរ]*

### ការចាប់ខ្លួន និងការឃុំខ្លួនសកម្មជនបឹងកក់ [៩៦]

*សង្កាត់ស្រះចក ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ*

- តំណាងសហគមន៍បឹងកក់ចំនួន ៤ នាក់(បូ ឆវី ហេង មុំ គង់ ចន្ថា និងទេព វន្នី)ត្រូវបានចាប់ខ្លួន ដោយឆ្មាំសន្តិសុខខ័ណ្ឌដូនពេញ នៅអំឡុងពេលតវ៉ាមួយជុំវិញ ជម្លោះដីធ្លីនៅបឹងកក់។ ពួកគេត្រូវបានឃុំខ្លួន ១ យប់ ហើយនៅថ្ងៃបន្ទាប់បាននាំខ្លួនមកចំពោះមុខតុលាការដើម្បីសួរយកចម្លើយ។
- នៅពេលកំពុងតវ៉ាអ្នកភូមិបឹងកក់ចំនួនប្រហែល ៥០ នាក់ ត្រូវបានមន្ត្រីកងរាជអាវុធហត្ថ មន្ត្រីនគរបាល និងនគរបាលអន្តរាគមន៍មួយក្រុមមានគ្នាប្រហែល ៥០ នាក់ ធ្វើការបំពារបំពានលើរាងកាយ។ អាជ្ញាធរទាំងនេះ ត្រូវបានដឹកនាំដោយ ហ៊ី ព្រូ ជាស្នងការរងនគរបាល រាជធានីភ្នំពេញ។

**ថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០១១**
**ករណីទី១០០**

### ការបំភិតបំភ័យតាមផ្លូវតុលាការ ទៅលើសកម្មជនជលផល [៩៧]

*ភូមិកែបថ្មី ខេត្តកំពត*

- ចាន់ ដារ៉ា និងចាន់ សុផាន់ណា ជាតំណាងសហគមន៍ ត្រូវបានកោះហៅមកសាកសួរចំពោះការចោទប្រកាន់ពីបទញុះញង់ទាក់ទងនឹងជម្លោះដីធ្លីជាមួយក្រុមហ៊ុនអភិវឌ្ឍន៍ឯកជនមួយ។
- កំពង់ផែខេត្តកំពត ជាកម្មសិទ្ធិរបស់ក្រុមហ៊ុនអភិវឌ្ឍន៍ទ្រព្យសម្បត្តិ វិញហួរ និងកែវ ជា បានទទួលការអនុញ្ញាតពីរដ្ឋាភិបាល ដើម្បីចាក់ដីបំពេញសមុទ្រទំហំ ១,០០០ ហិកតា នៅក្នុងភូមិរលួស ២០០ ហិកតា នៅក្នុងកែបថ្មី និងភូមិទទឹងថ្ងៃ ដើម្បីសាងសង់កំពង់ផែថ្មីចំនួន ២ ទៀត។ អ្នកភូមិរស់នៅម្តុំតំបន់ទាំងនោះ ត្រូវបានគេបញ្ជាឲ្យ

---

[៩៦] របាយការណ៍ឃ្លាំមើលសិទ្ធិមនុស្សអង្គការលីកាដូ ដែលមិនត្រូវបានបោះពុម្ពផ្សាយ: PP174OFEA11។

[៩៧] ការប្រកាសព័ត៌មានរបស់មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា "ការបំភិតបំភ័យតាមផ្លូវតុលាការ ទៅលើសកម្មជនសហគមន៍នៅខេត្តកំពត" ថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០១១: http://cchrcambodia.org/index_old.php?url=media/media .php&p=alert_detail. php&alid= 10&id=5។

ចាកចេញពីដីធ្លី។

- ស្ត្រីបានធ្វើសកម្មភាពតស៊ូមតិយ៉ាងច្រើន ក្នុងនាមសហគមន៍របស់ពួកគេ ដូចជាដើរប្រមូលស្នាមមេដៃដាក់ញត្តិជូនរដ្ឋសភា ធ្វើការប្រមូលផ្តុំសមាជិកសហគមន៍ ដើម្បីតវ៉ា និងអំពាវនាវដល់នាយករដ្ឋមន្ត្រី សុំឲ្យជួយដោះស្រាយកង្វល់ពួកគេអំពីគម្រោងអភិវឌ្ឍន៍នេះ។

**ថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១១**

**ករណីទី១០១**

**កងកម្លាំងប្រដាប់អាវុធ បើកការបាញ់សំដៅអ្នកភូមិ ធ្វើឲ្យរបួសសកម្មជន ៣ នាក់** [៥៨]

***ឃុំចក្រី ស្រុកភ្នំព្រឹក ខេត្តបាត់ដំបង***

- មេបញ្ជាការរងយោធាស្រុក បានបាញ់សំដៅទៅការប្រមូលផ្តុំរបស់អ្នកភូមិ ដោយអហិង្សា ដោយធ្វើឲ្យរបួសតំណាងសហគមន៍ចំនួន ៣ នាក់ គឺ សឹង ហៀង ជូ គុណា និងជឿន ជាង។
- អ្នកភូមិបានប្រមូលផ្តុំគ្នាក្នុងការព្យាយាមចូលរួមកិច្ចប្រជុំមួយ រវាងអាជ្ញាធរមូលដ្ឋាន និងក្រុមហ៊ុនទាក់ទងនឹងដីកំពុងមានទំនាស់ ដែលធ្វើឲ្យប៉ះពាល់ដល់ពួកគេ។
- ចាន់ នី ដែលជាមេបញ្ជាការរង គឺបានធ្វើជាឆ្មាំសន្តិសុខសម្រាប់ក្រុមហ៊ុនស្វូន សម្បត្តិ។

[៥៨] របាយការណ៍ឃ្លាំមើលសិទ្ធិមនុស្សអង្គការលីកាដូ ដែលមិនត្រូវបានបោះពុម្ពផ្សាយ: BB110PA11។

# ឧបសម្ព័ន្ធ ៣: អ្នកការពារសិទ្ធិមនុស្សនៅកម្ពុជា(ខែមករា ដល់ ខែតុលា ឆ្នាំ២០១២)

**ថ្ងៃទី៣ ខែមករា ឆ្នាំ២០១២**

**ករណីទី១០២**

*[សូមមើលករណី ១០៣ និង១២៣ ផងដែរ]*

## អ្នកភូមិត្រូវបានចាប់ខ្លួន នៅអំឡុងពេលបណ្តេញចេញដោយបង្ខំ [៩៩]

*សង្កាត់វាលវង់ ខ័ណ្ឌ ៧មករា រាជធានីភ្នំពេញ*

- អ្នកភូមិចំនួន ៨ នាក់ រាប់ទាំងមន្ត្រីនគរបាលជាស្ត្រីម្នាក់ផង ត្រូវបានចាប់ខ្លួននៅអំឡុងពេលធ្វើការបណ្តេញប្រជាពលរដ្ឋចំនួន ៣០០ គ្រួសារ យ៉ាងហិង្សានិងដោយបង្ខំចេញពីសហាគមន៍បូរីកីឡា។ អាជ្ញាធរទាំងនេះ ត្រូវបានដឹកនាំដោយ លោក ភួង ម៉ាឡៃ ជាស្នងការរងរាជធានីភ្នំពេញ និងកើត ឆែ ជាអភិបាលរងរាជធានីភ្នំពេញផងដែរ។
- នៅដើមឆ្នាំ២០០៣ "កិច្ចព្រមព្រៀងបែងចែកដីធ្លី" មួយត្រូវបានស្នើឡើងសម្រាប់សហាគមន៍បូរីកីឡា ដែលអនុញ្ញាតឲ្យក្រុមហ៊ុន Phanimex ជាក្រុមហ៊ុនសាងសង់មានខ្នងជាអ្នកមានអំណាច ធ្វើការអភិវឌ្ឍន៍តំបន់នេះមួយផ្នែកសម្រាប់គោលបំណងពាណិជ្ជកម្ម ដោយក្រុមហ៊ុននេះ ត្រូវសង់ផ្ទះនៅលើដីដែលសេសសល់សម្រាប់អ្នកភូមិនៅសហាគមន៍នេះរស់នៅ។ ក្រោមកិច្ចព្រមព្រៀងនេះ ក្រុមហ៊ុន Phanimex ត្រូវមានកាតព្វកិច្ចច្បាស់លាស់ ដើម្បីសាងសង់អគារផ្ទះល្វែងចំនួន ១០ អគារ នៅលើដីទំហំ ២ ហិកតា សម្រាប់អ្នកភូមិរស់នៅ ជាថ្នូរនឹងការទទួលបានមកវិញ នូវកម្មសិទ្ធិលើដីទំហំ ២,៦ ហិកតា បន្ថែម សម្រាប់ធ្វើការអភិវឌ្ឍន៍ខាងពាណិជ្ជកម្ម។
- ទោះបីយ៉ាងណាក៏ដោយ នៅក្នុងខែមេសា ឆ្នាំ២០១០ ក្រុមហ៊ុន Phanimex មិនបានគោរពកិច្ចព្រមព្រៀងនេះ ជាឯកតោភាគី (ដោយមានការយល់ព្រមពីរាជរដ្ឋាភិបាល) ហើយបានថ្លែងថា ក្រុមហ៊ុននឹងបញ្ឈប់ការសាងសង់អគារផ្ទះល្វែងសម្រាប់គ្រួសារប្រជាពលរដ្ឋ ដែលត្រូវបណ្តេញចេញ បន្ទាប់ពីសង់អគារផ្ទះល្វែងបានចំនួន ៨ អគារប៉ុណ្ណោះ។ ដូច្នេះ ប្រជាពលរដ្ឋសហាគមន៍បូរីកីឡាចំនួន ៣០០ គ្រួសារ ត្រូវបានគេទុកចោល និងដកឈ្មោះចេញពីកិច្ចព្រមព្រៀងដំបូង (ហើយពួកគេកំពុងតែរស់នៅលើផ្ទះសម្បែងក្នុងតំបន់នោះ)។ ផ្ទះសម្បែងទាំងនេះ ហើយដែលតំណាងក្រុមហ៊ុន Phanimex បានរុះកំទេចចោលកាលពីថ្ងៃទី៣ ខែមករា ឆ្នាំ២០១២។
- ការរុះកំទេចផ្ទះត្រូវបានធ្វើឡើងពីសំណាក់បុគ្គលិកក្រុមហ៊ុន Phanimex និងអាជ្ញាធរអមដោយគ្រឿងចក្រមួយគ្រឿង ដែលត្រូវប្រើដើម្បីកំទេចផ្ទះសម្បែង មុនពេលអ្នកភូមិ

[៩៩] របាយការណ៍ឃ្លាំមើលសិទ្ធិមនុស្សអង្គការលីកាដូ ដែលមិនត្រូវបានបោះពុម្ពផ្សាយ: PP009FE12។ សូមមើលផងដែរ សេចក្តីប្រកាសព័ត៌មានអង្គការលីកាដូ "ក្រុមសង្គមស៊ីវិលថ្កោលទោសការបណ្តេញអ្នករស់នៅសហាគមន៍បូរីកីឡាចេញដោយហិង្សា" ថ្ងៃទី៣ ខែមករា ឆ្នាំ២០១២: http://www.licadho-cambodia.org/pressrelease.php?perm=267 ។

មានឱកាសបានយកទ្រព្យសម្បត្តផ្ទាល់ខ្លួនចេញ។ កងកម្លាំងនគរបាលចំរុះចំនួនជាង ១០០ នាក់គឺជាអ្នកត្រួតត្រាមើលដំណើរការនោះ។ នគរបាលបានបាញ់ឧស្ម័នបង្ហូរទឹកភ្នែក និង គ្រាប់កាំភ្លើងពិតផងដែរ នៅអំឡុងពេលបណ្តេញចេញនោះ។

- មានប្រជាពលរដ្ឋចំនួនយ៉ាងហោចណាស់ ១២ នាក់ បានទទួលរងរបួសរាប់ទាំងនគរបាលម្នាក់ផង ក្នុងនោះអ្នកខ្លះទទួលរងរបួសជាទម្ងន់។

**ថ្ងៃទី១១ ខែមករា ឆ្នាំ២០១២**
**ករណីទី១០៣**

*[សូមមើលករណី ១០២ និង១២៣ ផងដែរ]*

**អ្នករស់នៅសហគមន៍បូរីកីឡា ត្រូវបានចាប់ខ្លួន និងឃុំខ្លួនខុស ដោយខុសច្បាប់នៅមជ្ឈមណ្ឌលសង្គមកិច្ចព្រៃស្ពឺ** [១០០]

***សង្កាត់វាលវង់ ខ័ណ្ឌ ៧មករា រាជធានីភ្នំពេញ***

- អតីតអ្នករស់នៅសហគមន៍បុរីកីឡាចំនួន ២៤ នាក់ និងកុមារចំនួន ៦ នាក់ រាប់ទាំងទារកអាយុ ៣ ខែផង ត្រូវបានឃុំខ្លួន ដោយខុសច្បាប់នៅមជ្ឈមណ្ឌលសង្គមកិច្ចព្រៃស្ពឺ បន្ទាប់ពីត្រូវបានចាប់ខ្លួននៅពេលកំពុងធ្វើការតវ៉ាដោយអហិង្សាមួយ នៅមុខសាលាក្រុងភ្នំពេញ។ គ្មានជនណាម្នាក់ក្នុងក្រុមនេះ ត្រូវបានចោទប្រកាន់ ឬសង្ស័យពីបទល្មើសអ្វីឡើយ។
- អ្នកភូមិកំពុងធ្វើការតវ៉ាដើម្បីទាមទារឲ្យដោះលែងអ្នកភូមិដូចគ្នា ដែលត្រូវបានចាប់ខ្លួនពីថ្ងៃមុនក្នុងខែដដែល នៅអំឡុងពេលបណ្តេញចេញ ដោយបង្ខំ និងហិង្សាមួយ *[សូមមើលករណីទី១០៨]*។ ពួកគេភាគច្រើន ត្រូវបានបង្ខំចិត្តរត់គេចពីមជ្ឈមណ្ឌលនេះដោយឡើងតាមរបង។ ពួកគេត្រូវបានឃុំខ្លួននៅក្នុងមជ្ឈមណ្ឌលនេះអស់រយៈពេលជាច្រើនថ្ងៃ។

**ថ្ងៃទី១៨ ខែមករា ឆ្នាំ២០១២**
**ករណីទី១០៤**

**យោធាបើកការបាញ់ទៅលើការតវ៉ាដោយអហិង្សា ដែលធ្វើឲ្យរបួសអ្នកភូមិចំនួន ៤ នាក់** [១០១]

***ស្រុកស្នួល ខេត្តក្រចេះ***

- បុគ្គលិកយោធាដើរតួជាឆ្មាំសន្តិសុខរបស់ក្រុមហ៊ុន TTY Co. Ltd បានបើកការបាញ់សំដៅទៅអ្នកភូមិមួយក្រុម ដែលបានមកប្រមូលផ្តុំគ្នា ដើម្បីទប់ស្កាត់មិនឲ្យគ្រឿងចក្រក្រុមហ៊ុនឈូសឆាយដីស្រែចំការរបស់ពួកគេ។ ដំឡូងមីដាំលើដីចំការប្រជាពលរដ្ឋចំនួន ២០៣ គ្រួសារ ត្រូវបានកំទេចចោល មុនពេលអ្នកភូមិអាចប្រមូលផល។
- ក្រុមហ៊ុន TTY Co. Ltd. នេះបានទទួលដីសម្បទានសេដ្ឋកិច្ចទំហំជាង ៩,០០០ហិកតា

[១០០] របាយការណ៍ឃ្លាំមើលសិទ្ធិមនុស្សអង្គការលីកាដូ ដែលមិនត្រូវបានបោះពុម្ពផ្សាយ: PP013IAD12។

[១០១] ខ្សែវីដេអូអង្គការលីកាដូ "យោធាបាញ់អ្នកតវ៉ានៅឥសានកម្ពុជា" ថ្ងៃទី២១ ខែមករា ឆ្នាំ២០១២: www.licadho-cambodia.org/video .php?perm=29។ សូមមើលផងដែរ: របាយការណ៍ឃ្លាំមើលសិទ្ធិមនុស្សអង្គការលីកាដូ ដែលមិនត្រូវបានបោះពុម្ពផ្សាយ: PP010PA12។

ក្នុងឆ្នាំ២០០៨ នៅស្រុកស្នួល។ ដីសម្បទានមួយផ្នែក បានជាន់លើដែនជម្រកសត្វព្រៃនៅស្រុកស្នួល។

- អ្នកភូមិចំនួន ៤ នាក់ បានទទួលរងរបួសដោយគ្រាប់កាំភ្លើង។ អាជ្ញាធរដែលមានវត្តមាននៅពេលកំពុងបាញ់នោះ មិនបានព្យាយាមតាមចាប់ខ្លួនជនល្មើសឡើយ ថ្វីបើបុគ្គលិកក្រុមហ៊ុនចំនួន ៣ នាក់ ក្រោយមកត្រូវបានចាប់ខ្លួនក៏ដោយ (ឆ្មាំសន្តិសុខចំនួន ២ នាក់ និងអគ្គនាយកចំនួន ១ នាក់)។ ពួកគេកំពុងរង់ចាំបើកសវនាការជំនុំជម្រះ។

**ថ្ងៃទី៣០ ខែមករា ឆ្នាំ២០១២**
**ករណីទី១០៥**

## ការបំភិតបំភ័យតាមផ្លូវតុលាការ ទៅលើសកម្មជនដីធ្លី [១០២]

***ខេត្តបាត់ដំបង***

- សាន សំនៀង ជាសកម្មជនសិទ្ធិដីធ្លីពីខេត្តបន្ទាយមានជ័យ ត្រូវបានសាលាដំបូងខេត្តបាត់ដំបង កោះហៅមកសាកសួរទាក់ទងនឹងការចោទប្រកាន់ពីបទធ្វើឲ្យខូចខាតទ្រព្យសម្បត្តិដោយចេតនា។ ដីកាកោះនោះ មិនមានព័ត៌មានអំពីប្រភេទបទល្មើសដែលបណ្តាលឲ្យមានការចោទប្រកាន់ ដូចជាកាលបរិច្ឆេទ ទីកន្លែង ឬមូលដ្ឋានច្បាប់ជាក់លាក់ឡើយ។
- នៅក្នុងខែធ្នូ ឆ្នាំ២០០៩ សាន សំនៀង បានរៀបចំការប្រមូលផ្តុំមួយទាក់ទងនឹងជម្លោះដីធ្លី រវាងពាណិជ្ជករក្នុងស្រុកជាស្ត្រីម្នាក់ឈ្មោះ ថេត ផារី និងសមាជិកសហគមន៍មកពីភូមិចំនួន ២ (ភូមិបឹងពីរ ឃុំល្វា ស្រុកបវិល ខេត្តបាត់ដំបង និងភូមិប្រាសាទរាំង ឃុំតាគង ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ)។

**ថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០១២**
**ករណីទី១០៦**

**[សូមមើលករណីទី៥ និង៣០ ផងដែរ]**

## យោធាបំបែកបាតុកម្មដោយអហិង្សា [១០៣]

***ឃុំអមលាំង ស្រុកថ្ពង ខេត្តកំពង់ស្ពឺ***

- អ្នកភូមិចំនួនប្រហែល ២០០ នាក់ (ពាក់ព័ន្ធក្នុងជម្លោះដីធ្លីជាមួយក្រុមហ៊ុនរបស់ឧកញ៉ា លី យ៉ុងផាត់ ជាពាណិជ្ជករ និងជាសមាជិកព្រឹទ្ធសភាគណបក្សប្រជាជន) បានមកប្រមូលផ្តុំគ្នានៅមុខសាលាដំបូងខេត្តកំពង់ស្ពឺ ដើម្បីទាមទារឲ្យមានការដោះលែង ជុំ ស្រីអួន ជាតំណាងសហគមន៍ (សម្រាប់សាវតារឿងសូមមើលករណីទី៥ និង៣០)។ ពួកគេត្រូវបានបំបែកដោយទាហានយោធាប្រដាប់អាវុធចំនួនប្រហែលជា ៦០

---

[១០២] ការប្រកាសព័ត៌មានរបស់អ្នកការពារសិទ្ធិមនុស្សនៃមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា "សកម្មជនខេត្តបន្ទាយមានជ័យ ត្រូវបានកោះហៅមកសាកសួរទាក់ទងនឹងការចោទប្រកាន់ពីបទល្មើសមិនច្បាស់លាស់" ថ្ងៃទី២៦ ខែមករា ឆ្នាំ២០១២: http://cchrcambodia.org/index_old.php?url=media/media.Php&p=alert_detail.php&alid=13&id=5 ។

[១០៣] របាយការណ៍ឃ្លាំមើលសិទ្ធិមនុស្សអង្គការលីកាដូ ដែលមិនត្រូវបានបោះពុម្ពផ្សាយ: KS004OFEA12។

នាក់ ដែលបានគំរាមបាញ់ ប្រសិនបើពួកគេបន្តធ្វើបាតុកម្ម។

**ថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១២**
**ករណីទី១០៧**

**ការបំភិតបំភ័យតាមផ្លូវតុលាការ ទៅលើបុគ្គលិកអង្គការមិនមែនរដ្ឋាភិបាល** [១០៤]
*ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ*

- លោក សួម ចាន់គា ជាបុគ្គលិកអង្គការអាដហុក ត្រូវបានសាលាដំបូងខេត្តកោះហៅមកឆ្លើយបំភ្លឺអំពីការចោទប្រកាន់ពីបទមួលបង្កាច់កេរ្តិ៍ ក្រោយពីគាត់មានការពាក់ព័ន្ធក្នុងករណីហិង្សាផ្អែកលើយេនឌ័រ។
- ពាក្យបណ្តឹងប្រឆាំងនឹងលោក សួម ចាន់គា ត្រូវបានធ្វើឡើងបន្ទាប់ពីមានអន្តរាគមន៍ពីអង្គការអាដហុកក្នុងករណីបៀតបៀនកេរ្តិ៍ខ្មាស និងការរំលោភរាងកាយ ដែលប្រព្រឹត្តដោយ លោក អ៊ុំ សុជាតិ ជាប្រធានមជ្ឈមណ្ឌលសកម្មភាពមីនកម្ពុជាប្រចាំខេត្តបន្ទាយមានជ័យ និងជាអ្នកសម្របសម្រួលកម្មវិធីដោះមីន (UNDP-CMAC Mine Clearance Program) និង ប៉ុង ពិសិដ្ឋ។ ប៉ុង ពិសិដ្ឋ គឺជាពាណិជ្ជករខាងសំណង់ និងខាងអចលនទ្រព្យដ៏សំខាន់ម្នាក់ និងជាបងប្អូនប្រុសរបស់មន្ត្រីរាជរដ្ឋាភិបាលជាន់ខ្ពស់មួយរូប។

**ថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១២**
**ករណីទី១០៨**

**កម្មករកាត់ដេរត្រូវបានគេបាញ់ឲ្យរងរបួសជាទម្ងន់ នៅពេលធ្វើកូដកម្ម** [១០៥]
*ភូមិតាពៅ ឃុំបាវិត ស្រុកបាវិត ខេត្តស្វាយរៀង*

- កម្មកររោងចក្រកាត់ដេរជាក្មេងស្រីចំនួន ៣ នាក់ (ប៊ុន ចិន្តា កែវ នា និងនុត សុខុម) ត្រូវបានគេបាញ់ឲ្យទទួលរងរបួសយ៉ាងធ្ងន់ធ្ងរ នៅអំឡុងពេលបាតុកម្មដោយអហិង្សាមួយ នៅក្នុងតំបន់សេដ្ឋកិច្ច ពិសេសម៉ាហាតាន់ (the Manhattan Special Economic Zone) នៅខេត្តស្វាយរៀង។ កម្មករទាំងនោះ កំពុងធ្វើបាតុកម្ម ដើម្បីទាមទារដំឡើងប្រាក់ឈ្នួល ហើយនឹងទាមទារលក្ខខ័ណ្ឌការងារឲ្យមានភាពប្រសើរឡើង។ ខ្មាន់កាំភ្លើងក្រោយមក ត្រូវបានគេស្គាល់ថាលោក ឈូក បណ្ឌិត ដែលនៅពេលនោះ ជាអភិបាលក្រុងបាវិត។
- បើទុកជាមានវត្តមានកងរាជអាវុធហត្ថនៅពេលនោះក៏ដោយ ក៏លោក ឈូក បណ្ឌិត នៅតែអាចគេចខ្លួនបានតាមម៉ូតូរបស់គាត់ ក្រោយពីបានបើកការបាញ់ប្រហារទៅលើកម្មករចំនួន ១,០០០ នាក់ ដែលកំពុងធ្វើកូដកម្ម ។

---

[១០៤] FIDH "ការរំខានយាយីពីតុលាការទៅលើលោក សួម ចាន់គា" ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១២: http://www.fidh.org/Judicial-harassment-against-Mr,11324។

[១០៥] សេចក្តីប្រកាសព័ត៌មានអង្គការលីកាដូ "បញ្ឈប់និទ្ទណ្ឌភាពហិង្សាដោយអាវុធ: ចាប់ខ្លួន និងធ្វើការចោទប្រកាន់ខ្មាន់កាំភ្លើងនៅខេត្តស្វាយរៀង" ថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១២: http://www.licadho-cambodia.org/pressrelease.php?perm=270។ សូមមើលផងដែរ: របាយការណ៍ឃ្លាំមើលសិទ្ធិមនុស្សអង្គការលីកាដូ ដែលមិនត្រូវបានបោះពុម្ពផ្សាយ: SR007AK12។

- នៅថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០១២ លោក ឈូក បណ្ឌិត ត្រូវបានអាជ្ញាធរសាកសួរយកចម្លើយ ហើយបានសារភាពថាគាត់បានបាញ់កាំភ្លើងរបស់គាត់នៅអំឡុងពេលធ្វើការតវ៉ា។ លោក ឈូក បណ្ឌិត មិនត្រូវបានគេចាប់ខ្លួនទេ។ គាត់ត្រូវបានចោទប្រកាន់ពីបទបង្ករបួសស្នាមដោយអចេតនា។

**ថ្ងៃទី១ ខែមិនា ឆ្នាំ២០១២**
**ករណីទី១០៩**

**សកម្មជនសហជីពកម្មករ ត្រូវបានគេបាញ់នឹងកាំភ្លើង និងរំខានយាយីជាមួយនឹងនិទ្ទណ្ឌភាព** [១០៦]

***ខេត្តសៀមរាប***

- ម៉ម រិទ្ធី ជាអនុប្រធានសហព័ន្ធកម្មករសេវាកម្ម និងទេសចរណ៍កម្ពុជា ( Cambodia Tourism and Service Worker Federation) និង គង់ គីមលាន ជាសកម្មជនសហជីពកម្មករម្នាក់ត្រូវបានសាលាឧទ្ធរណ៍កោះហៅ បន្ទាប់ពី Olivier Piot ជាម្ចាស់សណ្ឋាគារភូមិអង្គរ និងរមណីយដ្ឋានរុក្ខសាស្ត្រភូមិអង្គនៅខេត្តសៀមរាប បានដាក់ពាក្យបណ្តឹងដោយ ចោទប្រកាន់ពួកគេពីបទធ្វើឲ្យខូចខាតទ្រព្យសម្បត្តិដោយចេតនា។
- នៅក្នុងឆ្នាំ២០១១ កម្មករចំនួន ៦៧ នាក់ ត្រូវបានបណ្តេញចេញពីសណ្ឋាគាររបស់ Olivier Piot ក្រោយពីពួកគេបានផ្តើមចូលជាសមាជិក សហជីព ដែលនាំឲ្យមានការតវ៉ាមួយឈុត និងចំណាត់ការពីតុលាការ។
- នៅថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១១ ប្រធានសហជីពចំនួន ៣ នាក់រាប់ទាំង ម៉ម រិទ្ធី ផងត្រូវបានសាលាដំបូងខេត្តសៀមរាប កោះហៅមកសាកសួរ ចម្លើយបន្ទាប់ពីមានពាក្យបណ្តឹងមួយ ដែលថាកម្មករសហជីពបានធ្វើកូដកម្មដោយគ្មានបានជូនដំណឹង ដោយញុះញង់កម្មករដទៃទៀតឲ្យប្រព្រឹត្តបទឧក្រិដ្ឋ និងបង្កឲ្យខូចខាតទ្រព្យសម្បត្តិដោយចេតនា។ តុលាការបានសម្រេចមិនចាត់ការករណីនេះដោយសារតែមិនមានភស្តុតាងគ្រប់គ្រាន់។

**ថ្ងៃទី៣០ ខែមិនា ឆ្នាំ២០១២**
**ករណីទី១១០**

**អាជ្ញាធររារាំងមិនឲ្យដាក់ញត្តិជូនស្ថានទូតចិន** [១០៧]

***សង្កាត់ដើមគរ ខ័ណ្ឌទួលគោក រាជធានីភ្នំពេញ***

- តំណាងសហគមន៍ចំនួន ២ នាក់ មកពីខេត្តកោះកុងគឺ ទេព វ៉ាន់ណា និងឆាយម៉េងហ្វូរ ត្រូវបានចាប់ខ្លួន និងឃុំខ្លួននៅស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ បន្ទាប់ពីពួកគេបានឡើងមកកាន់រាជធានីភ្នំពេញ ដើម្បីដាក់ញត្តិជូនស្ថានទូតចិន។ ញត្តិ

---

[១០៦] ការប្រកាសព័ត៌មានរបស់អ្នកការពារសិទ្ធិមនុស្សនៃមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា "សកម្មជនសហជីពកម្មករ ត្រូវបានសាលាឧទ្ធរណ៍កោះហៅមកសាកសួរ" ថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០១២: http://cchrcambodia.org/index_old.php?url= media/media.php&p = alert_detail.php&alid=16&id=5។

[១០៧] របាយការណ៍ឃ្លាំមើលសិទ្ធិមនុស្សអង្គការលីកាដូ ដែលមិនត្រូវបានបោះពុម្ពផ្សាយ: PP051THI12។

នោះ គឺទាក់ទងនឹងដីកំពុងមានជម្លោះ រវាងប្រជាពលរដ្ឋចំនួន ១,០០០ គ្រួសារ មកពីស្រុកគីរីសាគរខេត្តកោះកុង និងក្រុមហ៊ុនអភិវឌ្ឍន៍សហាជីពចិន (Chinese Union Development Group Company (UDG)។

- អ្នកភូមិចំនួន ៣០ នាក់ ផ្សេងទៀត ដែលមកជាមួយតំណាងសហគមន៍ត្រូវបានគេយកចេញពីផ្ទះសំណាក់ បង្ខំឲ្យចូលក្នុងឡាន ហើយដឹកត្រឡប់ទៅផ្ទះសម្បែងពួកគេវិញនៅខេត្តកោះកុង។ អាជ្ញាធរទាំងនោះ ត្រូវបានដឹកនាំដោយលោក ទូច ណារ័ត្ន ជាស្នងការនគរបាលរាជធានីភ្នំពេញ។
- ញត្តិរបស់អ្នកភូមិមានស្នាមដៃចំនួន ៣៤៩ នាក់ ពួកគាត់មានគម្រោងប្រគល់ញត្តិនេះទៅឲ្យស្ថានទូតចិន នៅអំឡុងពេលទស្សនកិច្ចរបស់ប្រធានាធិបតីចិនសម្រាប់កិច្ចប្រជុំកំពូលអាស៊ាន។
- នៅក្នុងឆ្នាំ២០០៨ ក្រុមហ៊ុន UDG បានផ្ដើមឈ្ងួសឆាយដីព្រៃចំនួន ៣៦,០០០ ហិកតា នៅលើឆ្នេរសមុទ្រខេត្តកោះកុង ដើម្បីសាងសង់តំបន់ទេសចរណ៍ ដែលត្រូវចំណាយប្រាក់ ៣,៨ ពាន់លានដុល្លារអាមេរិករាប់ទាំងសណ្ឋាគារ តារាងវាយកូនហ្គូល និងព្រលានយន្តហោះ។

**ថ្ងៃទី១០ ខែមេសា ឆ្នាំ២០១២**
**ករណីទី១១១**

**សកម្មជនសហគមន៍បង្ខំចិត្តភៀសខ្លួន បន្ទាប់ពីមានការគំរាមដល់អាយុជីវិត**[១០៨]
***សង្កាត់ត្រពាំងអញ្ចាញបួន ខ័ណ្ឌពោធិសែនជ័យ រាជធានីភ្នំពេញ***

- អ្នកស្រី រស់ បុប្ផា ជាតំណាងសហគមន៍ផ្លូវរថភ្លើង បានភៀសខ្លួនចេញពី សហគមន៍របស់អ្នកស្រី បន្ទាប់ពីបានទទួលការគំរាមសម្លាប់ពីប្រធានភូមិ និង ត្រូវបានគំរាមចាប់ខ្លួនពីអាជ្ញាធរមូលដ្ឋាន និងតំបន់។
- កាលពីមួយឆ្នាំកន្លងទៅប្រជាពលរដ្ឋចំនួនជាង ១៦០ គ្រួសារត្រូវបានបណ្ដេញចេញ ដែលជាផ្នែកមួយនៃគំរោងស្ដារផ្លូវដែកឡើងវិញ ដែលបានទទួលមូលនិធិមួយចំណែកពីធនាគារអភិវឌ្ឍន៍អាស៊ី (ADB)។ ពួកគេត្រូវបានបណ្ដេញចេញឲ្យទៅរស់នៅភូមិត្រពាំងអញ្ចាញ ដែលជាផ្នែកនៃគម្រោងតាំងទីលំនៅដ្ឋានថ្មីមួយ។ នៅថ្ងៃទី២ ខែមេសាឆ្នាំ២០១២ រស់ បុប្ផា បានដាក់ពាក្យបណ្ដឹងទៅ ADB នៅកម្ពុជា ដោយអះអាងថា សំណងជួសជុលការបណ្ដេញចេញរបស់គាត់ មិនគ្រប់ គ្រាន់ទេដោយសារការងារ និងឱកាសរកចិញ្ចឹមជីវិតមានកំរិតនៅក្នុង ភូមិត្រពាំងអញ្ចាញ។

[១០៨] សេចក្ដីប្រកាសព័ត៌មានអង្គការលីកាដូ "ការវាយប្រហារហិង្សាពីអាជ្ញាធរមូលដ្ឋានទៅលើអ្នកភូមិនៅតំបន់តាំងទីលំនៅថ្មីសហគមន៍ផ្លូវរថភ្លើង" ថ្ងៃទី៦ ខែមេសា ឆ្នាំ២០១២:។ សូមមើលផងដែរ: ឯកសារអង្គការលើកលែងទោសអន្តរជាតិ "ស្ត្រីកម្ពុជាទទួលរងការគំរាមសម្លាប់: រស់ បុប្ផា" ថ្ងៃទី១៣ ខែមេសា ឆ្នាំ២០១២: http://www.amnesty.org/en/library /asset/ASA23/005/2012/en/cbb1b531-b422-45d3-9e3f-89099e50fab5/ asa230052012en.html។

- នៅថ្ងៃទី៤ ខែមេសា ឆ្នាំ២០១២ ប្រធានភូមិបានដឹកនាំអ្នកភូមិ និងឆ្មាំសន្តិសុខចំនួនពី ៣០ ទៅ ៤០ នាក់ ធ្វើការបំពានដោយហិង្សាទៅលើគ្រួសារប្រជាពលរដ្ឋ ដែលបានមកតាំងទីលំនៅថ្មី ដោយប្រើដំបងឆក់ កាំបិត និងរំពាត់។ ប្រធានភូមិនោះ កាន់កាំភ្លើងបានដើរសំដៅទៅផ្ទះ រស់ បុប្ផា ដោយគំរាមសម្លាប់គាត់ ប៉ុន្តែគាត់បានលាក់ខ្លួននៅទីកន្លែងផ្សេង។
- នៅថ្ងៃទី១០ ខែមេសា ឆ្នាំ២០១២ គណៈប្រតិភូមន្ត្រីក្នុងតំបន់ និងមន្ត្រីសាលារាជធានីភ្នំពេញរួមជាមួយនគរបាល និងបុគ្គលិកគណៈកម្មាធិការតាំងទីលំនៅដ្ឋានថ្មីអន្តរក្រសួង (IRC) បានទៅចាប់ខ្លួន រស់ បុប្ផា ដោយ ចោទប្រកាន់ពីបទចោរកម្ម ប៉ុន្តែគាត់មិនបាននៅផ្ទះទេថ្ងៃនោះ។ នៅពេលគាត់ត្រឡប់មកផ្ទះវិញ ប្រធានភូមិ និងអ្នកគាំទ្រគាត់បានមកជួបជុំគ្នានៅមុខផ្ទះរបស់ រស់ បុប្ផា ចំនួន ២ យប់ជាប់ៗគ្នា ផឹកស្រា និងគប់ដុំថ្ម ព្រមទាំងជេរប្រមាថគាត់។ ចាប់ពីពេលនោះមក រស់ បុប្ផា ព្រមទាំងក្រុមគ្រួសារក៏បានរត់គៀសខ្លួន។

**ថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១២**
**ករណីទី១១២**

## ប្រធានអង្គការមិនមែនរដ្ឋាភិបាលការពារបរិស្ថាន ត្រូវបានគេសម្លាប់ [១០៩]

*ភូមិកោះពៅ ឃុំបាក់ខ្លង ស្រុកមណ្ឌលសីមា ខេត្តកោះកុង*

- លោក ឈុត វុទ្ធី ជាប្រធានក្រុមការពារធនធានធម្មជាតិ និងជាសកម្មជនបរិស្ថានដ៏សំខាន់មួយរូបត្រូវបានបាញ់សម្លាប់ នៅពេលកំពុងធ្វើដំណើរអមអ្នកសារព័ត៌មានចំនួន ២ នាក់ ដើម្បីថតយករូបភាពអាជីវកម្មកាប់ឈើខុសច្បាប់។ កងរាជអាវុធហត្ថ និងទាហាន ដែលបំរើការជាឆ្មាំសន្តិសុខសម្រាប់ក្រុមហ៊ុនកាប់ឈើ Timber Green បានព្យាយាមរឹបអូសយកម៉ាស៊ីនថតសម្លេងរបស់ពួកគេ មុនពេលធ្វើការបាញ់ប្រហារដែលបានផ្តាច់ជីវិតកងរាជអាវុធហត្ថមួយរូបឈ្មោះ អ៊ិន រតនា ផងដែរ។
- (សម្រាប់ព័ត៌មានបន្ថែម សូមមើលករណីសិក្សាក្នុងតួសេចក្តីនៃរបាយការណ៍នេះ)។

---

[១០៩] របាយការណ៍ឃ្លាំមើលសិទ្ធិមនុស្សអង្គការលីកាដូ ដែលមិនត្រូវបានបោះពុម្ពផ្សាយ: KK012K12។ សូមមើលផងដែរ "សវនាការរឿងឃាតកម្ម៖ ព្រៃឈើជាសាក្សីក្នុងរឿងបាញ់ប្រហារដែលបណ្តាលឲ្យស្លាប់" ("Blood Trial: The Forest Witnesses an Unsettling Death") *The Economist,* ថ្ងៃទី៥ ខែឧសភា ឆ្នាំ២០១២: , http://www. economist .com/node/21554251។

**ថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១២**
**ករណីទី១១៣**

**ការបំភិតបំភ័យតាមផ្លូវតុលាការទៅលើសកម្មជនដីធ្លី** [១១០]

***ស្រុកក្រគរ ខេត្តពោធិ៍សាត់***

- គុច វែង ជាតំណាងសហគមន៍ ត្រូវបានចោទប្រកាន់ពីបទញុះញង់ បន្ទាប់ពីដឹកនាំអ្នកភូមិដូចគ្នាដើម្បីចរចារឲ្យបញ្ឈប់ក្រុមហ៊ុន Pheapimex បញ្ឈប់ការឈូសឆាយដីស្រែចំការរបស់ពួកគេ។
- អ្នកភូមិចំនួនប្រមាណជា ១២,០០០ នាក់ បច្ចុប្បន្នកំពុងពាក់ព័ន្ធក្នុងជម្លោះដីធ្លីជាមួយក្រុមហ៊ុន Pheapimex ដែលបានទទួលដីសម្បទានដីសេដ្ឋកិច្ចចំនួនជាង ៣១៥,០០០ ហិកតា នៅក្នុងខេត្តចំនួន ២ គឺខេត្តពោធិ៍សាត់ និងខេត្តកំពង់ឆ្នាំង។
- អ្នកភូមិចំនួន ៨ នាក់ បានទទួលដីកាកោះពីតុលាការកាលពីឆ្នាំមុន ទាក់ទងនឹងពាក្យបណ្ដឹងដែលក្រុមហ៊ុននេះបានប្ដឹងពីបទញុះញង់ បំផ្លិចបំផ្លាញទ្រព្យសម្បត្តិ និងរារាំងដល់ការអភិវឌ្ឍន៍។

**ថ្ងៃទី២២-២៤ ខែឧសភា ឆ្នាំ២០១២**
**ករណីទី១១៤**

*[សូមមើលករណីទី៣៦ ៥១ ៦៧ ៦៩ ៧០ ៧៨ ៩១ ៩២ ៩៩ ១១៥ និង ១២២ ផងដែរ]*

*[សូមមើលករណីទី២០ និង៧៥*

**សកម្មជនបឹងកក់ចំនួន ១៥ នាក់ត្រូវបានចាប់ខ្លួន ឃុំខ្លួន និងកាត់ទោស** [១១១]

***សហគមន៍បឹងកក់ រាជធានីភ្នំពេញ***

- ស្ត្រីចំនួន ១៣ នាក់ត្រូវបានចាប់ខ្លួននៅអំឡុងពេលបាតុកម្ម ដោយ អហិង្សាមួយដើម្បីគាំទ្រដល់ប្រជាពលរដ្ឋចំនួន ១៨ គ្រួសាររស់នៅភូមិ បឹងកក់ ១ ដែលផ្ទះសម្បែងរបស់ពួកគេត្រូវបានកំទេច និងបូមខ្សាច់ពន្លិច។
- កងរាជអាវុធហត្ថ នគរបាលអន្តរាគមន៍ប្រឆាំងនឹងកូដកម្ម និងឆ្មាំសន្តិសុខខ័ណ្ឌដូនពេញ បានបំបែកក្បួនបាតុកម្មពីដំបូងយ៉ាងហិង្សា។ បន្ទាប់មក នៅពេលស្ត្រីមួយចំនួនបានមកប្រមូលផ្ដុំគ្នាក្រោមដើមឈើ ដើម្បីច្រៀងចម្រៀងអំពីសិទ្ធិដីធ្លី អាជ្ញាធរបានឡោមព័ទ្ធក្រុមស្ត្រីនោះ ធ្វើការបំបែកការប្រមូលផ្ដុំ និងចាប់ខ្លួនពួកគេ។ ពួកអាជ្ញាធរបានឆែកឆេរ និងចាប់ខ្លួនស្ត្រីផ្សេងទៀត ដែលគេដឹងថាកំពុងតស៊ូមតិក្នុងនាមសហគមន៍ផងដែរ (ស្ត្រីខ្លះនៅក្បែរនោះ គឺគ្រាន់តែជាអ្នកឈរមើល)។ ស្ត្រីទាំងនោះត្រូវបានគេនាំយកទៅកាន់ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ ជាទីដែលពួកគេ

[១១០] "ការភ័យខ្លាចអមដោយដីកាកោះជុំវិញជម្លោះដីធ្លី" កាសែតភ្នំពេញប៉ុស្ដិ៍ ចេញផ្សាយថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១២: http://www.phnompenhpost.com/index.php/2012062056901/National-news/fear-accompanies-summons.html។

[១១១] ក្រុមការងារពិសេសសិទ្ធិលំនៅដ្ឋាន (HRTF) "ការថ្កោលទោសទៅលើការឆ្លើយតបដោយហិង្សា និងគ្មានយុត្តិកម្មចំពោះបាតុកម្ម ដោយអហិង្សា ដែលរៀបចំឡើងដោយអ្នករស់នៅសហគមន៍បឹងកក់" ថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១២: http://www.licadho-cambodia.org/pressrelease. php?perm=278។

*ទាក់ទងនឹងព្រះអង្គ លួន សូវ៉ាត ផងដែរ*

ត្រូវបានឃុំខ្លួន។

- នៅថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១២ បន្ទាប់ពីឃុំខ្លួនបាន ២ ថ្ងៃស្ត្រីទាំង ១៣ នាក់ ត្រូវបានចោទប្រកាន់ បើកសវនាការកាត់ទោសពីបទកាន់កាប់ខុសច្បាប់នូវអចលនទ្រព្យនីតិបុគ្គលសាធារណៈ និងប្រឆាំងអ្នករាជការសាធារណៈនៅថ្ងៃរសៀលមួយ។ ពួកគេត្រូវបានកាត់ទោសឲ្យជាប់ពន្ធនាគារម្នាក់ៗចំនួន ២ ឆ្នាំ ៥ ខែ បន្ទាប់ពីមានការជំនុំជម្រះមួយ ពោរពេញទៅដោយភាពមិនប្រក្រតី។[១១២] មេធាវីរបស់ពួកគេមិនត្រូវបានអនុញ្ញាតឲ្យពិនិត្យមើលសំណុំរឿង ឬភ័ស្តុតាងមិនត្រូវបានអនុញ្ញាតឲ្យដាក់បញ្ចូលសាក្សីដោះបន្ទុក ហើយសំណើរបស់ពួកគេក្នុងការសុំលើកសវនាការ (ដែលត្រូវបានធានាតាមច្បាប់ជាតិ ) ត្រូវចៅក្រមបដិសេធ។
- សៅ សារឿន និងលី ចាន់ណារី អ្នកទាំង ២ ជាតំណាងសហគមន៍បឹងកក់ ដែលមកកាន់តុលាការដើម្បីឆ្លើយបំភ្លឺជាសាក្សីដោះបន្ទុកសម្រាប់ស្ត្រីទាំងនោះ ត្រូវបានចាប់ខ្លួននៅក្រៅសាលាដំបូងរាជធានីភ្នំពេញ។ សវនាការបឋមមួយសម្រាប់អ្នកទាំងពីរបានចាប់ផ្តើមធ្វើភ្លាមៗ បន្ទាប់ពីបានប្រកាសសាលក្រមកាត់ទោសស្ត្រីទាំង ១៣ នាក់នោះ។ ពួកគេទាំង ២ នាក់ ត្រូវបានចោទប្រកាន់ពីបទកាន់កាប់ខុសច្បាប់នូវអចលនទ្រព្យនីតិបុគ្គលសាធារណៈ និងប្រឆាំងអ្នករាជការសាធារណៈផងដែរ។
- នៅខាងក្រៅតុលាការកម្លាំងនគរបាលចំរុះចំនួន ២០០ នាក់ បានព្យាយាមបំបែកក្រុមមនុស្សដោយហិង្សា ដែលបានមកប្រមូលផ្តុំគ្នាគាំទ្រស្ត្រីចំនួន ១៣ នាក់។
- ព្រះតេជគុណ លួន សូវ៉ាត ត្រូវបានមន្ត្រីសាសនា និងបុរសស្លៀកពាក់ស៊ីវិលគំរាម និងបង្ខំឲ្យចូលក្នុងរថយន្តមួយគ្រឿងដែលកំពុងរង់ចាំ ដោយមានជំនួយពីនគរបាល។ ព្រះអង្គត្រូវបានគេនាំព្រះកាយទៅកាន់វត្តបុទុមតី ជាទីដែលព្រះអង្គត្រូវបានសាកសួរជាច្រើនម៉ោង មុនពេលដោះលែង។
- នៅសវនាការសាលាឧទ្ធរណ៍ក្នុងខែមិថុនា ឆ្នាំ២០១២ សាលាឧទ្ធរណ៍បានសម្រេចដំកល់ទោសរបស់ស្ត្រីទាំងនោះ ប៉ុន្តែទោសដែលនៅសល់របស់ស្ត្រីម្នាក់ៗត្រូវព្យួរ។ អាស្រ័យហេតុនេះ ពួកគេត្រូវបានដោះលែង បន្ទាប់ពីពួកគេត្រូវបានឃុំខ្លួនក្នុងពន្ធនាគារអស់រយៈពេល ១ ខែ ៣ ថ្ងៃ។

---

[១១២] របាយការណ៍ឃ្លាំមើលសិទ្ធិមនុស្សអង្គការលីកាដូ ដែលមិនត្រូវបានបោះពុម្ពផ្សាយ: PP058IAD12។ សូមមើលផងដែរ: សេចក្តីប្រកាសព័ត៌មានអង្គការលីកាដូ "អង្គការមិនមែនរដ្ឋាភិបាលថ្កោលទោសការកាត់ទោសគ្មានមូលដ្ឋាន និងអំពើហិង្សាទៅលើអ្នកការពារសិទ្ធិមនុស្សកម្ពុជា" ថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១២: http://www.licadho-cambodia.org/pressrelease.php?perm=279។ សូមមើលផងដែរ: ខ្សែវីដេអូអង្គការលីកាដូ "ការចាប់ព្រះកាយព្រះអង្គ លួន សូវ៉ាត ទាំងបង្ខំនៅពេលកំពុងគាំទ្រសកម្មជនដីធ្លីចំនួន ១៣ នាក់ ដែលត្រូវបានឃុំខ្លួន" ថ្ងៃទី ២៤ ខែឧសភា ឆ្នាំ២០១២: http://www.licadho-cambodia.org/video.php?perm=32។

**ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១២**
**ករណីទី១១៥**

*[សូមមើលករណីទី៣៦ ៥១ ៦៧ ៦៩ ៧០ ៧៨ ៩១ ៩២ ៩៩ ១១៤ និង ១២២ ផងដែរ]*

## នគរបាលវាយដំអ្នកតវ៉ាសហគមន៍បឹងកក់ ស្ត្រីមានគតិម្នាក់ ត្រូវរលូតកូន [១១៣]

*រាជធានីភ្នំពេញ*

- ប៉ូវ ស្រីស្រស់ ជាបងប្អូនស្រីរបស់ ប៉ូវ សោភា គឺជាសកម្មជនម្នាក់ក្នុងចំណោមសកម្មជនសហគមន៍បឹងកក់ ១៣ នាក់ ដែលត្រូវបានកាត់ទោសបានទទួលរងនូវការរលូតកូន ក្រោយពីគាត់ត្រូវបានមន្ត្រីនគរបាលម្នាក់ទាត់។ មន្ត្រីនគរបាលនោះ គឺជាមន្ត្រីម្នាក់ក្នុងចំណោមមន្ត្រីជាច្រើន ដែលត្រូវបានដាក់ពង្រាយដើម្បីរារាំងអ្នកគាំទ្រមិនឲ្យចូលរួមការជំនុំជម្រះក្តី ចំពោះសកម្មជនសហគមន៍បឹងកក់ ១៣ នាក់ នៅសាលាឧទ្ធរណ៍។
- អ្នកគាំទ្រចំនួនប្រហែល ៥០០ នាក់ បានមកប្រមូលផ្តុំគ្នាដើម្បីចូលរួមសវនាការនៅសាលាឧទ្ធរណ៍ ប៉ុន្តែពួកគេត្រូវបាននគរបាលមួយចំនួន ធ្វើការរាំងខ្ទប់នៅមុំមាត់ទន្លេរាជធានីភ្នំពេញ នៅចម្ងាយតែប៉ុន្មានរយម៉ែត្រពីបន្ទប់សវនាការ។ នគរបាលបានប្រើហិង្សានៅពេលកុមារមួយក្រុមព្យាយាមដើរកាត់ខ្សែត្រៀមនគរបាល ដើម្បីចូលរួមសវនាការ។
- ប៉ូវ ស្រីស្រស់ ត្រូវបានគេវាយដំរហូតដល់គាត់សន្លប់បាត់ស្មារតី។ គេនាំយកគាត់ទៅមន្ទីរពេទ្យ ជាទីដែលគ្រូពេទ្យបានបញ្ជាក់ថា គាត់ទទួលរងការរលូតកូន។

**ថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០១២**
**ករណីទី១១៦**

## នគរបាលរាំងការដើរដង្ហែក្បួនរបស់សហជីព [១១៤]

*ខេត្តកណ្តាល*

- កម្មករចំនួនប្រហែល ៤,០០០ នាក់ មកពីរោងចក្រនានា ដែលផ្គត់ផ្គង់ Levi's និងGap ត្រូវបានរាំងខ្ទប់ដោយនគរបាល ក្រោយពីពួកគេបានព្យាយាមដើរដង្ហែក្បួនពីខេត្តកណ្តាលទៅកាន់ក្រសួងការងារ ការិយាល័យខុទ្ទការល័យនាយករដ្ឋមន្ត្រី ហ៊ុន សែន ស្ថានទូតអាមេរិក និងទីស្នាក់ការសហគមន៍អឺរ៉ុបនៅរាជធានីភ្នំពេញ។
- នគរបាល និងមន្ត្រីក្រសួងការងារ បានរាំងការដើរដង្ហែក្បួន បន្ទាប់ពីបានដើរទៅមុខអស់រយៈពេល ៩០ នាទី។ នៅអំឡុងពេលប៉ះទង្គិចគ្នានោះ កម្មករជាច្រើនបានទទួលរងរបួសបន្តិចបន្តួច។

---

[១១៣] យុត សុភចរិយា និងប៊ុត រស្មីគង្គា "យុទ្ធវិធីនគរបាលប្រឆាំងកូដកម្មកម្ពុជា មានការយកចិត្តទុកដាក់ពីសាធារណៈជន" កាសែតភ្នំពេញប៉ុស្ត៍ផ្សាយថ្ងៃទី១ ខែសីហា ឆ្នាំ២០១២: http://www.phnompenhpost.com/index.php/ 2012080157741/National-news/cambodian-riot-polices-tactics-in-spotlight.html។

[១១៤] មុំ គន្ធា "ការប៉ះទង្គិចគ្នារាំងការដើរដង្ហែក្បួនរបស់សហជីព" កាសែតភ្នំពេញប៉ុស្ត៍ចេញផ្សាយថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០១២: http://www .phnompenhpost.com/index.php/2012070657253/National-news/clash-thwarts-unions-march.html។

- កម្មករទាំងនោះ ធ្វើការឲ្យរោងចក្រទាំងឡាយ ដែលជាកម្មសិទ្ធិរបស់សហគ្រាស តៃ យ៉ាង (Tai Yang)។ ពួកគេបានធ្វើកូដកម្មចាប់តាំងពីថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១២ ហើយទាមទារប្រាក់ធ្វើដំណើរ ប្រាក់ស្នាក់នៅ ប្រាក់ការងារ និងប្រាក់មាតុភាព។

ថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១២
ករណីទី១១៧

**នគរបាលបានវាយតំណាងសហជីពយ៉ាងឃោរឃៅ ក្រោយពី មានការចាប់ខ្លួន**[១១៥]

***រាជធានីភ្នំពេញ***

- តំណាងសហជីពសហព័ន្ធកម្ពុជាឈ្មោះ រ៉ុង បញ្ញា ត្រូវបានគេវាយដំយ៉ាងឃោរឃៅ នឹងដំបងឆក់ចំក្បាល នៅអំឡុងពេលដើរដង្ហែក្បួនទាមទារសិទ្ធិការងារនៅរាជធានីភ្នំពេញ។ លោក រ៉ុង បញ្ញា បានដើរដង្ហែក្បួនជាមួយកម្មករកាត់ដេរចំនួន ១០ នាក់ចេញពីទីលានសេរីភាពតាមរាជធានីភ្នំពេញ ដើម្បីដាក់ញត្តិជូននាយករដ្ឋមន្ត្រីនៅឯភូមិគ្រឹះរបស់គាត់។ បន្ទាប់ពីបានប្រគល់ញត្តិទៅឲ្យតំណាងខុទ្ទកាល័យ ក្រុមមនុស្សបានអង្គុយក្នុងសួនសាធារណៈនៅជាប់នឹងវត្តបុទុមតី នៅពេលមន្ត្រីនគរបាលអន្តរាគមន៍រាជធានី និងនគរបាលខ័ណ្ឌដូនពេញចំនួន ៦០ នាក់ បានមកកាន់ពួកគេ ហើយប្រាប់ឲ្យពួកគេចាកចេញពីទីនោះ។ ក្រោយពីក្រុមមនុស្សសុំឲ្យទុកពេលសំរាកសិន នគរបាលក៏ចាប់ផ្ដើមវាយប្រហារលើរាងកាយរបស់ពួកគេតែម្ដង។ ថ្វីបើគាត់បានទទួលរងរបួសយ៉ាងធ្ងន់ធ្ងរក៏ដោយ ក៏លោក រ៉ុង បញ្ញា ទីបំផុតត្រូវបានគេដឹកចេញតាមឡាននគរបាល ហើយនឹងត្រូវឃុំខ្លួនអស់រយៈពេល ៤៨ ម៉ោង។ គាត់ត្រូវបានគេបង្ខំឲ្យផ្ដិតមេដៃលើចម្លើយសារភាព ដោយឲ្យសុំទោសចំពោះការញុះញង់ឲ្យមានជម្លោះរវាងអ្នកតវ៉ា និងនគរបាល។

ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១២
ករណីទី១១៨

*[សូមមើលករណីទី១១៩ ផងដែរ]*

**ការចាប់ខ្លួន និងការឃុំខ្លួនម្ចាស់វិទ្យុសំបុកឃ្មុំ**[១១៦]

***រាជធានីភ្នំពេញ***

- លោក ម៉ម សូណង់ដូ ជាម្ចាស់ស្ថានីយវិទ្យុសំបុកឃ្មុំឯករាជ្យ និងជាអ្នកបង្កើតអង្គការសិទ្ធិមនុស្សមិនមែនរដ្ឋាភិបាលមួយ ហៅថាសមាគមន៍អ្នកប្រជាធិបតេយ្យ ត្រូវបានចាប់ខ្លួនដោយនគរបាល តែប៉ុន្មានថ្ងៃបន្ទាប់ពី វិលត្រឡប់មកដល់ប្រទេសកម្ពុជា

---

[១១៥] សេចក្ដីប្រកាសព័ត៌មានអង្គការលីកាដូ "ការវាយដំទៅលើសហជីពជាំភ្នែកសម្រាប់កម្ពុជា នៅអំឡុងពេលកិច្ចប្រជុំកំពូលអាស៊ាន" ថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១២: http://www.licadho-cambodia.org/pressrelease.php?perm=286។ សូលមើលផងដែរ: ខ្សែវីដេអូអង្គការលីកាដូ "កម្មករសហជីពត្រូវបានវាយដំនៅអំឡុងពេលកិច្ចប្រជុំកំពូលអាស៊ាននៅរាជធានីកម្ពុជា" ថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១២: http://www.licadho-cambodia.org/video.php?perm=34។

[១១៦] សេចក្ដីប្រកាសព័តិមានអង្គការលីកាដូ "សុំឲ្យដោះលែងលោក ម៉ម សូណង់ដូ ម្ចាស់ស្ថានីយវិទ្យុឯករាជ្យ ដែលមានវ័យចំណាស់បំផុត" ថ្ងៃទី ១៦ ខែកក្កដា ឆ្នាំ២០១២: http://www.licadho-cambodia.org/pressrelease.php?perm=287។ សូមមើលផងដែរ: David Boyle" ការចាក់ផ្សាយព័ត៌មានតាមវិទ្យុលោក ម៉ម សូណង់ដូ បានកំណត់នាយករដ្ឋមន្ត្រីជាគោលដៅ" កាសែតភ្នំពេញប៉ុស្តិ៍ ចេញផ្សាយនៅថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១២: http://www.phnompenhpost.com/index.php/2012071857483/National-news/sonando-broadcast-targeted-pm.html ។

វិញ។ នាយករដ្ឋមន្ត្រីបានអំពាវនាវឲ្យចាប់ខ្លួនលោក ម៉ម សូណង់ដូ តែប៉ុន្មានសប្តាហ៍មុននេះ។

- លោក ម៉ម សូណង់ដូ ត្រូវបានចោទប្រកាន់ច្រើនបទល្មើសទាក់ទងនឹងការញុះញង់ឲ្យមានមានចលនាបះបោរទាក់ទងនឹងអ្វីដែលហៅថាចលនាបំបែករដ្ឋ នៅភូមិប្រម៉ា ខេត្តក្រចេះ។ នៅក្នុងខែឧសភា ឆ្នាំ២០១២ កងកម្លាំងប្រដាប់អាវុធរាជរដ្ឋាភិបាលបានធ្វើការបង្ក្រាបទៅលើភូមិ និងបណ្តេញប្រជាពលរដ្ឋរាប់រយគ្រួសារ ក្មេងស្រីម្នាក់អាយុ ១៤ ឆ្នាំម្នាក់ ត្រូវបានបាញ់ស្លាប់ក្នុងប្រតិបត្តិការណ៍នោះ [សូមមើលករណីទី ១០៦]។ គ្រួសារប្រជាពលរដ្ឋទាំងនោះ កំពុងមានការពាក់ព័ន្ធក្នុងជម្លោះដីធ្លីជាមួយក្រុមហ៊ុន Casotim ជាក្រុមហ៊ុនរុស្ស៊ី [សូមមើលករណីទី១០៦]។ អាជ្ញាធរបានអះអាងបន្ទាប់ពីមានហេតុការណ៍នេះថា អ្នកភូមិកំពុងព្យាយាមបំបែករដ្ឋ ហើយនឹងព្យាយាមភ្ជាប់លោក ម៉ម សូណង់ដូ ជាមួយករណីនេះក្នុងខែកក្កដា។
- នៅថ្ងៃមុនពេលនាយករដ្ឋមន្ត្រី ហ៊ុន សែន អំពាវនាវជាសារធារណៈឲ្យចាប់ខ្លួន លោក ម៉ម សូណង់ដូ នាយកស្ថានីយវិទ្យុសំបុកឃ្មុំរូបនេះ បានចាក់ផ្សាយព័ត៌មានតាមវិទ្យុពីទីក្រុង The Hague ជាទីដែលមេធាវីរបស់ចលនាអំណាចប្រជាពលរដ្ឋខ្មែរបានដាក់ពាក្យបណ្តឹងទៅកាន់តុលាការព្រហ្មទណ្ឌអន្តរជាតិ ដោយចោទប្រកាន់មន្ត្រីរាជរដ្ឋាភិបាលកម្ពុជាពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិទាក់ទងនឹងជម្លោះដីធ្លី។
- នៅថ្ងៃទី២ ខែកក្កដា ឆ្នាំ២០១២ លោកចៅក្រម ចុក ងួន ចៅក្រមស៊ើបសួរសាលាដំបូងខេត្តក្រចេះ បានចេញដីកាចាប់ខ្លួនលោក ម៉ម សូណង់ដូ ដោយចោទប្រកាន់គាត់ពីបទចូលរួមក្នុងចលនាបះបោរ ដោយញុះញង់ប្រជាពលរដ្ឋឲ្យកាន់អាវុធប្រឆាំងអាជ្ញាធររដ្ឋ និងប្រឆាំងអ្នករាជការសាធារណៈ។
- លោក ម៉ម សូណង់ដូ ដែលបានចេញទៅប្រទេសក្រៅ ហើយវិលត្រឡប់មករាជធានីភ្នំពេញវិញនៅថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១២ នៅពេលកិច្ចប្រជុំកំពូលអាស៊ានកំពុងប្រព្រឹត្តទៅ។ គាត់ត្រូវបានចាប់ខ្លួន ៣ ថ្ងៃ ក្រោយមកតែ ២៤ ម៉ោងប៉ុណ្ណោះ បន្ទាប់ពីរដ្ឋមន្ត្រីការបរទេស និងអ្នកការទូតសំខាន់ៗមួយចំនួន រាប់ទាំងរដ្ឋមន្ត្រីការបរទេសអាមេរិកលោកស្រី ហ៊ីលឡារី គ្លិនតុន (Hillary Clinton) ផងបានចាកចេញពីរាជធានីភ្នំពេញ។
- បន្ទាប់ពីជំនុំជម្រះអស់រយៈពេល ៤ ថ្ងៃចាប់ពីថ្ងៃទី១១ - ១៤ ខែកញ្ញា ឆ្នាំ២០១២ លោក ម៉ម សូណង់ដូ ត្រូវបានកាត់ទោស និងផ្តន្ទាទោសឲ្យជាប់ពន្ធនាគារចំនួន ២០ ឆ្នាំ។ សាលក្រមនេះ បណ្តាលឲ្យមានការថ្កោលទោសយ៉ាងច្រើន ទាំងនៅក្នុង

ប្រទេសកម្ពុជា និងនៅក្រៅប្រទេស។ ពុំមានភ័ស្តុតាង ឬការពាក់ព័ន្ធរបស់លោក ម៉ម សូណង់ដូ ជាមួយចលនាបំបែករដ្ឋគួរឲ្យជឿជាក់ត្រូវបានលើកយកមកបង្ហាញនៅពេលកំពុងជំនុំជម្រះក្តីឡើយ។

**ថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១២**
**ករណីទី១១៩**
***[សូមមើលករណីទី១១៨ ផងដែរ]***

## នគរបាលបង្ក្រាបអ្នកគាំទ្រម្ចាស់វិទ្យុ ដែលត្រូវឃុំខ្លួន [១១៧]

***ខេត្តកណ្តាល តាកែវ ព្រៃវែង និងខេត្តក្រចេះ***

- អ្នកគាំទ្រលោក ម៉ម សូណង់ដូ ជាម្ចាស់វិទ្យុសំបុកឃ្មុំត្រូវបានរារាំងមិនឲ្យដើរប្រមូលស្នាមមេដៃនៅក្នុងខេត្តចំនួន ៤ គឺខេត្តកណ្តាល តាកែវ ព្រៃវែង និងខេត្តក្រចេះ សម្រាប់ធ្វើញត្តិ ដើម្បីអំពាវនាវឲ្យមានការដោះលែងលោក ម៉ម សូណង់ដូ។
- អាជ្ញាធរបានរារាំងអ្នកគាំទ្រទាំងនោះ ដោយអះអាងថាពួកគេកំពុងរំខានដល់សណ្តាប់ធ្នាប់សាធារណៈ។ អ៊ិន ឈានហោន ជាបុគ្គលិកសមាគមន៍អ្នកប្រជាធិបតេយ្យមួយរូបត្រូវបានចាប់ខ្លួនក្នុងឃុំកំពង់គ ខេត្តក្រចេះ បន្ទាប់ពីអាជ្ញាធរបានប្រាប់គាត់ថា គាត់មិនបានសុំកា អនុញ្ញាតឲ្យដើរប្រមូលស្នាមមេដៃឡើយ។ នៅក្រោមច្បាប់កម្ពុជាក៏គ្មានលក្ខខ័ណ្ឌតម្រូវដូច្នេះដែរ។
- អ្នកគាំទ្រកំពុងព្យាយាមដើរប្រមូលស្នាមមេដៃ ដើម្បីធ្វើញត្តិដាក់ជូនទីភ្នាក់ងាររដ្ឋាភិបាល និងស្ថានទូតបរទេសចំនួន ៩ នៅថ្ងៃទី៣០ ខែ កក្កដា ឆ្នាំ២០១២។

**ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១២**
**ករណីទី១២០**

## អាជ្ញាធររារាំងវគ្គបណ្តុះបណ្តាលសិទ្ធិដីធ្លី [១១៨]

***ខេត្តរតនៈគិរី***

- វគ្គបណ្តុះបណ្តាលមួយស្តីពីសិទ្ធិដីធ្លី ដែលសហការរៀបចំដោយមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា និងអង្គការអាដហុក ត្រូវបានអាជ្ញាធរ និងមន្ត្រីនគរបាលរំខានរារាំងមិនឲ្យធ្វើ។
- លោកណាប់ ប៊ុនហេង ជាអភិបាលខេត្តរង បានព្យាយាមលើកយកសកម្មភាពនគរបាលមកសំអាងដោយនិយាយថា អ្នករៀបចំខកខានមិនបានជូនដំណឹងដល់អាជ្ញាធរ។ ទោះបីយ៉ាងណាក៏ដោយតាមមាត្រា ៣ នៃច្បាប់ស្តីពីការធ្វើបាតុកម្មដោយអហិង្សា អ្នករៀបចំត្រូវបានដាក់ឲ្យរួចផុតពីលក្ខខណ្ឌជូនដំណឹងសម្រាប់សកម្មភាព

[១១៧] May Titthara "នគរបាលបង្ក្រាបអ្នកគាំទ្រលោក ម៉ម សូណង់ដូ" កាសែតភ្នំពេញប៉ុស្ដិ៍" ចេញផ្សាយថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១២។

[១១៨] កាសែត The Cambodia Daily ចេញផ្សាយថ្ងៃទី២៧-២៨ ខែកក្កដា ឆ្នាំ២០១២។ សូមមើលផងដែរ: ខ្សែវីដេអូមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា" នៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១២ អាជ្ញាធរ និងមន្ត្រីនគរបាលបានរារាំងវគ្គបណ្តុះបណ្តាលមួយ ដែលសហការរៀបចំដោយមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា និងអង្គការអាដហុក" ថ្ងៃទី២ ខែសីហា ឆ្នាំ២០១២: http://www.youtube.com/watch?v=e37f00WTd24។

ផ្សព្វផ្សាយអប់រំទាំងអស់ ដើម្បីផលប្រយោជន៍សង្គម។ ម្យ៉ាងវិញទៀតវគ្គបណ្ដុះបណ្ដាលនេះ ត្រូវបានរៀបចំឡើងនៅក្នុងបរិវេណផ្ទះឯកជនមួយ។

**ថ្ងៃទី៩ ខែសីហា ឆ្នាំ២០១២**
**ករណីទី១២១**

## ការបំភិតបំភ័យតាមផ្លូវតុលាការទៅលើអ្នកស៊ើបអង្កេតសិទ្ធិមនុស្សជាន់ខ្ពស់ [១១៩]

*រាជធានីភ្នំពេញ*

- លោក ចាន់ សុវ៉េត ជាអ្នកស៊ើបអង្កេតជាន់ខ្ពស់ និងជាអនុប្រធានផ្នែកឃ្លាំមើលសិទ្ធិមនុស្សរបស់អង្គការអាដហុក ត្រូវបានសាលាដំបូងរាជធានីភ្នំពេញកោះហៅឲ្យចូលខ្លួននៅថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១២។ យោងតាមដីកាកោះលោក ចាន់ សុវ៉េត ត្រូវបានសង្ស័យពីបទរំលោភបំពានលើមាត្រា ៥៤៤ នៃក្រមព្រហ្មទណ្ឌ ដែលហាមផ្ដល់ជំនួយឲ្យចារី សហចារី អ្នកផ្ដើមគំនិត ឬអ្នកសមគំនិតក្នុងបទឧក្រិដ្ឋ។ ប្រសិនបើរកឃើញពិរុទ្ធភាពពីការចោទប្រកាន់ទាំងនេះ លោក ចាន់ សុវ៉េត អាចប្រឈមនឹងការកាត់ទោសឲ្យជាប់ពន្ធនាគាររហូតដល់ ៣ ឆ្នាំ និងពិន័យជាប្រាក់ចាប់ពី ២ លានរៀលដល់ ៦ លានរៀល។
- រាជរដ្ឋាភិបាលមិនបានបញ្ចេញឲ្យដឹងនូវសេចក្ដីពិស្ដារពិតប្រាកដ អំពីបទចោទប្រកាន់ទេ ប៉ុន្តែដីកាកោះទំនងជាជាប់ពាក់ព័ន្ធទៅនឹងដីជម្លោះ/គម្រោងបំបែករដ្ឋក្នុងខេត្តក្រចេះ [សូមមើលករណីទី១០៦]។
- នៅថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១២ លោក ផៃ វីរៈ ជាចៅក្រមសាលាដំបូងរាជធានីភ្នំពេញបានយល់ព្រមលើសំណើពីលោក សំ សុគង់ ជាមេធាវីការពារលោក ចាន់ សុវ៉េត ដើម្បីលើកពេលសវនាការ។ សវនាការពីដំបូងត្រូវបានលើកពេលទៅថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១២ ហើយចាប់ពីពេលនោះមក ក៏ត្រូវបានលើកពេលថែមទៀតដោយគ្មានពេលកំណត់។

**ថ្ងៃទី៤ ខែកញ្ញា ឆ្នាំ២០១២**
**ករណីទី១២២**

## សកម្មជនដីធ្លីសហគមន៍បឹងកក់ ត្រូវបានចាប់ខ្លួនពីបទសង្ស័យ [១២០]

*រាជធានីភ្នំពេញ*

- អ្នកស្រី យ៉ោម បុប្ផា ជាតំណាងសហគមន៍បឹងកក់ ដែលនិយាយឥតសំចៃមាត់ត្រូវបានចាប់ខ្លួន និងឃុំខ្លួននៅពន្ធនាគារព្រៃស (ម២) បន្ទាប់ពីអាជ្ញាធរអះអាងថា គាត់

[១១៩] សេចក្ដីប្រកាសព័ត៌មានអង្គការលីកាដូ "ការចោទប្រកាន់ទៅលើបុគ្គលិកអង្គការអាដហុក កត់សម្គាល់នូវការគំរាមកំហែងយ៉ាងធ្ងន់ធ្ងរបំផុតដល់ការងារខាងសិទ្ធិមនុស្សនៅកម្ពុជាសម្រាប់ទសវត្សរ៍នេះ" ថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១២: http://www.licadho-cambodia.org/ pressrelease.php?perm=289។

[១២០] សេចក្ដីប្រកាសព័ត៌មានរួមអង្គការលីកាដូ "រយៈពេល ២ ថ្ងៃ ដីកាឃុំខ្លួនបណ្ដោះអាសន្នចំនួន ២ គ្មានយុត្តិកម្ម" ថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១២: http://www.licadho-cambodia.org/pressrelease.php?perm=290។

*[សូមមើលករណី ទី៣៦ ៥១ ៦៧ ៦៩ ៧០ ៧៨ ៩១ ៩២ ៩៩ ១១៤ និង១១៥ ផងដែរ]*

មានពាក់ព័ន្ធក្នុងការវាយដំទៅលើមនុស្សចំនួន ២ នាក់ ដែលសង្ស័យថាបានលួចកញ្ចក់ឡានរបស់អ្នកស្រី។

- អ្នកស្រីត្រូវបានចោទប្រកាន់ពីបទប្រព្រឹត្តអំពើហិង្សាដោយចេតនា មានស្ថានទម្ងន់ទោសតាមមាត្រា ២១៨ នៃក្រមព្រហ្មទណ្ឌ។
- សាក្សីមួយចំនួនបានប្រាប់អ្នកស៊ើបអង្កេតសង្គមស៊ីវិលថា បុគ្គលដែលត្រូវបានគេវាយនោះ គឺត្រូវសង្ស័យថា បានលួចកញ្ចក់ឡានជាច្រើនលើក។ អ្នកស្រីបានប្ដឹងនគរបាលមូលដ្ឋានជាច្រើនដង ប៉ុន្តែមិនបានចាត់វិធានការឡើយ។ នៅថ្ងៃទី៧ ខែសីហា ឆ្នាំ២០១២ ជនសង្ស័យបានឈរនៅក្បែរឡានរបស់គាត់។ ពេលនោះ អ្នកភូមិមូលដ្ឋានបានកត់សម្គាល់ ហើយក៏បានវាយដំទៅលើជនសង្ស័យនោះតែម្ដង។
- អ្នកស្រីមិនដែលត្រូវបានអាជ្ញាធរហៅមកសាកសួរ អំពីឧប្បត្តិហេតុនេះឡើយ ហើយដោយខុសប្លែកពីនីតិវិធីធម្មតា លោក ចៅក្រម តែ សំអាង ជាចៅក្រមសាលាដំបូងរាជធានីភ្នំពេញបានចេញដីកានាំខ្លួនអ្នកស្រី និងប្ដីរបស់អ្នកស្រី (នេះជាវិធានការមួយខុសពី ដីកាកោះ ហៅមកសាកសួរធម្មតា)។ ដីកានាំខ្លួនគឺ សមមូលទៅនឹងដីកាចាប់ខ្លួន ក្នុងនោះដីកានេះអនុញ្ញាតឲ្យមានការឃុំខ្លួនជា បន្ទាន់។ បន្ទាប់ពីធ្វើការសាកសួរបន្តិចបន្តួចរួចមក លោក តែ សំអាង ជាចៅក្រមស៊ើបសួរបានបញ្ជាឲ្យឃុំខ្លួន អ្នកស្រី ប៉ុន្តែដោះលែងប្ដីរបស់គាត់ដែលមិនមែនជាសកម្មជន។
- អ្នកស្រីមានពាក់ព័ន្ធក្នុងការចូលរួមក្នុងបាតុកម្មដោយអហិង្សាជា ច្រើនលើកចាប់តាំងពីក្រុមហ៊ុនសូកាគូ (Shukaku Inc.) បានផ្ដើមបូមខ្សាច់ចាក់បំពេញបឹងកក់ ដោយធ្វើការបណ្ដេញប្រជាពលរដ្ឋរាប់ពាន់គ្រួសារចេញពីផ្ទះសម្បែងរបស់ពួកគេ។ គាត់បានដឹកនាំការតវ៉ាជាច្រើនលើកផងដែរ សម្រាប់គាំទ្រក្រុមស្ត្រីសហគមន៍បឹងកក់ចំនួន ១៣ នាក់ ដែលត្រូវបានចាប់ខ្លួននៅថ្ងៃទី២២ ខែឧសភា និងត្រូវបានឃុំខ្លួនក្នុងពន្ធនាគារជាង ១ ខែកន្លងមកនេះ។

ថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០១២

ករណីទី១២៣

*[សូមមើលករណីទី១០២ និង១០៣ ផងដែរ]*

## សកម្មជនដីធ្លីសហគមន៍បុរីកីឡាត្រូវបានឃុំខ្លួន បន្ទាប់ពីធ្វើការទាមទារសិទ្ធិដីធ្លីឲ្យកូនប្រុស [១២១]

*រាជធានីភ្នំពេញ*

- នៅថ្ងៃបន្ទាប់ពីអ្នកស្រី យ៉ោម បុប្ផា ត្រូវបានចាប់ខ្លួនអាជ្ញាធរបានបញ្ជាឲ្យឃុំខ្លួនអ្នកស្រី ទឹម សាក់មុន្នី ដែលជាអ្នកតំណាងស្ត្រីម្នាក់ដ៏សំខាន់របស់គ្រួសារប្រជាពលរដ្ឋ ដែលត្រូវបានគេបណ្តេញចេញពីសហគមន៍បូរីកីឡា។ គាត់ត្រូវបានចោទប្រកាន់ពីបទធ្វើសេចក្តីប្រកាសដោយភូតកុហកតាមមាត្រា ៦៣៣ នៃក្រមព្រហ្មទណ្ឌ។ គាត់ត្រូវបានឃុំខ្លួនក្នុងពន្ធនាគារព្រៃស (CC2)។
- ក្រុមហ៊ុន Phanimex បានដាក់ពាក្យបណ្តឹងប្រឆាំងនឹងអ្នកស្រី ទឹម សាក់មុន្នី ដែលម្ចាស់ក្រុមហ៊ុននោះ គឺលោកស្រី ស៊ុយ សុផាន។ ក្រុមហ៊ុន Phanimex បានទទួលដីសហគមន៍បូរីកីឡាជាថ្នូរនឹងការសន្យាមួយ ដើម្បីសាងសង់អគារផ្ទះល្វែងចំនួន ១០ អគារសម្រាប់អ្នកភូមិទាំងនេះរស់នៅ។ ទោះជាយ៉ាងណាក៏ដោយក្រុមហ៊ុននេះ បានសម្រេចសាងសង់អគារផ្ទះល្វែងតែចំនួន ៨ អគារប៉ុណ្ណោះ ដែលនាំឲ្យបន្តមានជម្លោះដីធ្លី។
- អាជ្ញាធរអះអាងថា ទឹម សាក់មុន្នី បានធ្វើសេចក្តីប្រកាសដោយភូតកុហកក្នុងគោលបំណងទទួលបានផ្ទះមួយល្វែងសម្រាប់កូនប្រុសរបស់គាត់ ដែលពិការនឹងមានអាយុ៤៩ឆ្នាំ ដែលជាអ្នករស់នៅសហគមន៍បុរីកីឡា។ កូនប្រុសរបស់គាត់ ដែលជាពោះម៉ាយ និងជាអតីតទាហាន ទទួលរងនូវជម្ងឺស្លាប់សរីរាង្គមួយផ្នែក ដែលមិនអាចនិយាយបាន។
- មាត្រា ៦៣៣ ហាមផ្តល់សេចក្តីប្រកាស ដោយភូតកុហកដល់រាជការសាធារណៈ ដើម្បីទទួលបានវិភាជន៍ ការបើកប្រាក់ ឬអត្ថប្រយោជន៍ដោយខុសច្បាប់។ បទល្មើសនេះអាចមានទោសជាប់ពន្ធនាគារពី ៦ ខែទៅ ២ ឆ្នាំ និងពិន័យជាប្រាក់ពី ១ លានរៀលទៅ ៤ លានរៀល (២៥០ ដុល្លារអាមេរិក - ១,០០០ ដុល្លាអាមេរិក។
- ជាពិសេសការប្រើការឃុំខ្លួនបណ្តោះអាសន្នក្នុងករណីអ្នកស្រី ទឹម សាក់មុន្នី នេះ មិនមានមូលហេតុល្អសោះ ដោយសារតែក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាចែងថា ការឃុំខ្លួនបណ្តោះអាសន្ន អាចត្រូវបានបង្គាប់តែក្នុងករណីពិសេសតែប៉ុណ្ណោះ។ ច្បាប់នេះចែងផងដែរថា ការឃុំខ្លួនបណ្តោះអាសន្នអាចត្រូវបានបង្គាប់ កាលណាការឃុំខ្លួន

---

[១២១] យោងឯកសារដូចគ្នានឹងជើងទំព័រទី១២០។

បណ្តោះអាសន្ននេះជាការចាំបាច់ ដើម្បីបញ្ចប់បទល្មើស ឬបង្ការបទល្មើសកុំឲ្យកើតជាថ្មី ដើម្បីរារាំងកុំឲ្យមានការគាបសង្កត់លើសាក្សី ឬជនរងគ្រោះ ឬដើម្បីរារាំងកុំឲ្យមានការត្រូវរ៉ូវគ្នារវាងជនត្រូវចោទ និងអ្នកសមគំនិត ដើម្បីរក្សាភ័ស្តុតាង ឬតម្រុយជាសម្ភារៈដើម្បីធានារក្សាសណ្តាប់ធ្នាប់សាធារណៈកុំឲ្យមានការច្របូកច្របល់ ដែលបណ្តាលមកពីបទល្មើស ឬដើម្បីធានារក្សាជនត្រូវចោទទុកជូនតុលាការចាត់ការតាមនីតិវិធី និងឬដើម្បីការពារសន្តិសុខឲ្យជនត្រូវចោទ។ ពុំមានករណីចាំបាច់ណាមួយក្នុងចំណោមករណីចាំបាច់ទាំងនោះនៅក្នុងករណី អ្នកស្រី ទឹម សាក់មុន្នី នេះឡើយ។

**ថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១២**
**ករណីទី១២៤**

## អ្នកសារព័ត៌មានដែលទម្លាយរឿងអាស្រូវ ត្រូវបានរកឃើញត្រូវគេធ្វើឃាត[១២២]

***ខេត្តរតនៈគីរី***

- លោក ហង្ស សេរីឧត្តម ជាអ្នកសារព័ត៌មានម្នាក់ដែលបញ្ចេញឲ្យដឹងអំពីអាជីវកម្មកាប់ឈើខុសច្បាប់នៅកម្ពុជាត្រូវបានរកឃើញថា ត្រូវគេសម្លាប់ក្នុងខេត្តរតនៈគិរី។ សាកសពរបស់គាត់ត្រូវបានរកឃើញក្នុងឃ្លុបផ្នែកខាងក្រោយរថយន្តរបស់គាត់។ គាត់ធ្វើការឲ្យកាសែតវរៈជនខ្មែរ។
- អ្នកស៊ើបអង្កេតអង្គការអាដហុកបានរាយការណ៍ថា ហង្ស សេរីឧត្តម ត្រូវបានគេវាយនឹងដំបង ហើយបន្សល់ទុកនូវស្នាមជាំនៅលើក្បាល និងផ្នែកផ្សេងៗនៃដងខ្លួនរបស់គាត់។ ប្រភពផ្សេងៗទៀតបានបញ្ជាក់ថា គាត់ត្រូវបានវាយនឹងពូថៅ។
- ក្នុងអត្ថបទចុងក្រោយរបស់គាត់មុននឹងទទួលមរណៈភាព លោក ហង្ស សេរីឧត្តម បានចោទប្រកាន់កូនប្រុសមេបញ្ជាការកងរាជអាវុធហត្ថ ពីបទជួញដូរឈើក្នុងរថយន្តកងរាជអាវុធហត្ថ ហើយនឹងពីបទជំរិតទារប្រាក់ពីប្រជាពលរដ្ឋ ដែលដឹកឈើស្របច្បាប់។

---

[១២២] "អ្នកសារព័ត៌មានត្រូវបានរកឃើញថាគេសម្លាប់" វិទ្យុអាស៊ីសេរីចាក់ផ្សាយថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១២: http://www.rfa.org/english /news/cambodia/journalist-09122012130944.html ហើយនឹង Charlie Wells "អ្នកសារព័ត៌មានខ្មែរ ដែលបង្ក្រាបអាជីវកម្មកាប់ឈើខុសច្បាប់ត្រូវបានរកឃើញត្រូវថា គេសម្លាប់" ព័ត៌មានប្រចាំថ្ងៃកាសែត New York ចេញផ្សាយថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១២: http://articles .nydailynews.com/2012-09-12/news/33794980_1_cambodian-center-cambodian-journalist-ratanakiri។

**ថ្ងៃទី១ ខែតុលា ឆ្នាំ២០១២**
**ករណីទី១២៥**

*[សូមមើលករណីទី១ ៩០ និង៩៤ ផងដែរ]*

**អ្នកសារព័ត៌មាន និងបុគ្គលិកអង្គការមិនមែនរដ្ឋាភិបាលសិទ្ធិមនុស្ស ត្រូវបានកោះហៅក្នុងករណីដីធ្លី** [១២៣]

***ខេត្តរតនគីរី***

- បុគ្គលិកអង្គការមិនមែនរដ្ឋាភិបាលខាងសិទ្ធិមនុស្សចំនួន ៣ នាក់ និងអ្នកធ្វើសេចក្ដីរាយការណ៍វិទ្យុអាស៊ីសេរីម្នាក់ ត្រូវបានព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តរតនៈគីរីកោះហៅឲ្យចូលខ្លួន ដើម្បីសាកសួរអំពីការចោទប្រកាន់ពីបទញុះញង់ឲ្យប្រព្រឹត្តបទល្មើស។
- ការចោទប្រកាន់ទាំងនេះ ត្រូវបានធ្វើឡើងផ្អែកលើពាក្យបណ្ដឹងមួយ ដែលប្ដឹងដោយលោក គិត ចិម ជាមេឃុំគណៈបក្សប្រជាជន។ អាជ្ញាធរចោទប្រកាន់ថាបុរសទាំងនោះបានញុះញង់សមាជិកជនជាតិដើមភាគតិចទំពួន ដែលជាប់ពាក់ព័ន្ធក្នុងជម្លោះដីធ្លីជាមួយក្រុមហ៊ុន DM Group។ ការតវ៉ាដោយអ្នកភូមិបានក្លាយជាអំពើហិង្សាក្នុងឆ្នាំ២០០៩។
- អ្នកដែលត្រូវបានកោះហៅមានឈ្មោះ លោក សុខ រដ្ឋា ជាអ្នកធ្វើសេចក្ដីរាយការណ៍វិទ្យុអាស៊ីសេរី (គេស្គាល់ថា រដ្ឋា វិសាល) លោក ប៉ែន ប៊ុនណា ជាបុគ្គលិកអង្គការអាដហុក និងលោក ឆាយ ធី ជាបុគ្គលិកអង្គការអាដហុកផងដែរ ព្រមទាំងលោក អ៊ូ វីរៈ ជាប្រធានមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា។
- ជម្លោះដីធ្លីនេះ ពាក់ព័ន្ធនឹងដីទំហំ ២៦០ ហិកតា ហើយជាលទ្ធផលជម្លោះនេះ ត្រូវបានគេមើលឃើញជាការចោទប្រកាន់តាមផ្លូវច្បាប់ ដែលធ្វើឡើងប្រឆាំងនឹងតំណាងចំនួនយ៉ាងហោចណាស់ ១០ នាក់ របស់សហគមន៍ទាំងឡាយ ដែលបានទទួលរងផលប៉ះពាល់។

---

[១២៣] សេចក្ដីប្រកាសព័ត៌មានគណៈកម្មការសិទ្ធិមនុស្សអាស៊ាន/មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា "កម្ពុជា: អ្នកធ្វើការខាងសិទ្ធិមនុស្សចំនួន ៣ នាក់ និងអ្នកសារព័ត៌មានម្នាក់ ត្រូវបានសាលាដំបូងខេត្តរតនៈគិរីកោះហៅឲ្យចូលខ្លួនទាក់ទងនឹងការចោទប្រកាន់ពីបទញុះញង់" ថ្ងៃទី៣ ខែតុលា ឆ្នាំ២០១២: http://www.humanrights.asia/news/forwarded-news/AHRC-FPR-046-2012។

## ឧបសម្ព័ន្ធ៤: អ្នកការពារសិទ្ធិមនុស្ស ត្រូវបានឃុំខ្លួនក្នុងពន្ធនាគារ គិតមកត្រឹមថ្ងៃទី១ ខែធ្នូ ឆ្នាំ២០១២)

| | ឈ្មោះ នាមត្រកូល និងនាមខ្លួន | ភេទ | អាយុ | ថ្ងៃចាប់ខ្លួន(ច)& ថ្ងៃឃុំខ្លួន(ឃ) | បទចោទ | រយៈពេលជាប់ទោស | ឈ្មោះពន្ធនាគារ | ទីតាំងករណី | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | ភូមិ | ឃុំ | ស្រុក | ខេត្ត |
| ១<br>២<br>៣ | ង៉ា ម៉ក<br>គង់ សុខហឿប<br>ទូច វ៉ាន់ឌី | ប<br>ប<br>ស | ៤៩<br>៥២<br>៥០ | ៩.៨.២០១០(ច&ឃ)<br>៨.៨.២០១១(ច&ឃ)<br>៨.៨.២០១១(ច&ឃ) | ប្លន់ និងបំផ្លិចបំផ្លាញទ្រព្យសម្បត្តិឯកជន (មាត្រា ៦ នៃច្បាប់ស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ និងមាត្រា ៥២ នៃច្បាប់អ៊ុនតាក់) | ទោស ៥ ឆ្នាំ កំពុងជាប់បណ្ដឹងឧទ្ធរណ៍. | បាត់ដំបង | អន្លង់កន្ទួត | ដូនបា | គាស់ក្រឡ | បាត់ដំបង |
| ៤ | វ៉ាន់ សារឿន | ប | ៥៦ | ១៨.៧.២០០៩(ច)<br>២០.៧.២០០៩(ឃ) | (១) ប្លន់ និងឃាតកម្ម (មាត្រា ៦ នៃច្បាប់ស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ) (២) ប៉ុនប៉ងឃាតកម្ម (មាត្រា ៣១ នៃច្បាប់អ៊ុនតាក់) និង (៣) ក្លែងឯកសារសាធារណៈ(មាត្រា ៤៩ នៃច្បាប់អ៊ុនតាក់) | ជំនុំជម្រះបទចោទ ទី ១ នាំឲ្យលើកលែងចោទ ប្រកាន់នៅថ្ងៃទី ១៣ ខែកុម្ភៈ ឆ្នាំ ២០១១។ កាត់ឲ្យជាប់ | បន្ទាយមានជ័យ | រស្មីសាមគ្គី | និមិត្ត | ប៉ោយប៉ែត | បន្ទាយមានជ័យ |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | | | | | | ទោស ពន្ធនាគារ ៤ ឆ្នាំ ពីបទ ប៉ុន ប៉ង ឃាតកម្ម។ | | | | | |
| ៥ | ស សុង | ប | ៥៥ | ២៣.១១.២០០៧ (ច) ២៤.១១.២០០៧ (ឃ) | ប៉ុនប៉ងឃាតកម្ម និងរំលោភបំពាន ទ្រព្យសម្បត្តិឯកជន (មាត្រា ៣២ នៃ ច្បាប់អ៊ុនតាក់ និងមាត្រា ២៤៨ នៃច្បាប់ភូមិបាល)។ | កាត់ឲ្យជាប់ទោស ១០ ឆ្នាំពី បទ ប៉ុនប៉ង ឃាតកម្ម និង ១៨ ខែ ពីបទ រំលោភ បំពានទ្រព្យ សម្បត្តិ ឯកជន។ | ពន្ធនាគារ ព្រៃស (CC១) | ឡពាង | តាជេស | កំពង់ត្រឡាច | កំពង់ឆ្នាំង |
| ៦ | ស៊ិន កប | | ៣៨ | ៤.២.២០០៨(ច& ឃ) | កាប់ឆ្ការព្រៃដើម្បី កាន់កាប់ដីខុស ច្បាប់ (មាត្រា ៩៧ នៃ ច្បាប់ព្រៃឈើ) | ៦ ឆ្នាំ | ឧត្តរមានជ័យ | រំចេក | N/A | អន្លង់វែង | ឧត្តរមានជ័យ |
| ៧ | ឡុង សុខន | ប | ៥២ | ២០.២.២០១២ | អំពើហិង្សាប្រឆាំង ទ្រព្យ | រង់ចាំ | ប៉ៃលិន | ផ្សារព្រំ | ស្ទឹងកាច់ | សាលា | ប៉ៃលិន |

| | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| ៨<br>៩ | សុខ សង្ហា<br>រស់ ធាន | ប<br>ប | ២៤<br>៣៤ | (ចៈឃ) | សម្បត្តិសារ ធារណៈ (មាត្រា ៣៤ និង ២៥៩ នៃច្បាប់ ភូមិបាល) | សវនាការ (Pretrial) | | | | ក្រៅ | |
| ១០ | គឹម យាង | ប | ៦៤ | ១៣.៥.២០១២ (ចៈឃ) | កាប់ឆ្ការព្រៃខុស ច្បាប់ដើម្បីកាន់ កាប់ដីព្រៃ (មាត្រា ៩៧ នៃ ច្បាប់ព្រៃ ឈើ) | រង់ចាំ សវនាការ (Pretrial) | កំពង់ធំ | ថ្មសំ លៀង | ក្រែយា | សន្ទុក | កំពង់ធំ |
| ១១ | ទឹម សាក់មុន្នី | ស | ៦៤ | ៥.៩.២០១២(ចៈឃ) | ធ្វើសេចក្តីប្រកាសដោយភូតកុហក (មាត្រា ៦៣៣ នៃក្រម ព្រហ្មទណ្ឌ) | រង់ចាំ សវនាការ (Pretrial) | ពន្ធនាគារ (CC២) | បូរីកីឡា | វាលវង់ | ៧មករា | ភ្នំពេញ |
| ១២ | យ៉ោម បុប្ផា | ស | ២៩ | ៤.៩.២០១២(ចៈឃ) | អំពើហិង្សាដោយចេតនា មាន ស្ថានទម្ងន់ទោស (មាត្រា ២១៨ នៃក្រមព្រហ្មទណ្ឌ) | រង់ចាំ សវនាការ (Pretrial) | ពន្ធនាគារ (CC២) | បឹងកក់ | ស្រះចក | ដូនពេញ | ភ្នំពេញ |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| ១៣ | ម៉ម សូណង់ដូ | ប | ៧០ | ១៥.៧.២០១២ (ចៃឃ) | ដឹកនាំចលនាបំបែករដ្ឋ (មាត្រា ២៨ ៤៥៦ ៤៥៧ ៤៦៤ ៥០៤ និ ៦០៩ នៃក្រមព្រហ្មទណ្ឌ) | ជំនុំជម្រះថ្ងៃទី១១ - ១៤ ខែកញ្ញាឆ្នាំ ២០១២។ ប្រកាសសាលក្រម ថ្ងៃទី១ ខែតុលាឆ្នាំ ២០១២។ កាត់ទោសឲ្យជាប់ពន្ធនាគារ ២០ ឆ្នាំ និងបង្គាប់ឲ្យបង់ការខូចខាត ១០ លានរៀល (២,៥០០ ដុល្លារអាមេរិក) | ពន្ធនាគារ(CC១) | បឹងទំពុន | មានជ័យ | ភ្នំពេញ |

www.licadho-cambodia.org